

របាយការណ៍នៃការស្រាវជ្រាវ

# ការចូលរួមរបស់ជនរងគ្រោះ និងយុត្តិធម៌អន្តរកាលនៅកម្ពុជា៖ ករណីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

ខែមេសា ឆ្នាំ២០១៦

impunity watch

# របាយការណ៍នៃការស្រាវជ្រាវ

# ការចូលរួមរបស់ជនរងគ្រោះ និងយុត្តិធម៌អន្តរកាល

# នៅកម្ពុជា៖ ករណី របស់អង្គជំនុំជម្រះវិសាមញ្ញ

# ក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

ខែមេសា ឆ្នាំ២០១៦

impunity watch

របាយការណ៍នៃការស្រាវជ្រាវ

# ការចូលរួមរបស់ជនរងគ្រោះ និងយុត្តិធម៌អន្តរកាល នៅកម្ពុជា៖ ករណី របស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

ខែមេសា ឆ្នាំ២០១៦

**អ្នកនិពន្ធ**
Dr. Rudina Jasini

**សេចក្តីថ្លែងអំណរគុណ**
ការស្រាវជ្រាវដែលបញ្ចូលក្នុងរបាយការណ៍នេះ ត្រូវបានធ្វើឡើង និងឧបត្ថម្ភដោយ អង្គការឃ្លាំមើលនិទណ្ឌភាព (Impunity Watch) ដែលជាផ្នែកនៃគម្រោងដ៏ធំ "លើកកម្ពស់ការចូលរួមដោយសកម្មក្នុងការដោះស្រាយបញ្ហាយុត្តិធម៌អតីតកាល និងអន្តរកាល"។ យើងខ្ញុំសូមដឹងគុណចំពោះអង្គការ និងបុគ្គលដែលបានរួមចំណែក និងឧបត្ថម្ភការស្រាវជ្រាវនៅប្រទេសកម្ពុជា។ ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណ ដល់អង្គភាពគាំពារជនរងគ្រោះ នៅអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក) អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) មជ្ឈមណ្ឌលសោតទស្សន៍បូផាណា និងក្រុមហ៊ុនបកប្រែ ប្រ៊ីជ អ៊ិនធើណេសិនណល ចំពោះការចូលរួមគាំទ្រយ៉ាងពេញលេញ។

សូមឧទ្ទិសរបាយការណ៍នេះជូនដល់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីទាំង ៥០ រូប ដែលបានចូលរួមក្នុងការស្រាវជ្រាវ ចែករំលែករឿងឈឺចាប់ និងការបាត់បង់ផ្ទាល់ខ្លួន ព្រមទាំងរឿងរបស់ពួកគាត់ទាក់ទងនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស នឹងភាពធន់ទ្រាំដ៏អស្ចារ្យ។ ទស្សនៈ និងការយល់ដឹងរបស់ពួកគាត់អំពីការចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក បាន ជួយគាំទ្រដល់ការវិភាគ និងរួមចំណែកក្នុងការយល់ដឹងបន្ថែមពីតួនាទី និងវិសាលភាពនៃការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក ព្រមទាំងតួនាទីដ៏ទូលំទូលាយនៃការចូលរួមយ៉ាងសកម្មរបស់ជនរងគ្រោះក្នុងយន្តការយុត្តិធម៌អន្តរកាល។

កែសម្រួលដោយ Ralph Sprenkels, Megan O’Riordan & David Taylor

*រូបក្រប៖ Rudina Jasini. កិច្ចប្រជុំក្រុមជាមួយជនរងគ្រោះនៅវត្តធនសិរី ក្នុងស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ប្រទេសកម្ពុជា។*

©Impunity Watch 2016

## ពាក្យកាត់

| | |
|---|---|
| **ADHOC** | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| **CDP** | ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា |
| **DC-Cam** | មជ្ឈមណ្ឌលឯកសារកម្ពុជា |
| **ECCC** | អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា |
| **IW** | អង្គការឃ្លាំមើលនិទណ្ឌភាព |
| **LAC** | អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា |
| **TJ** | យុត្តិធម៌អន្តរកាល |
| **TPO** | អង្គការចិត្តសង្គម អន្តរវប្បធម៌ |
| **UN** | អង្គការសហប្រជាជាតិ |
| **VSS** | អង្គភាពគាំពារជនរងគ្រោះ |

## មូលន័យសង្ខេប

ចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ប្រទេសកម្ពុជាគឺជាកន្លែងមួយដែលមានសោកនាដកម្មខ្លាំងបំផុតនៅសតវត្សរ៍ទី២០។
របបខ្មែរក្រហមបានរៀបចំកែប្រែសង្គមខ្មែរឱ្យទៅជាមនោគមវិជ្ជាកុំម្មុយនីសផ្តាច់ការ តាមរយៈការលុបបំបាត់វប្បធម៌ បច្ចេកវិទ្យា និងសាសនា ព្រមទាំងបង្ខំឱ្យរៀបការ និងធ្វើការធ្ងន់ធ្ងរលើសកម្លាំង។ ក្នុងដំណើរការនោះ ពួកគេបានបង្ខំឱ្យធ្វើការជាលក្ខណៈប្រព័ន្ធ បង្អត់អាហារ និងវាយសម្លាប់ប្រជាជន ១,៧លាននាក់ ទាំងជនជាតិខ្មែរ និងមិនមែនជនជាតិខ្មែរ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៦ ដែលជាយន្តការយុត្តិធម៌អន្តរកាលចំពោះព្រឹត្តិការណ៍ទាំងនេះ។ គោលដៅដែលមានអន្តរទំនាក់ទំនងនៃគណនេយ្យភាពបុគ្គល និងការផ្សះផ្សាជាតិ ដើរតួជាមូលដ្ឋានសម្រាប់ប្រតិបត្តិការយន្តការយុត្តិធម៌នេះ។

គម្រោងស្រាវជ្រាវនេះពិនិត្យដំណើរការសកម្មនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុង អ.វ.ត.ក។ ការស្រាវជ្រាវនេះ វិភាគពីរបៀបដែល អ.វ.ត.ក ដំណោះស្រាយចំពោះការរំលោភបំពានសិទ្ធិមនុស្សរបស់ជនរងគ្រោះ។ អ.វ.ត.ក ពិនិត្យយ៉ាងជាក់លាក់លើរបៀបដែលការចូលរួមបានកែប្រែការយល់ឃើញឥរិយាបថ និងបទពិសោធន៍របស់ជនរងគ្រោះ និងភាគីពាក់ព័ន្ធ។

ការស្រាវជ្រាវត្រូវបានធ្វើឡើងតាមរយៈវិធីសាស្ត្រចម្រុះនៃការសម្ភាសជាមួយជនរងគ្រោះ តាមបែបគុណវិស័យ និងស៊ីជម្រៅ និងការសម្ភាសក្រុម ជាមួយសហគមន៍ដែលរងគ្រោះ។ ការស្រាវជ្រាវទទួលបាននូវបទពិសោធន៍របស់ក្រុមសំខាន់ៗចំនួនបី៖ ជនរងគ្រោះដែលគេស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណី ដើមបណ្តឹងជាជនរងគ្រោះ និងក្រុមធំមួយទៀត គឺក្រុមជនរងគ្រោះ និងសហគន៍ដែលទទួលរងផលប៉ះពាល់ដែលមិនទាន់បានស្វែងរកការចូលរួមជាផ្លូវការ ឬដោយផ្ទាល់នៅក្នុងការជំនុំជម្រះរបស់ អ.វ.ត.ក។

អ.វ.ត.ក ត្រូវបានជ្រើសរើសជាករណីសិក្សាដោយសារតែនវានុវត្តន៍តុលាការដែលបានឈានទៅដល់ការបង្កើតប្រព័ន្ធប្រលោមលិកនៃការចូលរួមរបស់ជនរងគ្រោះតាមរយៈប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី។ ការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក គឺមានភាពដាច់ដោយឡែកទាំងវិសាលភាព និងទម្រង់ពីយន្តការតុលាការផ្សេងទៀត ដូចដែលគេបានឃើញយ៉ាងច្បាស់ក្នុងការពិពណ៌នាជនរងគ្រោះ ដែលមិនធ្លាប់មានពីមុនមកទេថាជា "ដើមបណ្តឹង" ពេញលេញក្នុងការជំនុំជម្រះ ជាជាងគ្រាន់តែជា 'អ្នកចូលរួម'។ វាមានការផ្ទុយពីប្រព័ន្ធចូលរួមរបស់ជនរងគ្រោះនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)។ក៏ប៉ុន្តែ អ.វ.ត.ក ត្រូវដោះស្រាយការលំបាកនៃការស្វែងរកតុល្យភាពរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួម។ ផ្ទុយពីបំណងធានាឱ្យមានការចូលរួមយ៉ាងសកម្មរបស់ជនរងគ្រោះ អ.វ.ត.ក មិនមានការត្រៀមសម្រាប់វិសាលភាព និងភាពស្មុគស្មាញនៃរចនាសម្ព័ន្ធ និងនីតិវិធីដែលអាចនឹងកើតមាន
ឡើង។

អ្វីដែលបានលេចចេញពីការស្រាវជ្រាវការអនុវត្តរបស់ អ.វ.ត.ក សម្រាប់ការចូលរួមរបស់ជនរងគ្រោះ គឺថាមានកត្តាខាងក្រៅដែលរាំងស្ទះដល់តុលាការ។ បញ្ហាដែល អ.វ.ត.ក ប្រឈមមុខគឺដោយសារតែមួយចំណែកនៃកម្រិតភាពឃោរឃៅនៅប្រទេសកម្ពុជា ដែលធ្វើឱ្យមានការលំបាកក្នុងការកំណត់ដាច់ស្រឡះ និងកំណត់កំហុសភាគីណាច្បាស់ឡើយ។ លើសពីនេះទៅទៀត មិនមែនគ្រប់ជនរងគ្រោះ ឬឧក្រិដ្ឋកម្មទាំងអស់

អាចត្រូវបានទទួលស្គាល់ឬផ្ដល់សំណង ឈានទៅដល់ការលំបាកដែលឧក្រិដ្ឋកម្មនិងជនរងគ្រោះត្រូវទទួលស្គាល់ និងអ្វីដែលត្រូវដកចេញនោះទេ។ តុលាការទទួលខុសត្រូវចំពោះអ្នកចូលរួមរបស់ខ្លួន និងប្រកាន់ខ្ជាប់បទដ្ឋានអន្តរជាតិដែលបានបង្កើតរួចរាល់ហើយ និងបទដ្ឋានយុត្តិធម៌ និងបទប្បញ្ញត្តិម្ចាស់ជំនួយ។ ជួនកាលភាគីទាំងនេះមិនបានទទួលអត្ថប្រយោជន៍អ្វីនោះទេ។

កត្តាទី២ដែលប៉ះពាល់ដល់ អ.វ.ត.ក គឺប្រព័ន្ធយុត្តិធម៌កម្ពុជា ‘ដែលមានបញ្ហា’ និងអំពើពុករលួយគ្រប់ទីកន្លែង។ *នយោបាយជាក់ស្ដែង (realpolitik)* របស់កម្ពុជាឆ្លុះបញ្ចាំងពីភាពស្មុគស្មាញផ្លូវច្បាប់ និងរចនាសម្ព័ន្ធរបស់តុលាការ។ រដ្ឋាភិបាលចង់រក្សាភាពម្ចាស់ការ និងធ្វើឱ្យមានការពិបាកក្នុងការស៊ើបអង្កេត ហើយគណនេយ្យភាពក៏នៅតែមានកម្រិតសម្រាប់មន្ត្រីសាធារណៈ។ ក្នុងនោះក៏មានបញ្ហាស្ថាប័ន ដូចជាភាពដែលមិនអាចអនុវត្តបាននូវក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ភាពមិនថ្មីករបស់ចៅក្រមកម្ពុជាជាមួយច្បាប់អន្តរជាតិ និងគម្លាតនីតិវិធីច្បាប់ដ៏សំខាន់ដែលគ្រប់គ្រង អ.វ.ត.ក។

ទី៣ ឥទ្ធិពលដោយឡែកនៃសង្គមខ្មែរឱ្យមានការបន្តស្វែងរកយុត្តិធម៌កាន់តែស្មុគស្មាញ។ ទំនៀមទម្លាប់បែបផ្ដាច់ការបានចូលទៅក្នុងវប្បធម៌នយោបាយ ដែលការស្ដាប់បង្គាប់ជាកត្តាដ៏សំខាន់។ វាត្រូវបានភ្ជាប់មកជាមួយនូវការពិត ដែលប្រជាជនខ្មែរភាគច្រើនជាពុទ្ធសាសនិក ហើយត្រូវបានចិញ្ចឹមបីបាច់ឡើងតាមប្រពៃណីសាសនានៃការអត់ទោស។

រចនាសម្ព័ន្ធផ្ទៃក្នុង និងបែបបទរបស់ អ.វ.ត.ក ក៏បង្ហាញបញ្ហាប្រឈមមួយចំនួនចំពោះការចូលរួមរបស់ជនរងគ្រោះដែរ។ លទ្ធផលបានបង្ហាញថា បទប្បញ្ញត្តិជាក់លាក់ទាក់ទងនឹងការជំនុំជម្រះរបស់តុលាការ បង្កើតឱ្យមានការពិបាកសម្រាប់ការចូលរួមដ៏ខ្លាំងក្លា។ ជនរងគ្រោះត្រូវជ្រើសរើសមុនពេលពួកគេចូលរួមថាតើពួកគាត់ចង់ធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី ឬជនរងគ្រោះ។ ជនរងគ្រោះដែលចូលរួមអាចនឹងបដិសេធឱកាសធ្វើសក្ខីកម្មតាមរយៈការស្បថស្បែ ដែលអាចរារាំងដល់ការកាត់ក្ដី ដែលជាលទ្ធផល ការធ្វើសក្ខីកម្មរបស់ពួកគាត់មានកម្រិតទម្ងន់នៃការជឿជាក់ទាប។ ដោយសារតែការខ្វះវិធាននិងនីតិវិធីគ្រប់ជ្រុងជ្រោយ ភាគីចូលរួមតែងតែមិនធ្វើបែបនោះទេ ដែលជាសក្ដានុពលនាំឱ្យមានការពិបាករកតុល្យភាពរវាងការចោទប្រកាន់ និងការការពារ ហើយជួនកាលមានការប៉ះពាល់ សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការកាត់ក្ដីដោយយុត្តិធម៌បាន។ លើសពីនេះទៅទៀត នេះមាននៅក្នុងឧទាហរណ៍មួយចំនួនដែលឈានទៅដល់ការពន្យារពេលនៃការជំនុំជម្រះក្ដី និងបញ្ហាជាមួយការបើកចំហ។

លើសពីនេះទៅទៀត ជនរងគ្រោះចូលរួមដោយមូលហេតុផ្សេងៗនិងប្រទាក់ក្រឡាគ្នា ដូចជា៖ យុត្តិធម៌ ការពិត និទានរឿងរបស់នរណាម្នាក់ អប់រំដល់ពិភពលោក សំណង និងការផ្សះផ្សា។ ពេលខ្លះគោលដៅទាំងនេះអាចមមានលក្ខណៈដាច់ដោយឡែកពីគ្នា។ ឧទាហរណ៍៖ ‘យុត្តិធម៌’ អាចត្រូវបានកំណត់ទស្សនវិស័យរបស់ក្រុមសមូហភាព និងក្រុមបុគ្គល ហើយមានន័យថាការដាក់ទោសទណ្ឌចំពោះអ្នកខ្លះ ប៉ុន្តែភាគច្រើនយល់ឃើញថាជាការទទួលស្គាល់។ ជនរងគ្រោះជាច្រើនក៏បានចូលរួមដោយសង្ឃឹមថាការកាត់ក្ដី អាចនឹងអនុញ្ញាតឱ្យពួកគេសួរជនជាប់ចោទ ទាក់ទងនឹងវាសនារបស់អ្នកជាទីស្រឡាញ់ ព្រមទាំងដើម្បីប្រាប់រឿងផ្ទាល់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ សាលជម្រះក្ដីធ្វើឱ្យមនុស្សកាន់តែមានបទពិសោធន៍អាក្រក់ដោយបញ្ហារចនាសម្ព័ន្ធ ព្រោះរចនាសម្ព័ន្ធតុលាការអនុញ្ញាតឱ្យឆ្លើយទៅតាមសំណួរ ដែលផ្ទុយនឹងការរៀបរាប់ផ្ទាល់ខ្លួនទាំងស្រុងរបស់ពួកគាត់។ ក្នុងនាមជាស្ថាប័ន អ.វ.ត.ក អាចបង្កើតការរៀបរាប់ថ្នាក់ជាតិទូទៅ ប៉ុន្តែនេះអាចជាការទទួលខុសត្រូវរបស់បុគ្គល។

នេះចោទជាសំណួរថាតើស្ថាប័នដូចជា អ.វ.ត.ក អាចចរចាការទទួលខុសត្រូវរបស់ខ្លួនសម្រាប់បុគ្គលព្រមទាំងសមូហភាពបានដែរទេ។ បញ្ហានេះក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងគម្រោងផ្តល់សំណង។ ដោយសារតែវិសាលភាពនៃឧក្រិដ្ឋកម្ម បំណងប្រាថ្នា និងសេចក្តីត្រូវការរបស់ជនរងគ្រោះសម្រាប់សំណង មិនអាចផ្តល់ជូនបានទាំងអស់ឡើយ។ ប៉ុន្តែ ត្រូវទទួលស្គាល់ថាតុលាការពិតជាបានព្យាយាមកាត់បន្ថយការខកចិត្តរបស់បុគ្គលជាអប្បបរមាទាក់ទងនឹងសំណងតាមរយៈកម្មវិធីផ្តល់សំណងសមូហភាព។

ការស្រាវជ្រាវបានបង្ហាញថាមានការស្តារឡើងវិញនូវសិទ្ធិអំណាច និងសេចក្តីថ្លៃថ្នូរតាមរយៈការចូលរួម។ ចំនួនអ្នកចូលរួមដែលជឿថាការផ្សះផ្សាត្រូវបានសម្រេចបាន ឬកំពុងដំណើរការគឺមានកំរិតខ្ពស់។ ដូច្នេះ វាមានសារៈសំខាន់ដែលការផ្តួចផ្តើមទាំងនេះនៅតែបន្ត។ ប៉ុន្តែ អ.វ.ត.ក គឺមិនទាន់បានត្រូវបានរៀបចំឱ្យបានល្អនៅឡើយទេ ហើយនៅត្រូវការធនធានជាច្រើនទៀតដើម្បីផ្តល់ការចូលរួមប្រកបដោយអត្ថន័យចំពោះជនរងគ្រោះ។ ការទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះដើម្បីទទួលបានយុត្តិធម៌និងសំណងដោយស្មើភាព និងប្រសិទ្ធភាព សម្រាប់ការរងទុក្ខវេទនាទាមទារឱ្យមានវិធីសាស្រ្តរួម និងគ្រប់ជ្រុងជ្រោយ ដែលតុលាការនេះមិនត្រូវបានរៀបចំឡើងដើម្បីសម្រេចបានដោយខ្លួនឯងនោះទេ។ ដូចនេះ មានតម្រូវការសម្រាប់គម្រោងសំណងដែលមានខ្លឹមសារដើម្បីដោះស្រាយវិសាលភាពនៃការប៉ះពាល់ ព្រមទាំងការបង្កើនតម្លាភាព និងការទទួលបានព័ត៌មានទាក់ទងនឹងការអនុវត្តដែលមានការចូលរួមមុនដល់ពេលជំនុំជម្រះ។ តាមរយៈការបែងចែកវិសាលភាពរបស់តុលាការឱ្យកាន់តែច្បាស់ ការជំនុំជម្រះអាចត្រូវបានធ្វើមានភាពឆាប់រហ័ស ហើយបញ្ហាយុត្តាធិការអាចត្រូវបានដោះស្រាយ។ យន្តការបន្ថែមដូចជា គណៈកម្មការផ្សះផ្សា និងស្វែងរកការពិត និងគម្រោងអប់រំគួរតែត្រូវបានប្រើប្រាស់ដើម្បីភ្ជាប់ និងបំពេញប្រព័ន្ធនៃការចូលរួមរបស់ដើម បណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ដែលទោសកំហុសត្រូវបានរកឃើញ។

## **តារាង**មាតិកា


ពាក្យកាត់ .... 4
មូលន័យសង្ខេប .... 5
តារាងមាតិកា .... 8
១ -សេចក្តីផ្តើម .... 9
២- វិធីសាស្ត្រ .... 10
២.១- វិធីសាស្ត្រស្រាវជ្រាវ .... 10
២.២- ការរៀបចំស្រាវជ្រាវ .... 12
២.៣- បញ្ហាប្រឈម និងបញ្ហា .... 14
៣- សាវតា និងការអភិវឌ្ឍ .... 16
៣.១- ឥទ្ធិពលក្នុងសង្គមកម្ពុជាក្រោយសង្គ្រាម .... 18
៣.២- ឥទ្ធិពលវប្បធម៌សង្គម .... 19
៣.៣- ឥទ្ធិពលនយោបាយនិងច្បាប់ .... 20
៤- យុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា .... 23
៤.១-អ.វ.ត.ក ជាយន្តកាលយុត្តិធម៌អន្តរកាលមួយ .... 24
៤.២- ការចូលរួមរបស់ជនរងគ្រោះនៅអ.វ.ត.ក៖ កំហុសម៉ាស៊ីនវាយពុម្ពអក្សរដែលមានតម្លៃ ឬនវានុវត្តន៍របស់តុលាការ? .... 25
៤.៣- សិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី .... 28
៤.៣.១.ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការអនុវត្ត .... 31
៥- តួនាទីនិងផលប៉ះពាល់នៃការចូលរួមរបស់ជនរងគ្រោះ .... 34
៥.១- ការលើកទឹកចិត្តជនរងគ្រោះក្នុងការចូលរួម .... 34
៥.២ ការស្វែងរកយុត្តិធម៌ .... 37
៥.២.១ ប្រតិកម្មទៅលើសាលក្រម .... 40
៥.៣ ការស្វែងរកការពិត .... 41
៥.៤ ការរៀបរាប់រឿងរ៉ាវ .... 47
៥.៥ ការអប់រំពិភពលោក .... 49
៥.៦- ការស្វែងរកសំណង .... 52
៥.៦.១- ផលវិបាកផ្លូវច្បាប់ និងជាក់ស្តែង .... 52
៥.៦.២- ការយល់ឃើញរបស់ជនរងគ្រោះ .... 56
៥.៧- ការផ្សះផ្សា .... 62
៦- សន្និដ្ឋានអំពីអត្ថប្រយោជន៍ និងការប្រឆាំងទៅលើផលប៉ះពាល់នៃការចូលរួមរបស់ជនរងគ្រោះ៖ ការពិនិត្យនៅក្នុងតថភាព .... 68
៦.១- ការប្រមើលមើលនូវផលប៉ះពាល់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី .... 68
៦.១.១- ការពន្យាពេលនៃការជំនុំជម្រះក្តីរបស់តុលាការ .... 69
៦.១.២- ការបង្ហាញនូវបញ្ហា .... 69
៦.១.៣- ផលប៉ះពាល់លើអយ្យការ និងមេធាវីការពារក្តី .... 70
៨. អនុសាសន៍ .... 78
៨.២- សម្រាប់ការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា .... 79
៩- គន្ថនិទ្ទេស .... 81

## ១សេចក្តីផ្តើម -

ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើង ជាផ្នែកនៃកម្មវិធីស្រាវជ្រាវដ៏ធំមួយ របស់អង្គការឃ្លាំមើលនិទណ្ឌភាព (IW) ទៅលើការចូលរួមរបស់ជនរងគ្រោះ។[1] ប្រទេសចំនួន ៦ ខុសគ្នាត្រូវបានជ្រើសរើសជាករណីសិក្សានៅក្នុងក្របខ័ណ្ឌប្រៀបធៀប។ គោលបំណងនៃការស្រាវជ្រាវគឺផ្តល់អ្នកជំនាញ និងអ្នកបង្កើតគោលនយោបាយនូវលទ្ធផលដែលអាចជួយពួកគេក្នុងការបង្កើន និងគាំទ្រការចូលរួមយ៉ាងសកម្ម និងប្រកបដោយអត្ថន័យរបស់ជនរងគ្រោះក្នុងយុត្តិធម៌អន្តរកាល (TJ)។[2] ការសិក្សាស្រាវជ្រាវរបស់ប្រទេសភាគច្រើនផ្តោតទៅលើការចូលរួមរបស់ជនរងគ្រោះទាក់ទងនឹងយន្តការ ស្ថាប័នរបស់ TJ ដែលគូសបញ្ជាក់ទស្សនវិស័យរបស់ជនរងគ្រោះ និងសហគមន៍ដែលទទួលរងផលប៉ះពាល់។

របាយការណ៍នេះគឺជាលទ្ធផលនៃគម្រោងស្រាវជ្រាវរយៈពេល ៦ខែ (ខែកក្កដា – ខែធ្នូ ឆ្នាំ២០១៤) ដែលធ្វើឡើងដោយ IW ទៅក្នុងការចូលរួមរបស់ជនរងគ្រោះក្នុងការជំនុំជម្រះក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)។ វត្ថុបំណងនៃការស្រាវជ្រាវនេះគឺដើម្បីផ្តល់ភ័ស្តុតាងជាក់ស្តែង និងការយល់ដឹងបន្ថែមទៅក្នុងឥទ្ធិពលនៃការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក ដែលបន្ថែមទៅលើទស្សនៈ ការរំពឹងទុក ឥរិយាបថ និងបទពិសោធន៍របស់ជនរងគ្រោះដែលបានចូលរួមក្នុងយន្តការ TJ ដ៏សំខាន់របស់ប្រទេសកម្ពុជា។ ការសិក្សាស្រាវជ្រាវផ្តោតទៅលើការសម្ភាស និងក្រុមពិភាក្សាជាមួយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥០រូប និងដើមបណ្តឹងជាជនរងគ្រោះអំពីបទពិសោធន៍នៃការចូលរួម។

TJ គឺជាទិដ្ឋភាពនៃការវិវត្តន៍ទស្សនវិជ្ជា និងការអនុវត្ត។ វិធីសាស្រ្តនៃការបង្កើតថ្មីដែលអនុម័តដោយ អ.វ.ត.ក គឺដាក់បញ្ចូលជនរងគ្រោះនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ជាដើមបណ្តឹងរដ្ឋប្បវេណីជាជាងគ្រាន់តែជាសាក្សី។ នេះបានបង្ហាញភាពខ្លាំង និងភាពខ្សោយដែលមានសក្តានុពលព្រមទាំងលទ្ធភាពសម្រាប់ទិសដៅអភិវឌ្ឍបន្ថែមនៅ TJ ។ ខណៈដែលអត្ថប្រយោជន៍នសការចូលរួមដូចជាការផ្តល់សិទ្ធិនីតិវិធីកាន់តែធំសម្រាប់ជនរងគ្រោះ និងការដោះស្រាយដ៏សំខាន់លេចចេញយ៉ាងច្បាស់រហូតមកដល់ពេលនេះ ភ័ស្តុតាងជាក់ស្តែង និងភ័ស្តុតាងយុត្តាធិការនៅមានកម្រិតក្នុងការគាំទ្រ អត្ថប្រយោជន៍ដែលសន្មតជាអង្គសេចក្តី។[3] ឥទ្ធិពលអវិជ្ជមានមួយចំនួននៃការចូលរួមរបស់ជនរងគ្រោះរួមទាំងផលវិបាកលើរាងកាយដែលអាចមានចំពោះជនរងគ្រោះ សហគមន៍ដែលទទួលរងផលប៉ះពាល់ និង TJ នៅកម្ពុជា ហើយត្រូវការវាយតម្លៃ និងការយល់ដឹងយ៉ាងល្អិតល្អន់។ បើទោះជាការសិក្សាស្រាវជ្រាវជាក់ស្តែងជាច្រើនដែលធ្វើឡើងនៅប៉ុន្មានឆ្នាំថ្មីៗនេះ បានរួមចំណែកក្នុងការស្វែងយល់ពីការចូលរួមការអនុវត្តកាន់តែប្រសើរ (ឧ. Stover, Balthazard & Koeng, 2011; Pham et al., 2011; Hoven, 2013) ការចូលរួមរបស់ជនរងគ្រោះជារឿងថ្មីក្នុង TJ នៅតែស្ថិតក្រោមស្រាវជ្រាវ។ នៅក្នុងបរិបទនេះ របាយការណ៍នេះមានគោលបំណងចង់សម្រួលភាពស្មុគស្មាញនៃការចូលរួមរបស់ជនរងគ្រោះឱ្យបានស្រួល។

---

[1] ចំពោះទិដ្ឋភាពទូទៅនៃស្ថានភាពទាក់ទងនឹងការចូលរួមរបស់ជនរងគ្រោះ និងចំពោះគម្រោងនៃក្របខ័ណ្ឌទស្សនទានសម្រាប់ការស្រាវជ្រាវនេះ សូមមើល Taylor, D (2014) ការចូលរួមរបស់ជនរងគ្រោះក្នុងយន្តការយុត្តិធម៌អន្តរកាលៈ អំណាចពិតប្រាកដ ឬការ សម្តែង? ឯកសារពិគ្រោះ អង្គការឃ្លាំមើលនិទណ្ឌភាព។ មាននៅៈ http://www.impunitywatch.org/docs/IW_Discussion_Paper_Victim_Participation1.pdf (ចូលទៅកាន់នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៥)

[2] ប្រទេសទាំង៦ ដែលពាក់ព័ន្ធគឺៈ ប៊ូរុនឌី កម្ពុជា ក្វាតេម៉ាឡា ហុងឌូរ៉ាស កេនយ៉ា និងទុយនីស៊ី។

[3] Taylor, D (2014) ការចូលរួមរបស់ជនរងគ្រោះក្នុងយន្តការយុត្តិធម៌អន្តរកាលៈ អំណាចពិតប្រាកដ ឬការសម្តែង? ឯកសារពិគ្រោះ អង្គការឃ្លាំមើលនិទណ្ឌភាព។

ការស្រាវជ្រាវដែលគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះ មានបំណងរួមចំណែកក្នុងការពិភាក្សាគោលនយោបាយ និងបង្កើតគោលនយោបាយស្តីពីការចូលរួមរបស់ជនរងគ្រោះ និងឥទ្ធិពលរបស់វាលើ TJ ។ វាស្វែងយល់ពីរបៀបដែលជនរងគ្រោះ និងសហគមន៍ដែលទទួលរងផលប៉ះពាល់មានបទពិសោធន៍នៃការចូលរួមយ៉ាងដូចម្តេច ថាតើក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ឬជាដើមបណ្តឹងជាជនរងគ្រោះក្នុងការជំនុំជម្រះនៅមុខ អ.វ.ត.ក។ វាផ្តល់នូវការយល់ដឹងជាក់ស្តែង (និងចំណុចល្អិត) នៃអត្ថប្រយោជន៍ និងគ្រោះថ្នាក់ដែលបានសន្មត ដែលជាលទ្ធផលនៃការចូលរួមរបស់ជនរងគ្រោះ។ ការស្រាវជ្រាវមានគោលបំណងផ្តល់ការត្រួតពិនិត្យភាពស្មុគស្មាញជាក់ស្តែង និងនិយាមយ៉ាងហ្មត់ចត់នៃការដាក់បញ្ចូលការចូលរួមរបស់ជនរងគ្រោះ ជាធាតុនៃយុត្តិធម៌ដែលស្តារឡើងវិញដែលបានសន្មតចូលទៅក្នុងយន្តការយុត្តិធម៌ក្នុងការដាក់ទោស។ វាត្រួតពិនិត្យវិធីសាស្ត្រយ៉ាងស៊ីជម្រៅដែលការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានពន្យល់ និងបង្ហាត់បង្ហាញក្នុងការជំនុំជម្រះក្តីនៅមុខ អ.វ.ត.ក។ វាធ្វើការពិនិត្យបែបនេះដោយវិភាគលើវិធីដែលសិទ្ធិទទួលបានដំណោះស្រាយចំពោះការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងររបស់ជនរងគ្រោះ ត្រូវបានដោះស្រាយដោយ អ.វ.ត.ក។ នៅកម្រិតច្បាស់ជាងនេះ វាក៏វាយតម្លៃពីរបៀបនៃការចូលរួមដែលបានកែប្រែការយល់ឃើញឥរិយាបថ និងបទពិសោធន៍របស់ជនរងគ្រោះ។

ក្រោយពីបង្ហាញការស្រាវជ្រាវ វិធីសាស្ត្រ និងបញ្ហារបស់វា របាយការណ៍ផ្តោតយ៉ាងទូលំទូលាយលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ និងឥទ្ធិពលនិយោបាយ និងសង្គមឈានទៅរកដំណើរការដែលកំពុងចាប់ផ្តើមនៃ TJ នៅកម្ពុជា និងការបង្កើត អ.វ.ត.ក។ បន្ទាប់មកវាបន្តទៅរកការត្រួតពិនិត្យក្របខ័ណ្ឌគតិយុត្តិ និងនីតិវិធីយ៉ាងទូលាយពាក់ព័ន្ធនឹងរចនាសម្ព័ន្ធស្ថាប័នរបស់អ.វ.ត.ក និងសិទ្ធិចូលរួមដែលផ្តល់ឱ្យជនរងគ្រោះ។ គោលបំណងនៃរបាយការប្តូរទៅជាការវិភាគបែបទ្រឹស្តី និងជាក់ស្តែង នៃគុណធម៌ តួនាទី វិសាលភាពឥទ្ធិពលនៃការចូលរួម។ វាវាយតម្លៃពីរបៀបនៃការចូលរួមដែលឈានទៅរកអត្ថប្រយោជន៍ដែលត្រូវបានសន្មតជាទូទៅ ថាតើមានផលវិបាកដែលមិនបានគិតទុកនៃការចូលរួមរបស់ជនរងគ្រោះ ព្រមទាំងថាតើមានឥទ្ធិពលអវិជ្ជមានអាចកើតមានដែរឬទេ។ ដោយត្រូវការជាចាំបាច់ របាយការណ៍ត្រួតពិនិត្យពីរបៀបការចូលរួមបានជួយជនរងគ្រោះឱ្យទទួលបានយុត្តិធម៌ពីខាងក្នុង ដោយស្វែងរកការពិតតាមរយៈការចូលរួមពីការសិក្សាអំពីរបប និងការជំរុញទឹកចិត្តពីក្រោយ ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ផ្តល់ការផ្សះផ្សា និងសំខាន់ស្មើគ្នាដោយទទួលបានសំណងប្រកបដោយអត្ថន័យ។

ជាចុងក្រោយ របាយការណ៍នេះសង្ឃឹមថានឹងរួមចំណែកដល់ការយល់ដឹងទូទៅដ៏ស៊ីជម្រៅ និងធំធេងលើការចូលរួមរបស់ជនរងគ្រោះនៅក្នុងយន្តការ TJ ។

## ២- វិធីសាស្ត្រ

### ២.១- វិធីសាស្ត្រស្រាវជ្រាវ

ក្របខ័ណ្ឌដែលបង្កើតដោយ IW សម្រាប់គម្រោងស្រាវជ្រាវប្រៀបធៀបត្រូវបានរៀបចំឡើងជាមួយទស្សនៈផ្តល់ជូនការយល់ដឹងបន្ថែមទៅក្នុងឥទ្ធិពលនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងយន្តការ TJ។[4] វាបង្កើតឡើងដោយផ្អែកលើទស្សនៈ ការរំពឹងទុក បទពិសោធន៍ និងការជំរុញទឹកចិត្តរបស់ជនរងគ្រោះក្នុងការបង្កើនសមត្ថភាពរបស់អ្នកបង្កើតគោលនយោបាយ និងអ្នកជំនាញដាក់ចូលក្នុងប្រព័ន្ធជាធរមាននៃការចូលរួមរបស់ជនរងគ្រោះប្រកបដោយអត្ថន័យ។

[4] ការស្រាវជ្រាវដែលដាក់បញ្ចូលនៅក្នុងក្របខ័ណ្ឌនេះរួមមានការសិក្សាស្រាវជ្រាវពីប្រទេសកេនយ៉ា ប៊ូរុនឌី ក្វាតេម៉ាឡា ហុងឌូរ៉ាស ទុយនីស៊ី និងការស្រាវជ្រាវនៅកម្ពុជានេះ។

ការស្រាវជ្រាវទូលំទូលាយស្វែងរកពីរបៀបជនរងគ្រោះ និងសហគមន៍ដែលទទួលរងការប៉ះពាល់មួយចំនួនមានបទពិសោធន៍ចូលរួមដោយផ្ទាល់ ឬប្រយោល អ្នកចូលរួមសកម្ម ឬអសកម្ម។[5] វាក៏ផ្តល់ការយល់ដឹងជាក់ស្តែងផងដែរទៅក្នុងគំនិតចិត្តសង្គមនៃការចូលរួម ជារបៀបក្នុងការបង្កើតការយល់ដឹងនៃការប្រៀបធៀបនៃអត្ថប្រយោជន៍ និងហានិភ័យជាក់ស្តែងនៃការចូលរួម។ គម្រោងស្រាវជ្រាវស្វែងរកការរក្សាទុកឯកសារជាពិសេសពីរបៀបជនរងគ្រោះនិងសហគមន៍ដែលទទួលរងផលប៉ះពាល់ តំណាងដោយសំណាកគំរូនៃការសម្ភាសជាបុគ្គលនិងជាក្រុម បទពិសោធន៍ និងការយល់ឃើញនៃការចូលរួមរបស់ជនរងគ្រោះ ការកំណត់អត្ថន័យ និងសារៈសំខាន់ទាំងការចូលរួម និងការមិនចូលរួម។ ការស្រាវជ្រាវបន្តការខិតខំប្រឹងប្រែងផលិតរូបភាពធំទូលាយនៃរបៀបការចូលរួមរបស់ជនរងគ្រោះត្រូវបានឆ្លងកាត់ផ្ទាល់ រួមទាំងការវិភាកទស្សនៈនៃជនរងគ្រោះដែលមិនបានចូលរួម និងការរៀបចំដំបូន្មានសម្រាប់អ្នកជំនាញ និងអ្នកបង្កើតគោលនយោបាយ។

បើទោះជារបាយការណ៍នេះ រួមទាំងរបាយការណ៍ជាក់លាក់នៃប្រទេសទាំងប្រាំផ្សេងទៀតជាឯកសារដាច់ដោយឡែកក៏ដោយ វាគួរតែត្រូវបានអានដោយរួមផ្សំជាមួយទ្រឹស្តីគ្រប់គ្រងវិសាលភាព និងប៉ារ៉ាម៉ែត្រនៃគម្រោងនេះ។ ជាពិសេស ឯកសារពិគ្រោះ IW ស្តីពីការចូលរួមរបស់ជនរងគ្រោះផ្តល់ក្របខ័ណ្ឌទស្សនទាន និង ពិធីសារស្រាវជ្រាវរបស់ IW ធ្វើគម្រោងក្របខ័ណ្ឌវិធីសាស្ត្រសម្រាប់ការស្រាវជ្រាវ។

ការស្រាវជ្រាវបែបគុណភាពដែលធ្វើនៅកម្ពុជាអនុវត្តវិធីសាស្ត្រចម្រុះ ដែលប្រើប្រាស់កិច្ចសម្ភាសន៍ស៊ីជម្រៅបែបគុណភាពជាគោល និងក្រុមគោលដៅ ជាមួយជនរងគ្រោះ និងសហគមន៍ដែលទទួលរងផលប៉ះពាល់។ វិធីសាស្ត្រសំខាន់ៗត្រូវបានបំពេញដោយការរំឭកទ្រឹស្តី និងច្បាប់យុត្តិសាស្ត្រជាក់លាក់ចំពោះប្រទេសកម្ពុជា ព្រមទាំងកិច្ចសម្ភាសន៍ និងអន្តរទំនាក់ទំនងក្រៅផ្លូវការជាមួយ អ្នកជំនាញ អ្នកបង្កើតគោលនយោបាយ និងអ្នកឯកទេស។

ក្របខ័ណ្ឌទស្សនទានគ្របដណ្តប់ ត្រូវផ្តោតលើវិធីសាស្ត្រទ្រឹស្តីមានស្រាប់ជាច្រើន។ ធាតុនៃការរំឭកទ្រឹស្តីនៃការស្រាវជ្រាវ ដែលដាក់បញ្ចូលទៅក្នុងការវិភាគលម្អិតនៃបញ្ហាដែលលើកឡើងនៅក្នុងរបាយការណ៍នេះ រួមមានក្នុងចំណោមការបោះពុម្ពផ្សាយផ្សេងៗទៀតស្តីពី TJ និងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ លក្ខន្តិកៈ សន្ធិសញ្ញា អនុសញ្ញា ច្បាប់ និងវិធានផ្ទៃក្នុងគ្រប់គ្រងការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក។ ការបោះពុម្ពផ្សាយទាំងនេះមាននៅកន្លែងផ្ទុកឯកសារសាធារណៈ និងមាននៅបណ្ណាល័យ និង/ឬ នៅអ៊ីនធើណិត។ ការរំឭកច្បាប់យុត្តិសាស្ត្រមានការវិភាគស្ថាប័នច្បាប់យុត្តិ សាស្ត្ររបស់ អ.វ.ត.ក។ បើទោះជាយុត្តិសាស្ត្របង្កើតដោយតុលាការនេះត្រូវបានកំណត់ទាក់ទងនឹងបរិមាណ តែចរិតដែលសិទ្ធិចូលរួមរបស់អ្នកចូលរួមត្រូវបានតម្រូវដោយ អ.វ.ត.ក តាមរយៈការវិនិច្ឆ័យ សេចក្តីសម្រេច និងការពន្យល់បកស្រាយដែលភ្ជាប់ជាមួយ ផ្តល់ការវិភាគបែបគុណភាពនៃយន្តការច្បាប់សំខាន់នេះ។ ការសង្ខេបនៃការវិនិច្ឆ័យ សេចក្តីសម្រេច និងទស្សនៈទាំងនេះដែលដាក់ជូនដោយ អ.វ.ត.ក មានតម្លៃយ៉ាងខ្លាំងសម្រាប់ការស្រាវជ្រាវនេះ តាមរបៀបដែលសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួមដែលត្រូវបានពន្យល់បកស្រាយ បានកំណត់វិសាលភាពនិងខ្លឹមសារនៃការចូលរួមបែបនេះ។

---

[5] សម្រាប់កិច្ចពិភាក្សាគ្រប់ជ្រុងជ្រោយនៃភាពខុសគ្នាទាំងនេះ សូមមើលៈ Taylor, D (2014) ការចូលរួមរបស់ជនរងគ្រោះក្នុងយន្តការយុត្តិធម៌អន្តរកាលៈអំណាចពិតប្រាកដ ឬការសម្តែង? ឯកសារពិគ្រោះ អង្គការឃ្លាំមើលនិទណ្ឌភាព។ មាននៅៈ http://www.impunitywatch.org/docs/IW_Discussion_Paper_Victim_Participation1.pdf (ចូលទៅកាន់នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៥)។

កិច្ចសម្ភាសន៍ស៊ីជម្រៅបែបគុណវិស័យ ត្រូវបានចាត់ទុកជាចំណុចគោលសំខាន់របស់ការស្រាវជ្រាវ។ សមាសធាតុនេះសម្ភាសរកតម្រុយ និងការយល់ដឹងដែលរកបានប្រមូលពីការធ្វើរំឭកទ្រឹស្តី និងការស្រាវជ្រាវផ្តោតលើច្បាប់យុត្តិសាស្ត្រដើម្បីបន្តសំណួរយកចម្លើយ និងប្រធានបទសំខាន់ៗនៃការស្រាវជ្រាវ។ វាផ្តោតលើក្របខ័ណ្ឌទ្រឹស្តីសម្រាប់ការស្រាវជ្រាវនៃការចូលរួមរបស់ជនរងគ្រោះនៅ TJ ដែលផ្តល់ជូនក្នុងឯកសារពិគ្រោះរបស់ IW ។[6] គោលដៅគឺដើម្បីស្វែងរកទស្សនៈ ឥរិយាបថ និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងជាជនរងគ្រោះនៅក្នុងការជំនុំជម្រះនៅមុខ អ.វ.ត.ក ។ ការស្រាវជ្រាវជាក់ស្តែងសង្កត់ធ្ងន់លើការសិក្សាស្រាវជ្រាវនៃការចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ត្រូវបានធ្វើឡើងជាង ២ខែកន្លះ រួមមានការប្រមូលទិន្នន័យតាមរយៈការសម្ភាសពាក់កណ្តាលផ្លូវការ ការពិភាក្សា និងទំនាក់ទំនងក្រៅផ្លូវការជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងជាជនរងគ្រោះ និងក្រុមគោលដៅ។ វាធ្វើឡើងតាមរយៈការវិភាគ និងបទពិសោធន៍នៃការសម្ភាសជនរងគ្រោះដែលការស្រាវជ្រាវនេះ ជួយសម្រួលទម្រង់ វិសាលភាព និងភាពស្មុគស្មាញ នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងប្រយោជន៍ដែលបានសន្មតទុក ព្រមទាំងគ្រោះថ្នាក់ដែលអាចកើតមានមួយចំនួនដែលកើតឡើងពីការចូលរួមរបស់ជនរងគ្រោះ។ បន្ថែមលើការស្រាវជ្រាវបែបទ្រឹស្តី និងជាក់ស្តែងដែលធ្វើឡើងសម្រាប់គម្រោងនេះ បរិបទនៃលទ្ធផលរបស់របាយការណ៍ក៏ត្រូវបានបង្ហាញពីរបៀបវារៈស្រាវជ្រាវបែបទូលំទូលាយ ដែលត្រូវបានធ្វើឡើងជាផ្នែកនៃសារណាថ្នាក់បណ្ឌិតរបស់អ្នកនិពន្ធ។

## ២.២- ការរៀបចំស្រាវជ្រាវ

ដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងជាជនរងគ្រោះចំនួនហាសិបរូប ត្រូវបានសម្ភាស និងការពិភាក្សាក្រុមចំនួន ប្រាំក្រុម ត្រូវបានរៀបចំឡើងនៅចន្លោះថ្ងៃទី៥ ខែកញ្ញា និង ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៤។ ការសម្ភាស និងក្រុមពិភាក្សាត្រូវបានធ្វើឡើងនៅទីតាំងដូចខាងក្រោម៖ រាជធានីភ្នំពេញ និងស្រុកនៅជុំវិញ ស្រុកបសេដ្ឋក្នុងខេត្តកំពង់ស្ពឺ ខេត្តសៀមរាបនិងស្រុកនៅជុំវិញ ស្រុកពួក ខេត្តព្រៃវែង ខេត្តកំពង់ចាម និងស្រុកឧត្តុង្គ។ វិធីសាស្ត្រសំណាកដែលកំណត់ត្រូវបានយកដើម្បីកំណត់អ្នកចូលរួមនៅក្នុងការស្រាវជ្រាវផ្ទាល់។ ការចុះសិក្សាដល់ទីកន្លែងមានបំណងប្រមូលទស្សនៈ និងបទពិសោធន៍របស់ក្រុមសំខាន់ៗចំនួន៣៖ (១) ជនរងគ្រោះដែលទទួលស្គាល់ជាផ្លូវការដោយ អ.វ.ត.ក ជាដើមបណ្តឹងរដ្ឋប្បវេណី (២) ដើមបណ្តឹងជាជនរងគ្រោះ និង(៣) ក្រុមធំនៃជនរងគ្រោះ និងសហគមន៍ដែលទទួលរងផលប៉ះពាល់ដែលបានស្វែងរកការចូលរួមជាផ្លូវការឬ “ដោយផ្ទាល់” នៅក្នុងការជំនុំជម្រះ អ.វ.ត.ក។

សម្រាប់គោលបំណងនៃការស្រាវជ្រាវ ផ្អែកលើការកំណត់របស់អ.វ.ត.ក លើក្រុមជនរងគ្រោះផ្សេងៗគ្នា។ ដើម្បីសម្រេចគោលបំណងនេះ “ដើមបណ្តឹងរដ្ឋប្បវេណី” ត្រូវបានកំណត់ជា៖

> អ្នកចូលរួមផ្លូវការក្នុងការជំនុំជម្រះប្រឆាំងនឹងអ្នកដែលត្រូវចោទប្រកាន់ថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រោមការស៊ើបអង្កេតរបស់ អ.វ.ត.ក [...] ពួកគេពេញចិត្តនឹងសិទ្ធិយ៉ាងទូលំទូលាយដែលស្រដៀងនឹងការចោទប្រកាន់ និងការការពារ។ ការក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រឹមតែបានផ្តល់ជនរងគ្រោះនូវសិទ្ធិចូលរួមក្នុងការជំនុំជម្រះក្តីយ៉ាងសកម្មប៉ុណ្ណោះទេ ថែមទាំងអនុញ្ញាតឱ្យជនរងគ្រោះស្នើសុំតុលាការសម្រាប់សំណងសមូហភាព

6 ដូចខាងលើ។

និងសំណងផ្លូវចិត្តពីទណ្ឌិតផងដែរ។[7]

ផ្ទុយទៅវិញ ពាក្យ "ដើមបណ្ដឹងជាជនរងគ្រោះ" ត្រូវបានកំណត់បែបនេះៈ

> បុគ្គល ឬនីតិបុគ្គលដែលមានព័ត៌មានដែលមានប្រយោជន៍ទាក់ទងនឹងឧក្រិដ្ឋកម្មនៃខ្មែរក្រហមក្រោមយុត្តាធិការរបស់ អ.វ.ត.ក អាចដាក់ពាក្យបណ្ដឹងដោយបំពេញទម្រង់ព័ត៌មានជនរងគ្រោះ ហើយដាក់ជូនអង្គភាពគាំពារជនរងគ្រោះ (VSS)។ បន្ទាប់មកព័ត៌មាននៅក្នុងពាក្យបណ្ដឹង អាចនឹងត្រូវបានប្រើប្រាស់ដើម្បីជួយដល់ការស៊ើបអង្កេត។ អ្នកប្ដឹងមិនចូលរួមជាភាគីនៅក្នុងសវនាការ ហើយពួកគេមិនត្រូវបានផ្ដល់សិទ្ធិស្នើសុំតុលាការសម្រាប់សំណងឡើយ។ ប៉ុន្តែ ពួកគេអាចត្រូវបានស្នើឱ្យផ្ដល់ភ័ស្តុតាង ឬធ្វើសក្ខីកម្មជាសាក្សី។[8]

ចំណុចសំខាន់នៃសំណាកគំរូទី១ បានផ្ដោតទៅលើសំណាកគំរូជាក់លាក់នៃជនរងគ្រោះ ៣៥ រូប ដែលបានធ្វើឱ្យពាក្យបណ្ដឹងរបស់ខ្លួនទទួលស្គាល់ជាផ្លូវការដោយ អ.វ.ត.ក បានផ្ដល់សក្ខីកម្ម និងទទួលសំណង។ ក្រុមនេះត្រូវបានជ្រើសរើសជាសំណាកគំរូដោយប្រើព័ត៌មានដែលទទួលបាពី VSS អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។ កាន់តែច្បាស់ជាងនេះទៅទៀត លោក ហង្ស វណ្ណះ ដែលជាប្រធាន VSS នៅអ.វ.ត.ក បានផ្ដល់ក្រដាសឯកសារបញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី ដែលបែងចែកតាមតំបន់ភូមិសាស្ត្រ។ សហមេធាវីនាំមុខ ត្រូវបានទាក់ទងក្រោយពីបានទទួលបញ្ជីនេះពី VSS។ បន្ទាប់មកពួកគេទទួលបានការណែនាំចំពោះនីតិវិធីនៅទីនោះសម្រាប់ទាក់ទងដើមបណ្ដឹងរដ្ឋប្បវេណី។ បន្ទាប់មកទៀត មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានទាក់ទងនឹងអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងស្រុក ក្រុង និងភូមិដែលបានកំណត់ ដែលត្រូវសម្ភាស។ ទីតាំងទាំងនេះត្រូវបានជ្រើសរើសតាមរយៈព័ត៌មាន និងដំបូន្មានដែល ផ្ដល់ដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដោយមានទស្សនៈបង្កើនធនធានជាអតិបរមា និងយកឈ្នះបញ្ហាតំបន់ភូមិសាស្ត្រ។

ចំណុចសំខាន់នៃសំណាកគំរូទី២ បានផ្ដោតទៅលើសំណាកគំរូជាក់លាក់នៃជនរងគ្រោះ ១៥រូប ដែលបានដាក់ពាក្យបណ្ដឹងដោយបំពេញ និងដាក់ជូនទម្រង់ព័ត៌មានជនរងគ្រោះឱ្យ VSS ប៉ុន្តែជាអ្នកដែលមិនត្រូវបានផ្ដល់ឋានៈជាដើមបណ្ដឹងរដ្ឋប្បវេណី។ ក្រុមនេះត្រូវបានជ្រើសរើសជាសំណាកគំរូដោយប្រើព័ត៌មានដែលទទួលបាពី VSS អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងសំណាកគំរូ snowball។ នៅក្នុងទីតាំងភូមិសាស្ត្រជាក់លាក់ណាមួយដែលការសម្ភាសជាមួយដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើង ការរៀបចំត្រូវបានធ្វើសម្រាប់ទាក់ទង និងសម្ភាសដើមបណ្ដឹងជាជនរងគ្រោះ។ ក្នុងគោលបំណងនេះ ទំនាក់ទំនងជាមួយ NGO ក្នុងស្រុក និងសកម្មជនសិទ្ធិមនុស្សបានបង្ហាញថាមានគុណតម្លៃ។

ចំណុចសំខាន់នៃសំណាកគំរូចុងក្រោយបានប្រើប្រាស់សំណាកគំរូដូចគ្នានៃទីតាំងភូមិសាស្ត្រពីចំណុចសំខាន់នៃសំណាកគំរូទី១ និងទី២។ វាបានប្រើប្រាស់សំណាកគំរូដោយចៃដន្យដែលមានគោលបំណង ដើម្បីកំណត់ជនរងគ្រោះ

---

[7] សូមមើល http://www.eccc.gov.kh/en/victims-support/participation (ចូលទៅកាន់នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៥)។
[8] ដូចខាងលើ។

និងសហគមន៍ដែលទទួលរងផលប៉ះពាល់ដែលមិនស្វែងរកការចូលរួមក្នុងការជំនុំជម្រះក្តីជាផ្លូវការ ឬដោយផ្ទាល់។ ចំណាប់អារម្មណ៍រួមពីកិច្ចសម្ភាសទាំងនេះគឺថា អ្នកផ្តល់បទសម្ភាសទាំងនោះចាត់ទុកខ្លួនឯងជាអ្នកតំណាងនៃសហគមន៍ពាក់ព័ន្ធរបស់ពួកគេ ហើយថាមិនមានការមិនពេញចិត្ត ឬការខកចិត្តណាមួយទាក់ទងនឹងដំណើរការជ្រើសរើស ឬសម្ភាសលេចឡើងគួរឱ្យកត់សម្គាល់ឡើយ។

## ២.៣- បញ្ហាប្រឈម និងបញ្ហា

ការចុះសិក្សាដល់ទីកន្លែងនៅក្នុងបរិបទនៃសង្គមក្រោយមានជម្លោះដែលបំផ្លិចបំផ្លាចដោយសង្គ្រាម ហើយភាពក្រីក្រនាំមកនូវបញ្ហាប្រឈមមួយចំនួននៃបុគ្គល និងជាតិពន្ធុសម្រាប់អ្នកស្រាវជ្រាវ។ កិច្ចការបែបនេះក្លាយជាបញ្ហាប្រឈមកាន់តែខ្លាំងនៅពេល គោលបំណងនៃការស្រាវជ្រាវជាក់ស្តែងគឺលើជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ។

សំណួរបឋមមួយចំនួនត្រូវបានគិតពិចារណាមុនពេលចាប់ផ្តើមគម្រោងនេះ។ យើងមានការគោរព ចំពោះក្រមសីលធម៌ក្នុងការធ្វើការស្រាវជ្រាវជាក់ស្តែង ក្នុងចំណោមសហគមន៍ជនរងគ្រោះ។សំណួរនានារួមមាន៖ តើមានភាពខុសគ្នាអ្វីខ្លះអំពីការសម្ភាសជនរងគ្រោះ និងអ្នកនៅរស់ពីអំពើហឹង្សា និងសោកនាដកម្ម ធៀបទៅនឹងប្រភេទសម្ភាសដែលធ្វើឡើងដោយអ្នកជំនាញខាងច្បាប់ និងអ្នកបង្កើតគោលនយោបាយ? តើបច្ចេកទេសពិសេស និងកាតព្វកិច្ចក្រមសីលធម៌ក្នុងប្រភេទសម្ភាសទាំងនេះ? តើយើងអាចចៀសវាងបុគ្គលដែលមានជំងឺបាក់ស្បាតក្លាយជាជនរងគ្រោះម្តងទៀតដោយរបៀបណា? តើតុល្យភាពដែលត្រូវធ្វើរវាងការទទួលបានព័ត៌មានដែលមានគុណភាពខ្ពស់ពីការសម្ភាស និងការកំណត់ហានិភ័យដែលមានជាប់ជាមួយ ដែលពាក់ព័ន្ធក្នុងការព្យាយាមដើម្បីទទួលបានទិន្នន័យ?

ការគិតពីបញ្ហាប្រឈមដែលជួបប្រទះក្នុងការស្រាវជ្រាវ វាសំខាន់ក្នុងការទទួលស្គាល់ថាមាន បញ្ហាពិសេស២ គឺ រចនាសម្ព័ន្ធនៅអន់ និងភាពក្រីក្រខ្លាំងមានឥទ្ធិពលគួរឱ្យកត់សម្គាល់ទៅលើការអាចចូលទៅដល់របស់ជនរងគ្រោះព្រមទាំងគុណភាពនៃការសម្ភាស។ ក្នុងបរិបទនេះ វាជាទំនាក់ទំនងដ៏មានប្រយោជន៍ជាមួយទីភ្នាក់ងារនៅក្នុងស្រុក និងបុគ្គលដើម្បីទទួលបានព័ត៌មានពាក់ព័ន្ធបំផុតជាពិសេសទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ។

ជាចុងក្រោយ លក្ខណៈវប្បធម៌ ជំនឿលើពុទ្ធសាសនាដ៏លើសលប់ និងជាពិសេសបញ្ហាភាសាគួរតែត្រូវបានទទួលស្គាល់ជាកត្តាដែលជះឥទ្ធិពលដល់ការស្រាវជ្រាវក្នុងកម្ពុជា។ ពួកគេអាចតំណាងឧបសគ្គបន្ថែមទៀតដើម្បីទទួលបានការសម្ភាសប្រកបដោយប្រសិទ្ធភាព ជាពិសេសព្រោះការដែលអាចនិយាយភាសាកំណើត អាចសំខាន់ក្នុងការទទួលបានការចូលទៅជួបអ្នកឆ្លើយសម្ភាស និងកសាងទំនុកចិត្ត (Andrews 1995; Tsang, 1998) ។ ពីអ្នកបកប្រែក្នុងស្រុកដែលមានបទពិសោធន៍ និងទស្សនវិស័យជាក់ស្តែងត្រូវបានទំនាក់ទំនងអំឡុងពេលសម្ភាស ដែលបន្ទាប់មកធ្វើប្រតិចារឹកសំឡេងដែលបានថតទុក និងការកត់ត្រា។ លទ្ធភាពសម្រាប់កំហុសត្រូវបានកាត់បន្ថយបន្ថែមទៀតដោយរក្សាទុកសម្រង់ឃ្លាដែលដកស្រង់ចេញពីសម្ភាសជាមួយជនរងគ្រោះក្នុងទម្រង់ដើម។ នៅកម្រិតស្តង់ដារ តែងតែមានហានិភ័យដែលអ្នកបកប្រែក្នុងនាមជាអ្នកខាងក្រៅចំពោះដំណើរការស្រាវជ្រាវអាចបំផ្លាញសេចក្តីទុកចិត្ត និងទំនាក់ទំនងដែលអ្នកស្រាវជ្រាវត្រូវខំប្រឹងប្រែងធ្វើការដើម្បីរក្សាឱ្យបាន។

ក្រៅពីបញ្ហាប្រឈម និងឧបសគ្គផ្សេងៗដែលជួបប្រទះក្នុងអំឡុងពេលស្រាវជ្រាវនេះ គុណភាពនៃការសម្ភាសមិនត្រូវបានប៉ះពាល់ ហើយវត្ថុបំណងសំខាន់ត្រូវបានសម្រេចយ៉ាងល្អកនុងចំណោមផ្សេងទៀតតាមរយៈការសម្របសម្រួល និងជំនួយដែលផ្តល់ដោយភាគីទី៣ ដូចជាអ្នកបកប្រែ VSS និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

ក្រៅពីបញ្ហាប្រឈម និងឧបសគ្គផ្សេងៗដែលជួបប្រទះក្នុងអំឡុងពេលស្រាវជ្រាវនេះ

## ៣- សារតា និងការអភិវឌ្ឍ

ប្រទេសកម្ពុជាធ្លាប់មានអរិយធម៌រុងរឿងពីបុរាណ និងជាអាណាចក្រខ្មែរដ៏ខ្លាំងក្លា តែផ្ទុយទៅវិញមានកេរ្តិ៍ឈ្មោះអសោចនៅសតវត្សរ៍ទី២០ ចំពោះសោកនាដកម្មមនុស្សដ៏ធំបំផុតរបស់មនុស្សជាតិមួយ និងសម្លាប់មនុស្សយ៉ាងឃោរឃៅបំផុត (Jasini & Phan, 2011: 379)។ ខ្មែរក្រហម[9] គឺជាឧទាហរណ៍តែមួយគត់នៃរបបដែលរួមផ្សំ 'មនោគមវិជ្ជាជ្រុលនិយមដែលមានកំហឹងជាតិពន្ធ និងភាពព្រៃផ្សៃមិនគោរពជីវិតមនុស្ស'។[10] ការមិនមានភាពស្មើគ្នានៅក្នុងទម្រង់ ទំហំ និងភាពព្រៃផ្សៃ របបខ្មែរក្រហមបានអនុវត្តយុទ្ធនាការជាប្រព័ន្ធនៃឃាតកម្ម និងការអត់ឃ្លានចាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ខែមករា ឆ្នាំ១៩៧៩ ដែលបានសម្លាប់ខ្មែរ និងបរទេសជាង១,៧លាននាក់។

ខ្មែរក្រហមចាប់ផ្តើមបេសកកម្មបំផ្លិចបំផ្លាញសង្គមខ្មែរដោយគ្មានមេត្តា។ គ្មានអ្វីដែលអាចបញ្ជាក់បង្ហាញប្រសើរជាងយុទ្ធនាការរបបឱ្យត្រឡប់សង្គមទៅ 'ឆ្នាំសូន្យ' (Kiernan, 2008: 339)។ យុទ្ធនាការនេះអាចនាំឱ្យមានវិធានធ្ងន់ធ្ងរបានបង្ខំឱ្យប្រជាជនធ្វើការងារលើសកម្លាំង រៀបការទាំងបង្ខំ គ្មានការចេះដឹង ព្រមទាំងដាក់គំនាបលើសិទ្ធិក្នុងការថ្វាយបង្គំ ការបង្ហាញមនសិការ និងវប្បធម៌។ ភាពភ័យខ្លាចដែលបង្កដោយរបបត្រូវបានជំរុញដោយមនោគមវិជ្ជាប្រឆាំងនឹងចក្រពត្តិនិយម។ លទ្ធផលនៃរបបគឺជាប្រជាជាតិ 'ដែលត្រូវបានចាប់ជម្រិត និងហ៊ុំព័ទ្ធពីខាងក្នុង' ។ វាគឺជាការបង្កើត 'រដ្ឋនៃមន្ទីរឃុំឃាំងដែលអ្នកទោស ៨លាននាក់ប្រើពេលរបស់ពួកគាត់នៅក្នុងការបង្ខាំងដាច់ដោយឡែក' ហើយអ្នកជាប់ឃុំជាច្រើន 'ត្រូវបង្ខំឱ្យធ្វើការ អត់ឃ្លាន និងវាយដំរហូតដល់ស្លាប់'។ (Kiernan, 2002: 9)

ឥទ្ធិពលជាក់ស្តែងនៃចំនួន និងតួលេខទាំងនេះត្រូវបានដឹងឮយ៉ាងច្បាស់ អំឡុងពេលសម្ភាសជាមួយជនរងគ្រោះនៃរបបខ្មែរក្រហម ជាផ្នែកនៃការស្រាវជ្រាវចុះដល់ទីតាំងផ្ទាល់ដែលធ្វើឡើងក្នុងគម្រោងនេះ។ ការដឹងឮ និងការវិភាគតម្រូវរបស់ជនរងគ្រោះដែលចូលរួមក្នុងដំណើរការ TJ កម្ពុជាគឺមិនអាចទៅរួចដោយមិនបង្ហាញទំហំឈឺចាប់របស់ជនរងគ្រោះ។ លើសពីនេះទៅទៀត ការយល់ដឹងសមស្របនៃភាពស្មុគស្មាញក្នុងប្រវត្តិសាស្ត្រ និងសង្គមនៃរបបខ្មែរក្រហមមិនអាចកើតឡើងដោយឯករាជ្យនៃបទពិសោធន៍ និងការបាក់ស្បាតផ្ទាល់ខ្លួនដែលរងទុក្ខដោយជនរងគ្រោះ។[11] ចំណុចនេះ អាចបង្ហាញយ៉ាងល្អ ដោយយោងតាមសក្ខីកម្មរបស់អ្នកសម្ភាសផ្តល់បទសម្ភាស។ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ដែលត្រូវបានសម្ភាសសម្រាប់ការស្រាវជ្រាវនេះបានបញ្ជាក់ថា៖

> ខ្ញុំបានឆ្លងកាត់ទុក្ខលំបាកច្រើនរាប់មិនអស់នៅក្នុងសម័យនោះ។ ខ្ញុំមានបងប្អូនបង្កើត ៣នាក់។ ប្អូនប្រុសរបស់ខ្ញុំត្រូវបានបាញ់សម្លាប់ប្រតិបត្តិការយោធា។ បងប្អូនថ្លៃប្រុស

---

9 ខ្មែរក្រហម ដែលពាក្យបង្កើតថ្មីដោយអតីតព្រះមហាក្សត្រខ្មែរ ព្រះនាម នរោត្តម សីហនុ សំដៅលើគណៈបក្សនយោបាយកម្ពុជាដែលដឹកនាំតាមបែបកុម្មុយនីសពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

10 សូមមើលកម្មវិធីបនប្រល័យពូជសាសន៍កម្ពុជានៅសាកលវិទ្យាល័យ Yale ។ មាននៅ៖ http://www.yale.edu/cgp/ (ចូលយកនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៥)

11 ការទទួលបានបទពិសោធន៍សាជាថ្មីគឺជាព្រឹត្តិការណ៍ដែលបណ្តាលឱ្យបាក់ស្បាត សម្រាប់អ្នកផ្តល់បទសម្ភាសនៅក្នុងខ្លួនវាផ្ទាល់។ នេះអាចជាដឹងឮពីការដកស្រង់ខាងក្រោមពីកិច្ចសម្ភាសន៍ធ្វើឡើងជាមួយដើមបណ្តឹងរដ្ឋប្បវេណីនៅរាជធានីភ្នំពេញ៖

> *តាមពិត ខ្ញុំមិនចង់រំឭករឿងរបស់ខ្ញុំទេ។ ខ្ញុំមិនចង់ស្រមៃមើលម្តងទៀតពីអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហមឡើយ ព្រោះខ្ញុំគិតបានគិតថាជីវិតខ្ញុំគ្មានន័យអ្វីសោះ... ខ្ញុំបានបាត់បង់សមាជិកគ្រួសារខ្ញុំទាំងអស់... ខ្ញុំបានបាត់បង់អនាគតព្រោះខ្ញុំបានរស់នៅជាមួយគ្រួសារដទៃ ហើយមិនមានឱកាសរៀនសូត្រទេ។ នៅឆ្នាំ១៩៧៩ ខ្ញុំមានអាយុ១៧ឆ្នាំ... ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើជាទាហាន តែមិនមែនមានន័យថាខ្ញុំចង់ធ្វើជាអ្នកស្នេហាជាតិទេ ប៉ុន្តែដោយសារខ្ញុំចង់ស្លាប់តែប៉ុណ្ណោះ។*

(ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ៖ សំណុំរឿង០០២ នៅភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤)។

> របស់ខ្ញុំត្រូវបានចាប់ខ្លួនក្នុងបទចោទប្រកាន់ជាជនជាតិវៀតណាម ហើយត្រូវបានបញ្ជូនទៅខេត្តកំពង់ស្ពឺដែលគាត់ត្រូវបានឃុំខ្លួននៅក្នុងរូងភ្នំ ហើយទំនងជាស្លាប់នៅទីនោះ។ ម្យ៉ាងវិញទៀត យាយរបស់ខ្ញុំ បានស្លាប់ដោយសារអត់ឃ្លាន។ បងប្អូនស្រីរបស់ធ្វើការក្នុងកងសហករធ្វើស្រែ ហើយក្រោយមកស្លាប់បន្ទាប់ពីរបបប៉ុលពត។ ឪពុកម្តាយរបស់ខ្ញុំត្រូវបានបំបែកពីគ្នា... អំឡុងពេលសម័យប៉ុលពត យើងត្រូវនិយាយដោយប្រុងប្រយ័ត្ន។ កំហុសបន្តិចបន្តួចអាចនាំទៅរកសេចក្តីស្លាប់។[12]

យន្តការ ដំណើរការ និងនវានុវត្តន៍ដែលបង្កើតដោយសង្គមក្រោយពីដើបពីសោកនាដកម្មត្រូវតែធ្វើការវាយតម្លៃប្រឆាំងនឹងការរងទុក្ខវេទនា។ ដូចនេះ រាល់ការពិចារណានៃការជំរុញទឹកចិត្ត និងការវាយតម្លៃនៅពីក្រោយជនរងគ្រោះនៅកម្ពុជាមិនអាចបំបែកចេញពីទំហំនៃការឈឺចាប់
ក្រោមរបបខ្មែរក្រហមបានឡើយ។ ឧទាហរណ៍៖
មនុស្សជាច្រើនអាចចាត់ទុកទំហំនៃភាពឃោរឃៅដែលប្រព្រឹត្តដោយខ្មែរក្រហម ខណៈលុបបំបាត់លទ្ធភាពសម្រាប់សំណងជាក់ស្តែង
ក៏ប៉ុន្តែចាត់ទុកការចូលរួមរបស់ពួកគាត់នៅក្នុងការជំនុំជម្រះក្តីថាមានសារៈសំខាន់។
ចំណុចនេះបង្ហាញតាមរយៈសម្រង់ឃ្លាខាងក្រោម៖

> បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ខ្ញុំបានដឹងថាខ្ញុំបានទទួលជីវិតថ្មី។ នៅពេលដែលខ្ញុំបានដឹងថា អ.វ.ត.ក ត្រូវបានបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ខ្ញុំពិតជាចង់ដឹងអំពី អ.វ.ត.ក... ខ្ញុំមិនបានគិតថាតុលាការអាចនឹងស្វែងរកការពិតសម្រាប់ប្រជាជនខ្មែរនោះទេ។ ប៉ុន្តែ សមាគមអាដហុក[13] បានមកទីនេះស្វែងរកជនរងគ្រោះដែលចង់ដាក់ពាក្យបណ្តឹងក្នុងករណី ០០២។ ខ្ញុំបានចូលរួមជាមួយជនរងគ្រោះទាំងនោះ ដើម្បីដាក់ពាក្យបណ្តឹងក្នុងករណី ០០២ ដើម្បីឱ្យជនល្មើសទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានធ្វើចំពោះខ្ញុំ និងគ្រួសារខ្ញុំ។ ខ្ញុំចង់បានយុត្តិធម៌សម្រាប់ខ្លួនខ្ញុំ *និងប្រជាជនខ្មែរ* ។ ខ្ញុំចង់ជួយតុលាការស្វែងរកឧក្រិដ្ឋកម្មដែលជនជាប់ចោទទាំង ៤រូប បានប្រព្រឹត្ត។ ពួកគេបាននាំការឈឺចាប់ដល់ប្រជាជនខ្មែរ... ហើយការឈឺចាប់បែបនេះមិនអាចទូទាត់សងវិញបានទេ ការឈឺចាប់ទាំងនេះមិនវាស់វែងបានឡើយ។[14]

កម្រិតផ្លាស់ប្តូរព្រឹត្តិការណ៍ដែលកើតឡើងក្នុងប្រទេសកម្ពុជា
ដែលផ្តល់ជាប្រវត្តិស្ថានភាពនៃរបាយការណ៍នេះ
និងការយល់ដឹងរបស់យើងពីការចូលរួមរបស់ជនរងគ្រោះដែលប្រមូលផ្តុំក្នុងពាក្យពេចន៍

---

[12] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០១ និង០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសៀមរាប ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤) ។

[13] អាដហុក (សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា) គឺជាអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាស្ថាបនាដោយអ្នកទោសនយោបាយខ្មែរក្រហម។ សមាគមនេះផ្តល់យោបល់ផ្លូវច្បាប់ និងធ្វើការស៊ើបអង្កេតការរំលោភបំពានសិទ្ធិមនុស្សនៅកម្ពុជា។ កម្មវិធីចុះតាមមូលដ្ឋានរបស់សមាគមអាដហុក ដែលទាមទារឱ្យមានការចូលរួមរបស់ជនរងគ្រោះខ្ពស់ក្នុងការកាត់ក្តីពីមុខ អ.វ.ត.ក ។ សូមមើល៖
www.adhoc-cambodia.org (ចូលទៅកាន់នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៥)។

[14] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង ០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅភ្នំពេញ ថ្ងៃទី០៣ ខែ វិច្ឆិកា ឆ្នាំ២០១៤) ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម។

របស់ជនរងគ្រោះម្នាក់ដែលបានលើកឡើងថាគាត់ 'មិនដែលបានឃើញប្រជាជាតិមួយសម្លាប់ប្រជាជនរបស់ខ្លួនដូចនេះទេ'។[15]

### ៣.១- ឥទ្ធិពលក្នុងសង្គមកម្ពុជាក្រោយសង្គ្រាម

ក្នុងនាមជាសង្គមក្រោយសង្គ្រាម ប្រទេសកម្ពុជាក៏នៅតែជួបការលំបាកឈានទៅដល់លក្ខខណ្ឌអតីតរបស់ខ្លួន ហើយជួបប្រទះបញ្ហាប្រឈមក្នុងការស្វែងរកយុត្តិធម៌។ ក្នុងករណីខ្លះដែលជនល្មើស និងបទល្មើសគួរតែត្រូវបានទទួលស្គាល់ នៅតែមានជម្លោះ។ តុល្យភាពរវាងការបង្កើតការផ្សះផ្សា និងការដោះស្រាយតម្រូវការ និងសិទ្ធិរបស់ជនរងគ្រោះនៅតែពិបាកកំណត់។[16] ដូចនេះ មានឥទ្ធិពលខុសៗគ្នាដែលកំណត់លក្ខខណ្ឌស្ថានភាពអន្តរកាលនៃសង្គមខ្មែរ ដែលត្រូវបានពណ៌នាដោយអ្នកអត្ថាធិប្បាយ ថាជា 'អង្គភាពរួមក្នុងអន្តរកាលយ៉ាងឆាប់រហ័ស បែកបាក់ និងខ្ទេចខ្ទាំអស់រយៈពេលជាច្រើនទសវត្សរ៍... តាមរបៀបដែលអាចគិតដល់' (Wilshire, 2005: 69)។ ម៉ាទ្រិកនៃកត្តាដែលខុសប្លែកពីគេ និងឥទ្ធិពលពិសេស ដែលបង្កើតបានជាសង្គមខ្មែរ ប្រទេសក្នុងអន្តរកាល ប្រកាសស្វែងរកយុត្តិធម៌រាល់បញ្ហាស្មុគស្មាញ និងពិបាកទាំងអស់ ទាំងសម្រាប់សង្គមខ្មែរទូទៅ និងជនរងគ្រោះជាពិសេស។ ឧបសគ្គនៃចរិតលក្ខណៈផ្លូវច្បាប់ ភ័ស្តុតាង និងនីតិវិធី អាស្រ័យលើរបៀបធ្វើឱ្យជនល្មើសរបបខ្មែរក្រហមដែលនៅរស់ទទួលខុសត្រូវ។

ការពិបាកទាំងនេះមិនមែនចរិតលក្ខណៈបច្ចេកទេសសុទ្ធសាធនោះទេ ប៉ុន្តែភ្ជាប់ទៅនឹងការពិបាកដែលគេបានយល់ឃើញចំពោះប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្ពុជា ព្រមទាំងបញ្ហាអំពើពុករលួយដែលកើតមានជានិច្ច ហើយកាន់តែទូទៅចំពោះ*នយោបាយជាក់ស្តែង*នៃប្រព័ន្ធដែលជា 'អំណាចនយោបាយដែលធ្វើឡើងដោយរដ្ឋាភិបាល' (Bates, 2007: 185)។ ឥទ្ធិពលទាំងនេះត្រូវបានឆ្លុះបញ្ចាំងពីភាពស្មុគស្មាញផ្លូវច្បាប់ និងរចនាសម្ព័ន្ធនៃ អ.វ.ត.ក។[17]

អ.វ.ត.ក គឺជាចំណុចស្នូលនៃដំណើរការ TJ កម្ពុជា។ អ.វ.ត.ក គឺជាសាលាក្តីកូនកាត់ ដោយរួមបញ្ចូលចៅក្រម និងអ្នកជំនាញផ្លូវច្បាប់ជនជាតិខ្មែរ និងអន្តរជាតិ។ វាឈរជាអង្គភាពសាលាក្តីទោលក្នុងការកាត់ក្តី អ្នកដែលត្រូវទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មនៃរបបខ្មែរក្រហម។ តុលាការមានកិច្ចការពិបាកក្នុងការយល់ពីភាពស្មុគស្មាញរវាងអត្ថប្រយោជន៍អង្គភាពជាតិ និងអន្តរជាតិរបស់ខ្លួន ព្រមទាំងអ្នកចូលរួមក្នុងសាលសវនាការរួមមានព្រះរាជអាជ្ញា មេធាវីការពារ និងជាពិសេសជនរងគ្រោះ។ អ.វ.ត.ក ផ្តល់ឱកាសពិសេសប្លែកពីគេដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហមក្នុងការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជំនុំជម្រះក្តីផ្លូវច្បាប់ ដែលកំណត់តាមរបៀបនេះជាវឌ្ឍនភាពដ៏សំខាន់ សម្រាប់សិទ្ធិជនរងគ្រោះនៃការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ។ តាមពិត លក្ខណៈ និងកម្រិតនៃការចូលរួមដែលផ្តល់ដល់ជនរងគ្រោះក្នុងដំណើរការកាត់ក្តី ជាព័ត៌មានលម្អិតនៃភាពជោគជ័យ និងឥទ្ធិពលនៃ អ.វ.ត.ក ជាយន្តការយុត្តិធម៌អន្តរកាល។

---

[15] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង ០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៤)។

[16] Jasini, R (2015) ការចូលរួមរបស់ជនរងគ្រោះក្នុងនីតិវិធីឧក្រិដ្ឋកម្មអន្តរជាតិ សារណាដែលមិនបានបោះពុម្ពផ្សាយនៅសាកលវិទ្យាល័យ Oxford, Oxford, UK។

[17] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រាប់កាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ (ច្បាប់អ.វ.ត.ក) ដោយដាក់បញ្ចូលសវនកម្មដែលបានប្រកាសនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤(នស/រកម/១០០៤/០០៦) មាត្រាទី៣-៨។មាននៅ http://www.eccc.gov.kh/sites/default/files/legal-documents/KR_Law_as_amended_27_Oct_2004_Eng.pdf (ចូលទៅកាន់នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥)។

បើទោះជាយ៉ាងណាក៏ដោយ ការចូលរួមត្រូវបានគេរៀបចំ មិនមែនត្រឹមតែលើកត្តាផ្ទៃក្នុង ក៏ប៉ុន្តែក៏មកពីកត្តាខាងក្រៅផងដែរ ដូចជា ឥទ្ធិពលសង្គម និងវប្បធម៌ដែលកំណត់ចរិតសង្គមខ្មែរ។ ទិដ្ឋភាពទូទៅនៃឥទ្ធិពលវប្បធម៌សង្គម និងនយោបាយផ្លូវច្បាប់សំខាន់ៗរបស់សង្គមខ្មែរនឹងធ្វើឱ្យការយល់ដឹងរបស់យើងកាន់តែស៊ីជម្រៅនៃភាពស្មុគស្មាញជុំវិញការចូលរួមដើមបណ្ដឹងរដ្ឋប្បវេណីក្នុងគំរូ TJ របស់កម្ពុជា។

### ៣.២- ឥទ្ធិពលវប្បធម៌សង្គម

ឥទ្ធិពលវប្បធម៌សង្គមរបស់សង្គមខ្មែរ ត្រូវបានដឹងឮតាមរយៈការនិយាយប្រាប់ពីភាពឃោរឃៅព្រៃផ្សៃដែលបានប្រព្រឹត្តដោយខ្មែរក្រហម និងសម័យក្រោយរបបខ្មែរក្រហម ខណៈដែលប្រទេសកម្ពុជាព្យាយាមស្វែងយល់ពីព្រឹត្តិការណ៍ទាំងនោះ និងការតស៊ូដើម្បីឆ្ពោះទៅរកយុត្តិធម៌ និងការផ្សះផ្សា។ ការធ្វើសមាហរណកម្មឡើងវិញ និងនិតិសម្បទានៃចំនួនអតីតកម្មាភិបាលខ្មែរក្រហមដ៏ច្រើនបានបង្ហាញថាវាមានការពិបាកខ្លាំង។ ឧទាហរណ៍៖ នៅពេលសួរថាហេតុអ្វីបានជាពួកគាត់ចូលរួមក្នុងការសម្លាប់រង្គាល អតីតសមាជិក និងទាហានស៊ីឈ្នួលនៃរបបនោះបញ្ជាក់ថាពួកគេ 'គ្រាន់តែធ្វើតាមបញ្ជា'។

យើងមានការពិភាក្សាដេញដោលថាតើជាការធ្វើតាមបញ្ជារបស់អាជ្ញាធរអាចត្រូវបានគេឃើញថាជាអត្តចរិតវប្បធម៌ខ្មែរ។ ទោះជាយ៉ាងណា វាច្បាស់ណាស់ថាប្រពៃណីអ្នកផ្ដាច់ការបានបំពេញទៅក្នុងវប្បធម៌នយោបាយដែលការស្ដាប់បញ្ជាគឺជាកត្តាសំខាន់។ នេះបានបង្ហាញពីខ្លួនឯងតាមរបៀបជាច្រើនអំឡុងការដឹកនាំរបស់ខ្មែរក្រហម។ បន្ទាប់មកវប្បធម៌នៃការទទួលយក និងការស្ដាប់បង្គាប់យ៉ាងសកម្មដែលតម្រូវដោយរដ្ឋ បញ្ជាក់ពីមូលហេតុដែលសង្គមខ្មែរត្រូវបានពណ៌នាថាស្ទាក់ស្ទើរ ឬប្រឆាំងនឹងភាពប្រាកដប្រជាចំពោះការប្រែក្លាយ និងការផ្លាស់ប្ដូរ។ លោក Chandler បានសិក្សាយ៉ាងស៊ីជម្រៅ ហើយបានពិពណ៌នាប្រទេសនេះថាស្ថិតក្នុងសភាពនៃ 'ភាពមិនមានការផ្លាស់ប្ដូរ' (2008: 14)។ ស្ថានភាពនៃកិច្ចការនេះត្រូវបានលាតត្រដាងកាន់តែខ្លាំងដោយទំហំនៃការថ្វាយបង្គំតាមបែបសាសនា និងទំនៀមទម្លាប់វប្បធម៌ក្នុងប្រទេសកម្ពុជា។ ក្នុងនាមជាប្រទេសដែលកាន់ពុទ្ធសាសនាស្ទើរតែទាំងស្រុង ជាទូទៅសង្គមខ្មែរស្វែងរកយុត្តិធម៌ផ្អែកលើមូលដ្ឋាននៃការផ្សះផ្សាជាជាងចងពៀរ (Harris, 2005)។ ដូចនេះ ជារួម វាត្រូវបានសន្មតថាការទទួលយក ការយោគយល់ និងមេត្តាធម៌ ព្រមទាំងជំនឿលើការចាប់ជាតិដែលជាទស្សនទានទាក់ទងនឹងជំនឿពុទ្ធសាសនា ជាញឹកញាប់គ្របដណ្ដប់ការទាមទារគណនេយ្យភាពដែលជាទិដ្ឋភាពដែលមានជាប់នឹងទស្សនទានយុត្តិធម៌ព្រហ្មទណ្ឌ។ ប៉ុន្តែការស្រាវជ្រាវជាក់ស្ដែងតាមទម្រង់នៃការសម្ភាសជនរងគ្រោះដែលធ្វើឡើងសម្រាប់ការស្រាវជ្រាវនេះបង្ហាញរូបកាន់តែច្បាស់ជាពិសេសដោយសារអ្នកផ្ដល់បទសម្ភាសបញ្ជាក់សារៈសំខាន់ដល់ពួកគេពីយន្តការគណនេយ្យភាពដែលផ្ដល់ដោយ អ.វ.ត.ក។ ឥទ្ធិពល មួយចំនួននៅពេលថ្មីៗនេះត្រូវបានដាក់បង្ហាញដូចខាងក្រោម៖

> ចំណាប់អារម្មណ៍ដំបូងរបស់ខ្ញុំគឺខ្ញុំត្រូវការស្វែងរកយុត្តិធម៌ឱ្យឪពុកម្ដាយរបស់ខ្ញុំ។ ខ្ញុំបានគិតថាប្រសិនបើខ្ញុំមានឱកាស ខ្ញុំនឹងស្វែងរកយុត្តិធម៌សម្រាប់ឪពុកម្ដាយរបស់ខ្ញុំ ព្រមទាំងប្រជាជនខ្មែរផ្សេងទៀត។ ប៉ុន្តែរឿងដំបូងដែលខ្ញុំចាប់អារម្មណ៍បំផុតគឺព័ត៌មានដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានមានផែនការបង្កើតតុលាការ ហើយខ្ញុំរីករាយដែលឮបែបនោះ។ ខ្ញុំសង្ឃឹមថាប្រសិនបើតុលាការបែបនោះត្រូវបានបង្កើតឡើងដោយជោគជ័យ ខ្ញុំនឹងព្យាយាមគ្រប់វិធីដែលខ្ញុំអាចធ្វើដើម្បីដាក់ពាក្យបណ្ដឹងនៅតុលាការដើម្បីខ្ញុំអាចស្វែងរកយុត្តិធម៌ឱ្យឪពុកម្ដាយខ្ញុំ និងប្រជាជនខ្មែរ។ ខ្ញុំសប្បាយចិត្ត

> និងសង្ឃឹមពីការបង្កើតតុលាការ ពីព្រោះខ្ញុំបានគិតថា បើទោះជាឪពុកម្តាយខ្ញុំស្លាប់ទៅហើយក៏ដោយ ពួកគាត់ស្លាប់ដោយដឹងថា កូនប្រុសរបស់ពួកគាត់បានព្យាយាម អស់ពីសមត្ថភាពដើម្បីស្វែងរកយុត្តិធម៌ឱ្យពួកគាត់។ ខ្ញុំសង្ឃឹមថា ប្រជាជននៅទូទាំងពិភពលោក មិនមែនគ្រាន់តែប្រជាជននៅក្នុងប្រទេសកម្ពុជាទេ នឹងចូលរួមក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម ដូច្នេះពួកគេទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្ត។[18]

ដូចនេះ ការស្វែងរកយុត្តិធម៌ក្នុងសង្គមកម្ពុជាក្រោយសង្គ្រាមត្រូវបានធ្វើឡើងគ្រប់បញ្ញាប្រឈម និងភាពស្មុគស្មាញជាច្រើនដោយ មិនមែនត្រឹមតែកត្តាវប្បធម៌សង្គមប៉ុណ្ណោះទេ ថែមទាំងឥទ្ធិពលនយោបាយនិងច្បាប់ជាពិសេសផងដែរ ដែលនឹងត្រូវពិភាក្សានៅក្នុងផ្នែករងខាងក្រោម។

## ៣.៣- ឥទ្ធិពលនយោបាយនិងច្បាប់

ការយល់ដឹងពីឥទ្ធិពលនយោបាយ និងច្បាប់មួយចំនួនក្នុងប្រទេសកម្ពុជានឹងផ្តល់បរិបទបន្ថែមចំពោះលទ្ធផល និងទស្សនៈរបស់ជនរងគ្រោះដែលមាននៅក្នុងរបាយការណ៍នេះ។

រដ្ឋាភិបាលកម្ពុជាចង់រក្សាភាពជាម្ចាស់ការនៃការជំនុំជម្រះផ្លូវច្បាប់នៅ អ.វ.ត.ក ដែលប៉ះពាល់ដល់ឯករាជ្យភាព និងមុខងារប្រកបដោយប្រសិទ្ធភាពរបស់តុលាការ។ មន្ត្រី ព្រះរាជអាជ្ញា និងចៅក្រមកម្ពុជាដែលត្រូវតែងតាំងដោយរដ្ឋាភិបាលឱ្យធ្វើការនៅ អ.វ.ត.ក បានបង្ហាញភាពស្ទាក់ស្ទើរជាបន្តបន្ទាប់ និងជួនកាលបដិសេធពេញមុខចំពោះការសហការទាក់ទងនឹងការកាត់ទោសជនសង្ស័យបន្តទៀត។ គេអាចនិយាយបានថា នេះដោយសារតែមន្ត្រីរដ្ឋាភិបាលមួយចំនួនជាអតីតសមាជិកខ្មែរក្រហម។ លោកនាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន សែន ដែលខ្លួនគាត់ផ្ទាល់ជាអតីតមន្ត្រីខ្មែរក្រហម ត្រូវបានគេចោទថាបានគាំទ្រកងកម្លាំងនគរបាលដោយប្រយោល មិនឱ្យពួកគេសហការក្នុងការចាប់ខ្លួនជនសង្ស័យ។[19] លើសពីនេះទៅទៀត យោងតាមអង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) លោក ហ៊ុន សែន បានបញ្ជាក់ថាការបន្តការកាត់ទោសជនសង្ស័យផ្សេងទៀត អាចនឹងគំរាមដល់ស្ថិរភាពនយោបាយនៅក្នុងប្រទេស។[20] នាពេលថ្មីៗនេះទៀត ក្រោយពីសេចក្តីប្រកាសថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលជនជាប់ចោទទី២ ត្រូវបានចោទប្រកាន់ជាផ្លូវការក្នុងករណី ០០៤ លោក ហ៊ុន សែន បានបញ្ជាក់ថាប្រទេសកម្ពុជាអាចនឹងធ្លាក់ចូលទៅក្នុង 'សង្គ្រាមស៊ីវិល' ប្រសិនបើ ការចោទប្រកាន់ប្រឆាំងនឹងអតីតកម្មាភិបាលខ្មែរក្រហមត្រូវបានធ្វើឡើងជាបន្តទៀត។[21]

អំពើអរិភាពចំពោះតុលាការក៏គួរត្រូវបានពិចារណា ក្នុងការទាក់ទងនឹងការផ្លាស់ប្តូរជំហររបស់លោកហ៊ុន សែន ហើយក្រោយមកមានការលាក់លៀមទាក់ទងនឹងការកាត់ទោសឧក្រិដ្ឋជន។ បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ភ្លាម រដ្ឋាភិបាល ហ៊ុន សែន ដែលគាំទ្រដោយវៀតណាម បានរៀបចំអ្វីដែលបានត្រូវបានចាត់ទុកជាការជំនុំជម្រះក្តីឱ្យគ្រាន់តែល្អមើល

---

[18] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង ០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសៀមរាប ថ្ងៃទី២៤ ខែ តុលា ឆ្នាំ២០១៤)។

[19] The New York Times 'អំពើអរិភាពរបស់លោក**ហ៊ុន សែន** បានដាក់សាលាក្តីខ្មែរក្រហមដែលមានអាយុកាលមួយទសវត្សរ៍នេះស្ថិតក្នុងភាពងឿងឆ្ងល់' ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥។

[20] របាយការណ៍អង្គការឃ្លាំមើលសិទ្ធិមនុស្ស 'ប្រទេសកម្ពុជា៖ បញ្ឈប់ការរាំងស្ទះយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម' ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៥។ មាននៅ៖ http://www.hrw.org/news/2015/03/22/cambodia-stop-blocking-justice-khmer-rouge-crimes (ចូលទៅកាន់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៥)។

[21] សូមមើល៖ www.upi.com/top_news/world-news/2015/03/27/ex-khmer-rouge-official-charged-with-crimes-against-humanity/7231427498610/ (ចូលទៅកាន់ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥)។

ដោយផ្តន្ទាទោស*កំបាំងមុខ* លើអតីតមេដឹកនាំខ្មែរក្រហមឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ ដោយពេលវេលាបានកន្លងផុតទៅ និងចុងបញ្ចប់នៃសង្គ្រាមត្រូវជាក់ ក្តីប្រាថ្នាសម្រាប់ការកាត់ក្តីមានការថយចុះ។ ទន្ទឹមនឹងនេះ លោក ហ៊ុន សែន បានស្វែងរកការទាក់ទាញឱ្យពួកខ្មែរក្រហមចុះចូលក្នុងសង្គមខ្មែរវិញ ដោយសន្យាផ្តល់ការលើកលែងទោស។ ប៉ុន្តែនៅឆ្នាំ១៩៩៧ សំណើរផ្លូវការត្រូវបានធ្វើឡើងដើម្បីសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីបង្កើតសាលាក្តី។ ការចរចាដ៏យូរអង្វែងជិតមួយទសវត្សរ៍ទើបបានកើតឡើង មុនពេល អ.វ.ត.ក ចាប់ផ្តើមជាផ្លូវការ ប្រតិបត្តិការរបស់ខ្លួននៅឆ្នាំ២០០៦។[22] បរិបទនេះបង្ហាញពាក្យសម្តីធ្ងន់ៗក្នុងបរិយាកាសតានតឹង និងចោទប្រកាន់ផ្នែកនយោបាយដែល អ.វ.ត.ក ដំណើរការ។

កិច្ចអន្តរាគមន៍នយោបាយបែបនេះ ដាក់បញ្ហាប្រឈមសម្រាប់ស្វែងរកយុត្តិធម៌នៅប្រទេសកម្ពុជា ដោយមិនមែនគ្រាន់តែដោយសារតុលាការជាសាលាក្តីកូនកាត់ ដែលមានទំនាក់ទំនងយ៉ាងរឹងមាំទៅនឹងប្រព័ន្ធច្បាប់ក្នុងប្រទេសកម្ពុជាឡើយ។ សរុបមក សូមចាំថា ចៅក្រម និងមន្ត្រីតុលាការផ្សេងទៀត យ៉ាងហោចណាស់ជាផ្នែកមួយ ត្រូវបានតែងតាំងដោយរដ្ឋាភិបាល។ ដូចនេះ ឥទ្ធិពលដ៏ពិបាកត្រូវបានបង្កើតឡើងដោយភាពឯករាជ្យរបស់តុលាការ ដែលជាផ្នែកនៃមន្ត្រីរបស់ខ្លួន និងការប្រកាន់ខ្ជាប់របស់ខ្លួនចំពោះបទដ្ឋានអន្តរជាតិស្ថិតនៅក្រោមការពិនិត្យពិច័យភ្លាមៗ។

បន្ថែមលើភាពស្មុគស្មាញនយោបាយដែលទើបតែបានគូសបញ្ជាក់ ក៏មានឥទ្ធិពលផ្លូវច្បាប់ និងបញ្ហាប្រឈមដែលប៉ះពាល់ដល់យន្តការស្វែងរកយុត្តិធម៌អន្តរកាលកម្ពុជា។ ជាទូទៅ ច្បាប់ត្រូវបានគេឃើញនៅប្រទេសកម្ពុជា ‘ថាជាឧបករណ៍បញ្ជាក់ភាពត្រឹមត្រូវរបស់អ្នកមានអំណាច’ (Bates, 2007: 191) ។ ដោយសារតែអ្នកកាន់អំណាចក្នុងប្រវត្តិសាស្រ្តកម្ពុជាទាំងមូលត្រូវបានគេឃើញថាស្ថិតនៅលើច្បាប់ នេះមិនមែនជាអ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះទេ។ មានការគាំទ្រនឹងទស្សនទានដែលមានកម្រិតនៃគណនេយ្យភាពនៃមន្ត្រីរដ្ឋាភិបាល ហើយទោះបីជាបទល្មើសដូចជាការស្បថបំពាន ការស៊ីកជ៉ាន់ និងការបង្ខិតបង្ខំសាក្សីនៅតែមានក្នុងច្បាប់ព្រហ្មទណ្ឌកម្ពុជា ហើយមិនមានបទល្មើសព្រហ្មទណ្ឌណាកើតមានចំពោះការរារាំងដោយចេតនាលើការពិនិត្យអង្គហេតុនៃបទឧក្រិដ្ឋ។[23] ទាក់ទងនឹងនេះ អំពើពុករលួយនៅតែមានជាបញ្ហារាលដាលមួយផ្សេងទៀត។

ចំណុចទាំងនេះបានបង្ហាញឱ្យឃើញយ៉ាងច្បាស់តាមរយៈភាពស្ទាក់ស្ទើរទូទៅក្នុងចំណោមអ្នកផ្តល់បទសម្ភាស ក្នុងការនិយាយអំពីតួនាទីរបស់រដ្ឋាភិបាលកម្ពុជាក្នុងការទាមទារយុត្តិធម៌ឱ្យជនរងគ្រោះ ដែលបង្ហាញពីភាពភ័យខ្លាច និងភាពមិនស្រណុកក្នុងចិត្ត។ ដូចនេះ បុគ្គលម្នាក់ដែលត្រូវបានសម្ភាសបានប្រកាន់ខ្ជាប់គំនិតរបស់ខ្លួនចាប់តាំងពីដំបូង នៅពេលចុះជួបសម្រាប់ការសម្ភាសដោយនិយាយថា ‘ខ្ញុំអាចគ្រាន់តែឆ្លើយសំណួរណាដែលពាក់ព័ន្ធនឹង អ.វ.ត.ក ប៉ុណ្ណោះ ហើយបទពិសោធន៍ [របស់ខ្ញុំ] នៅមន្ទីរឃុំឃាំង ស២១[24]

[22] សម្រាប់ទិដ្ឋភាពទូទៅច្បាស់លាស់នៃបរិបទប្រវត្តិសាស្រ្តចំពោះអ.វ.ត.ក សូមមើលៈ អង្គការឃ្លាំមើលនិទណ្ឌភាព ការរំឭកវិញ្ញាណក្ខន្ធដែលពាក់ព័ន្ធដំណើរការស្វែងរកយុត្តិធម៌អន្តរកាលនៅប្រទេសកម្ពុជាៈ ការរុករក នៅឆ្នាំ២០១៥។ មាននៅៈ http://www.impunitywatch.org/docs/CambodiaCountryExploration.pdf (ចូលទៅកាន់ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៥)។
[23] បទប្បញ្ញត្តិទាក់ទងនឹងច្បាប់តុលាការ និងព្រហ្មទណ្ឌ និងនីតិវិធីជាធរមាននៅកម្ពុជាអំឡុងពេលសម័យអន្តរកាល ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ អនុម័តនៅពេលអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា(UNTAC) ។
[24] អតីតវិទ្យាល័យ មន្ទីរឃុំឃាំងល្បីឈ្មោះខាងអាក្រក់ ស-២១ (ស-២១) ត្រូវបានប្រើប្រាស់ដោយរបបខ្មែរក្រហមទូទាំងការគ្រប់គ្រងរបស់ខ្លួន។ តាមអត្ថន័យដើមភាសាខ្មែរ ‘ទួលស្លែង’ មានន័យថា ‘ទួលនៃដើមឈើពុល’។ គេបានសន្និដ្ឋានថាប្រជាជនប្រហែល

ប៉ុន្តែមិនអាចឆ្លើយសំណួរណាដែលអាចប៉ះពាល់ដល់រដ្ឋាភិបាលទេ។[25] លើសពីនេះទៅទៀត ឧបសគ្គស្ថាប័នជាច្រើនដូចជាមន្ទិលសង្ស័យអំពីភាពដែលអាចអនុវត្តបាននៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ភាពមិនទាន់ស្គាល់ច្បាស់របស់ចៅក្រមកម្ពុជាជាមួយបទដ្ឋានច្បាប់អន្តរជាតិ និងគម្លាតក្នុងវិធាននីតិវិធី និងអង្គសេចក្តីដែលគ្រប់គ្រង អ.វ.ត.ក និងភាពប្រសព្វគ្នានៃយុត្តាធិការរបស់ខ្លួនជាមួយបញ្ហាប្រឈមនយោបាយ ផ្នែកច្បាប់ និងនីតិវិធីដើម្បីបង្កើតឧបសគ្គដែលពិបាកដោះស្រាយក្នុងការស្វែងរកយុត្តិធម៌ និងការផ្សះផ្សាកម្ពុជា។ ផ្នែកនីមួយៗនេះមានផលប៉ះពាល់ផ្ទាល់ដល់ជនរងគ្រោះនៃរបប និងការចូលរួមក្នុងការចូលរួមក្នុងនីតិវិធីតុលាការរបស់ពួកគេ។

២០.០០០នាក់បានស្លាប់នៅមន្ទីរឃុំឃាំងស-២១។ ទីតាំងនោះត្រូវបានរក្សាទុក ហើយមានឈ្មោះសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

25 ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង ០០១ និងសំណុំរឿង០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណី នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤)។

**៤- យុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា**

ជាទូទៅ ការពិនិត្យសង្កេតមូលដ្ឋានទស្សនទាននិងទស្សនវិជ្ជាដែលជាមូលដ្ឋានគាំទ្រតួនាទីរបស់យុត្តិធម៌អន្តរកាល នៅក្នុងករណីរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរមានសារសំខាន់ចំពោះការវិភាគស៊ីជម្រៅនៃការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក ហើយតួនាទីរបស់ខ្លួននៅក្នុងសង្គមក្រោយជម្លោះរបស់ប្រទេសកម្ពុជា។ សង្គមក្រោយជម្លោះតែងតែប្រឈមជាមួយសំណួរមូលដ្ឋាននូវ 'របៀបដោះស្រាយបន្ទុកដ៏ធ្ងន់នៅក្នុងអតីតកាលខ្មៅងងឹតរបស់ពួកគេ' (Weitekamp et al., ២០០៦: ២១៨) ហើយប្រភេទណាមួយនៃយុត្តិធម៌អន្តរកាលដែលពួកគេចង់បន្ត។ មានយន្តកាលយុត្តិធម៌អន្តរកាលខ្លះៗដែលកំពុងដំណើរការ គឺជាផ្នែកមួយដ៏សំខាន់នៃសង្គមក្រោយជម្លោះ សម្រាប់កិច្ចការកសាងសន្តិភាពប្រកបដោយនិរន្តរភាពដោយបង្កើនយុត្តិធម៌ និងធានាការផ្សះផ្សា (Kerr & Mobekk ២០០៧:២២៦)[26]។ យុត្តិធម៌អន្តរកាលគឺជាសញ្ញាណស្មុគស្មាញ ហើយទម្រង់និងខ្លឹមសាររបស់ខ្លួនពឹងផ្អែកយ៉ាងខ្លាំងទៅលើបរិបទសង្គមនៅក្នុងបញ្ហានេះ។ បើទោះជាមាន ជាទូទៅ ពួកយើងកំណត់លក្ខខណ្ឌ'យុត្តិធម៌អន្តរកាល'ជា៖

> សំណុំនៃវិធានតុលាការ និងមិនមែនតុលាការ អនុវត្តនៅក្នុងប្រទេសដែលធ្វើការដោះស្រាយអំពើហិង្សាកន្លងមក ដើម្បីកែតម្រូវប្រវត្តិនៃការរំលោភសិទ្ធិមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់។ វិធានការរួមមានការកាត់ទោសព្រហ្មទណ្ឌនិងគណៈកម្មការស្វែងរកការពិត កម្មវិធីសំណងជំងឺចិត្ត និងប្រភេទខុសៗគ្នានៃកំណែទម្រង់ស្ថាប័ន[27]។

នៅក្នុងការស្វែងរកយុត្តិធម៌អន្តរកាលនៅក្នុងប្រទេសកម្ពុជា ទាមទារគម្រោងច្បាស់លាស់ និងហ្មត់ចត់ ហើយនិងការវាយតម្លៃសមហេតុផលនូវអ្វីដែលអាចសម្រេចទៅបាន។ ទស្សទានជំនួយស្មារតីទំលំទូលាយនៃយុត្តិធម៌អន្តរកាលគ្របដណ្តប់លើទស្សនាទានខុសប្លែកពីគ្នា ដូចជាយុត្តិធម៌ក្នុងការដាក់ទោសនិងការស្តារឡើងវិញ ដែលជាញឹកញាប់ឆ្លុះបញ្ចាំងអំពីទស្សនទានរួមបញ្ចូលគ្នានៃគណនេយ្យភាព ការពិត សំណងជំងឺចិត្ត និងការផ្សះផ្សាដូចដែល Weitekamp និងអ្នកដទៃទៀតបានបង្ហាញ។ (Weitekamp et al. ២០០៦: ២១៨)។ នៅក្នុងការបំភ្លឺនេះ យន្តកាលយុត្តិធម៌អន្តរកាលសហសម័យបានផ្តោតយ៉ាងខ្លាំងទៅលើការសម្តែងតួរដោយជនរងគ្រោះ ដែលជាផ្នែកមួយនៃដំណើរការផ្តោតលើជនរងគ្រោះបន្ថែម។

ការផ្តោតយ៉ាងខ្លាំងនេះត្រូវបានសង្កេតមិនត្រឹមតែនៅក្នុងវិស័យអ្នកបង្កើតគោលនយោបាយ និងដំណើរការរបស់តុលាការតែប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងទស្សនៈទ្រឹស្តីស្មើភាពគ្នាផងដែរ។ ហេតុដូចនេះ តួនាទីបន្ថែមផ្តល់តាមរយៈសិទ្ធិនីតិវិធីនិងដំណោះស្រាយសំខាន់ៗជាច្រើនទៅកាន់ជនរងគ្រោះនៃរបបខ្មែរក្រហម បានក្លាយជាប្រធានបទនៃការជជែកពិភាក្សាយ៉ាងល្អិតល្អន់ក្នុងចំណោមអ្នកបង្កើតគោលនយោបាយ សិក្សាធិការ និងអ្នកជំនាញ។ ទោះបីជានៅមានភាពក្មេងខ្ចីការដាក់ពាក្យបណ្តឹងនៃដើមការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការកាត់ក្តីលើកទី១ និងលើកទី២ នៅ អ.វ.ត.ក បានផ្តល់ការយល់ដឹងដែលមានតម្លៃដល់សហគមន៍អន្តរជាតិ និងការយល់ពីភាពស្មុគស្មាញជុំវិញការចូលរួមរបស់ជនរងគ្រោះ

[26] R.Kerr & E. Mobekk (២០០៧) ទំព័រទី២

[27] អង្គការឃ្លាំងមើលនិទណ្ឌភាព លើកកម្ពស់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងការដោះស្រាយជាមួយយុត្តិធម៌អន្តរកាលនិងអតីតកាល គ្របខណ្ឌស្រាវជ្រាវដែលអាចប្រៀបធៀបបាន (ខែមីនា ឆ្នាំ២០១៤)។

ហើយជាពិសេសទៅទៀតគឺយល់ពីទស្សនរបស់ជនរងគ្រោះ និងឥរិយាបថចំពោះការចូលរួមសកម្មនៅអ.វ.ត.ក។

ជាពិសេស អ.វ.ត.កផ្ដល់ឱកាសតែមួយគត់ដល់ជនរងគ្រោះនៃរបបខ្មែរក្រហមក្នុងការចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណី នៅក្នុងនិតិវិធីច្បាប់ដែលជាវិធីក្នុងការបង្កើនសិទ្ធិរបស់ជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ។

## ៤.១-អ.វ.ត.ក ជាយន្តកាលយុត្តិធម៌អន្តរកាលមួយ

នៅក្នុងសង្គមក្រោយជម្លោះជាច្រើន ស្ថាបនិករបស់អ.វ.ត.ក'ត្រូវពិចារណាលើមតិជំទាស់ភាគច្រើន' (Ciorcari ២០០៨) ដែលលេចចេញឡើងនូវតុល្យភាពរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការកាត់ក្ដីត្រឹមត្រូវ និងសិទ្ធិនៃការបើកសវនាការយ៉ាងឆាប់រហ័ស និងសិទ្ធិរបស់ជនរងគ្រោះក្នុងការចូលរួម។

ដោយគិតពិចារណាដល់បរិបទសង្គម និងនយោបាយជុំវិញការជំនុំជម្រះក្ដី វាត្រូវបានចាត់ទុកជាការសំខាន់ដែល 'ជនជាតិកម្ពុជាឆ្លុះបញ្ចាំងពីដំណើរការដែលជាការចង់បានបំផុតរបស់ប្រជាជនកម្ពុជា ជាទូទៅ។'[28] គោលដៅដែលមានអន្តរទំនាក់ទំនងនៃគណនេយ្យភាពរបស់បុគ្គល និងការផ្សះផ្សាជាតិអាចដើរតួរជាសរសរស្ដម្ភ បន្ទាប់ពីយន្តការយុត្តិធម៌នេះបានប្រតិបត្តិ។ បន្ទាប់ពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងប្រទេសកម្ពុជា[29] តុលាការឧក្រិដ្ឋកម្មពិសេសដែលមានសមាសធាតុស្ថាយុត្តិធម៌ដ៏ខ្លាំងមួយ ដែលជាតំណាងនៅក្នុងស្ថាប័ននៃការចូលរួមពីដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបង្កើតឡើង។ កិច្ចខិតខំប្រឹងប្រែងនេះជាជំហានដំបូងដែលបានក្លាយជា អ.វ.ត.ក ជាចុងក្រោយ។ ៦ឆ្នាំនៃការចរចារយ៉ាងល្អិតល្អន់បានបង្កើតតុលាការឧក្រិដ្ឋកម្មកូនកាត់ដែលមិនធ្លាប់កើតមានពីមុននៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ដើម្បីយល់ពីលក្ខណពិសេសនៃតុលាការនេះ វាត្រូវបានគេមើលឃើញថាជាមូលដ្ឋាន 'តុល្យភាពប្រឆាំងរវាងរដ្ឋាភិបាលកម្ពុជាក្នុងការរក្សាភាពជាកម្មសិទ្ធិរបស់ខ្លួន(ឬការគ្រប់គ្រងដែលមានហេតុផល) ហើយអង្គការសហប្រជាជាតិ'មានការព្រួយបារម្ភក្នុងការធានាថាស្តង់ដាអន្តរជាតិនៃយុត្តិធម៌ត្រូវបានការពារ' (Rose ២០១២)។ ជាពិសេស ភាគីពាក់ព័ន្ធត្រូវចងចាំទាំងអស់គ្នាថាការងាររបស់អ.វ.ត.កអាចមានវិធានការប្រឆាំងនឹងស្តង់ដារនិងបទដ្ឋាននៃតុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានបង្កើតរួច។ នៅក្នុងបរិបទនេះ Jain មានទស្សនដូចខាងក្រោមៈ

> គ្រប់ទីកន្លែងនិងផ្នែកជាច្រើន វាហាក់បីដូចជាគ្មានការកំណត់នូវអ្វី[តុលាការព្រហ្មទណ្ឌអន្តរជាតិ] ដើម្បីរំពឹងក្នុងការសម្រេច – បន្ថែមពីលើគោលដៅទូទៅនៃតុលាការព្រហ្មទណ្ឌ តុលាការទាំងនេះត្រូវបានប្រគល់កិច្ចការក្នុងការសម្រេចបាននូវសន្តិភាព ប្រាប់ពីការពិតដែលមិនអាចជំទាស់បាន បង្កើតកំណត់ត្រាប្រវត្តិសាស្ត្រសម្រាប់សង្គមនិងអប់រំទៅកាន់ពិភពលោកដើម្បីប្រឆាំងអំពើហិង្សាដ៏ឃោឃៅ។ (Jain ២០០៩:២៨៩)។

[28] សូមមើល'របាយការណ៍នៃក្រុមអ្នកជំនាញសម្រាប់ការកសាងប្រទេសកម្ពុជាអនុលោមតាមសេចក្ដីសម្រេចរបស់មហាសន្និបាត ៥២/១៣៥' ឯកសារលេខ ស/១៩៩៩/២៣១ ១៦ ខែមីនា ឆ្នាំ១៩៩៩ ៣៣-៣៤ ដែលអាចរកបាននៅ http://cambodia.ohchr.org/WebDOCs/DocReports/4-Other-Reports/Other_CMB16031999E.pdf (ចូលទៅកាន់នៅថ្ងៃទី១៨ខែតុលាឆ្នាំ២០១៥)។

[29] សូមមើលកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដែលទាក់ទងនឹងការចោទប្រកាន់នៅក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជាដែលប្រព្រឹត្តឡើងក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ សេចក្ដីសម្រេចរបស់អង្គការសហប្រជាជាតិ ៥៧/២២៨នៃ១៨ ខែធ្នូ ឆ្នាំ២០០២។ អាចរកបាននៅ http://www.eccc.gov.kh/sites/default/files/legal-documents/Agreement_between_UN_and_RGC.pdf (ចូលទៅកាន់នៅថ្ងៃទី០៦ខែវិច្ឆិការឆ្នាំ២០១៥)

ក៏ប៉ុន្តែ រាល់គោលបំណងដែលបានរៀបរាប់ដូចខាងលើ គោលបំណងបន្ថែមរបស់ អ.វ.ត.ក គឺដើម្បីបំពេញតម្រូវការរបស់ជនរងគ្រោះនៃរបបខ្មែរក្រហម និងស្វែងរកយុត្តិធម៌ឱ្យពួកគេ។ អ.វ.ត.ក កើតចេញពីការចាប់ផ្តើមដែលតុលាការនេះជួបប្រទះដោយការចរចារក្នុងស្រុក និងអន្តរជាតិដែលមានការអូសបន្លាយ ខ្វះការគាំទ្រផ្នែកនយោបាយដែលអាចទុកចិត្តបាន មានការជិតដាមដោយការជ្រៀតចូលនយោបាយម្តងកាល ដែលត្រូវបានបន្ថែមមូលនិធិមិនគ្រប់គ្រាន់ និងមិនច្បាស់លាស់ និងខ្វះនូវគ្រឿងបរិក្ខារដើម្បីបើកដំណើរការតុលាការដែលមានលក្ខណៈស្មុគស្មាញ។ នៅក្នុងទិដ្ឋភាពទាំងអស់នេះ បេសកកម្មរបស់អ.វ.ត.ក មិនអាចធ្វើបានឡើយ។

## ៤.២- ការចូលរួមរបស់ជនរងគ្រោះនៅអ.វ.ត.កៈ កំហុសម៉ាស៊ីនវាយពុម្ពអក្សរដែលមានតម្លៃ ឬនវានុវត្តន៍របស់តុលាការ?

ទោះបីជាមានការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក ដែលមានលក្ខណៈពិសេស និងត្រូវបានប្រកាសជាលទ្ធផលសម្រេចមួយនៃលទ្ធផលសម្រេចផ្សេងទៀតរបស់តុលាការ របៀបនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដោះស្រាយ ដោយសារតែការចាប់ផ្តើមរបស់ខ្លួននៅតែរក្សាជំហររបស់ខ្លួនសម្រាប់តុលាការ និងភាគីពាក់ព័ន្ធទាំងអស់។ ជាការពិតណាស់ វាហាក់បីដូចជាការពង្រីកតួនាទីរបស់ជនរងគ្រោះនៅ អ.វ.ត.ក គឺជាលទ្ធផលផ្ទាល់របស់រចនាសម្ព័ន្ធកូនកាត់របស់ អ.វ.ត.ក **(Boyle** ២០៦:៣០៨)។ នៅក្នុងបរិបទនេះ អ.វ.ត.ក ហាក់បីដូចជាមិនបានរៀបចំសម្រាប់ការចូលរួមរបស់ជនរងគ្រោះក្នុងពេលចាប់ផ្តើម ហើយសំណួរនៃការពាក់ព័ន្ធរបស់ជនរងគ្រោះ’ គឺជាបញ្ហាចុងក្រោយដែលបានដោះស្រាយដោយតុលាការ (McGonigle Leyh ២០១១: ១៧៣)។ នៅពេលដាក់បញ្ចូលជនរងគ្រោះនៅក្នុងការជម្រះក្តីដែលត្រូវបានរកឃើញនៅក្នុងឯកសារយោងខ្លះនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់របស់អ.វ.ត.ក[30] វិសាលភាព និងរូបភាពនៃការចូលរួមមិនមានភាពច្បាស់លាស់ រហូតដល់អត្ថបទនៃវិន័យផ្ទៃក្នុងរបស់ អ.វ.ត.ក បានបង្កើតនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ (Bair ២០០៩: ៥០៦)។ ឯកសារយោងដែលពាក់ព័ន្ធតែមួយគត់ចំពោះទស្សនាទានរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចរកឃើញនៅក្នុងប្រការ ៣៦ នៃច្បាប់ អ.វ.ត.ក ដែលផ្តល់សិទ្ធិដល់ជនរងគ្រោះក្នុងការប្តឹងទាស់ទៅកាន់អង្គជំនុំជម្រះតុលាការកំពូល។ វាអាចជាការជជែកវែកញែកបានថាគ្មានពាក្យប្លែកនៅក្នុងអត្ថបទច្បាប់មូលដ្ឋាន។ នៅក្នុងន័យនេះ មន្ត្រីច្បាប់ជាន់ខ្ពស់មួយរូបនៅក្នុងអង្គជំនុំជម្រះបានពន្យល់ថា

> ខ្ញុំយល់ថាទិន្នន័យតែមួយគត់សម្រាប់ការដាក់ទម្រង់បែបបទនៃការចូលរួមរបស់ជនរងគ្រោះគឺជាការបកស្រាយនៃឃ្លាមួយនេះ។ វាហាក់បីដូចជាកំហុសរបស់ម៉ាស៊ីនបោះពុម្ព ដោយសារវាគ្មានឯកសារយោងសម្រាប់ជនរងគ្រោះនៅក្នុងក្របខណ្ឌច្បាប់នៃ អ.វ.ត.ក។ ហើយចម្លើយដែលទទួលបានពីមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺថាយើងមិនមានភាពច្បាស់លាស់នូវរបៀបធ្វើឱ្យវាមានប្រសិទ្ធិភាព ប៉ុន្តែប្រព័ន្ធមួយដែលយើងស្គាល់គឺប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី ហើយវាត្រូវបានបង្កើតឡើង។ ខ្ញុំសំដៅវាជាកំហុសរបស់ម៉ាស៊ីនបោះពុម្ពដ៏ធំមួយនៅក្នុងប្រវត្តិសាស្ត្រនៃតុលាការ។[31]

[30] កិច្ចព្រមព្រៀងនេះសំដៅទៅលើការទទួលខុសត្រូវរបស់អ.វ.ត.កដើម្បីផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សីនៅក្នុងប្រការ២៣។ ច្បាប់របស់អ.វ.ត.កគឺដូចគ្នាទៅនឹងប្រការ៣៣និងបង្កើតនីតិវិធីដោយសហព្រះរាជអាជ្ញាជាសួរសំណួរទៅកាន់ជនរងគ្រោះបាន(ប្រការ២៣) ហើយជនរងគ្រោះអាចប្តឹងទាស់នូវសាលក្រមដែលមិនពេញចិត្តនៅកម្រិតសវនការ(ប្រការ៣៦)។ ទោះបីជាយ៉ាងណាក៏ដោយ នេះគឺជាវិន័យផ្ទៃក្នុងដែលផ្តល់ក្របខណ្ឌច្បាប់ពេញលេញនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងអ.វ.ត.ក

[31] កិច្ចសន្ទនាជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះតុលាការអ.វ.ត.ក សម្គាល់នៅលើសំណុំរឿងជាមួយអ្នកនិពន្ធ។

សម្រង់សម្តីនេះបង្ហាញនូវរឿងជាច្រើន។ តុលាការនេះបានបកស្រាយបទប្បញ្ញត្តិស្រពិចស្រពិលនៅក្នុងច្បាប់មូលដ្ឋាននៅក្នុងវិធីបញ្ចូលការចូលរួមរបស់ជនរងគ្រោះ។ ច្បាប់នេះគឺផ្អែកលើប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណីដែលយើងស្គាល់ជាទូទៅនៅក្នុងប្រទេសបារាំង និងនៅក្នុងដែនសមត្ថកិច្ចដែលប្រព័ន្ធច្បាប់បានមកពីប្រទេសបារាំង(ដូចជាប្រទេសកម្ពុជា)។ នៅក្នុងប្រទេសបារាំង ជនរងគ្រោះមានឱកាសចូលរួមទាមទារសំណងរដ្ឋប្បវេណីចំពោះការកាត់ទោសព្រហ្មទណ្ឌ ឬក្នុងការបង្កឱ្យមានដំណើរការព្រហ្មទណ្ឌ ហេតុដូចនេះ ឱ្យជនរងគ្រោះចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី (*partie civile*) នៅក្នុងសំណុំរឿងនេះ។ នៅក្នុងប្រព័ន្ធច្បាប់របស់ប្រទេសបារាំង ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិជាច្រើននៅមុនពេលសវនាការ ពេលជំនុំជម្រះក្តី និងដំណាក់កាលប្តឹងឧទ្ធរណ៍ (Bacik et al ១៩៩៨: ៥៩)។ អ្វីដែលសំខាន់នោះ សិទ្ធិក្នុងការចូលរួមនៃដើមបណ្តឹងរដ្ឋប្បវេណីជាទូទៅមានក្នុងករណីដែលពួកគេទាក់ទងនឹងការទាមទារសំណងជំងឺចិត្តរបស់ជនរងគ្រោះពីជនជាប់ចោទ (Doak ២០០៥: ៣១១ Van Dijk et al ១៩៨៦)។

នៅក្នុងបរិបទនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងប្រទេសកម្ពុជា វាមានសារៈសំខាន់ក្នុងការទទួលស្គាល់តួនាទីរបស់ក្រុមតស៊ូមតិរបស់ជនរងគ្រោះ និងអង្គការសិទ្ធិមនុស្សនៅក្នុងការបង្កើនតួនាទីរបស់ជនរងគ្រោះនៅអ.វ.ត.ក។ ដោយសារតែមានការបញ្ចុះបញ្ចូលច្រើនដោយអង្គការដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM)[32] សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍនៅកម្ពុជា (ADHOC)[33] ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP)[34] និងផ្សេងទៀត ការចូលរួមរបស់ជនរងគ្រោះបានចាប់ផ្តើមក្លាយជាលក្ខណៈពិសេសរបស់តុលាការនិងឃើញមាននូវវត្តមានយ៉ាងច្រើននៅក្នុងឯកសារគ្រប់គ្រងរបស់តុលាការដែលបានកែតម្រូវ (Bair ២០០៩: ៥១៩ McGonigle Leyh ២០១១:១៧២)។

ខណៈពេលដែលសារៈសំខាន់នៃការចូលរួមរបស់ជនរងគ្រោះ និងភាពចំកណ្តាលចំពោះយុត្តិធម៌អន្តរកាលត្រូវបានទទួលស្គាល់និងប្រកាសដោយអ្នកតស៊ូមតិសិទ្ធិមនុស្សនិងអ្នកបង្កើតគោលនយោបាយ ហេតុដូចនេះហើយ ការទទួលស្គាល់បែបនោះទទួលបានការចាប់អារម្មណ៍ច្រើននៅពេលមានការទទួលស្គាល់ដោយចៅក្រមផ្ទាល់។ ដូចចៅក្រម Cartwright បានគូសបញ្ជាក់ថា៖

> មេធាវី ឬចៅក្រមនឹងប្រាប់អ្នកថាពាក្យពេចន៍ម៉ឺងម៉ាត់នៃដីការចោទប្រកាន់ដែលចោទប្រកាន់ជនជាប់ចោទនូវឧក្រិដ្ឋកម្មធ្ងន់ធ្ងរនឹងមានប្រសិទ្ធិភាពនៅពេលជនរងគ្រោះនិយាយនៅក្នុងតុលាការ ... អ្វីដែលសំខាន់សម្រាប់ខ្ញុំ ចម្លើយសាក្សីរបស់ជនរងគ្រោះផ្តល់នូវអារម្មណ៍រស់រវើកទៅកាន់ប្រវត្តិសាស្ត្រនៃរបបនេះ និងហាក់បីដូចជាធ្វើឱ្យយើងត្រឡប់ទៅកាន់ប្រទេសកម្ពុជាក្នុងទសវត្សន៍ឆ្នាំ ១៩៧០ ដែលស្ថិតនៅក្រោមការដឹកនាំរបស់ប៉ុលពត[35]។

ទោះបីជាយ៉ាងណាក៏ដោយ ការទទួលស្គាល់ផ្នែកយុត្តិធម៌នេះ មិនមែនត្រឹមតែជាលក្ខណនិមិត្តរូបនោះទេ។ តួនាទីសំខាន់ដែលអាចដើរតួដោយជនរងគ្រោះនៅក្នុងវិសាលភាពរបស់តុលាការព្រហ្មទណ្ឌដែលត្រូវបានធ្វើឡើងនៅ អ.វ.ត.ក ត្រូវបានអនុវត្តដោយសហមេធាវីឈានមុខអន្តរជាតិ

---

[32] សូមមើល៖ http://www.dccam.org/ (ចូលនៅថ្ងៃទី១២ខែវិច្ឆិការឆ្នាំ២០១៥)។
[33] សូមមើល៖ http://www.adhoc-cambodia.org/ (ចូលនៅថ្ងៃទី១២ខែវិច្ឆិការឆ្នាំ២០១៥)។
[34] សូមមើល៖ http://www.cdpcambodia.org/content.php?id=46 (ចូលនៅថ្ងៃទី១៤ ខែវិច្ឆិការឆ្នាំ២០១៥)។
[35] Dame Silvia Cartwright (ចៅក្រមអង្គជំនុំជម្រះដំបូងនៅអ.វ.ត.ក) សវនការព្រហ្មទណ្ឌអន្តរជាតិ។ គោរពតាមពាក្យសន្យា? មេរៀនរបស់ Hawke ប្រចាំឆ្នាំ២០១១ Adelaide នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១១។ មាននៅ៖ http://w3.unisa.edu.au/hawkecentre/ahl/2011AHL_Cartwright.pdf (ចូលទៅកាន់នៅថ្ងៃទី១២ ខែវិច្ឆិការ ឆ្នាំ២០១៥)។

ដែលជាអ្នកតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០១៖
‘នៅក្នុងរបៀបចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានលើកយកទិដ្ឋភាពរបស់មនុស្សទៅក្នុងការជំនុំជម្រះក្តី។’[36]
ទិដ្ឋភាពនេះសាកសមជាមួយវោហានៃការគស្ញមតិសិទ្ធិរបស់ជនរងគ្រោះដែលចាត់ទុកការចូលរួមរបស់ជនរងគ្រោះនៅអ.វ.ត.កជាវេទិការសម្រាប់ជនរងគ្រោះនិងជាការបញ្ចេញនូវមនុស្សជាតិដោយផ្តល់សំលេងដល់ជនរងគ្រោះដើម្បីបញ្ជាក់ពីភាពឈឺចាប់និងការរងគ្រោះ។ (Elander ២០១៣: ៩៥-១១៥)។

ទោះបីជាយ៉ាងណាក៏ដោយ គំរូរបស់អ.វ.ត.កបានបង្ហាញថា ទោះបីជាការព្យាករណ៍ទុកមុនដូចជាការអភិវឌ្ឍនៅក្នុងការវាយតម្លៃសំណួរនូវតម្រូវការនៅក្នុងយុត្តិធម៌អន្តរកាលឱ្យបានហ្មត់ចត់មិនថាការចូលរួមរបស់ជនរងគ្រោះនៅលើតួនាទីដែលមានស្រាប់នៃ ‘ជនរងគ្រោះជាសាក្សី’ ដែលតែងតែជាអត្ថប្រយោជន៍ល្អបំផុតរបស់ជនរងគ្រោះ ឬយុត្តិធម៌។ ការវិភាគស៊ីជម្រៅបន្ថែមបង្ហាញពីការ
សន្មត់ជាក់លាក់អំពីតួនាទី និងប្រសិទ្ធិភាពនៃការចូលរួមរបស់ជនរងគ្រោះ ដែលត្រូវបានលាក់បាំងនៅក្នុងទស្សនៈសេរីនៅក្នុងការចូលរួមរបស់ជនរងគ្រោះ។
យើងត្រូវស៊ើបអង្កេតបន្ថែមនូវរបៀបចូលរួមរបស់ជនរងគ្រោះដែលត្រូវបានអនុវត្ត។

ដើម្បីឱ្យកាន់តែច្បាស់ជាងនេះទៅទៀតនោះ
ការពិភាក្សាដែលបានធ្វើឡើងដោយអ្នកនិពន្ធដែលមានអ្នកជំនាញ
និងមន្ត្រីអនុវត្តច្បាប់នៅអ.វ.ត.កបានបង្ហាញពីទិដ្ឋភាពសង្ស័យស្តីពីការចូលរួមរបស់ជនរងគ្រោះ
និងបង្ហាញពីការបំភ្លឺភាពស្មុគស្មាញ និងការអនុវត្តកម្មវិធីនៃយន្តកាលច្បាប់នេះ។ ដូចមន្ត្រីច្បាប់ជាន់ខ្ពស់ម្នាក់បានពន្យល់ថា៖

> ខ្ញុំតែងតែមានការងឿនឆ្ងល់នៅពេល [ការចូលរួមរបស់ជនរងគ្រោះ] ត្រូវបានរៀបរាប់ជានវានុវត្តន៍និងសំខាន់ៗ។ ចំពោះខ្ញុំ វាគឺជាប្រព័ន្ធប្រតិកិរិយាអភិរក្សបំផុត ។ វាគ្មានគំនិតច្នៃប្រឌិតក្នុងការកំណត់វានោះឡើយ។ ជាក់ស្តែង វាជាការរួមបញ្ចូលដើមបណ្តឹងរដ្ឋវប្បវេណីដោ
> យមិនរើសមុខដូចដែលវាកើតឡើងនៅប្រទេសបារាំងនៅក្នុងបរិយាកាសនេះ។[37]

តាមការស្រាវជ្រាវបានបញ្ជាក់ថានេះមិនមែនជាគំនិតខុសពីគេនោះទេ។
គំនិតស្រដៀងគ្នាត្រូវបានចែករំលែកដោយសមាជិកសហព្រះរាជអាជ្ញា មេធាវីការពារក្តីក៏ដូចជាអ្នកផ្សេងទៀតដែលមានកម្មវត្ថុនៃបណ្តឹងនៅក្នុងដំណើរការ។ ឧទាហរណ៍ អយ្យការជាន់ខ្ពស់បានគូសបញ្ជាក់ថា៖

> តុលាការនេះមិនទាន់ធ្វើបានល្អនៅក្នុងការបង្កើតនិងគ្រប់គ្រងតាមការរំពឹងទុករបស់ជនរងគ្រោះនៅឡើយទេ។
> ពួកគេអនុវត្តគំរូនៃការចូលរួមពេញលេញនេះជាភាគីនៅក្នុងកិច្ចដំណើរការ
> ចេញក្រៅនិងផ្សព្វផ្សាយទៅកាន់ពិភពលោកដែលនេះជាប្រព័ន្ធខុសគ្នា និងរាប់បញ្ចូលដោយគ្មានការគិតប្រុងប្រយ័ត្នចំពោះការអនុវត្តដែលប្រព័ន្ធនេះអាចមានសម្រាប់តុលាការនិងជនរងគ្រោះ។[38]

ប្រធានបទសំខាន់ដែលសង្កត់លើសម្រង់ពាក្យទាំងនេះគឺថាការចូលរួមរបស់ជនរងគ្រោះជាប្រតិកិរិយាចៀសជាងយន្តការច្បាប់បដិវត្តន៍ពិតប្រាកដ
ហើយជនឆបោកនិងអ.វ.ត.កគឺមិនបានរៀបចំបានល្អដើម្បីសហការការចូលរួមរបស់ជនរងគ្រោះទៅក្នុងនីតិវិធី។ តាមសេចក្តីសន្និដ្ឋាន ការខ្វះខាតការចាប់ផ្តើមនៃការរៀបចំ

[36] កិច្ចសន្ទនាជាមួយ Elisabeth Simonneau-Fort សហមេធាវីដឹកនាំដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០១ សម្គាល់នៅលើសំណុំរឿងជាមួយអ្នកនិពន្ធ។
[37] កិច្ចសន្ទនាជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះតុលាការនៃអ.វ.ត.កសម្គាល់លើឯកសារជាមួយអ្នកនិពន្ធ។
[38] កិច្ចសន្ទនាជាមួយជំនួយការព្រះរាជអាជ្ញាជាន់ខ្ពស់ ការិយាល័យអ.វ.ត.កនៃសហព្រះរាជអាជ្ញារ សម្គាល់លើសំណុំរឿងរបស់អ្នកនិពន្ធ។

ការបង្កើតឡើងដោយកិច្ចការគួរឱ្យខ្លាច និងភាពស្មុគស្មាញនៃការរៀបចំយន្តកាលត្រឹមត្រូវនិងសំខាន់សម្រាប់ការចូលរួមរបស់ជនរងគ្រោះគឺកាន់តែធ្ងន់ធ្ងរដោយការស្ទាក់ស្ទើររបស់មន្ត្រីរដ្ឋាភិបាល’ក្នុងការសហការពេញលេញ ដូចដែលពន្យល់លម្អិតនៅខាងលើ។

### ៤.៣- សិទ្ធិចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

វិធានផ្ទៃក្នុងរបស់អ.វ.ត.កឱ្យនិយមន័យ‘ជនរងគ្រោះ’ជាបុគ្គលសាមញ្ញ ឬនីតិបុគ្គលដែលរងគ្រោះដោយសារតែបទល្មើសណាមួយដែលប្រព្រឹត្តនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក។[39]
វិធានផ្ទៃក្នុងរបស់អ.វ.ត.កអនុញ្ញាតឱ្យជនរងគ្រោះចូលរួមតាមបីរបៀប៖ ជាដើមបណ្តឹងជនរងគ្រោះ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងន័យនេះ វាត្រូវបានកត់សម្គាល់ថាដោយសារខ្វះចន្លោះនៅក្នុងនីតិវិធីនៅក្នុងច្បាប់គ្រប់គ្រងនីតិវិធីរបស់អ.វ.ត.ក ជនរងគ្រោះត្រូវបានតម្រូវឱ្យជ្រើសរើសមុននៅក្នុងនីតិវិធីមិនថាគាត់ចង់ចូលរួមជាសាក្សី ជាដើមបណ្តឹងជនរងគ្រោះ ឬជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ជនរងគ្រោះដែលបានចូលរួមអាចធ្វើការបដិសេធនូវឱកាសជាសក្ខីកម្មដែលត្រូវស្បថស្បែរ ដែលអាចប៉ះពាល់ដល់ឱកាសរបស់អយ្យការ ក្នុងការបង្ហាញព័ត៌មានដែលអាចដាក់បន្ទុកលើដល់ចុងចោទ។ បញ្ហានេះជាក់ស្តែងឃើញនៅក្នុងសំណុំរឿង០០១ដែលជនរងគ្រោះផ្ទាល់ជាច្រើន ‘ដែលផ្តល់សក្ខីកម្មក្នុងការស្បថស្បែរទៅលើទោសរបស់ចុងចោទដោយជំនួសមកវិញជាការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី’ (McGonigle Leyh ២០០៩: ២១២)។ ជាលទ្ធផលនៃការមិនផ្តល់សក្ខីកម្មក្នុងការស្បថស្បែរ សក្ខីភាពរបស់ពួកគេមានទម្ងន់តិចជាងទម្ងន់នៃសាក្សី។

ទោះបីជាយ៉ាងណាក៏ដោយ វាជាករណីដែលដើមបណ្តឹងរដ្ឋប្បវេណីអនុវត្តសិទ្ធិសំខាន់ៗនៅក្រោមវិធានផ្ទៃក្នុងនៅក្នុងអង្គភាពរបស់អ.វ.ត.កនៃច្បាប់នីតិវិធី។ ពួកគេមានសិទ្ធិពេញលេញក្នុងការមើលសំណុំរឿង ក្នុងការកំណត់ការបើកអង្គជំនុំជម្រះមុនពេល និងបណ្តឹងឧទ្ធរណ៍ ដើម្បីបង្កើតសំអាងជាក់ស្តែងនិងស្របច្បាប់ ដើម្បីចូលរួមក្នុងសវនាការ ដើម្បីស្នើសុំសាក្សី ដើម្បីសួរសាក្សី ដើម្បីធ្វើការសាកសួរជនជាប់ចោទ ដើម្បីលើកសេចក្តីសន្និដ្ឋានការពារ ដើម្បីបដិសេធសេចក្តីសន្និដ្ឋានការពារនៃការចោទប្រកាន់ និងអ្វីដែលសំខាន់បំផុតគឺដើម្បីស្នើសុំទាមទារសំណងជំងឺចិត្ត។ តួនាទីរបស់មេធាវីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីគឺការអនុវត្តសិទ្ធិទាំងនេះ។ ក្នុងអំឡុងពេលសំណុំរឿង០០២ តួនាទីរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានកើនឡើងតាមរយៈការបញ្ច្រាបចូលនៃនីតិវិធី។ មានតែសហមេធាវីនាំមុខតែពីររូបប៉ុណ្ណោះត្រូវបានអនុញ្ញាតក្នុងការបញ្ចេញកង្វល់របស់ជនរងគ្រោះនៅក្នុងការជំនុំជម្រះក្តី។ តើលទ្ធផលនៅក្នុងតួនាទីមិនសូវសំខាន់របស់ដើមបណ្តឹងរដ្ឋប្បវេណីគួរឬមិនគួរជាចំណុចពិភាក្សាមួយ។ទោះបីជាយ៉ាងណាក៏ដោយ អ្វីដែលកើតឡើងចេញពីការស្រាវជ្រាវនេះគឺមុខងាររបស់ដើមបណ្តឹងរដ្ឋប្បវេណីពិតជាត្រូវបានធ្វើឱ្យប្រសើរឡើងដោយមានការបញ្ជូនសំលេងច្រើនតាមរយៈការតស៊ូមតិពីរនៅក្នុងតុលាការ ដែលធ្វើឱ្យកើនឡើងនូវការទទួលបាននូវសង្គតិភាពនិងប្រសិទ្ធភាពគួរឱ្យកត់សម្គាល់។ ការចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹង ឬសាក្សីនៅក្នុងនីតិវិធីមានផលប៉ះពាល់ខុសគ្នា។ ជាធម្មតា វិសាលភាពនៃផលប៉ះពាល់នេះពឹងផ្អែកលើទស្សនៈនិងគោលបំណងរបស់អ្នកចូលរួមនិងភាគីពាក់ព័ន្ធ។ ដូច្នេះ សំណួរពាក់ព័ន្ធនឹងផលប៉ះពាល់មិនអាចឆ្លើយបាននៅលើមូលដ្ឋានទូទៅមួយឡើយ។ នេះគឺជាស្ថានភាពលំបាកនៅក្នុងការជ្រើសរើសរវាងលទ្ធភាពក្នុងការធ្វើសក្ខីកម្មដែលត្រូវស្បថស្បែរ

[39] វិធានផ្ទៃក្នុង (Rev. ៩) ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ សន្ទនុក្រម។

និងលទ្ធភាពក្នុងការទាមទារសំណង និងបន្តប្តឹងឧទ្ធរណ៍។

ដូចនេះ ការចូលរួមរបស់ជនរងគ្រោះមានភាពខុសគ្នានៅក្នុងវិសាលភាព និងទម្រង់បែបបទ និងផ្តល់វិមាត្រថ្មីចំពោះយន្តការគណនេយ្យភាពដែលត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយអំពើឃោរឃៅដែលប្រព្រឹត្តដោយខ្មែរក្រហម។ លទ្ធផលនេះបានភាពកាន់តែប្រសើ តាមរយៈកាត់ចាត់ទុកជនរងគ្រោះ( ដែលមិនធ្លាប់មានពីមុនមកទេ) ថាជា "ដើមបណ្តឹង" ពេញលេញក្នុងការជំនុំជម្រះ ជាជាងគ្រាន់តែជា 'អ្នកចូលរួម'។ ជំហរនេះមានភាពផ្ទុយស្រឡះពីស្ថានភាពដែលបានផ្តល់ទៅឱ្យជនរងគ្រោះចំពោះមុខតុលាការ ICC។[40]

ចំណុចនេះមិនគួរលើកឡើងឆ្ងាយឡើយ ក្នុងនាមជាតួនាទីនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការការកាត់ទោសមានកម្រិតខុសគ្នា និងនៅក្នុងប្រភេទពីការចូលរួមដោយភាគីពេញលេញធម្មតា ដែលត្រូវបានឱ្យឈ្មោះថាអយ្យការ និងមេធាវីការពារក្តី។ យល់ដឹងពីតួនាទីពិតប្រាកដរបស់ជនរងគ្រោះនៅក្នុងដំណើរការដែលទាមទារការទទួលស្គាល់ការពិត ដែលថាយន្តកាលនេះត្រូវបានប្រើប្រាស់ក្នុងការផ្តល់សំលេងដល់អ្នកទាំងអស់នោះ ដែលរងគ្រោះពីផលប៉ះពាល់ដោយគ្មានលទ្ធភាពក្នុងការការស្វែងរកដំណើរការតុលាការប្រឆាំងអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ឬគោលបំណងដ៏សំខាន់នៃយុត្តិធម៌ និងប្រសិទ្ធភាព។

នេះគឺជាឧទាហរណ៍ដ៏ល្អបំផុតដោយយោងទៅតាមវិធានផ្ទៃក្នុង។ ច្បាប់២៣ (១) បានបង្ហាញថាគោលបំណងនៃសកម្មភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី អនុញ្ញាតឱ្យជនរងគ្រោះចូលរួមក្នុងនីតិវិធីប្រឆាំងការទទួលខុសត្រូវដោយគាំទ្រការកាត់ក្តី' និងអនុញ្ញាតឱ្យពួកគាត់ 'ស្វែងរកសំណងផ្លូវចិត្តនិងសំណងសមូហភាព។' ពាក្យពេចន៍នៅក្នុងបទប្បញ្ញត្តិនេះគឺមានការកត់សម្គាល់លើផ្នែកជាច្រើន។ ជាពិសេស ការបញ្ជាក់ 'ដោយការគាំទ្រការកាត់ទោស' ទុកកន្លែងសម្រាប់បកស្រាយនិងអាចនាំឱ្យមានលទ្ធផលមិនល្អ។ ដូចដែល McGonigle Leyh បានលើកឡើងថា 'ពាក្យនេះបានបង្ហាញថាលទ្ធភាពដែលដើមបណ្តឹងរដ្ឋប្បវេណីអាចគាំទ្រអយ្យការដែលមានភាពស្រដៀងគ្នានឹងរបៀបជំនួយការរបស់សហព្រះរាជអាជ្ញាគាំទ្រអយ្យការជាសារធារណៈនៅក្នុងប្រព័ន្ធជាតិជាច្រើន ដូចជាតាមរយៈការបញ្ជូនភ័ស្តុតាងនៅលើទោសនៃការចោទប្រកាន់ ហើយការចូលរួមនោះគឺមិនមានការកំណត់ចំពោះផលប្រយោជន៍របស់គេទាក់ទងនឹងសំណងឡើយ' (២០១២: ៣៨៨)។ នៅផ្នែកផ្សេងទៀត ពាក្យនេះអាចលេចឡើងផងដែរនូវការបង្ហាញថាជនរងគ្រោះចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីដែលស្វែងរកការផ្តន្ទាទោសនៃចុងចោទ។ ជនរងគ្រោះបានអំពាវនាវឱ្យមានការលើកបណ្តឹងចោលនៃការចោទប្រកាន់ ឧទាហរណ៍ក្នុងការរង្វះផ្សាជាតិ វាហាក់បីដូចជាមិនទំនងដើម្បីឱ្យសមស្របទៅនឹងលក្ខណវិនិច្ឆ័យដែលមានចែងនៅក្នុងច្បាប់។ ជាចុងក្រោយ ពាក្យដែលទាក់ទងទៅនឹងសំណងមានសារៈសំខាន់ដោយសារតែវាទទួលស្គាល់ថាជនរងគ្រោះទទួលសិទ្ធិក្នុងការឧបាស្រ័យហើយមានការគាំទ្រការកាត់ក្តីជាមួយគ្នា នេះគឺជាហេតុផលសំខាន់សម្រាប់ការចូលរួមរបស់ពួកគេនៅក្នុងនីតិវិធី (McGonigle Leyh ២០១២; ២៨៨)។ ទោះបីជាយ៉ាងណាក៏ដោយ វាត្រូវបានគេកត់សម្គាល់ថាគ្មានមូលនិធិពិសេសណាមួយធ្លាប់មានការបង្កើតនៅអ.វ.ត.ក មានន័យថាការទាមទារសំណងជំងឺចិត្តរបស់ជនរងគ្រោះត្រូវភ្ជាប់ជាមួយការទាមទារនៅក្នុងនីតិវិធីព្រហ្មទណ្ឌនិងមិនអាចឧបាស្រ័យអ្នកផ្សេងទៀតជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ជាលទ្ធផលក្នុងខណៈពេលដែលវាមិនមែនជាករណីដែលដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ស្វែងរកសំណងជំងឺចិត្ត

[40] នៅក្នុងពាក្យបច្ចេកទេសនៃលក្ខន្តិកៈនិងច្បាប់នៃនីតិវិធីនិងភស្តុតាង ព្រះរាជអាជ្ញានិងមេធាវីការពារក្តីសំដៅទៅលើ 'ភាគី'និងជនរងគ្រោះដែលបានចូលរួមជា'អ្នកចូលរួម'។ សូមមើល http://www.icc-cpi.int/nr/rdonlyres/ea9aeff7-5752-4f84-be94-0a655eb30e16/0/rome_statute_english.pdf?wptouch_preview_theme=enabled (ចូលទៅកាន់ថ្ងៃទី៨ ខែវិច្ឆិការ ឆ្នាំ២០១៥)។

យ៉ាងណាក៏ដោយវាគឺជាការចាំបាច់សម្រាប់ជនរងគ្រោះដែលមានបំណងក្នុងការស្វែងរកសំណងជំងឺចិត្តក្នុងការចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណី។

របបដែលបានរៀបរាប់នេះបានក្លាយជាប្រធានបទទាំងការសរសើរនិងការរិះគន់។ វាត្រូវបានសរសើរដោយសារនេះជាលើកដំបូងដែលជនរងគ្រោះដោយសារអំពើឃោឃៅជាច្រើនអាចចូលរួមយ៉ាងសកម្មជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនការព្រហ្មទណ្ឌអន្តរជាតិ។ កិច្ចសម្ភាសន៍មួយក្នុងចំណោមដើមបណ្ដឹងរដ្ឋប្បវេណីបានគូសបញ្ជាក់ពីគុណធម៌នៃផលប្រយោជន៍បុគ្គលដែលបានមកពីការចូលរួមមានដូចជា៖

> សម្រាប់អ្នកទាំងនោះដែលចំណាយពេលវេលានិងការចូលរួមរបស់ពួកគេនៅក្នុងតុលាការ ហើយការចូលរួមដែលមានគុណតម្លៃដ៏ខ្ពស់...សម្រាប់ខ្ញុំ អ្វីដែលសំខាន់បំផុតគឺអាចចូលរួមក្នុងនីតិវិធីដើម្បីស្វែងរកការទទួលខុសត្រូវរបស់ឧក្រិដ្ឋជន សិក្សាបន្ថែមអំពីរបបខ្មែរក្រហម ប្រឈមមុខនឹងការចោទប្រកាន់ និងជាចុងក្រោយ រៀបរាប់អំពីការឈឺចាប់របស់ខ្ញុំ។[41]

ទោះបីជាយ៉ាងណាក៏ដោយ ការចូលរួមរបស់ជនរងគ្រោះមុនពេលអ.វ.ត.កត្រូវបានរិះគន់តាមរបៀបជាច្រើន។ តាមទស្សនៈរបស់ជនរងគ្រោះ ដំណោះស្រាយឆ្លើយតបដែលមានទៅកាន់តុលាការគឺមានការរឹតបន្តឹងខ្លាំង សំណងជំងឺចិត្តត្រូវបានកំណត់សំណងផ្លូវចិត្តជាសមូហភាព។ ការមិនពេញចិត្តទៅលើផ្នែកណាមួយនៃជនរងគ្រោះ ត្រូវបានសង្កេតមើលតាមរយៈកិច្ចសម្ភាសន៍គឺជាឧទាហរណ៍មួយនៅក្នុងចំណោមសម្រង់ពាក្យដូចខាងក្រោម៖

> នៅក្នុងលក្ខខណ្ឌនៃសំណងជំងឺចិត្ត តុលាការផ្ដល់សំណងជំងឺចិត្តជាសមូហភាពដូចជាការកសាងស្តូបរំលឹកវិញ្ញាណក្ខន្ធ។ខ្ញុំការពេញចិត្តនឹងគំនិតនេះ ប៉ុន្តែខ្ញុំចង់ឱ្យតុលាការព្យាយាមយល់ពីអារម្មណ៍ដែលចែករំលែកដោយដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់។ រាល់ដើមបណ្ដឹងទាំងអស់នៅក្នុងសំណុំរឿង០០១ និង០០២ចង់បានសំណងជំងឺចិត្តបុគ្គល។ យើងដឹងថាសំណងជំងឺចិត្តគឺមិនបានផ្ដល់សម្រាប់វិន័យផ្ទៃក្នុងនោះទេ ប៉ុន្តែសំណងជំងឺចិត្តបែបនោះត្រូវបានស្នើរសុំតាំងពីដំបូង។ ហើយឥលូវយើងមានអារម្មណ៍ថាអ្វីដែលនៅសេសសល់គឺមិនទាន់បានបំពេញ។[42]

ស្រដៀងគ្នានោះដែរ អ្នកផ្ដល់បទសម្ភាសន៍ផ្សេងទៀតបានលើកឡើងថា

> តុលាការផ្ដល់ស្តូបរំលឹកវិញ្ញាណក្ខន្ធនិងឯកសារដល់ជនរងគ្រោះតែប៉ុណ្ណោះ។ ដូច្នេះ ការចូលរួមគឺជាទម្រង់នៃយុត្តិធម៌ ប៉ុន្តែនៅក្នុងលក្ខខណ្ឌនៃសំណងជំងឺចិត្ត វាគឺមិនមានភាពយុត្តិធម៌ទេ ដូចវាមិនសាកសមនូវអ្វីដែលយើងបាត់បង់នៅក្នុងរបបខ្មែរក្រហម ដូចដែលយើងបាត់បង់ឪពុកម្ដាយនិងសាច់ញ្ញាតិ។ ដូចនេះ ខ្ញុំមិនសប្បាយចិត្តទេ។[43]

លើសពីនេះទៅទៀត នៅក្នុងការយល់ដឹងទូលំទូលាយ និងនៅក្នុងការមើលឃើញរបស់អ្នកជំនាញដែលធ្វើការនៅក្នុងតុលាការ ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានភ្ជាប់ជាមួយការពន្យាពេលដែលមិនចាំបាច់នៅក្នុងការកា

[41] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០២របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៨)។
[42] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ និង០០២ ភ្នំពេញ ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៨)។
[43] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨)។

ត់ក្តីក្នុងតុលាការក៏ដូចជាការយល់ឃើញថាសិទ្ធិរបស់ចុងចោទក្នុងការកាត់ក្តីត្រឹមត្រូវនិងបើកសវនការយ៉ាងឆាប់រហ័សអាចត្រូវបានរំលោភបំពាន។ ការចូលរួមរបស់ជនរងគ្រោះត្រូវបានកំណត់ជាលិខិតគតិយុត្តិដែលមានលក្ខណស្មុគស្មាញ។

## ៤.៣.១.ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការអនុវត្ត

នីតិវិធីនៅក្នុងសំណុំរឿង០០១ និង០០២មានឯកសារនៅក្នុងការកំណត់ទម្រង់និងវិសាលភាពនៃការចូលរួមរបស់ជនរងគ្រោះ។ និយមន័យនិងការកំណត់ប៉ារ៉ាម៉ែត្ររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ ត្រូវបានរៀបចំជាមូលដ្ឋានសម្រាប់សំណុំរឿង០០២។ វាមានលក្ខណៈស្មុគស្មាញច្រើនដោយសារតែមានការចោទប្រកាន់ខ្លាំង ស្ថានភាពជាក់ស្តែងមានលក្ខណៈស្មុគស្មាញ ហើយចំនួនជនរងគ្រោះមានច្រើន។ សំណុំរឿង០០២ត្រូវបានបំបែកជាការជំនុំជម្រះក្តីពីរ ការជំនុំជម្រះក្តីនីមួយៗដោះស្រាយផ្នែកខុសគ្នានៃដីកាចោទប្រកាន់។[44]មានបុគ្គលប្រហែលជាង៤០០០ នាក់បានដាក់ពាក្យក្នុងការចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ និងមានបុគ្គលចំនួន៣៨៦៦នាក់ត្រូវបានជ្រើសរើស ហើយថ្មីៗនេះបានដើរតួជាដើមបណ្តឹងរដ្ឋប្បវេណី។

ក្នុងអំឡុងពេលដំណាក់កាលមុនការកាត់ក្តី ដើមបណ្តឹងរដ្ឋប្បវេណីអនុវត្តសិទ្ធិចូលរួមសំខាន់ៗជាច្រើន។ ដូច្នេះ ការចាប់ផ្តើមនីតិវិធីមុនពេលកាត់ក្តីនៅក្នុងសំណុំរឿង០០១ត្រូវបានកំណត់ដោយយុទ្ធសាស្ត្រអំណោយផលដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។ ជនរងគ្រោះត្រូវបានផ្តល់សិទ្ធដើម្បីមើលសំណុំរឿងបញ្ជូនការចោទប្រកាន់សម្រាប់ការស៊ើបអង្កតជាក់លាក់ ប្រឈមមុននឹងការចោទប្រកាន់ដាក់ពាក្យបណ្តឹងជាលាយលក្ខ័អក្សរនិងអន្តរាគមន៍ដោយផ្ទាល់មាត់ ក៏ដូចជាការសម្រេចចិត្តក្នុងការដាក់បណ្តឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះ។ ការកាត់ក្តីនៅក្នុងសំណុំរឿង០០១របស់ឌុចត្រូវបានចាត់ទុកជាការជំនុំជម្រះក្តីអន្តរជាតិ[45]ដែលជនរងគ្រោះនៃអំពើឃោឃៅនេះបានចូលរួមយ៉ាងសកម្មជាដើមបណ្តឹងរដ្ឋប្បវេណី។ គិតជាចំនួនលេខ ជនរងគ្រោះផ្ទាល់និងមិនផ្ទាល់ចំនួន៩៣នាក់មានការឆ្លើយតបទៅការកោះហៅដើម្បីចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី។ ពួកគេត្រូវបានតំណាងដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី រាប់បញ្ចូលទាំងមេធាវីជាតិនិងអន្តរជាតិ។ ការសហការរវាងមេធាវីបង្ហាញភស្តុតាងពីបញ្ហាប្រឈមទោះបីជាចែករំលែកគោលដៅដូចគ្នា។ នេះដោយសារតែមានការខ្វែងយោបល់គ្នាជាច្រើននៅលើបញ្ហាច្បាប់និងនីតិវិធីក៏ដូចជាយុទ្ធសាស្ត្រតស៊ូមតិ។[46] ដូចនេះ វាជាការពិតដែលថាដើមបណ្តឹងរដ្ឋប្បវេណីអនុវត្តសិទ្ធិសំខាន់ៗក្នុងអំឡុងពេលដំណើរការនីតិវិធីជំនុំជម្រះ ការខ្វះការសហការមានន័យថាដើមបណ្តឹងរដ្ឋប្បវេណីមិនចាំបាច់និយាយចេញនូវសំលេងតែមួយនៅក្នុងបន្ទប់សវនាការនោះទេ។ ដូច្នេះ មានការស្រងាកចិត្តនិងខកចិត្តក្នុងចំណោមជនរងគ្រោះទាំងនោះដែលមានការធ្ងន់ធ្ងរបន្ថែមទៀតដោយការចេញសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងដែលឌុច ទណ្ឌិតបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនិងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងសឺណែវឆ្នាំ១៩៤៩ ត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារ៣៥ឆ្នាំ

[44] សូមមើល http://www.eccc.gov.kh/en/case/topic/2 (ចូលនៅថ្ងៃទី១៥ខែវិច្ឆិការឆ្នាំ២០១៥)។

[45] 'អន្តរជាតិ' គឺជាទស្សនាទានជំនួយស្មារតីដែលត្រូវបានប្រើប្រាស់ដើម្បីបង្ហាញលក្ខណពិសេសនៃតុលាការកូនកាត់ជាច្រើនដែលបានបង្កើតចៅក្រមជាតិនិងអន្តរជាតិ និងអនុវត្តច្បាប់អន្តរជាតិក៏ដូចជាច្បាប់ជាតិ។ ឧទាហរណ៍នៃតុលាការនោះមានដូចជាសង្គ្រាមKosovo និងតុលាការព្រហ្មទណ្ឌជនជាតិភាគតិចនៅទីម័រខាងកើត តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡាអូន និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សូមមើល Romano Nollkaemper និង Jann K. Kleffner (eds) (២០០៤)។

[46] ការខ្វែងយោបល់គ្នាដូចនេះចាប់ផ្តើមមិនថាជនរងគ្រោះអាចចូលរួមពាក់ព័ន្ធនឹងបញ្ហាកាត់ទោស មិនថាគាំទ្រអំណះអំណាននៃការចោទប្រកាន់សម្រាប់ការប្រើប្រាស់ក្រុមសហចារីជាមធ្យោបាយនៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងមិនថាខិតខំទាមទារសំណងជំងឺចិត្តជាទឹកប្រាក់។

និងចំនួនដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកាត់បន្ថយពី៩៣មក៦៤នាក់។[47] នេះដោយសារតែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចដោយមានប្រសិទ្ធិភាពថាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ហាញពី 'ការតភ្ជាប់ធម្មតាដោយផ្ទាល់ចំពោះការបង្ហាញការរងរបួសស្នាមដែលខ្លួនបានរង'។[48]

ចុងចោទនិងសហព្រះរាជអាជ្ញាប្តឹងជំទាស់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងទៅកាន់អង្គជំនុំជម្រះតុលាការកំពូល។ ជាសរុប ដើមបណ្តឹងរដ្ឋប្បវេណី៤១នាក់ រាប់បញ្ចូលអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធចំនួន២២នាក់ក៏បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការអាចទទួលយកបានរបស់ពួកគេ និង/ឬ ការទាមទារសំណងចិត្ត។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចូនការសម្រេចចិត្តរបស់ខ្លួននៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ ប្រានចោលការកាត់ទោស៣៥ឆ្នាំដែលបានប្រកាសដោយអង្គជំនុំជម្រះតុលាការដំបូងនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០ និងជំនួសមកវិញនូវការកាត់ទោសឌុចក្នុងការដាក់ពន្ធនាគារមួយជីវិតដែលជាការកាត់ទោសដ៏ធ្ងន់បំផុតតាមដែលតែអ.វ.ត.កអាចអនុវត្តបាន ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់បណ្តឹងឧទ្ធរណ៍ដល់អ្នកសុំដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលការដាក់ពាក្យនោះត្រូវបានបដិសេធនៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការដំបូង។ នៅក្នុងសាលាឧទ្ធរណ៍ អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញពាក្យស្នើសុំជាភស្តុតាងរបស់ពួកគេ និងត្រូវបានទទួលស្គាល់ជាលទ្ធផលថាជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១។[49]

ដោយគ្មានមន្ទិលសង្ស័យអ្វីទាំងអស់ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០១ត្រូវបានកំណត់តាំងពីពេលចាប់ផ្តើមដោយច្បាប់សំខាន់ៗ និងបញ្ហាប្រឈមនីតិវិធីដែលបណ្តាលមកពីការខ្វះខាតភាពច្បាស់លាស់ និងវិធានគ្រប់ជ្រុងជ្រោយ និងនីតិវិធី។

ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២/០១[50] តែងតែបង្កើតបញ្ហាក្នុងការគ្រប់គ្រងការកាត់ក្តីដែលបណ្តាលឱ្យមានដំណើរការដោយការធ្វើវិសោធនកម្មថេរ ការធ្វើវិសោធនកម្មឡើងវិញ និងការបកស្រាយឡើងវិញ។ ចៅក្រមរបស់អ.វ.ត.កកែសម្រួលបទបញ្ញត្តិនៃវិធានផ្ទៃក្នុងដែលគ្រប់គ្រងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងការប៉ុនប៉ងក្នុងការធានានូវយុត្តិធម៌និងប្រសិទ្ធភាពនៅក្នុងនីតិវិធីដែលជាការទទួលស្គាល់នូវសារៈសំខាន់នៃការចូលរួមរបស់ជនរងគ្រោះក៏ដូចជាបញ្ហាដែលបានគូសបញ្ជាក់នៅក្នុងសំណុំរឿង០០១។ ត្រឹមថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ វិធានផ្ទៃក្នុងត្រូវកែសម្រួលមិនតិចជាងប្រាំបួនដងនោះទេ។[51]

ការកែសម្រួលដ៏ខ្លាំងបំផុតពាក់ព័ន្ធនឹងនីតិវិធីកាត់ក្តីដែលមានប្រសិទ្ធភាពក្នុងខែកុម្ភៈឆ្នាំ២០១០ និងផ្តល់ផលប៉ះពាល់ដល់ការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២។ ការធ្វើវិសោធនកម្មមួយដ៏សំខាន់ពាក់ព័ន្ធនឹងការបង្កើតសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ មេធាវីជាតិ និងអន្តរជាតិ ដែលត្រូវបានជ្រើសរើសនិងផ្តល់មូលនិធិដោយអ.វ.ត.ក។ [52]

---

[47] សំណុំរឿងនៃកាំងហ្គេចអ៊ាវ (សំណុំរឿង០០១ អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ paras ៦៣២ និង៦៣៣។ ការកាត់ទោសរបស់គាត់ត្រូវបានកាត់បន្ថយ៥ឆ្នាំជាសំណងសម្រាប់ការឃុំខ្លួនខុសច្បាប់ដោយតុលាការយោធាកម្ពុជារវាងថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ និង ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៧។ គាត់ទទួលបានការសរសើរសម្រាប់ពេលវេលាដែលបានចំណាយនៅក្នុងការឃុំខ្លួននៅក្រោមអាជ្ញាធរនៃតុលាការយោធាកម្ពុជានិងអ.វ.ត.ក។

[48] សំណុំរឿងកាំងហ្គេចអ៊ាវ(សំណុំរឿង០០១) *Case of Kaing Guek Eav (Case 001),* Decision of the Trial Chamber Concerning Proof of Identity for Civil Party Applicants, Trial Chamber, 26 February 2009, para 38.

[49] សំណុំរឿងរបស់កាំងហ្គេចអ៊ាវ(សំណុំរឿង០០១) សេចក្តីសម្រេចរបស់តុលាការកំពូល នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ដែលអាចរកបាននូវ៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/Case%20001AppealJudgementEn.pdf (ចូលនៅថ្ងៃទី១២ ខែវិច្ឆិការ ឆ្នាំ២០១៥)។

[50] ការកាត់ក្តីដំបូង (សំណុំរឿង០០២/០១) គិតចាប់ពីថ្ងៃទី២១ ខែវិច្ឆិការ ឆ្នាំ២០១១ ជាចំបងផ្តោតលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងនឹងចលនាប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញហើយក្រោយមកចេញពីតំបន់ផ្សេងទៀតនិងការកាត់ទោសនៃទាហានរបបសាធារណរដ្ឋខ្មែរនៅកន្លែងពិឃាតទួលពោធិ៍ជ្រៃភ្លាមបន្ទាប់ពីរបបខ្មែរក្រហមដែលបានកាន់កាប់ក្នុងឆ្នាំ ១៩៧៥ សូមមើល៖ http://www.eccc.gov.kh/en/case/topic/2.

[51] សូមមើល http://www.eccc.gov.kh/sites/default/files/legal-documents/Internal_Rules_Rev_9_Eng.pdf (ចូលនៅថ្ងៃទី១៣ ខែវិច្ឆិការ ឆ្នាំ២០១៥)។

[52] ដូចឯកសារយោងខាងលើ។

សហមេធាវីនាំមុខទទួលបន្ទុកលើការតស៊ូមតិភាគច្រើន យុទ្ធសាស្ត្រ និងការតំណាងចំពោះមុខតុលាការតាងនាមឱ្យដើមបណ្តឹងរដ្ឋប្បវេណី។[53] នៅក្នុងដំណាក់កាលមុនអង្គសេចក្តី ដើមបណ្តឹងរដ្ឋប្បវេណីអាចមានអ្នកតំណាងដោយមេធាវីរបស់ពួកគេផ្ទាល់។ ទោះបីជាមិនត្រូវបានអនុញ្ញាតក្នុងការដោះស្រាយជម្លោះទៅកាន់តុលាការ ទោះជាយ៉ាងណាក៏ដោយ មេធាវីទាំងនោះនឹងបន្តដើរតួយ៉ាងសំខាន់ដោយបញ្ជូនសំណើរស្នើសុំសម្រាប់ការស៊ើបអង្កេតក្នុងអំឡុងពេលដំណាក់កាលមុនអង្គសេចក្តី និងផ្តល់ការគាំទ្រទៅកាន់សហមេធាវីនាំមុខនៅក្នុងការជំនុំជម្រះ។ ជាទូទៅ វាត្រូវបានកត់សម្គាល់ថាសហមេធាវីប្រឹក្សាជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីសហការនូវយុទ្ធសាស្ត្រ និងការតស៊ូមតិ។

សំណុំរឿង០០២/០១ ត្រូវបានបញ្ចប់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ហើយការវិនិច្ឆ័យលើការកាត់ទោសត្រូវបានប្រកាសនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ហើយជនជាប់ចោទពីរនាក់នៅសល់ នួនជា និងខៀវសំផន (ឡេងធារិទ្ធមានសភាពទ្រុតទ្រៀមក្នុងការឈរនៅសវនាការ ហើយឡេងសារីទទួលមរណភាពនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣) ត្រូវបានរកឃើញថាមានទោសឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងត្រូវបានកាត់ទោសឱ្យជាប់គុកមួយជីវិត។[54] ចុងចោទទាំងពីរបានដាក់បណ្តឹងសារទុក្ខប្រឆាំងនឹងការវិនិច្ឆ័យ នីតិវិធីឧទ្ធរណ៍កំពុងដំណើរការ។ ភាពស្មុគស្មាញនៅក្នុងសំណុំរឿង០០២ ដែលទាក់ទងជនជាប់ចោទវ័យចាស់ជរាពីររូបដែលនៅសល់ ទីតាំងប្រព្រឹត្តបទល្មើសដែលគ្របដណ្តប់ក្នុងតំបន់ខុសៗគ្នាទូទាំងប្រទេសកម្ពុជា និងក្រុមដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤០០០នាក់មានសារៈសំខាន់ក្នុងការទាមទារ ដោយគ្មានមន្ទិលសង្ស័យអ្វីទាំងអស់ និងទម្រង់បែបបទដែលចាំបាច់ពាក់ព័ន្ធនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សវនាការពិនិត្យលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ប្រឆាំងនឹងខៀវសំផន និងនួនជា ដែលគិតចាប់ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤។[55] វាបន្សល់នូវការមើលឃើញនិងវាស់ស្ទង់នូវផលវិបាកទាំងអស់នៃការចូលរួមជាសមូហភាពនៅក្នុងដំណាក់កាលជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ដែលនឹងប្រព្រឹត្តទៅ។

[53] ដូចឯកសារយោងខាងលើ។
[54] ព្រះរាជអាជ្ញា v. នួនជា និងខៀវសំផលក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អយ ការវិនិច្ឆ័យ(ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤) មាននៅ៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/2014-08-07%2017:04/E313_Trial%20Chamber%20Judgement%20Case%20002_01_ENG.pdf (ចូលនៅថ្ងៃទី១៧ ខែវិច្ឆិការ ឆ្នាំ២០១៥)។
[55] សូមមើល http://www.eccc.gov.kh/en/case/topic/1299 (ចូលនៅថ្ងៃទី១៨ ខែវិច្ឆិការ ឆ្នាំ២០១៥)។

## ៥- តួនាទីនិងផលប៉ះពាល់នៃការចូលរួមរបស់ជនរងគ្រោះ

ការផ្តល់សិទ្ធិអំណាចដល់ជនរងគ្រោះនៃរបបខ្មែរក្រហមបានឆ្លុះបញ្ចាំងនៅក្នុងទម្រង់នៃការចូលរួមដោយផ្ទាល់និងសកម្មជាភាគីពាក់ព័ន្ធបឋមជាមួយ ‘ឥទ្ធិពលនៃការធ្វើការសម្រេចចិត្ត’ (Arnstein ១៩៦៩)[56]។ នៅអ.វ.ត.កបាននាំយកមកនូវការកំណត់រូបរាងដែលផ្តោតទៅលើតម្រូវការសម្រាប់ការយល់ដឹងនៃគុណធម៌និងផលប៉ះពាល់ទូលំទូលាយនិងសំខាន់ៗ - ជាមួយការផ្តោតទៅលើស្របគ្នានៅក្នុងផលប្រយោជន៍ និងថាមវន្តអវិជ្ជមានតាមដែលអាចធ្វើទៅបាន- នៃការចូលរួមរបស់ជនរងគ្រោះ។ ការរួមបញ្ចូលរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាភាពថ្មីនៅក្នុងវិស័យនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ផលវិបាកនៃយន្តការនេះហាក់បីដូចជាទទួលបានជោគជ័យតាមរយៈទឹកនៅអ.វ.ត.កបានបង្ហាញនូវការបង្កើនសក្តានុពលនិងការកម្រិត។[57]

លទ្ធផលនៃការវិភាគខាងក្រោមបានបង្កើតទិដ្ឋភាពខុសៗគ្នានៅក្នុងការចូលរួមរបស់ជនរងគ្រោះនៅអ.វ.ត.ក និងនៅលើការស្រាវជ្រាវផ្អែកលើបទពិសោធន៍ដែលបានធ្វើឡើងជាមួយជនរងគ្រោះនៅក្នុងមូលដ្ឋានក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១៤ ។ ពួកគេស្វែងរកការបង្ហាញភស្តុតាងនូវផលប្រយោជន៍សន្ទត់ជាមុនក៏ដូចជាការបង្ហាញការបំភ្លឺលើកំហុសឆ្គងធ្ងន់ធ្ងរនៃការចូលរួមរបស់ជនរងគ្រោះ។

### ៥.១- ការលើកទឹកចិត្តជនរងគ្រោះក្នុងការចូលរួម

ជាប្រថ្នូលក្នុងការសរសើរនូវតួនាទីនិងផលប៉ះពាល់នៃការចូលរួមរបស់ជនរងគ្រោះ វាមានសារៈសំខាន់ក្នុងការយល់ពីការលើកទឹកចិត្តនៅពីក្រោយការសម្រេចចិត្តដើម្បីស្វែងរកការចូលរួម។ ការលើកទឹកចិត្តដែលជាស្នូលសំខាន់ដែលបានគូសបញ្ជាក់អំពីការចូលរួមរបស់ជនរងគ្រោះត្រូវបានកំណត់ដោយ Stover និងអ្នកផ្សេងទៀតនៅក្នុងការធ្វើការស្រាវជ្រាវចំណេះដឹងរបស់ពួកគេនៅក្នុងឆ្នាំ២០១១។ ប្រធានបទនេះហ៊ុំព័ទ្ធ៖ តម្រូវការដើម្បីដឹង តម្រូវការក្នុងការរៀបរាប់រឿង និងតម្រូវការដើម្បីអប់រំទៅកាន់ពិភពលោក។ អ្វីដែលសំខាន់នោះ ការធ្វើការស្រាវជ្រាវសម្រាប់របាយការណ៍នេះបានអះអាងបន្ថែមនូវលទ្ធផលទាំងនេះ ឆ្លុះបញ្ចាំងពីការធ្វើការស្រាវជ្រាវដោយត្រឹមត្រូវដោយ Stover et al. (២០១១)។ទោះបីជាយ៉ាងណាក៏ដោយ ដូចដែលបានបកស្រាយយ៉ាងខ្លី របាយការណ៍នេះនឹងក្រឡេកមើលនូវរបៀបប្រធានបទលេចឡើងមានដំណើរការទៅមុខ ពង្រីកការវិភាគដ៏សំខាន់នៃ Stover et al. (២០១១)។ លើសពីនេះទៅទៀត អ្នកសម្ភាសន៍ជនរងគ្រោះនិងក្រុមគោលដៅត្រូវបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជាត្រូវបានបង្ហាញពីសារៈសំខាន់នៃការស្វែងរកសំណងជំងឺចិត្ត និងជំរុញការផ្សះផ្សាជាតិនៅក្នុងលក្ខខណ្ឌលើកទឹកចិត្តជនរងគ្រោះក្នុងការចូលរួម។ ដូច្នេះគន្លឹះលើកទឹកចិត្តទាំងនេះនឹងបង្កើតការវិភាគសំខាន់ៗដូចខាងក្រោម៖

- ស្វែងរកយុត្តិធម៌
- ស្វែងរកការពិត
- រៀបរាប់ពីរឿងរ៉ាវ
- អប់រំពិភពលោក
- ស្វែករកសំណងជំងឺចិត្ត

56 ការបញ្ជាក់ការប្រៀបធៀបមានគោលបំណងដើម្បីបង្ហាញនូវជនរងគ្រោះ’ មិនផ្ទាល់ និងឥទ្ធិពលអរូបីយដោយគុណធម៌នៃការចូលរួមរបស់ពួកគេនៅលើដំណើរការនៃការសម្រេចចិត្ត។

57 Jasini, R. (២០១៥) ធ្វើឱ្យតាមបរិបទរបស់ការចូលរួមរបស់ជនរងគ្រោះនៅក្នុងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ និក្ខេបបទដែលមិនបានបោះពុម្ព សកលវិទ្យាល័យអុសហ្វ័ត អុសហ្វ័ត UK។

- ជំរុញឱ្យមានការផ្សះផ្សា។

ដូចនេះ
នេះគឺជាហេតុផលខុសគ្នាដែលជនរងគ្រោះត្រូវបានលើកទឹកចិត្តក្នុងការចូលរួមនៅក្នុងការជំនុំជម្រះក្ដីមុនពេលអ.វ.ត.កជាដើមបណ្ដឹងរដ្ឋប្បវេណី។
ទាំងនេះត្រូវបាននាំយកមកនូវសេចក្ដីអធិប្បាយដូចខាងក្រោមដែលធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសកម្មភាពសម្ភាសន៍ដែលបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍បុគ្គលម្នាក់បាននិយាយថា

> ខ្ញុំរស់នៅក្នុងការឈឺចាប់ជារៀងរហូតមក។ ខ្ញុំបានបាត់បង់ឪពុកម្ដាយទាំងពីររូប ហើយនេះគឺជារឿងរ៉ាវផ្ទាល់ខ្លួននិងអារម្មណ៍ពិតសម្រាប់ខ្ញុំដែលជាផ្នែកមួយនៅក្នុងដំណើរការនេះ។[58]

[58] ប្រតិចារឹកនៃបទសម្ភាសន៍ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ ភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៤)។

នៅក្នុងបរិបទដូចគ្នានេះ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានលើកឡើងថា៖

> ដំបូងឡើយ ខ្ញុំមិនបានដឹងពីនីតិវិធី ឬគោលបំណងនៃតុលាការនេះទេ។ ជាអាទិ៍ នៅពេលដែលខ្ញុំបានដាក់ពាក្យបណ្តឹងនាពេលនោះ ខ្ញុំគ្រាន់តែចង់បានយុត្តិធម៌ឱ្យជនរងគ្រោះនិងសាច់ញាតិរបស់ខ្ញុំដែលបានបាត់បង់ជីវិតទៅ។ ហើយរូបខ្ញុំផ្ទាល់ចង់រកសេចក្តីស្ងប់ចិត្តតែប៉ុណ្ណោះ។[59]

ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តកំពង់ចាម បានរំឭកថា៖

> កត្តាដែលជំរុញលើកទឹកចិត្តឱ្យខ្ញុំបានដាក់ពាក្យបណ្តឹងទៅ អ.វ.ត.ក នោះគឺ៖ ទីមួយ ខ្ញុំគឺជាជនរងគ្រោះដោយផ្ទាល់ និងបានបាត់បង់សាច់ញាតិជាច្រើននាសម័យនោះ ដូច្នេះហើយខ្ញុំចង់ឱ្យវាក្លាយជាប្រវត្តិសាស្ត្រសម្រាប់កូនចៅជំនាន់ក្រោយដើម្បីសិក្សារៀនសូត្រពីវា។ ទីពីរ ខ្ញុំក៏ចង់ស្វែងរកយុត្តិធម៌សម្រាប់បងប្អូន និងសាច់ញាតិរបស់ខ្ញុំផងដែរ... បន្ទាប់មក ខ្ញុំសូមផ្តល់នូវភ័ស្តុតាងចោទប្រកាន់ទៅលើជនជាប់ចោទទាំងនោះ... ដើម្បីឱ្យពួកគេដឹងថា ពួកគេបានប្រព្រឹត្តកំហុសធ្ងន់មួយដ៏ធំ។[60]

ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ផ្សេងទៀត ដែលបានចូលរួមក្នុងសំណុំរឿង ០០១ និងដែលបានទទួលរងពីការធ្វើទារុណកម្ម និងការបន្ថោកបន្ទាប បានលើកឡើងដូចខាងក្រោម៖

> គោលបំណង ដែលខ្ញុំបានដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១ នេះ គឺដើម្បីស្វែងរកការពិតសម្រាប់អ្នកដែលនៅរស់រានមានជីវិត និងអ្នកដែលបានស្លាប់ទៅនាសម័យនោះ មើលឃើញជនជាប់ចោទសារភាពទោសថា ពួកគេពិតជាបានប្រព្រឹត្តបទឧក្រិដ្ឋមែននាពេលនោះ និងស្នើសុំសំណង មិនថាជាសំណងផ្លូវចិត្ត និងសំណងសម្ភារភាពនោះទេ។[61]

ទស្សនៈខុសប្លែកគ្នាបន្តិចបន្តួច ត្រូវបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត ថា៖

> នៅពេលដែល អ.វ.ត.ក បានចាប់ផ្តើមនូវសវនាការនេះ ជាមួយការឈឺចាប់ដែលខ្ញុំខំស៊ូទ្រាំ ខ្ញុំចង់ដាក់ពាក្យបណ្តឹងដើម្បីរំសាយនូវការឈឺចាប់ទាំងនោះ។ ខ្ញុំក៏ចង់បានប្រទេសមួយដែលជានីតិរដ្ឋផងដែរ។ ហេតុដូច្នេះហើយ នៅពេលអនាគត មនុស្ស ទាំងឡាយនឹងមិនត្រូវបានកាត់ទោស ដោយពុំបានជំនុំជម្រះនោះទេ។[62]

ផ្នែកខាងក្រោមនេះ នឹងពិនិត្យមើលលើចំណុចដាច់ដោយឡែកពីគ្នា ក៏ដូចជាចំណុចទាក់ទងផងដែរ ។ ក្នុងអំឡុងពេលធ្វើការវិភាគ រាល់ឯកសារយោងពាក់ព័ន្ធនឹងរឿងរ៉ាវ និងការយល់ឃើញផ្ទាល់ខ្លួនរបស់ជនរងគ្រោះ មានសារៈសំខាន់ណាស់ចំពោះការស្វែងយល់លម្អិតនៃការលើកទឹកចិត្ត និង

[59] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០១ និង ០០២ ភ្នំពេញ ថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០១៤)។

[60] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០១ និង ០០២ កំពង់ចាម ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ ២០១៤)។

[61] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០១ ភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៤)។

[62] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០១ ភ្នំពេញ ថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០១៤)។

ជាមូលហេតុជំរុញឱ្យជនរងគ្រោះចូលរួមក្នុងការជំនុំជម្រះក្តីនេះ នៅចំពោះមុខអ.វ.ត.ក។

៥.២ ការស្វែងរកយុត្តិធម៌

ការស្វែងរកយុត្តិធម៌សម្រាប់អ្នកដទៃនិងខ្លួនឯង ជាប្រធានបទដ៏សំខាន់ដោយគ្មានភាពសង្ស័យ ដែលជារឿងធម្មតាសម្រាប់បទសម្ភាសន៍ទាំងអស់ដែលបានធ្វើឡើង។ បើទោះបីជាយ៉ាងណាក៏ដោយ យុត្តិធម៌ គឺជាពាក្យដែលតែងតែប្រែប្រួលជានិច្ច។

ក្នុងន័យនេះ ការរួមបញ្ចូលគ្នានូវគំនិតនៃយុត្តិធម៌ គឺជាសញ្ញាមួយនៃបដិទានដើម្បីកែតម្រូវ*ភាពអយុត្តិធម៌*ឡើងវិញ ឬកែប្រែនូវកំហុសឆ្គងទាំងឡាយនោះទេ។ ក្នុងការអនុវត្តជាក់ស្តែង បើយោងតាមទស្សនទានរបស់ជនរងគ្រោះនិងអ្នកដទៃទៀត ពួកគេចង់ឱ្យចេញលទ្ធផលជាក់ស្តែង តាមរយៈសាលក្រមផ្តន្ទាទោស។ ក៏ប៉ុន្តែ សាលក្រមផ្តន្ទាទោសនេះ នឹងមិនបាន "កែប្រែកំហុសឆ្គង" ដោយឯកឯងនោះទេ។ នេះបង្ហាញពីសញ្ញាផ្សេងៗទៀតនៃភាពយុត្តិធម៌ ដែលមិនអាចឃ្លាតចាកឆ្ងាយពីទឹកចិត្តផ្សេងៗដែលនាំឱ្យមានការចូលរួមរបស់ជនរងគ្រោះ។ ទីមួយ វាតម្រូវឱ្យមានការស្វែងរកការពិត និងការផ្សះផ្សា ហើយជាពិសេស ទីពីរ ទាក់ទងនឹងសំណើនៃសំណងទាំងឡាយ។ ចុងក្រោយនេះ ការជំរុញទឹកចិត្ត កើតចេញពីគំរូដ៏ល្អប្រសើរនៃយុត្តិធម៌។ សូមចង់ចាំថា យុត្តិធម៌អាចត្រូវបានស្វែងយល់ទៅបាន ទាំងពីទស្សនទានបុគ្គលនីមួយៗ និងទស្សនទានសមូហភាព ដូចដែលវាលើកឡើងដោយអ្នកផ្តល់បទសម្ភាសន៍៖

> ខ្ញុំគឺជាជនរងគ្រោះដោយផ្ទាល់ពីរបបខ្មែរក្រហម។ ការចូលរួមរបស់ខ្ញុំនៅ អ.វ.ត.ក នេះ មានសារៈសំខាន់ណាស់ដោយសារតែហេតុផលពីរយ៉ាង៖ ទី១ ដើម្បីស្វែងរកយុត្តិធម៌សម្រាប់រូបខ្ញុំនិងសាច់ញាតិរបស់ខ្ញុំ។ ទី២ ដើម្បីជួយប្រព័ន្ធនេះក្នុងការផ្តល់ឱ្យនូវភ័ស្តុតាងចោទប្រកាន់ ឆ្ពោះទៅរកការបង្កើតគណនេយ្យភាពដើម្បីបម្រើដល់វិស័យយុត្តិធម៌។[63]

ដូចដែលបានបង្ហាញខាងក្រោមនេះ សញ្ញានៃភាពយុត្តិធម៌ពិតជាកើតមានឡើងជាក់ស្តែងក្នុងគ្រប់បទសម្ភាសន៍ទាំងឡាយ។ បន្ទាប់មក តាមទស្សនៈរបស់ជនរងគ្រោះ ពួកគេជឿជាក់ថា ការចូលរួមរបស់ពួកគេក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ពិតជាមានសារៈសំខាន់ណាស់ក្នុងការសម្រេចឱ្យបាននូវយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា មិនថានៅកម្រិតបុគ្គលនីមួយៗ និងសមូហភាពឡើយ។ វាគួរឱ្យកត់សម្គាល់ផងដែរក្នុងការបង្ហាញថា បទសម្ភាសន៍ដែលបានធ្វើឡើងសម្រាប់ការស្រាវជ្រាវនេះ ហាក់ដូចជាចង់លើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណី កាន់តែផ្តោតទៅលើការស្វែងរកភាពយុត្តិធម៌ បើគិតពីគុណតម្លៃនៃការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយសវនាការ តាមរយៈការចូលរួមរបស់ពួកគាត់។ មួយផ្នែកគឺ ដោយសារតែការទទួលបានយ៉ាងល្អប្រសើរនូវព័ត៌មាន និងធនធានគាំទ្រទាំងឡាយ នៅខណៈដើមបណ្តឹងជាជនរងគ្រោះដែលត្រូវបានសម្ភាសនោះ មិនមានការគាំទ្រនិងធនធានគ្រប់គ្រាន់ឡើយ។ នេះជាអ្វីៗទាំងអស់ដែលមានលក្ខណៈពិតប្រាកដជាងមុនសម្រាប់សហគមន៍ទូទៅ ដែលមិនមានកម្មវត្ថុជាក់ស្តែងនៅក្នុងសវនាការ អ.វ.ត.ក ឡើយ។ បើទោះបីជាយ៉ាងក៏ដោយ វាជារឿងពិតដែលថា សង្គមកម្ពុជាជឿជាក់លើសារៈសំខាន់ដ៏លើសលុបចំពោះគំរូនៃភាពយុត្តិធម៌នេះ។ ក៏ប៉ុន្តែ សំណួរដែលថា តើយុត្តិធម៌អាចទទួលបាននៅខាងក្រៅពីបរិវេណនៃសាលសវនាការនេះ ឬទេ ឧទាហរណ៍ ជាជាងតាមរយៈការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានឆ្លើយតបដោយក្រឡេកទៅមើលការបង្ហាញឱ្យដោយឯករាជ្យ លើគំរូអរូបីនៃយុត្តិធម៌

[63] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០១ និង០០២ ភ្នំពេញ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៤)។

ក្នុងកិច្ចពិភាក្សាបន្ទាប់ទៀត។ ជាចុងបញ្ចប់ គេបានលើកសំណួរឡើងថាតើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ពិតជាបង្កើតទម្រង់មួយប្រកបដោយប្រសិទ្ធភាព និងអត្ថប្រយោជន៍លើការពង្រឹងយុត្តិធម៌មែននោះទេ។

វិធាន ២៣(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានចែងថា គោលបំណងនៃសកម្មភាពដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីនេះ ត្រូវចូលរួមក្នុងសវនាការនៅចំពោះមុខតុលាការ ‘ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវ ដោយគាំទ្រលើការចោទប្រកាន់នានា’ ហើយដើម្បីអនុញ្ញាតឱ្យជនរងគ្រោះអាច ‘ស្វែងរកសំណងផ្លូវចិត្តនិងសំណងសមូហភាព’ បាន។ យើងត្រូវត្រឡប់ទៅរកក្របខ័ណ្ឌគតិយុត្តិស្តីពីសំណងនិងសារៈសំខាន់របស់វាសម្រាប់ជនរងគ្រោះ។ ក្នុងពេលនេះ ទិកភាពនៃតួនាទីរបស់ជនរងគ្រោះក្នុងសវនាការនៅចំពោះមុខ អ.វ.ត.ក គួរត្រូវបានកត់សម្គាល់ឡើងថា៖ ការគាំទ្រលើការចោទប្រកាន់នេះ មានការទាក់ទងយ៉ាងខ្លាំងទៅនឹងនិយមន័យនៃពាក្យយុត្តិធម៌ ដែលបានលើកឡើងពីខាងលើ។

Stover et al. នៅក្នុងការសិក្សារបស់ពួកគេ បានរកឃើញថា កង្វល់របស់ជនរងគ្រោះមានការពាក់ព័ន្ធយ៉ាងសំខាន់ទៅនឹងយុត្តិធម៌បុគ្គល៖

> សម្រាប់ភាគច្រើន... ផ្អែកទៅលើតម្រូវការក្នុងការផ្តល់សក្ខីកម្មជាលក្ខណៈបុគ្គល និងចេញពីក្នុងចិត្ត ជាជាងផ្អែកលើអារម្មណ៍នៃការទទួលខុសត្រូវដើម្បីធ្វើអំពើល្អសម្រាប់ប្រជាពលរដ្ឋកម្ពុជា ឬមនុស្សជាតិទាំងអស់ បើទោះបីជាមនោសញ្ចេតនាមិនបាត់បង់ទាំងស្រុងក៏ដោយ។ (Stover et al, ២០១១: ៥២០)

ក្នុងកម្រិតមួយ រូបភាពនេះត្រូវបានឆ្លុះបញ្ចាំងក្នុងការស្រាវជ្រាវដែលបានធ្វើឡើងសម្រាប់គម្រោងនេះក្នុងប្រទេសកម្ពុជា។ ហេតុដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ពីខេត្តព្រៃវែង ដែលបានឃុំខ្លួនក្នុងគុកព្រៃសក្នុងអំឡុងសម័យខ្មែរក្រហម បាននិយាយអំពីការស្វែងរកយុត្តិធម៌ និងការយល់ដឹងរបស់គាត់ទាក់ទងនឹងតួនាទីនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុង អ.វ.ត.ក ក្នុងបរិបទនេះដោយមានសម្តីដូចខាងក្រោម៖

> នៅពេលខ្ញុំបានដាក់ពាក្យបណ្តឹងនាពេលនោះ ខ្ញុំគ្រាន់តែចង់បានយុត្តិធម៌ឱ្យជនរងគ្រោះនិងសាច់ញាតិរបស់ខ្ញុំដែលបានបាត់បង់ជីវិតទៅហើយ។ ហើយខ្ញុំផ្ទាល់ចង់រកសេចក្តីស្ងប់ចិត្តតែប៉ុណ្ណោះ ដោយមិនមានការសោកស្តាយនោះទេ បើទោះជាមិនបានដាក់ពាក្យបណ្តឹងដើម្បីរកយុត្តិធម៌សម្រាប់ខ្លួនឯងក៏ដោយ។

យ៉ាងក៏ដោយ ការសិក្សាស្រាវជ្រាវនេះបានបង្ហាញពីរូបភាពដែលមានលក្ខណៈលម្អិតជាងមុន។ ការស្វែងរកយុត្តិធម៌ មិនគ្រាន់តែជាការស្វែងរកយុត្តិធម៌ និងការទទួលខុសត្រូវសម្រាប់ការឈឺចាប់ផ្ទាល់ខ្លួនប៉ុណ្ណោះទេ ក៏ប៉ុន្តែសម្រាប់ប្រជាជនកម្ពុជាទូទៅផងដែរ។ សម្រាប់ពួកគេ រយៈពេល ៣៥ ឆ្នាំបន្ទាប់ពីការភ័យខ្លាចនៃរបបខ្មែរក្រហម ការផ្សះផ្សានិងគោលបំណងរួមផ្សេងទៀតមានលក្ខណៈចាំបាច់សម្រាប់ធ្វើដំណើរទៅខាងមុខ។

ទិកភាពនេះ
មានភាពច្បាស់លាស់នៅក្នុងកិច្ចសម្ភាសន៍ផ្សេងៗទៀតដែលបានធ្វើឡើងជាមួយដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលបានទទួលរងការជម្លៀសដោយបង្ខំ និងអំពើឃោរឃៅ ហើយដែលត្រូវបានផ្តល់ឱកាសឱ្យផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការបានសង្កត់ធ្ងន់
លើការប្តេជ្ញាចិត្តរបស់គាត់ ដើម្បីធ្វើឱ្យចារីដែលបានប្រព្រឹត្តអំពើឃោរឃៅក្នុងរបបខ្មែរក្រហម

ទទួលខុសត្រូវចំពោះព្រឹត្តិការណ៍ដែលបានកើតលើខ្លួនគាត់និងប្រជាជនកម្ពុជាទាំងមូល៖

> ការបង្កើត អ.វ.ត.ក នេះឡើង បានផ្តល់ឱ្យខ្ញុំនូវក្តីសង្ឃឹមជាច្រើន។ នៅពេលដែល អាដហុក បានមកដល់ស្រុករបស់ខ្ញុំ ដើម្បីស្វែងជនរងគ្រោះដែលចង់ដាក់បណ្តឹងក្នុងសំណុំរឿង ០០២ ខ្ញុំបានគិតថា នេះគឺជាឱកាសមួយដ៏ល្អប្រសើរសម្រាប់ខ្ញុំ ដើម្បីឱ្យអ្នកទាំងអស់គ្នាបានដឹងឮពីរឿងរ៉ាវរបស់ខ្ញុំ និងស្វែងរកយុត្តិធម៌ដែរ។ ដូច្នេះហើយ ខ្ញុំបានចូលរួមក្នុងសវនាការនេះដើម្បីធ្វើឱ្យចារីទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានប្រព្រឹត្តមកលើខ្ញុំ ហើយខ្ញុំនិងក្រុមគ្រួសារ ចង់បានយុត្តិធម៌សម្រាប់ខ្លួនឯងនិង*ប្រជាជនកម្ពុជា*។ ខ្ញុំគិតថា វាមានសារៈសំខាន់ណាស់សម្រាប់ខ្ញុំក្នុងការជួយតុលាការដើម្បីស្វែងទោសកំហុសរបស់ជនជាប់ចោទនេះ។[64]

មតិយោបល់ស្រដៀងគ្នា ត្រូវបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណីម្នាងទៀត ដែលបានមានប្រសាសន៍ថា៖

> ខ្ញុំសូមប្រាប់អ្នកទាំងអស់គ្នាថា ខ្ញុំចង់ស្វែងរកយុត្តិធម៌សម្រាប់រូបខ្ញុំ និង*ជនរងគ្រោះទាំងអស់នៅក្នុងប្រទេស*។ ហើយខ្ញុំចង់ឱ្យសាលាក្តីនេះជួយខ្ញុំក្នុងការស្វែងយុត្តិធម៌។ ខ្ញុំជឿជាក់ថា សាលាក្តីនេះ នឹងអាចជួយស្វែងរកយុត្តិធម៌ដល់រូបខ្ញុំ។ នៅពេលដែលសាលាក្តីនេះ អាចស្វែងរកយុត្តិធម៌ជូនជនរងគ្រោះបាន ខ្ញុំពិតជាសប្បាយចិត្តខ្លាំងណាស់ពីព្រោះវាជួយខ្ញុំ និងជនរងគ្រោះផ្សេងទៀតស្វែងរកយុត្តិធម៌ និងធ្វើឱ្យកូនចៅជំនាន់ក្រោយបានដឹងពីវា ក្នុងគោលបំណងបញ្ចៀសអំពើឃោរឃៅដូចនេះ នាពេលក្រោយទៀត។[65]

វាមានលក្ខណៈច្បាស់លាស់ពីខាងលើដែលថា ការស្វែងរកយុត្តិធម៌មានទំនាក់ទំនងទៅនឹងការលើកទឹកចិត្តពីខាងក្នុងសម្រាប់ជនរងគ្រោះដើម្បីឱ្យចូលរួមក្នុងការជំនុំជម្រះក្តីនេះ។ វាក៏ជាប់ពាក់ព័ន្ធនឹងសនិទានភាពសំខាន់ៗផ្សេងទៀតចំពោះការចូលរួមរបស់ជនរងគ្រោះក្នុង អ.វ.ត.ក ផងដែរ ដូចជា ការស្វែងរកការពិត ការប្រាប់កូនចៅជំនាន់ក្រោយពីសេចក្តីរន្ធត់នៃរបបខ្មែរក្រហម និងការទទួលបានសំណងផ្លូវចិត្តនិងសំណងសមូហភាព។ សម្រាប់ហេតុផលនេះ សវនាការឧក្រិដ្ឋកម្ម 'សាមញ្ញ' ដែលអាចសម្រេចបាននូវវត្ថុបំណង និងការលើកទឹកចិត្តដែលបណ្តាលឱ្យមានការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែក្នុងលក្ខណៈថយចុះ ប្រសិនបើទាំងអស់ ហើយដែលផ្តោតយ៉ាងសំខាន់លើការទទួលខុសត្រូវ នឹងមិនមានភាពគ្រប់គ្រាន់ដើម្បីនាំមកនូវយុត្តិធម៌នោះទេ ដែលស្ថិតក្នុងកម្រិតទាបបំផុតមួយ នៅខណៈពេលដែលពាក្យនេះត្រូវបានជ្រួលជ្រាបក្នុងបុគ្គលនីមួយៗ ដែលផ្ទុយពីការយល់ដឹងរួមផ្សេងទៀត។ លទ្ធផលស្រាវជ្រាវនោះត្រូវបានឆ្លុះបញ្ចាំងឡើងក្នុងការសិក្សាមួយដែលបានធ្វើឡើងដោយ Pham et al., តាមរយៈដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់បទសម្ភាសន៍ ផ្តោតលើសាលក្រមផ្តន្ទាទោសដែលជាលទ្ធផលវិជ្ជមាននៃការជំនុំជម្រះក្តីដែលតែងតែបានលើកឡើង។ លទ្ធផលសំខាន់ៗផ្សេងទៀតរួមមាន៖ ការរួមចំណែកដល់សវនាការទៅលើការបង្កើតកំណត់ត្រាប្រវត្តិសាស្ត្រ ឱកាសសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការពណ៌នាពីរឿងរ៉ាវរបស់ខ្លួន និងការអនុញ្ញាតឱ្យជនជាប់ចោទអាចប្រាប់ពីដំណើររឿងផ្ទាល់នូវអ្វីដែលបានកើត

[64] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ភ្នំពេញ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៤)។ ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម។
[65] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។ ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម។

ចេញពីទស្សនៈរបស់គេ ទទួលស្គាល់និងធ្វើការសូមទោសសម្រាប់អ្វីដែលគាត់បានប្រព្រឹត្ត (Pham et al, ២០១១: ២៨០)។

### ៥.២.១ ប្រតិកម្មទៅលើសាលក្រម

ការសម្រេចបានយុត្តិធម៌ជូនជនរងគ្រោះ អាចត្រូវបានវាស់វែងដោយឯកសារយោងលើសាលក្រមដែលបានចេញដោយ អ.វ.ត.ក។ ដូចដែលនឹងកោះហៅឡើងវិញ អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងឧទ្ធរណ៍បានផ្ដន្ទាទោស *ឌុច* ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ដែលខុសពីសេចក្ដីសម្រេចរបស់សាលាដំបូងក្នុងសំណុំរឿង ០០១ ដែលបានផ្ដន្ទាទោស*ឌុច*ឱ្យជាប់ពន្ធនាគាររយៈពេល៣៥ ឆ្នាំ។[66] ក្នុងករណីសំណុំរឿង ០០២ តុលាការបានផ្ដន្ទាទោសបុគ្គលពីររូបផ្សេងទៀត ដែលបានជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលបានធ្វើឡើងក្នុងអំឡុងពេលរបបខ្មែរក្រហមឱ្យជាប់ពន្ធនាគារអស់មួយជីវិត ដែលជាទោសប្បញ្ញត្តិកម្រិតធ្ងន់បំផុតដូចបានចែងក្នុងច្បាប់របស់ អ.វ.ត.ក។[67]

ក្នុងន័យលក្ខខណ្ឌទូទៅ ការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ជនរងគ្រោះមានការព្រមព្រៀងទាំងស្រុងចំពោះការផ្ដន្ទាទោសអស់មួយជីវិតដែលបានអនុវត្តលើពិរុទ្ធជនទាំងនោះ។ ក៏ប៉ុន្តែការព្រួយបារម្ភ និងកង្វះខាតនៃការយល់ដឹងនៅតែមាន ពាក់ព័ន្ធទៅនឹងសិទ្ធិបណ្ដឹងឧទ្ធរណ៍។ ដូច្នេះ ពាក់ព័ន្ធនឹងសាលក្រមនេះដែលផ្ដល់ឱ្យក្នុងករណីសំណុំរឿង ០០២ ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរៀបរាប់ការឈឺចុកចាប់របស់ខ្លួនក្នុងសម័យខ្មែរក្រហម ប្រដូចទៅនឹង 'អ្វីដែលមិនអាចវាស់ស្ទង់បាន' និងត្រូវបានជម្លៀសចេញពីរាជធានី បានលើកឡើងថា៖

> ខ្ញុំពិតជាសប្បាយចិត្តជាមួយសាលក្រមនេះណាស់។ ប្រសិនបើពួកគេត្រូវបានផ្ដន្ទាទោសតែមួយ ឬពីរឆ្នាំក្នុងពន្ធនាគារ ពួកគេនៅតែអាចរស់នៅដោយមានសេរីភាព បន្ទាប់ពីពេលវេលាដាក់ទោសនេះបានកន្លងផុតទៅ។ ក៏ប៉ុន្តែយើងពិតជាពេញចិត្តចំពោះការផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតនេះណាស់។ ក៏ប៉ុន្តែរឿងរ៉ាវតែមួយដែលខ្ញុំមិនពេញចិត្តនោះ គឺថាពួកគេកំពុងតែដាក់បណ្ដឹងជំទាស់ទៅនឹងសាលក្រមនេះ ហើយមេធាវីរបស់ពួកគេបានប្ដឹងឧទ្ធរណ៍ និងកំពុងតែរង់ចាំសេចក្ដីសម្រេចក្ដីពីអង្គជំនុំជម្រះតុលាការ[កំពូល]។[68]

កង្វល់ ដែលពាក់ព័ន្ធនឹងរយៈពេលនៃនីតិវិធីនេះ ជាពិសេសស្របទៅតាមសិទ្ធិនៃប្ដឹងឧទ្ធរណ៍ នៅតែស្ថិតក្នុងដើមបណ្ដឹងរដ្ឋប្បវេណីភាគច្រើន ដែលបានផ្ដល់បទសម្ភាសន៍ ដូចដែលបានបង្ហាញដោយមតិយោបល់ខាងក្រោម ដោយដើមបណ្ដឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះនៅរស់រានមានជីវិតម្នាក់ពីមន្ទីរឃុំឃាំង ស-២១ និងដែលបានចូលរួមក្នុងករណីទាំងពីរថា៖

[66] *សំណុំរឿង កាំង ហ្គេកអ៊ាវ (សំណុំរឿង ០០១),* ការវិនិច្ឆ័យកាត់ទោសរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២។ អាចរកបាននៅ៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/Case%20001AppealJudgementEn.pdf (បានចូលទៅកាន់ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៥)។

[67] សំណុំរឿង ០០២/០១ ការសម្រេចរបស់អង្គជំនុំជម្រះសវនាការ ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ សេចក្ដីវិនិច្ឆ័យ។ អាចរកបាននៅ៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/2014-08-07%2017:04/E313_Trial%20Chamber%20Judgement%20Case%20002_01_ENG.pdf (បានចូលទៅកាន់ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ ២០១៥)។

[68] ប្រតិចារឹកនៃបទសម្ភាសន៍ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្ដឹងរដ្ឋប្បវេណីសំណុំរឿង០០២ ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤) ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម។

> ការព្រួយបារម្ភរបស់ខ្ញុំ គឺថាជនជាប់ចោទអាចស្លាប់ទៅបាន មុនពេលការកាត់ក្ដីរបស់[សាលាឧទ្ធរណ៍]។ ប្រសិនបើដូច្នេះ វានឹងមិនយុត្តិធម៌ទេសម្រាប់ជនរងគ្រោះក៏ដូចជាពិភពលោកទាំងមូល... ដូច្នេះហើយ យើងបានព្យាយាមជំរុញសវនាការនេះឱ្យដំណើរការបានកាន់តែលឿនតាមដែលអាចធ្វើទៅបាន។ ក៏ប៉ុន្តែ ឥឡូវនេះខ្ញុំបានឮថា ជនជាប់ចោទនឹងប្ដឹងជំទាស់ក្នុងសំណុំរឿង០០២... ហើយវាត្រូវការពេលវេលាបន្ថែមទៀត។[69]

ទីមួយ ការព្រួយបារម្ភសំខាន់ៗរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺពាក់ព័ន្ធថា ពិរុទ្ធជនដែលបានកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មិនបានឃើញពន្លឺថ្ងៃទៀតទេ ហើយទី២ គឺថាមានកម្រិតនៃអវសានពាក់ព័ន្ធនឹងសាលក្រមនេះ។ ទាំងនេះក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងមតិយោបល់ខាងក្រោមដែលបានផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណីដូចគ្នា
ដោយមានទំនាក់ទំនងទៅនឹងសាលក្រមសាលាដំបូងក្នុងសំណុំរឿង០០១៖

> ចៅក្រម បានផ្ដន្ទាទោស *ឌុច* ឱ្យជាប់ពន្ធនាគាររយៈពេល ៣៥ឆ្នាំ។ យើងក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៩៣ រូប មិនបានពេញចិត្តនឹងសេចក្ដីសម្រេចនេះទេ ហើយយើងបានប្ដឹងជំទាស់ទៅតុលាការកំពូល... ហេតុដូច្នេះ *ឌុច*ត្រូវបានផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត ហើយនេះគឺជាយុត្តិធម៌សម្រាប់រូបខ្ញុំ និងជនរងគ្រោះផ្សេងទៀត។[70]

វាបានលេចឡើងពីរឿងរ៉ាវកាលពីមុនដែលថា ដើមបណ្ដឹងរដ្ឋប្បវេណីជឿជាក់លើសារៈសំខាន់គួរឱ្យកត់សម្គាល់ទៅនឹងលទ្ធផលនៃការជំនុំជម្រះក្ដី ជាពិសេសទាក់ទងនឹងសាលក្រមនិងការផ្ដន្ទាទោស។ លើសពីនេះទៅទៀត វាបានចង្អុលឱ្យឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងពាក់ព័ន្ធនឹងលទ្ធផលនេះ ជាងដើមបណ្ដឹងជាជនរងគ្រោះ ដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីបានខិតខំប្រឹងប្រែងច្រើនក្នុងសវនាការនៅ អ.វ.ត.ក។

## ៥.៣ ការស្វែងរកការពិត

ដូច Stover និងអ្នកផ្សេងទៀតដែលបានធ្វើការស្រាវជ្រាវទៅដល់ទីកន្លែងជាមួយជនរងគ្រោះពីពេលមុន បន្ទាប់ពីការជំនុំជម្រះក្ដីក្នុងសំណុំរឿង០០១ បានមកដល់ទីបញ្ចប់នឹងលើកអំណះអំណាងដូចខាងក្រោម៖

> តម្រូវការជាក់ស្ដែងនេះ
> សម្រាប់ព័ត៌មានលម្អិតស្ដីពីជោគវាសនារបស់មនុស្សជាទីស្រឡាញ់ - បើទោះបីជាមានការឈឺចាប់ក៏ដោយ- បង្កឱ្យមានផលប៉ះពាល់ដល់គ្រួសារនៃជនរងគ្រោះនៅជុំវិញពិភពលោក ដោយមិនគិតពីបរិបទវប្បធម៌ ឬនយោបាយឡើយ។ (Stover et al, ២០១១: ៥១៩)

មិនមានការបដិសេធលើសេចក្ដីប្រាថ្នារបស់ជនរងគ្រោះ
ដើម្បីចូលរួមដោយផ្ទាល់ក្នុងសវនាការជនុំជម្រះក្ដីតាមរយៈការសួរសំណួរទៅលើជនជាប់ចោទ

[69] ប្រតិចារឹកនៃបទសម្ភាសន៍ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្ដឹងរដ្ឋប្បវេណីសំណុំរឿង ០០១ និង ០០២ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤) ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម។
[70] ដូចខាងលើ។

និងសាក្សី ហើយនេះគឺពាក់ព័ន្ធទៅនឹងសេចក្ដីប្រាថ្នាក្នុងចិត្តរបស់ពួកគាត់ដើម្បីប្រឈមមុខនឹងជនជាប់ចោទ។ នេះបានកំណត់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពីទម្រង់ផ្សេងៗនៃការចូលរួមក្នុង TJ ដូចជាការចូលរួមដោយប្រយោលការកត់សម្គាល់។ល។ ដើមបណ្ដឹងរដ្ឋប្បវេណី អាចចូលរួមយ៉ាងសកម្មក្នុងសវនាការនេះបានដោយធ្វើការសួរសំណួរនិងទាក់ទងជាមួយអយ្យការ។ វានឹងមិនអាចកើតឡើងបានទេបើពាក់ព័ន្ធនឹងទម្រង់ផ្សេងទៀតនៃការចូលរួមដែលមានភាពអសកម្មតាមការជាក់ស្ដែង។ តាមការពិតទៅសម្រាប់ជនរងគ្រោះភាគច្រើន ដែលបានចូលរួមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះក្ដីលើ *ឌុច* ការប្រឈមមុខជាមួយ *ឌុច* និងការមានឱកាសចោទជាសំណួរពាក់ព័ន្ធនឹងជោគវាសនានីមួយៗរបស់មនុស្សនិងមិត្តភក្ដិជាទីស្រឡាញ់ដែលបានបង្កើតជាពេលវេលាសំខាន់សម្រាប់ស្រាវជ្រាវស្វែងរកការពិត។ នេះគឺជាការសន្និដ្ឋានរបស់ Stover et al., ដែលបានលើកឡើងខាងលើ។ ហេតុដូច្នេះគេបានរកឃើញថា ការជួបជាមួយ *ឌុច* អំឡុងពេលសវនាការជំនុំជម្រះ៖

> …បង្ហាញពីពេលវេលាដ៏សំខាន់ក្នុងការស្វែងរកការពិតស្ដីពីជោគវាសនានៃមនុស្សជាទីស្រឡាញ់។ នៅពេលឆ្លុះបញ្ចាំងលើដំណើរការរួមនេះ វាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ថា មានការរីកចម្រើនមួយចំនួនកើតចេញពីការចូលរួមរបស់ជនរងគ្រោះ។ ដូចដែលបានដកស្រង់នៅក្នុងការស្ទង់មតិដែលបានធ្វើឡើងដោយ Stover និងអ្នកដទៃទៀត បន្ទាប់ពីបញ្ចប់ការជំនុំជម្រះក្ដី *ឌុច* ការចូលរួមរបស់ជនរងគ្រោះក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ត្រូវបានចាត់ទុកថាការមានតម្លៃបំផុត និងមានការប្រែប្រួលមួយចំនួន ដែលសង្កត់ធ្ងន់លើការលើកទឹកចិត្តក្នុងការផ្ដល់ភ័ស្ដុតាងតំណាងឱ្យសមាជិកគ្រួសារដែលបាត់បង់ជីវិត។ (Stover et al, ៥៣៦)

សម្រង់ខាងលើនេះ គូសបញ្ជាក់ពីចំណុចដែល ការចូលរួមរបស់ជនរងគ្រោះអាចជាតម្លៃប្រែប្រួលក្នុងលក្ខណៈទាបបំផុតសម្រាប់ការចូលរួមមួយចំនួននោះ។ ទស្សនៈទាក់ទងនឹងយុត្តិធម៌ប្រែប្រួលមានតម្រូវការសម្រាប់ការផ្លាស់ប្ដូររចនាសម្ព័ន្ធនិងតាមស្ថាប័ន យុត្តិធម៌សង្គមសេដ្ឋកិច្ចនិងនយោបាយ ហើយជាប់ពាក់ព័ន្ធនឹងការទទួលស្គាល់និងដោះស្រាយតម្រូវការនិងការរំពឹងទុកយ៉ាងច្រើននៃប្រជាជនក្នុងស្រុក។ ការផ្លាស់ប្ដូរក្នុងន័យនេះ ត្រូវប្រើប្រាស់វិធីសាស្ត្រក្នុងស្រុកទៅលើយុត្តិធម៌ដែលរួមរស់ជាមួយទិដ្ឋភាពពិភពលោកនិងការអនុវត្តសំខាន់ៗ លើយុត្តិធម៌អន្តរកាល។ ក៏ប៉ុន្តែកម្រិតដែលការផ្លាស់ប្ដូរកើតឡើងលើកម្រិតធំនិងសង្គម ជាជាងគ្រាន់តែលើកម្រិតនៃបុគ្គលនីមួយៗដែលបានកំណត់ទុកដោយ Stover ត្រូវការការសង្កេតលើផលប៉ះពាល់នៃការចូលរួមរបស់ជនរងគ្រោះក្នុងរយៈពេលដ៏យូរមួយ។

អ្វីដែលការស្រាវជ្រាវថ្មីៗនេះបានរកឃើញនោះគឺថា បន្ទាប់ពីសំណុំរឿង ០០២ លទ្ធផលស្រាវជ្រាវរបស់ Stover et al. នៅមានភាពពិតប្រាកដនៅថ្ងៃនេះ៖ ការតទល់ដោយផ្ទាល់របស់ជនជាប់ចោទគឺជាកត្តាជំរុញមួយនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុង អ.វ.ត.ក។ នេះត្រូវបានបញ្ជាក់ឡើងក្នុងរយៈពេលមិនច្បាស់លាស់ ជាងក្នុងបទសម្ភាសន៍ដែលបានធ្វើឡើងដោយដើមបណ្ដឹងរដ្ឋប្បវេណីដែលបានលើកឡើងដោយពេញលេញថា៖

> ខ្ញុំបានសាកសួរពួកគេថា នៅពេលដែលអ្នកជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិតេយ្យ តើអ្នកធ្លាប់គិតពីគោលបំណងនៃការបង្កើតរបបកម្ពុជាប្រជាធិតេយ្យដែរឬទេ? ហើយអ្វីទៅជាផលប្រយោជន៍នៃកាប់សម្លាប់ប្រជាជនកម្ពុជា? តើនរណាគេជាអ្នកទទួល

> បន្ទុកលើបញ្ហានេះ? តើនរណាគេដែលស្ថិតនៅពីក្រោយនៃការកាប់សម្លាប់ប្រជាជននេះ? ទាំងនេះជាសំណួរទីមួយរបស់ខ្ញុំ។ សំណួរទីពីរគឺ ក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហេតុអ្វីបានជាអ្នកចាប់ខ្លួននិងសម្លាប់សិស្សនិស្សិត បញ្ញវន្ត និងមន្ត្រីរាជការរបបសាធារណរដ្ឋខ្មែរ? តើវាជាគោលនយោបាយនៃរបបកម្ពុជាប្រជាធិតេយ្យ ឬវាជាគោលនយោបាយរបស់ប្រទេសមហាអំណាចផ្សេងទៀតដែរឬទេ? សំណួរទីបីគឺថា បន្ទាប់ពីជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហេតុអ្វីបានជាអ្នកសម្លាប់អ្នកត្រូវជម្លៀសទាំងនោះ? ហេតុអ្វីដែលបានអ្នកធ្វើដូច្នេះដែរសូម្បីតែកុមារផងដែរ?... សំណួរទីបួនគឺ តើអ្នកធ្លាប់គិតពីព្រេងវាសនារបស់ប្រទេសកម្ពុជាដែរឬទេ នៅពេលដែលអ្នកបង្កើតមនោគមវិជ្ជាកុម្មុយនីស្តដ៏ព្រៃផ្សៃនេះ និងបង្កភាពគ្រោះថ្នាក់ដល់ប្រជាជនក្រោមការដឹកនាំរបស់ខ្លួន? សំណួរទីប្រាំ ក្នុងនាមអ្នកជាបញ្ញវន្តមួយរូបដែលបានសិក្សាពីបរទេស ហេតុអ្វីបានជាអ្នកបង្កើតទស្សនៈឡប់ឆ្កួតនេះដើម្បីសម្លាប់ប្រជាជនរបស់ខ្លួន? ដោយសារតែមនុស្សត្រូវការសិទ្ធិរបស់ខ្លួនដើម្បីរស់នៅក្នុងសង្គមមួយប្រកបដោយសេចក្តីថ្លៃថ្នូរ... ហេតុអ្វីបានអ្នកសម្លាប់ប្រជាជនទាំងនោះ? ដូច្នេះខ្ញុំចង់ឱ្យពួកគេបង្ហាញពី [ចម្លើយទាំងនោះ]។ នេះគឺជាសំណួរទាំងប្រាំដែលខ្ញុំបានសួរ នួន ជា និងខៀវ សំផន។[71]

សំណួរទាំងប្រាំនេះត្រូវបានចោទសួរទៅជនជាប់ចោទពីររូប ហើយចុងបញ្ចប់ជាពិរុទ្ធជនក្នុងសំណុំរឿង ០០២។ អ.វ.ត.ក បានផ្តល់វេទិកាមួយសម្រាប់ធ្វើការសាកសួរសំណួរទាំងនោះ។ បើទោះបីជាយ៉ាងណាក៏ដោយ កម្រិតនៃការចង់ការពិតរបស់ជនរងគ្រោះត្រូវបានបំពេញឡើងតាមធម្មតាអាស្រ័យទៅលើកម្រិតនៃព័ត៌មានដែលបានបង្ហាញដោយជនជាប់ចោទ។ ហេតុដូច្នេះហើយ នៅខណៈពេលដើមណ្តឹងរដ្ឋប្បវេណីដូចគ្នាដែលបានផ្តល់បទសម្ភាសន៍សម្រាប់ការស្រាវជាវ
បានបន្តក្នុងរយៈពេលកំណត់មួយថា៖

> ក៏ប៉ុន្តែចំណុចដ៏សំខាន់បំផុតដែលធ្វើឱ្យខ្ញុំមិនពេញចិត្តនោះគឺថា
> ពួកគេមិនបានឆ្លើយសំណួរទាំងប្រាំដែលបានចោទសួរឱ្យបានស៊ីជម្រៅនោះទេ។
> នេះមានន័យថា ពួកគេនៅតែលាក់បាំងនូវព័ត៌មានមួយចំនួន... តាមគំនិតរបស់ខ្ញុំ អ្វីដែលខ្ញុំចង់បាន គឺចង់ឱ្យពួកគេបើកចំហព័ត៌មានទាំងនោះ និងទទួលស្គាល់ថា មនុស្សជាតិត្រូវមានសេចក្តីថ្លៃថ្នូរ ហើយត្រូវយកចិត្តទុកដាក់ប្រកបដោយសីលធម៌ ហើយត្រូវសារភាពថា ទង្វើដែលពួកគេបានធ្វើទៅលើប្រជាជនកម្ពុជា មិនអាចទទួលយកបាននោះទេ។ ជាពិសេសសម្រាប់ខ្ញុំ និងឪពុកម្តាយរបស់ខ្ញុំ នេះជាសោកនាដកម្មក៏អាក្រក់បំផុត។ ខ្ញុំនៅតែមានស្លាកស្នាមនៃវិប្បដិសារី ហើយខ្ញុំមិនសប្បាយចិត្តនោះទេ ពីព្រោះឪពុកម្តាយរបស់ខ្ញុំត្រូវបានសម្លាប់នាពេលនោះ
> ហើយទិដ្ឋភាពយុត្តិធម៌សម្រាប់
> ឪពុកម្តាយរបស់ខ្ញុំហាក់ដូចជាមានភាពងងឹតនៅឡើយ។[72]

ដើមបណ្តឹងរដ្ឋប្បវេណីមួយទៀត ដែលត្រូវបានសម្ភាសន៍នៅរាជធានីភ្នំពេញមានសុទ្ធិនិយមខ្លាំងស្តីពីផលប្រយោជន៍នៃកិច្ចការស្វែងរកការពិតនៃការចូលរួមរបស់ជនរងគ្រោះ នៅចំពោះមុខ អ.វ.ត.ក

---

[71] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០២ សៀមរាប ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤) ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម។ អ្នកផ្តល់បទសម្ភាសន៍ជាបញ្ញវន្តអំឡុងរបបខ្មែរក្រហម។
[72] ដូចខាងលើ។

ដែលលើកឡើងថា៖

> ខ្ញុំបានស្វែងយល់ជាច្រើនពីសវនាការនេះ។ វាបង្ហាញឱ្យខ្ញុំឃើញយ៉ាងច្បាស់ពីមនោគមវិទ្យាបដិវត្តន៍ ដែលយើងមិនធ្លាប់បានដឹងកាលពីមុនមក។ ឥឡូវនេះវាបានធ្វើឱ្យយើង ជាជនរងគ្រោះ ដឹងពីគោលនយោបាយខ្មៅងងឹត និងសកម្មភាពឃោរឃៅរបស់អ្នកដែលទទួលខុសត្រូវក្នុងរបបកម្ពុជាប្រជាធិតេយ្យ។ យើងមិនដែលដឹងពីបញ្ហានេះនោះទេ ក៏ប៉ុន្តែឥឡូវនេះ យើងបានដឹងវាហើយពីអ.វ.ត.ក។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ អ.វ.ត.ក ដែលជួយខ្ញុំឱ្យបានឃើញពីសកម្មភាពទាំងនោះនៅក្នុងរបបកម្ពុជាប្រជាធិតេយ្យ។[73]

ស្រដៀងគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីមកពីខេត្តកំពង់ចាមបានច្រានចោលតាមបែបវិជ្ជមានទៅលើយន្តការស្វែងរកការពិត
ដែលបានផ្តល់ឡើងតាមរយៈការចូលរួមរបស់ជនរងគ្រោះនៅអ.វ.ត.ក
ដែលគូសបញ្ជាក់ពីព័ត៌មាននៅមានកម្រិតខ្លាំងដែលមាន ក្នុងអំឡុងរបបខ្មែរក្រហម និងឆ្នាំបន្ទាប់រហូតដល់ថ្ងៃនេះ៖

> ពាក់ព័ន្ធនឹងការពិតនេះដែរ មុនពេលដែលយើងមាន DC-CAM[74] ដែលជាទីកន្លែងយើងអាចសិក្សាស្វែងយល់ពីការពិតបាន។ ក៏ប៉ុន្តែ ចាប់តាំងពីការបង្កើតវាមកទាំងតុលាការ ក៏ដូចជា ថៅក្រមស៊ើបអង្កេតបានព្យាយាមស្វែងរកការពិតផងដែរ។ នៅពេលនោះ យើងមិនបានដឹងពីអ្វីដែលខៀវ សំផន អៀង សារី និងអៀងធីរិទ្ធបានធ្វើនោះឡើយ ក៏ប៉ុន្តែបន្ទាប់មក ខ្ញុំបានស្វែងយល់ពីបញ្ហាទាំងនោះតាមរយៈតុលាការនេះ៖ មេដឹកនាំទាំងនោះសុទ្ធតែទទួលបានការអប់រំខ្ពស់ ក៏ប៉ុន្តែហេតុអ្វីបានជាពួកគេប្រព្រឹត្តអំពើដ៏ឃោរឃៅក្នុងការដឹកនាំប្រទេសបែបនេះទៅវិញ?

ការស្វែងយល់ឱ្យកាន់តែច្បាស់បន្ថែមទៀតពីកម្លាំងនៃអំណាច មូលដ្ឋានគាំទ្រមនោគមវិជ្ជា និងរចនាសម្ព័ន្ធនយោបាយរបស់ខ្មែរក្រហម ត្រូវបានផ្តល់ឱ្យតាមរយៈការរួមបញ្ចូលគ្នានូវមធ្យោបាយពាក់ព័ន្ធពីរយ៉ាង៖ ការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការសវនាការ ដូចជាទំនាក់ទំនងគ្នាទៅវិញទៅមកជាមួយមេធាវី ហើយនិងព័ត៌មានដែលបានទទួលពី VSS អាដហុកនិង NGO។ នេះជាប្រធានបទធម្មតាក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ ដែលបានបង្ហាញឡើងដោយឧទាហរណ៍ដែលការចាប់អារម្មណ៍ត្រូវបានផ្តោតទៅលើកម្រិតនៃការឈឺចុកចាប់ក្នុងរបបនេះ៖

> ជាលទ្ធផលនៃតុលាការនេះ ខ្ញុំបានស្វែងយល់កាន់តែច្បាស់។ មានអំពើឃោរឃៅមួយចំនួនដែល ខ្ញុំបានស្វែងយល់ពីសវនាការកាត់ក្តីនេះ។ កាលពីមុន ខ្ញុំបានដឹងពីអ្វីដែលខ្ញុំបានឆ្លងកាត់ ហើយមនុស្សមួយចំនួននៅជុំវិញខ្ញុំ។ តាមរយៈការចូលរួមក្នុងសវនាការនេះ ខ្ញុំដឹងពីរឿងរ៉ាវរបស់មនុស្សជាច្រើននៅទូទាំងប្រទេសដែលទទួលការឈឺចាប់ចេញពីអំពើឃោរឃៅដែលបានធ្វើឡើងដោយខ្មែរក្រហម ជាពិសេសអំពើហិង្សាផ្លូវភេទ ក្នុងសំណុំរឿង០០២ ដែលក្នុងនោះខ្ញុំក៏ជាជនរងគ្រោះផងដែរ។

[73] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។
[74] សូមចូលមើលទៅកាន់៖ http://www.dccam.org/ (បានចូលទៅកាន់ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥)។

ទស្សនៈបែបនេះ ត្រូវបានលើកបង្ហាញឡើងយ៉ាងរឹងមាំនៅក្នុងសម្រង់ខាងក្រោមនេះចេញពីបទសម្ភាសន៍ដែលបានធ្វើឡើងនៅភ្នំពេញជាមួយដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដែលបានសម្តែងមតិថា ការចូលរួមក្នុងសវនាការជំនុំជម្រះនេះ៖

> បានជួយឱ្យមានការយល់ដឹងបន្ថែមទៀតស្តីពីរបបខ្មែរក្រហម។ កាលពីមុន យើងមិនបានដឹងពីរបបខ្មែរក្រហមច្បាស់លាស់នោះទេ។ ក្រោមការដឹកនាំក្នុងរបបលន់ ណុល យើងគ្រាន់តែឮពាក្យ 'ខ្មែរក្រហម' ប៉ុណ្ណោះ ក៏ប៉ុន្តែយើងមិនបានដឹងពីមេដឹកនាំនាសម័យនោះឡើយ ដូចជា អៀង សារី ប៉ុល ពត និងនួន ជាជាដើម។ បន្ទាប់ពីការបង្កើត អ.វ.ត.ក នេះរួចហើយ យើងបានដឹងច្រើនជាងពីមុន ពីព្រោះតុលាការនេះបានបង្ហាញពីមេដឹកនាំសម័យខ្មែរក្រហមឱ្យពួកយើងបានឃើញ ហើយឥឡូវនេះ យើងដឹងថា នរណាជាអ្នកបញ្ជាឱ្យមានការកាប់សម្លាប់ដោយចេតនាលើទៅប្រជាពលរដ្ឋស្លូតត្រង់... នៅពេលនោះ យើងក៏បានឮពាក្យ 'អង្គការ' ប៉ុន្តែយើងមិនបានដឹងថា 'អង្គការ' ជានរណា ឬជាអ្វីនោះទេ។[75]

ដូច្នេះ ក្នុងសំណុំរឿងជាច្រើន ការស្វែងរកការពិត បានចោទជាសំណួរថ្មីៗ ហើយវាអាចត្រូវបានចោទសួរថាតើសំណួរទាំងអស់នោះ ពិតជាសមស្របទៅតាមសវនាការជំនុំជម្រះនៅក្នុងអ.វ.ត.ក ដែរឬទេ។ មិនថាគោលបំណងនៃការស្វែងរកការពិត ដែលចាត់ទុកថាជាផលប៉ះពាល់នៃគម្រោងដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានបង្ហាញដោយស្មើភាពគ្នាក្នុងវេទិកាក្រៅពីផ្នែកនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅតែជាបញ្ហានៅឡើយ។

ក៏ប៉ុន្តែអ្វីដែលច្បាស់នោះគឺថា ការស្វែងរកការពិតតម្រូវឱ្យមានកម្រិតសមរម្យនៃការគាំទ្រជនរងគ្រោះដែលត្រូវចូលរួមដោយភាគីថៅក្រម និងមិនមែនថៅក្រម។ ដូចដែលបានបញ្ជាក់ពីខាងលើ អង្គការដូចជាអាដហុក CDP LAC និង TPO មានសារៈសំខាន់ណាស់ក្នុងបទប្បញ្ញត្តិនៃសេវាគាំពារជនរងគ្រោះ។ VSS នៅអ.វ.ត.ក រួមមានមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានការទទួលខុសត្រូវចំពោះការចែករំលែកព័ត៌មានទៅដើមបណ្តឹងរដ្ឋប្បវេណី និងបានរៀបចំសិក្ខាសាលានៅនឹងកន្លែងដែលជាផ្នែកមួយនៃកម្មវិធីចុះតាមមូលដ្ឋាន។

ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បាននិយាយពីការចូលរួមក្នុងន័យវិជ្ជមាន ដែលគូសបង្ហាញពីការងារសំខាន់ៗដែលបានធ្វើឡើងដោយកម្មវិធីចុះតាមមូលដ្ឋាន៖

> កាលពីមុន ខ្ញុំមិនបានដឹងច្រើនទេ ក៏ប៉ុន្តែចាប់តាំងពីពេលដែលខ្ញុំបានចាប់ផ្តើមចូលរួមក្នុងសិក្ខាសាលានៅកន្លែងជាច្រើនមក... ខ្ញុំមានការយល់ដឹងច្រើនអំពីសកម្មភាព [របស់មេដឹកនាំសម័យខ្មែរក្រហម]។ នៅពេលដែលខ្ញុំបានចូលទៅមើលកន្លែងធ្វើទារុណកម្មផ្សេងៗដូចជា គុកទួលស្លែង ខ្ញុំបានឃើញវាដោយភ្នែកផ្ទាល់របស់ខ្ញុំ។ គេក៏បាននាំខ្ញុំទៅមើលនៅជើងឯកទៀតដែរ។ កាលពីមុន ខ្ញុំមិនបានដឹងពីបញ្ហានេះនោះទេ។ ខ្ញុំមិនដែលដឹងថាកន្លែងធ្វើទារុណកម្មនៅឯណាឡើយ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំបានដឹង និងឃើញច្រើនជាងមុន។[76]

---

[75] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០២ ភ្នំពេញ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤)។ "Angkar" ក្នុងអត្ថបទនេះជាពាក្យខ្មែរមានន័យថា "អង្គការ" និងតំណាងឱ្យបក្សកម្មុនិសនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ការសរសេរ "Angka" ក៏មានផងដែរពេលខ្លះ។

[76] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។

បើទោះបីជាយ៉ាងក៏ដោយ នេះមិនមែនគ្រាន់តែដើមបណ្តឹងរដ្ឋប្បវេណីនោះទេដែលសង្កត់ធ្ងន់លើសារៈសំខាន់សម្រាប់ពួកគាត់ដើម្បីស្វែងរកការពិតតាមរយៈសវនាការជំនុំជម្រះ។ ក្នុងនាមជាអ្នកផ្តល់បទបសម្ភាសន៍ដែលមិនបានដាក់ពាក្យប្តឹង ឬស្នើដើម្បីធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងៈ

> នេះជាលើកទីពីររបស់ខ្ញុំហើយដែលបានចូលរួមក្នុងការជំនុំជម្រះក្តីពីសាលាសវនាការសាធារណៈ។ ខ្ញុំបានរៀនសូត្រច្រើនពីប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធនៃរបបខ្មែរក្រហម ហើយការលើកទឹកចិត្តនៅពីក្រោយរបបនេះ... ខ្ញុំបានទទួលផលប្រយោជន៍ពីការចូលរួមក្នុងសវនាការនេះ បើទោះបីជាខ្ញុំមិនអាចជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ។[77]

នេះក៏ត្រូវបានគាំទ្រលើកឡើងនៅក្នុងបទសម្ភាសន៍ផ្សេងទៀតជាមួយជនរងគ្រោះដែលមិនបានចូលរួម ដូចដែលសម្រង់ខាងក្រោមនេះបានបង្ហាញៈ -

> សម្រាប់ខ្ញុំ វាមានសារៈសំខាន់ណាស់ចំពោះការមានវត្តមានក្នុងតុលាការនេះដើម្បីចូលរួមក្នុងការជំនុំជម្រះក្តី។ អង្គភាពគាំពារជនរងគ្រោះបានធ្វើការងារយ៉ាងល្អប្រសើរក្នុងការរក្សាទំនាក់ទំនងជាមួយជនរងគ្រោះ ដូចជារូបខ្ញុំផ្ទាល់ ពីព្រោះនេះបានជួយអប់រំប្រជាជនកម្ពុជាស្តីពីប្រវត្តិសាស្ត្រដ៏ជូរចត់ជារួមគ្នានេះ។ ក៏ប៉ុន្តែការមិនអាចសួរសំណួរទៅជនជាប់ចោទបាន គឺជាចំណុចអវិជ្ជមាន ជាពិសេសដែលខ្ញុំហាក់មិនយល់ពីចំណុចពិបាកនេះ។[78] -

ចំណុចពីរយ៉ាងមានលក្ខណៈគួរឱ្យកត់សម្គាល់ស្តីពីសម្រង់ខាងលើ។

ទីមួយ ការស្វែងការពិតអាចត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយនៃការចូលរួមជាជាងក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី។ ក៏ប៉ុន្តែ ភាពអសកម្មដែលមានជាប់ពាក់ព័ន្ធក្នុងការចូលរួមដោយប្រយោលនោះ ក្នុងនាមជាអ្នកស៊ើបអង្កេតការកាត់ក្តី កំណត់ពីសមត្ថភាពរបស់ជនរងគ្រោះដើម្បីសាកសួរពីសំណួរទៅជនជាប់ចោទ ហើយជាទូទៅចូលរួមយ៉ាងសកម្មបន្ថែមទៀតក្នុងការជំនុំជម្រះក្តីនេះ។ ចំណុចទីពីរដែលត្រូវកត់សម្គាល់នោះគឺថា បទសម្ភាសន៍ដែលបានធ្វើឡើងជាមួយទាំងដើមបណ្តឹងរដ្ឋប្បវេណីនិងជនរងគ្រោះដែលមិនបានចូលរួម មិនបានបង្ហាញថាការមិនរាប់បញ្ចូលមួយចំនួនពីការចូលរួមដោយផ្ទាល់ក្នុងការជំនុំជម្រះក្តីដែលនាំឱ្យមានការអាក់អន់ចិត្តលើផ្នែករបស់អ្នកដទៃឡើយ។

សម្រង់សម្តីខាងលើនេះ បង្ហាញយ៉ាងច្បាស់ពីសារៈសំខាន់សម្រាប់ជនរងគ្រោះដើម្បីសិក្សាពីការពិតនិងស្វែងយល់ពីអតីតកាល។ អ្នកផ្តល់បទសម្ភាសន៍ទាំងអស់ ដូចជាដើមបណ្តឹងរដ្ឋប្បវេណីដើមបណ្តឹងជាជនរងគ្រោះ និងអ្នកមិនបានចូលរួម បានចាត់ទុក អ.វ.ត.ក ជាការវិវត្តដ៏សំខាន់មួយក្នុងការស្វែងរកការពិត។ ជាធម្មតា ការចូលរួមដោយផ្ទាល់តាមរយៈការសាកសួរសំណួរទាំងឡាយទៅជនជាប់ចោទ ត្រូវបានកម្រិតឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូច។ នេះនឹងគូសបញ្ជាក់ពីមូលដ្ឋានជាសមូហភាពក្នុងការស្វែងរកយុត្តិធម៌ និងម្យ៉ាងទៀតជាមូលដ្ឋានជាលក្ខណៈបុគ្គលក្នុងលក្ខណៈស្វែងរកការពិតផ្ទាល់ខ្លួនតាមរយៈការប្រឈមដោយផ្ទាល់ជា

[77] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៤)។
[78] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៤)។

មួយនឹងជនជាប់ចោទ។ ទិដ្ឋភាពដែលបញ្ជាក់ដោយភាពគឺដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងជាជនរងគ្រោះ ដូចដែលបានដកស្រង់ពីខាងលើ បង្ហាញថា បញ្ហានៃការស្វែងរកការពិត ការរៀបរាប់រឿង និងការអប់រំពិភពលោកពីភាពរន្ធត់និងអំពើឃោរឃៅនៃរបបខ្មែរក្រហម មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។ ឥឡូវនេះ ការផ្តោតសំខាន់នៃរបាយការណ៍នឹងត្រឡប់ទៅជាបញ្ហាពាក់ព័ន្ធទាំងនេះ។

### ៥.៤ ការរៀបរាប់រឿងរ៉ាវ

ខណៈដែលទំហំនៃការស្វែងរកការពិត បង្ហាញពីទិដ្ឋភាពផ្តោតលើលទ្ធផលនៃការចូលរួមរបស់ជនរងគ្រោះក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី *ការរៀបរាប់រឿង*នេះឆ្លុះបញ្ចាំងពីទស្សនៈផ្អែកលើធាតុចូលបន្ថែមទៀត ពោលគឺសារៈសំខាន់ដែលកម្រត្រូវបានលើកឡើង។ នៅពេលដែលអ្នកបច្ចេកទេសខាងមនោវិភាគ DoriLaub បានលើកអំណះអំណាងថា 'រឿងរ៉ាវទាំងនោះមានជាប់ជិតដានក្នុងអ្នកដែលនៅរស់រានមានជីវិត តម្រូវការដ៏ចាំបាច់ដែលត្រូវរៀបរាប់ និងដឹងពីរឿងនោះ') (Laub, ១៩៩២: ៩៨)។ ឯកសារយោងលើតម្រូវការក្នុងការបញ្ជាក់ពីបទពិសោធន៍ក្នុងរបបខ្មែរក្រហមត្រូវបានរកឃើញស្ទើរគ្រប់បទសម្ភាសន៍ទាំងអស់ដែលបានធ្វើឡើងសម្រាប់ការស្រាវជ្រាវនេះ តាមផលប៉ះពាល់ ជាជាងគ្រាន់តែរៀបរាប់ឡើង។ នៅពេលអ្នកផ្តល់បទសម្ភាសន៍ដែលបានពណ៌នាលើចំណុចជាក់លាក់នេះ បានពន្យល់ថា៖

> នៅពេលផ្តល់សក្ខីកម្មចំពោះមុខតុលាការ ដំបូង ខ្ញុំមានមោទនភាពណាស់ពីព្រោះក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់ សាលាក្តីបានជ្រើសរើសខ្ញុំដើម្បីផ្តល់សក្ខីកម្ម និងពណ៌នាពីការឈឺចុកចាប់ និងការពិបាករបស់ខ្ញុំក្នុងរបបខ្មែរក្រហមទៅឱ្យសាធារណៈជនដឹងឮ ដូច្នេះពួកគេបានដឹងពីការឈឺចុកចាប់របស់ប្រជាពលរដ្ឋនាសម័យនោះ។ ខ្ញុំមានមោទនភាព ពីព្រោះខ្ញុំបានពណ៌នាពីការឈឺចុកចាប់នេះទៅតុលាការចំពោះមុខជនជាប់ចោទ។ ខ្ញុំមានមោទនភាពនិងក្តីរំភើបយ៉ាងខ្លាំងដែលបានតំណាងឱ្យជនរងគ្រោះទាំងអស់។[79]

នេះមិនមែនចង់និយាយថា ការរៀបរាប់រឿង បើទោះបីជាភាពចាំបាច់នៃចិត្តវិជ្ជា ជារឿយៗមានភាពងាយស្រួល ហើយការផ្តល់សក្ខីកម្មក្នុងតុលាការ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីសម្រាប់បញ្ហានោះក៏ដោយ គឺនៅតែមានភាពលំបាកទៀត។ ការឆ្លើយតបលើចិត្តសីរិរៈ-បាតុភូតដដែលនៅពេលយើងពណ៌នាពីសម័យប៉ះទង្គិចផ្លូវចិត្តពីអតីតកាល អ្នករស់រានមានជីវិតទាំងនោះជាធម្មតាមានប្រតិកម្មខាងផ្លូវកាយ ក៏ដូចជាផ្លូវចិត្ត ត្រូវបានពណ៌នាក្នុងរឿងអក្សរសាស្ត្រ (សូមមើលឧទាហរណ៍ Stover, ២០១១: ៥២៤)។ ការលំបាកនៃការវិលត្រឡប់ក្នុងលក្ខណៈនេះ និងការរស់នៅសាជាថ្មីក្នុងពេលអតីតកាល អាចក៏ត្រូវបានសង្កេតក្នុងបទសម្ភាសន៍ដែលបានធ្វើឡើងសម្រាប់ការស្រាវជ្រាវនេះ។ ហេតុដូច្នេះ ដូចដែលដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា៖

> ខ្ញុំមិនចង់រំឭកពីរឿងរបស់ខ្ញុំទេ។ ខ្ញុំមិនចង់ស្រមើស្រមៃម្តងទៀតទេពីអ្វីដែលបានកើតឡើងក្រោមការដឹកនាំរបស់របបខ្មែរក្រហម នៅពេលដែលខ្ញុំគិតថាជីវិតទាំងអស់របស់ខ្ញុំគឺគ្មានន័យសោះឡើយ។ ខ្ញុំគិតថា ខ្ញុំនឹងព្យាយាមស៊ូទ្រាំលាក់បាំងវា

[79] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។

> រហូតដល់ពេលខ្ញុំស្លាប់។ នេះគឺជាការគិតរបស់ខ្ញុំ។[80]

ក្រៅពីការលំបាកក្នុងការផ្តល់សក្ខីកម្ម សារៈសំខាន់របស់វា ជាទូទៅត្រូវបានទទួលស្គាល់ដោយជនរងគ្រោះនិងភាគីដទៃក្នុងសវនាការ។ ដូចដែលកត់សម្គាល់ដោយ de Hemptinne (២០១០:១៦៧)៖

> ការផ្តល់សិទ្ធិដល់ជនរងគ្រោះដើម្បីបង្ហាញពីការឈឺចុកចាប់និងទាមទារសំណងអាចជួយជនរងគ្រោះឱ្យធូរស្បើយពីបទសោធន៍ដ៏លំបាកនោះ។ ក្រៅពីគោលបំណងទាមទារសំណង ការចូលរួមរបស់ជនរងគ្រោះក៏អាចដើរតួជាតម្លៃនិមត្តិរូបផងដែរ។ ការផ្តល់ឱ្យជនរងគ្រោះនូវ 'ឱកាសបញ្ចេញមតិ' នៅក្នុងការជំនុំជម្រះ អាចធ្វើឱ្យការងាររបស់សាលាក្តីមានតម្លាភាព និងអាចចូលរួមបានបន្ថែមទៀតពីជនរងគ្រោះ។

ហេតុដូច្នេះ មានគោលបំណងនិងតម្លៃផ្សេងៗដែលការចូលរួមរបស់ជនរងគ្រោះត្រូវបានរៀបចំឡើងដោយពាក់ព័ន្ធដោយផ្ទាល់ទៅនឹងតម្រូវការរបស់ជនរងគ្រោះក្នុងការចែករំលែករឿងរ៉ាវរបស់ខ្លួន។ ទីមួយ ការប្រាប់ទៅតុលាការនិងពិភពលោកទាំងមូលអំពីបទពិសោធន៍របស់ពួកគាត់គឺជាផ្នែកមួយនៃដំណើរការធ្វើឱ្យប្រសើរឡើងរបស់ជនរងគ្រោះ ឬអ្វីដែល de Hemptinne (២០១០) បានហៅថា 'គោលបំណងទាមទារសំណង'។ ចំណុចដែលពាក់ព័ន្ធខាងលើនេះគឺជាគំនិតដែលសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះត្រូវបានណែនាំដោយការផ្តល់ពួកគាត់នូវសិទ្ធិចូលរួមនៅចំពោះមុខតុលាការ ដែលចាត់ទុកពួកគាត់ជាអ្នកចូលរួមយ៉ាងសកម្មជាជាងកម្មវត្ថុតូចតាចនៃសំណួរ៖ យើងអាចហៅវាបានថាជា ទស្សនៈប្រកបដោយសេចក្តីថ្លៃថ្នូរដោយពាក់ព័ន្ធនឹងសិទ្ធិក្នុងការរៀបរាប់រឿង ដែលជាសមាសភាពដ៏សំខាន់នៃភាពថ្លៃថ្នូររបស់មនុស្ស បន្ទាប់ពីទទួលបានការរងគ្រោះយ៉ាងធ្ងន់នេះ។

គោលបំណងដែលចាត់ទុកថានៅឆ្ងាយ មានតម្លៃពីខាងក្នុង។ ក៏ប៉ុន្តែមានមូលហេតុដ៏សំខាន់ដែលអនុញ្ញាតឱ្យជនរងគ្រោះបញ្ចេញមតិពីរឿងរ៉ាវរបស់ខ្លួនអាចទទួលបានផលប្រយោជន៍។ នេះរួមមានទាំងតម្លៃនិមិត្តរូបនៃការចូលរួមរបស់ជនរងគ្រោះ ដែល de Hemptinne (២០១០) បានលើកអំណះអំណាងយ៉ាងត្រឹមត្រូវ លើកកម្ពស់តម្លាភាពនិងការទទួលបាន ក្នុងផ្នែកមួយនៃសាលាក្តីនេះ។ វាក៏នាំទៅរកចំណុចក្រោយដែលជាការឆ្ពោះទៅរកការផ្តល់សក្ខីកកម្មដោយផ្ទាល់របស់ជនរងគ្រោះ -មិនថាជា សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីឡើយ ជួយធ្វើឱ្យប្រសើរឡើងនូវការពេញចិត្តរបស់តុលាការទៅអ្វីដែលបានកើតឡើងអំឡុងរបបខ្មែរក្រហម។ នៅពេលសហមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានលើកអំណះអំណាងនៅក្នុងបទសម្ភាសន៍ដែលត្រូវបានធ្វើឡើងដាច់ដោយឡែកនោះ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី 'នាំជីវិតទៅហេតុការណ៍ពិត'។[81] មេធាវីម្នាក់ទៀតបានលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណី 'លើកយករឿងអ្វីមួយដែលខុសប្លែកជាតួឯកនៃហេតុការណ៍ពិត'

---

[80] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ភ្នំពេញ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤)។

[81] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០១ និង០០២ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤)។

ហើយអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីលើកមក គឺជាអ្វីដែលពួកគេបានទទួលការឈឺចុកចាប់ដែលពួកគេកំពុងស្វែងរកការចោទប្រកាន់ និងស្នើសុំសំណង។'[82]

គោលបំណងនិងតម្លៃដ៏សំខាន់នេះ ទាំងពីខាងក្នុង ក៏ដូចជាតាមលក្ខខណ្ឌគួរត្រូវបានចងចាំក្នុងការវាយតម្លៃលើកម្រិតដែលរបបនៃការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក ឆ្លើយតបទៅនឹងការរំពឹងទុក និងធានាថា សំឡេងរបស់ពួកគេត្រូវបានដឹងឮ។ ផ្ទុយពីបំណងប្រាថ្នាដ៏ធំធេងរបស់ជនរងគ្រោះក្នុងការប្រឈមនឹងជនជាប់ចោទ និងធ្វើឱ្យសំឡេងគេត្រូវបានដឹងឮ ការធ្វើដូច្នេះនៅក្នុងបរិបទនៃនីតិវិធីនៃសវនាការជំនុំជម្រះក្តីនេះ មិនបានផ្តល់នូវវេទិកាដើម្បីឱ្យជនរងគ្រោះទាំងនោះបានចែករំលែកពីរឿងរ៉ាវដោយសេរីនោះទេ។ សាលសវនាការត្រូវបានដេញដោលដោយកម្រិតពីខាងដើម។ ជាធម្មតា ដើមបណ្តឹងរដ្ឋប្បវេណីនឹងឆ្លើយនូវសំណួរជាក់លាក់ដែលបានចោទលើពួកគេ ជាជាងបង្ហាញពីការរៀបរាប់ពីរឿងផ្ទាល់ខ្លួន និងទាក់ទង។ ទស្សនទាននេះ ត្រូវបានលើកឡើងក្នុងបទសម្ភាសន៍ភាគច្រើន និងបញ្ជាក់ឡើងក្នុងលក្ខខណ្ឌម៉ឺងម៉ាត់ក្នុងសម្រង់ពីបទសម្ភាសន៍ដែលបានធ្វើជាមួយអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរ ស-២១ និងអតីតសិល្បៈករ៖

> បាទ ខ្ញុំមានឱកាសក្នុងការរៀបរាប់ពីរឿងរ៉ាវរបស់ខ្ញុំ។ ក៏ប៉ុន្តែវាមានរយៈពេលខ្លីណាស់។ ទាក់ទងនឹងបញ្ហានេះដែរ ក្នុងការជំនុំជម្រះក្តីដំបូងនេះ [ករណីសំណុំរឿង០០១] ខ្ញុំបានជម្រាបតុលាការពីអ្វីដែលខ្ញុំធ្លាប់បានឆ្លងកាត់អំឡុងរបបប៉ុល ពត។ ខ្ញុំត្រូវគេយកទៅធ្វើទារុណកម្ម ដោយទាំងមិនបានធ្វើអ្វីខុសទាល់តែសោះ… ដូច្នេះ ខ្ញុំពិតជាមានការសោកស្តាយខ្លាំង ដោយសារតែមិនមានយុត្តិធម៌សម្រាប់រូបខ្ញុំ។[83]

ដូច្នេះ ការស្រាវជ្រាវនេះ បង្ហាញថា ការរៀបរាប់រឿងរ៉ាវរបស់ពួកគេកើតមានឡើងក្នុងម៉ាទ្រីសដែលមានច្រើនផ្នែក ជាមួយដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានអនុញ្ញាតឱ្យផ្តល់ភ័ស្តុតាងដែលបានមកពីសក្ខីកម្មនេះ ដែលមានការជាប់ពាក់ព័ន្ធយ៉ាងខ្លាំងក្នុងនីតិវិធីនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត មានឱកាសកម្រិតខ្លាំងដើម្បីរៀបរាប់ពីរឿងរ៉ាវ និងដើម្បីធ្វើឱ្យសំឡេងរបស់ពួកគេបានដឹងឮ។ តាមរយៈការដាក់ជូន សកម្មភាពនេះត្រូវបានឡើងដោយសហមេធាវីនាំមុខ ដែលផ្ទុយទៅនឹងការផ្តល់ភ័ស្តុតាងដោយផ្ទាល់។ ក៏ប៉ុន្តែ ដើមបណ្តឹងជាជនរងគ្រោះដែលបានហៅឡើងដោយភាគីម្ខាងទៀតដើម្បីផ្តល់នូវភ័ស្តុតាងក្រោមពាក្យសម្បថក្នុងនាមជាសាក្សី មិនត្រូវបានអនុញ្ញាតក្នុងការផ្តល់សក្ខីកម្មក្នុងតុលាការដោយអ.វ.ត.ក នោះទេ។ ដូច្នេះ សហមេធាវីនាំមុខ ក៏ដូចជាមេធាវីនីមួយៗ បានចូលរួមយ៉ាងខ្លាំងក្នុងការផ្តល់ព័ត៌មានចាំបាច់ ក៏ដូចការរៀបចំដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការផ្តល់សក្ខីកម្មរបស់ពួកគេនៅចំពោះមុខតុលាការ។

## ៥.៥ ការអប់រំពិភពលោក

តម្លៃអប់រំនៃការផ្តល់សក្ខីកម្មរបស់ជនរងគ្រោះ ត្រូវបានចាត់ទុកជាទិដ្ឋភាពដ៏សំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលដើមបណ្តឹងរដ្ឋប្បវេណី

[82] កិច្ចសន្ទនាជាមួយ Elisabeth Simonneau-Fort, សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ.វ.ត.ក ក្នុងសំណុំរឿង០០២/០១ កំណត់សម្គាល់លើសំណុំរឿងជាមួយអ្នកនិពន្ធ។

[83] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០១ និង០០២ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤)។

ដែលគេបានស្គាល់ពីសំឡេងដ៏ខ្លាំងក្លាក្នុងការគាំទ្រសិទ្ធិនិងតម្រូវការរបស់ជនរងគ្រោះ បានលើកអំណះអំណាងដោយជាប់ពាក់ព័ន្ធនឹងការចូលរួមរបស់ជនរងគ្រោះនៅអ.វ.ត.ក ថា៖

> គំនិតទាំងស្រុង គឺថាលោកអ្នកអាចធ្វើការរៀបរាប់ ចងក្រងឯកសារកាលប្បវត្តិកំណត់ត្រាក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ដែលអាចបានស្វែងយល់ពីសមាជិកគ្រួសារកូនៗរបស់ពួកគេ និងពិភពលោកទាំងមូល។[84]

ជាធម្មតា គំនិតនៃការអប់រំពិភពលោកនេះ និងជាពិសេសនៃការចែករំលែកនូវចំណេះដឹងពីអំពើឃោរឃៅនៃរបបខ្មែរក្រហមទៅកូនចៅជំនាន់ក្រោយ នៅរក្សាភាពចាំបាច់នៃព្រំដែនរបស់សាលតុលាការ។ វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការស៊ើបអង្កេតលើចិត្តសាស្ត្រ ដែលមនុស្សគ្រប់មានអារម្មណ៍ចាំបាច់ក្នុងរៀបរាប់រឿងរ៉ាវរបស់ខ្លួន។ ក្នុងនាមជាអតីតគ្រូបង្រៀនម្នាក់និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ បានមានប្រសាសន៍ថា៖

> ខ្ញុំអាចបង្វែរពីកំហឹងរបស់ខ្ញុំទៅជាការរៀបរាប់រឿងរ៉ាវវិញ។ នៅពេលដែលខ្ញុំមានពេលទំនេរនាពេលយប់ ខ្ញុំបានប្រាប់ចៅៗរបស់ខ្ញុំពីអ្វីដែលបានកើតឡើងក្នុងរបបខ្មែរ ក្រហម។ ក្នុងជំនាន់នេះ ក្មេងៗសម័យឥឡូវមួយចំនួន មិនជឿថា ប្រជាជនសម័យនោះអាចនៅរស់រានមានជីវិតបាន ដោយគ្រាន់តែហូបបបរមួយកូនចានសម្រាប់អាហារមួយពេល ហើយនៅតែអាចធ្វើការបានពេញមួយថ្ងៃ។ នៅពេលដែលមានការប្រជុំដើមបណ្តឹងរដ្ឋប្បវេណី និងការប្រជុំក្នុងតំបន់ ខ្ញុំបាននឹកឃើញពីរឿងរ៉ាវទាំងនោះ ហើយខ្ញុំដឹងថា សព្វថ្ងៃនេះ ខ្ញុំមានអារម្មណ៍ស្ងប់ហើយ។ មិនដូចកាលពីមុន នៅពេលដែលយើងនឹកឃើញពីអ្វីដែលយើងបានឆ្លងកាត់ យើងពិតជាចង់សម្លាប់ពួកទាំងនោះណាស់ ឬដោយខ្លួនយើងផ្ទាល់។ ការនឹកឃើញពីព្រឹត្តិការណ៍ទាំងនោះធ្វើឱ្យយើងមានការឈឺចាប់យ៉ាងខ្លាំង។[85]

ក៏ប៉ុន្តែ អ.វ.ត.ក បានផ្តល់នូវទីកន្លែងជំនុំជម្រះផ្លូវការ និងតាមស្ថាប័នសម្រាប់តម្លៃអប់រំលើសក្តីកម្មរបស់ជនរងគ្រោះ ហើយទិដ្ឋភាពនៃការចូលរួមរបស់ជនរងគ្រោះនេះ គឺជាការនាំមុខគេនៃការលើកទឹកចិត្ត ដើម្បីចូលរួមជាផ្នែកមួយនៃអង្គសវនាការរបស់មនុស្សច្រើនដែលបានផ្តល់បទសម្ភាសន៍។ ហេតុដូច្នេះ នៅក្នុងបរិបទនៃសំណើទាមទារសំណងដែលបានដាក់ព្រឹត្តិការណ៍របបខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិរបស់ប្រទេសកម្ពុជា អ្នកចូលរួមក្នុងការប្រជុំក្រុមគោលដៅនៅវត្តធនសេរី បានលើកឡើងថា៖

[84] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០១ ភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៤)។
[85] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។

> តាមរយៈការដាក់បញ្ចូលប្រវត្តិសាស្ត្រនេះក្នុងកម្មវិធីសិក្សា ក្មេងៗជំនាន់ក្រោយនឹងបានដឹងពីភាពឃោរឃៅដែលបានកើតឡើងអំឡុងរបបខ្មែរក្រហម... ខ្ញុំក៏ចង់ដាក់បញ្ចូលការវិនិច្ឆ័យរបស់តុលាការដែលបានធ្វើឡើងដោយ អ.វ.ត.ក និងសំណងដែលត្រូវផ្តល់ឱ្យជនរងគ្រោះ ដូច្នេះក្មេងៗនឹងដឹងពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម និងលទ្ធផលនៃសវនាការលើឧក្រិដ្ឋជនទាំងនេះ។[86]

មតិយោបល់នេះ បានលើកឡើងក្នុងចំណោមអ្នកចូលរួមទាំងអស់គ្នានៃក្រុមគោលដៅ។ សារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រនិងការអប់រំមានពីរយ៉ាង ដែលការដឹងពីអតីតកាលមានតម្លៃពីខាងក្នុង ដើម្បីស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន។ ការស្វែងយល់ពីប្រវត្តិសាស្ត្រមានគោលបំណងបន្តក្នុងការអនុញ្ញាតឱ្យមនុស្សទាំងឡាយកំណត់ពីអនាគតរបស់ខ្លួនបាន។ នៅក្នុងបរិបទបច្ចុប្បន្ននេះ វាបង្ហាញពីគោលបំណងទប់ស្កាត់ជាសំខាន់ក្នុងការធានាថាអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងដោយពួកខ្មែរក្រហមនេះ មិនត្រូវកើតមានឡើងម្តងទៀតនោះទេ ដែលមានការបញ្ជាក់ពីសម្រង់ខាងក្រោម៖

> នៅពេលដែលតុលាការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះហើយ ខ្ញុំនឹងសប្បាយពីព្រោះវាជួយឱ្យខ្ញុំនិងជនរងគ្រោះដទៃទៀតបានស្វែងរកយុត្តិធម៌ និងធ្វើឱ្យកូនចៅជំនាន់ក្រោយដឹងពីអំពើឃោរឃៅនាសម័យនោះ ដើម្បីកុំឱ្យសកម្មភាពព្រៃផ្សៃនោះមានកើតឡើងម្តងទៀត។[87]

ជារួម សញ្ញាណនៃប្រវត្តិសាស្ត្រនេះគឺស្ថិតនៅចំកណ្តាលនៃយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិដែលយើងតែងតែស្រមៃនឹកដល់។ ខណៈពេលដែលទទួលស្គាល់ពីតម្លៃដ៏ធំធេងដែលជនរងគ្រោះត្រូវទទួលបានព័ត៌មាននិងតម្លៃអប់រំនៃការចូលរួមរបស់ពួកគេ យើងត្រូវតែទទួលស្គាល់ថា គោលបំណងនៃការអប់រំអាចត្រូវបានសម្រេចឡើងដោយកម្មវិធីចុះតាមមូលដ្ឋានដ៏ធំធេង។ ពាក់ព័ន្ធនឹងបញ្ហានេះ សកម្មភាពចុះតាមមូលដ្ឋានផ្សេងៗទៀតក្នុងសហគមន៍មូលដ្ឋានមានសារៈសំខាន់យ៉ាងច្បាស់ដូចនឹងការងាររបស់ អ.វ.ត.ក ដែរ។ សកម្មភាពចុះតាមមូលដ្ឋានទាំងនេះត្រូវបានទទួលស្គាល់ជាចម្បងដោយ VSS របស់តុលាការ ហើយពួកគេបានបញ្ជាក់ពីភាពជោគជ័យដ៏គួរឱ្យកត់សម្គាល់។ ដូច្នេះ មានមនុស្សប្រមាណជាង ១០០.០០០ នាក់ដែលបានមកទីនេះដើម្បីសង្កេតមើលការជំនុំជម្រះក្តីនេះក្នុងអ.វ.ត.ក។ យើងគួរតែគិតទៅដល់សំណួរថាតើគោលបំណងនៃការអប់រំប្រជាជន កម្ពុជា និងពិភពលោក អាចទទួលបានជោគជ័យតាមរយៈកំណត់ត្រាចៅក្រមរបស់តុលាការ ឬកម្មវិធីចុះតាមមូលដ្ឋាន។ នេះនាំយើងឆ្ពោះទៅរកចំណុចដែលបានធ្វើឡើងនៅចំណុចចាប់ផ្តើមដំបូងនៃផ្នែកនេះ ដែលសង្កេតធ្ងន់លើការចូលរួមដោយផ្ទាល់ជាមួយក្មេងៗ ក៏ដូចកម្មវិធីរបស់រដ្ឋាភិបាលដែលហួសពីព្រំដែនរបស់សាលតុលាការ។

[86] សូមមើលដើមបណ្តឹងរដ្ឋប្បវេណីក្រុមគោលដៅសំណុំរឿង ០០២ វត្តធនសេរី ភូមិកំពង់ត្របែក ឃុំត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។ ប្រតិចារឹកនៃការប្រជុំស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ។
[87] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។

យើងបានឃើញនៅក្នុងការពិភាក្សានៃការស្វែងរកការពិតថា ក្នុងកម្រិតមួយ វាអាចត្រូវបានបន្ត បើទោះបីជាមិនមានស្ថានភាពផ្លូវការរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ចំណុចស្រដៀងគ្នានេះ អាចត្រូវបានលើកឡើងយ៉ាងរឹងមាំនៅទីនេះ៖ ចូលរួមក្នុងកម្មវិធីចុះតាមមូលដ្ឋាន ដែលបានផ្តល់ឱ្យដោយតុលាការ និងអង្គការ NGO មួយចំនួនទៀត អាចត្រូវបានចាត់ទុកជាលក្ខណៈមួយនៃការចូលរួមប្រកបដោយអត្ថន័យ ទាំងតាមរយៈការចែកចាយព័ត៌មាន និងសម្របសម្រួលការស៊ើបអង្កេតនៃសវនាការជំនុំជម្រះក្តីនេះ។ ទាក់ទងនឹងតម្រូវការលើការអប់រំពិភពលោក កម្មវិធីចុះតាមមូលដ្ឋានមានលក្ខណៈប្រកបដោយប្រសិទ្ធភាពនៃការចូលរួម នៅពេលដែលពួកគេអាចទទួលខុសត្រូវលើភាពស្មុគស្មាញនៃចំណុចទាំងឡាយ ដែលការជំនុំជម្រះលើឧក្រិដ្ឋកម្មដែលមាន ឬមិនមានការចូលរួមពីដើមបណ្តឹងរដ្ឋប្បវេណី មិនអាចត្រូវបានពិចារណា ដោយពន្យល់ថា មធ្យោបាយទំនាក់ទំនងដ៏ត្រឹមត្រូវ ត្រូវបានប្រើប្រាស់ នៅខណៈដែលកម្រិតអក្ខរភាពរបស់ប្រជាជននៅមានកម្រិតទាបក្នុងប្រទេសកម្ពុជានៅឡើយ។

ពាក់ព័ន្ធនឹងចំណុចខាងលើនេះ គឺជាគំនិតដែលបានបង្កប់នូវអត្ថន័យក្នុងបទសម្ភាសន៍ជាច្រើន ដែលការស្វែងរកការពិត តម្រូវការដើម្បីរៀបរាប់ពីរឿងរ៉ាវ និងការអប់រំពិភពលោក មានលក្ខណៈស្រដៀងគ្នាទៅនឹងពាក្យថា កាក់មួយមានមុខពីរខុសគ្នា។ ដូចដែលបានលើកឡើងយ៉ាងសមស្របដោយអ្នកត្រូវសម្ភាសន៍ ការបង្កើតអ.វ.ត.ក ឡើង និងការរួមបញ្ចូលគ្នាលើគម្រោងចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថា៖

> ពិតជាបានជួយពួកគេបង្ហាញពីការពិត ដើម្បីឱ្យពួកគេដឹងពីវិបត្តិដែលបានកើតឡើងដោយរបបខ្មែរក្រហម ហើយដូច្នេះមនុស្សជាច្រើនបានស្វែងពីបញ្ហានេះបានល្អប្រសើរ។ លើសពីនេះទៀត ក្មេងៗជំនាន់ក្រោយ ក៏មានឱកាសដើម្បីស្វែងយល់បន្ថែមពីរបបនេះ។[88]

## ៥.៦- ការស្វែងរកសំណង

### ៥.៦.១- ផលវិបាកផ្លូវច្បាប់ និងជាក់ស្តែង

បញ្ហាមួយក្នុងចំណោមបញ្ហាដ៏ចម្រូងចម្រាសនិងស្មុគស្មាញទាំងឡាយ ពោលគឺជាចម្ងល់ពីសំណង ដែលបានរៀបរាប់ដោយតុលាការក្នុង ‘គោលបំណងឱ្យមានលក្ខណៈជានិមិត្តរូប ជាជាងសំណងផ្ទាល់’ បានបង្ហាញ អ.វ.ត.ក ជាមួយនឹងបញ្ហាប្រឈម និងភាពលំបាកជាច្រើន។ នេះគឺជាហេតុផលស្របច្បាប់និងជាក់ស្តែង ដែលនឹងត្រូវបានកំណត់ដោយខ្លីម្នាក់ម្តងៗ។ ក៏ប៉ុន្តែ សូមចងចាំថា ផលវិបាក និងការដាក់កម្រិតស្របផ្លូវនិងជាក់ស្តែង មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។

ក្នុងក្របខ័ណ្ឌច្បាប់ សំណង ត្រូវបានចាត់ទុកជាដំណោះស្រាយសម្រាប់ជម្លោះរវាងរដ្ឋនិងរដ្ឋ ជាជាងសំណងខូចខាតលើជនរងគ្រោះ។ ក៏ប៉ុន្តែ ច្បាប់អន្តរជាតិ បានចាប់យកជំហានទាំងនោះបន្ទាប់មក ដែលបញ្ចប់ជាមួយសេចក្តីសម្រេចរបស់ UN ស្តីពីគោលការណ៍ និងសេចក្តីណែនាំគ្រឹះ ដែលបានលើកឡើងដោយគ្មានការកែប្រែដែលជនរងគ្រោះពីអំពើឃោរឃៅយ៉ាងធំធេង មានសិទ្ធិទៅលើ ‘ទទួលបានសំណងគ្រប់គ្រាន់ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា’។

---

88 ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងជាជនរងគ្រោះ ភូមិស្រះកែវ ឃុំរាំងចាស់ ស្រុកឧត្តុង្គ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៤)។

ស្រដៀងគ្នានេះ លោកបាន គីមូន អគ្គលេខាធិការ UN បានលើកឡើងក្នុងរបាយការណ៍មួយក្នុងឆ្នាំ ២០១១ ថា៖

> សំណង គឺជាយន្តការដែលមាន ផ្តោតលើជនរងគ្រោះ និងជាមធ្យោបាយដ៏សំខាន់នៃការធ្វើឱ្យមានភាពខុសប្លែកគ្នាក្នុងជីវិតរបស់ជនរងគ្រោះ។ បទពិសោធន៍ UN បង្ហាញថា សំណងអាចសម្របសម្រួលដល់ការផ្សះផ្សា និងភាពជឿជាក់ខ្លួនឯងក្នុងប្រទេស ហើយដូច្នេះនាំទៅរកសន្តិភាពឋិតថេរ និងយូរអង្វែងក្នុងសង្គមក្រោយសង្គ្រាម។

លទ្ធភាពនៃសំណង គឺជាចំណុចស្នូលនៃការចូលរួមរបស់ជនរងគ្រោះដោយទាក់ទងនឹង អ.វ.ត.ក។ បើទោះបីជាអវត្តមានពីអ.វ.ត.កដែលជាអ្នកបង្កើតលក្ខខន្តិៈនេះក៏ដោយ ក៏វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បានចែងថា គោលបំណងសំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការជំនុំជម្រះក្តីមានពីរយ៉ាង។ វិធាន ២៣ *quinquies* បានបង្ហាញដូចខាងក្រោម៖

> ប្រសិនបើជនជាប់ចោទត្រូវបានកាត់ទោស អង្គជំនុំជម្រះអាចផ្តល់ជាសំណងសមូហភាព និងសំណងផ្លូវចិត្តទៅដើមបណ្តឹងរដ្ឋប្បវេណីបាន។ សំណងសមូហភាព និងសំណងផ្លូវចិត្តសម្រាប់គោលបំណងនៃវិធានទាំងនេះ គឺជាវិធានដែលថា៖
>
> (ក) ត្រូវទទួលស្គាល់ការឈឺចាប់ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលជាលទ្ធផលនៃការប្រព្រឹត្តបទឧក្រិដ្ឋដែលជនជាប់ចោទត្រូវបានកាត់ទោស និង
>
> (ខ) ត្រូវផ្តល់អត្ថប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលដោះស្រាយការឈឺចាប់នេះ។
>
> អត្ថប្រយោជន៍ទាំងនេះ មិនត្រូវធ្វើឡើងក្នុងលក្ខណៈទូទាត់ជាសាច់ប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណី។

ក៏ប៉ុន្តែ ការចូលរួមរបស់ជនរងគ្រោះ ផ្តល់ការគាំទ្រលើកាត់ទោសនេះ។ ដូចដែលបានឃើញពីខាងលើ វាក៏បានអនុញ្ញាតឱ្យមាន ‘សំណងសមូហភាព និងសំណងផ្លូវចិត្ត’ ត្រូវបានទាមទារឡើងថ្វីបើមានតែដើមបណ្តឹងរដ្ឋប្បវេណីក៏ដោយ។ ការឈឺចុកចាប់ ‘ផ្លូវចិត្ត’ ត្រូវបានបកស្រាយឡើងជាមធ្យោបាយមួយដែលបានរៀបចំឡើងទូទាត់សងខាងផ្លូវចិត្ត ដែលខុសពីការឈឺចាប់ជាក់ស្តែង ហើយសំណង ‘សមូហភាព’ ជាការបញ្ជាក់នៃភាពមិនអាចទៅរួចនៃការផ្តល់សំណងហិរញ្ញវត្ថុដល់បុគ្គលនីមួយៗ។[89] យោងតាម Bassiouni (២០០៦: ២០៥) សំណងគឺជា ‘មធ្យោបាយមួយដែលជំរុញឱ្យជនរងគ្រោះចូលរួម’។

ក្នុងន័យជាក់លាក់នេះ ការអវត្តមាននៃប្រភេទការពិតសម្រាប់ជនរងគ្រោះមានលក្ខណៈសំខាន់គួរឱ្យកត់សម្គាល់។

---

[89] *សំណុំរឿងកាំង ហ្កេកអ៊ាវ (សំណុំរឿង ០០១)* ការសម្រេចរបស់អង្គជំនុំជម្រះសវនាការ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌទី ៦៦២ ដល់ ៦៦៣។

ដោយហេតុថាមានតែជនជាប់ចោទទាំងបីនាក់ទេដែលត្រូវបានកាត់ទោសរហូតមកដល់បច្ចុប្បន្ន ហើយជនជាប់ចោទទាំងនោះមានស្ថានភាពក្រលំបាក និងទទួលបានជំនួយស្របច្បាប់ លទ្ធភាពទ្រឹស្តីនៃសំណងមិនបានឈរលើលក្ខណៈវិនិច្ឆ័យនៃភាពក្រីក្រនោះទេ។

បន្ថែមពីនេះទៀត គេបានលើកអំណះអំណាងយ៉ាងរឹងមាំថា តាមពិតទៅ ក្តីរំពឹងទុកនៃសំណងសំខាន់ៗទៅជនរងគ្រោះ មិនត្រូវបានលើកទឹកចិត្តឡើយ ដោយមធ្យោបាយ*ចំពោះកិច្ច*ដែលការជំនុំជម្រះក្តីត្រូវបានធ្វើឡើងជារឿយៗ។ នេះបង្ហាញពីគុណវិបត្តិនៃនីតិវិធីនិងសំខាន់ៗនៃរបបសំណង។ ហេតុដូច្នេះ ចៅក្រម Cartwright បានលើកឡើងថា៖

> ចំពោះខ្ញុំ ដំណើរការនៃការចូលរួម និងការស្វែងរកសំណងមិនទាន់ទទួលយកបាននោះទេ។ បន្ទាប់ពីដោះស្រាយតាមរយៈដំណើរការស្មុគស្មាញ ខ្ជះខ្ជាយពេលវេលា និងប៉ះទង្គិចដល់ផ្លូវចិត្ត... ជនរងគ្រោះបានរកឃើញថា សវនាការជំនុំជម្រះក្តីនេះមិនមានយុត្តាធិការណា ដើម្បីបញ្ហាអ្វីមួយឱ្យចេញពីការទទួលស្គាល់ផ្លូវការក្នុងការវិនិ ច្ឆ័យ។[90]

វិធាន ២៣ *quinquies* ដែលបានចែងខាងលើនេះ លើកឡើងពីបញ្ហាទាំងឡាយដែលជនរងគ្រោះបានជួបប្រទះក្នុងការស្វែងរកសំណង។ ទីមួយ សំណងត្រូវបានផ្តល់ជូនដោយប្រឆាំងនឹងឧក្រិដ្ឋជន ដែលសំណងទាំងនោះមិនគ្រប់គ្រាន់ដើម្បីធ្វើជាដំណោះស្រាយទៅអ្នកដែលបានរងការឈឺចាប់ពីមហន្តរាយដ៏ធំនេះឡើយ។ ទីពីរ អ.វ.ត.ក នៅខ្វះយុត្តាធិការរឹងមាំផ្លូវច្បាប់។ ក្នុងការសម្រេចនៃសំណុំរឿង ០០១ តុលាការបានលើកឡើងដោយច្បាស់លាស់ថា ‘អ.វ.ត.ក នៅខ្វះសមត្ថភាពក្នុងការពង្រឹងការផ្តល់សំណង។ ដូច្នេះ សំណងដែលបានផ្តល់ដោយអ.វ.ត.កប្រឆាំងនឹងជនជាប់ចោទអាចពង្រឹងទៅកើតនៅពេលចាំបាច់ក្នុងប្រព័ន្ធតុលាការកម្ពុជាសាមញ្ញតែប៉ុណ្ណោះ។’[91] កិច្ចសហប្រតិបត្តិការពីអំណាចចៅក្រមរបស់កម្ពុជាមិនអាចកើតមានឡើងឆាប់នោះទេ ហើយកំណែទម្រង់នៃក្របខ័ណ្ឌគតិយុត្តិរបស់អ.វ.ត.ក នឹងមានលក្ខណៈពិបាកជាងនេះទៅទៀតដើម្បីទទួលយកទៅបាន។

ជាការពិតណាស់ កំហុសឆ្គងជាច្រើនទាំងនេះ មានលក្ខណៈខុសគ្នាទៅនឹងការរំពឹងទុកដ៏ខ្ពស់របស់ជនរងគ្រោះពាក់ព័ន្ធនឹងសំណង។ ក្នុងសំណុំរឿង ០០១ អ.វ.ត.ក បានផ្តល់ឱ្យនូវសំណើសំណងរួមគ្នារបស់ជនរងគ្រោះចំនួន ពីរ ដែលមានការរួមបញ្ចូលគ្នានៃឈ្មោះគ្រប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងការវិនិច្ឆ័យទោស និងការចងក្រង បោះពុម្ព និងចែកចាយនូវសេចក្តីថ្លែងការណ៍សុំអភ័យទោសរបស់ *ឌុច*។ សំណើដែលនៅសេសសល់ ដូចជាការទទួលបានការថែទាំសុខភាពដោយឥតគិតថ្លៃ ការផ្តល់មូលនិធិលើកម្មវិធីអប់រំ និងការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធ ត្រូវបានបដិសេធលើមូលដ្ឋានគ្រឹះផ្សេងពីគ្នា មិនថាដោយសារតែការកង្វះខាតភាពច្បាស់លាស់ ឬពីព្រោះតែសំណើទាំងនោះហួសពីលទ្ធភាពរបស់អ.វ.ត.ក។ ការវិនិច្ឆ័យរបស់តុលាការ ត្រូវបាន

---

[90]Dame Silvia Cartwright (ចៅក្រមអង្គជំនុំជម្រះសវនាការរបស់ អ.វ.ត.ក), ‘ការជំនុំជម្រះក្តីបទឧក្រិដ្ឋអន្តរជាតិ។ កិច្ចសន្យាដែលបានបំពេញ?’ ( ការបង្រៀនប្រចាំឆ្នាំរបស់ Hawke, Adelaide ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១១)។ អាចរកបាននៅ៖ [http://w3.unisa.edu.au/hawkecentre/ahl/2011AHL_Cartwright.pdf](http://w3.unisa.edu.au/hawkecentre/ahl/2011AHL_Cartwright.pdf) (បានចូលទៅកាន់ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៥)។

[91] សំណុំរឿង*កាំង ហ្គេកអ៊ាវ* (សណុំរឿង ០០១) ការសម្រេចរបស់អង្គជំនុំជម្រះសវនាការ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌទី ៦៦១ ជើងទំព័រ ១១៤៤។

រៀបរាប់ឡើងដោយមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីក្នុង ‘លក្ខណៈតិចតួចបំផុត អភិរក្សបំផុត និងប្រហែលជាវាមានលក្ខណៈត្រឹមត្រូវដោយនិយាយមិនអាចស្រមើស្រមៃបានថា អាចត្រូវបានគេបញ្ឆោ’។[92] អ.វ.ត.ក ខ្លួនឯងបានលើកឡើងក្នុងការវិនិច្ឆ័យរបស់ខ្លួនក្នុងសំណុំរឿង០០២/០១ ‘ដូចដែលមានភាពជាក់ស្ដែងតាមរយៈសំណុំរឿង ០០១ ដែលពិរុទ្ធជនមានជីវភាពក្រលំបាក សំណងដែលផ្ដល់ឱ្យក្រោមគំរូនៃដើមបណ្ដឹងរដ្ឋប្បវេណី ហាក់មិនបង្កើននូវលទ្ធផលរូបិគ្គរឱ្យកត់សម្គាល់សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី’។[93]

តាមពិតទៅ អ.វ.ត.ក មិនបានគិតខ្លួនឯងថា ជាអ្នកមានសមត្ថភាពក្នុងពង្រីករបបសំណងទាំងឡាយជាងនេះទៀតទេ ដែល

> អង្គជំនុំជម្រះគឺ... ត្រូវបានដាក់កម្រិតក្នុងកិច្ចការរបស់ខ្លួនដោយតាមសំណើមុនពេលដែលវានិងប្រភេទនៃសំណង ត្រូវបានអនុញ្ញាតដូចបានចែងក្នុងវិធានផ្ទៃក្នុង។ ការកំណត់នៃលក្ខណៈនេះ មិនអាចចៀសចេញបានតាមរយៈយុត្តិសាស្ត្រណាមួយឡើយ ក៏ប៉ុន្តែវាត្រូវការវិសោធនកម្មនៃវិធានទាំងនោះ។[94]

ភាពមិនទាក់ទងគ្នារវាងការរំពឹងទុកនិងធាតុពិតលើមូលដ្ឋាននេះ ត្រូវបានបង្ហាញឡើងក្នុងលក្ខណៈដ៏ខ្លាំងក្លាដោយមន្ត្រីច្បាប់ជាន់ខ្ពស់ក្នុងអង្គជំនុំជម្រះ ដែលបាននិយាយថា៖

> មនុស្សដែលមិនបានដឹងពីធាតុពិតនៃនីតិវិធីស្របច្បាប់នេះទេ មានការរំពឹងទុកខ្ពស់ ដែលមិនគួរឱ្យជឿលើគម្រោងសំណងនេះ។ ក៏ប៉ុន្តែ វាមិនមានមូលដ្ឋានក្នុងធាតុពិតនោះទេ។ យើងមានប្រព័ន្ធដែលជំរុញយើង ពីព្រោះថា វាជាអ្វីដែលអ្នកទាំងអស់គ្នាចង់បាន ក៏ប៉ុន្តែនៅពេលដែលយើងអនុវត្តវា យើងពិតជាជាប់ចោទលើការកង្វះខាតខាងការច្នៃប្រឌិតថ្មីនេះ។ គម្រោងសំណងត្រូវបានបំពេញឡើងដោយរៀបចំមិនបានត្រឹមត្រូវ។[95]

ហើយនៅពេលមេធាវីការពារបានមានប្រសាសន៍ ដោយមានកង្វល់ថា

> ពួកគេមិនបានឱ្យជនរងគ្រោះអ្វីទាល់សោះនៅទីនេះ។ នៅពេលលោកអ្នកសិក្សាពីការវិនិច្ឆ័យកាត់ទោសរបស់សាលាឧទ្ធរណ៍ក្នុងសំណុំរឿង *ឌុច* លោកអ្នកមិនអាចធ្វើអ្វីបានទេ ប៉ុន្តែមានការញាក់ផ្អើលយ៉ាងខ្លាំង។ តើវាជាសំណងដ៏សំខាន់ដែរឬទេសម្រាប់នរណាម្នាក់នៅប្រទេសកម្ពុជា ដោយគ្រាន់តែបញ្ចេញឈ្មោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផ្សាយលើគេហទំព័រ ខ្ញុំពិតជាមិនបានដឹង ក៏ប៉ុន្តែខ្ញុំនឹងសន្មត់ថា

---

[92] កិច្ចសន្ទនាជាមួយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសំណុំរឿង ០០១ អ.វ.ត.ក កំណត់សម្គាល់ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ។

[93] ព្រះរាជអាជ្ញា និង *នួន ជា និងខៀវ សំផន* សំណុំរឿងលេខ០០២/១៩-០៩-២០០៧/អ.វ.ត.ក/TC ការសម្រេច (ថ្ងៃទី៧ខែសីហា ឆ្នាំ២០១៤) កថាខណ្ឌទី ១១១២។ អាចរកបាននៅ៖ http://www.eccc.gov.kh/sites/default/files/documents/courtdoc/2014-08-07%2017:04/E313_Trial%20Chamber%20Judgement%20Case%20002_01_ENG.pdf (បានចូលទៅកាន់ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥)។

[94] *សំណុំរឿងកាំង ហ្កេកអ៊ាវ (សណុំរឿង ០០១)* ការសម្រេចរបស់អង្គជំនុំជម្រះសវនាការ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌទី ៦៦២។

[95] កិច្ចសន្ទនាជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះថៅក្រមរបស់អ.វ.ត.ក កំណត់សម្គាល់ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ។

វាមិនមែននោះទេ។[96]

តាមរយៈការរិះគន់ តុលាការក្នុងសំណុំរឿង ០០២/០១ បានលើកទឹកចិត្តឱ្យមេធាវីផ្តោតលើផ្នែកទីពីរនៃរបបសំណង ដែលបង្កភាពងាយស្រួលដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីកំណត់ពីគម្រោងដែលបានផ្តល់មូលនិធិដោយម្ចាស់ជំនួយទីបីជាចម្បង។ តាមពិតទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ត្រូវចាត់ឱ្យឯកភាពលើគម្រោងដែលការផ្តល់មូលនិធិគ្រប់គ្រាន់ពីខាងក្រៅ ត្រូវបានបន្តឡើងជាមួយសេវាកម្មគាំពារជនរងគ្រោះ (VSS) របស់ អ.វ.ត.ក។ ជាពិតណាស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ថា ខ្លួនស្ថិតក្នុងភាពលំបាកនៅទីនេះ។ ក៏ប៉ុន្តែ វិធីសាស្ត្រថ្មីនេះតំណាងឱ្យវិធី សាស្ត្រល្អប្រសើរជាងមុនដែលបានធ្វើឡើងដោយ អ.វ.ត.ក ពាក់ព័ន្ធនឹងសំណងដែលត្រូវផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយតុលាការក្នុងការវិនិច្ឆ័យរបស់ខ្លួនបានសម្រេចនូវសំណើសំណងសរុបចំនួន ១១ ក្នុងចំណោមសំណើចំនួន ១៣ ដូចជាសំណើសម្រាប់គម្រោងអប់រំ ការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធ និងកម្មវិធីជួយខ្លួនឯង។[97]

ដើម្បីយល់ថា តើវិធីសាស្ត្រមានកម្រិតដូចបានឆ្លុះបញ្ចាំងក្នុងសំណងដែលផ្តល់ដោយតុលាការក្នុងសំណុំរឿង ០០១ និង ០០២/០១ សមតាមការរំពឹងចង់បានរបស់ជនរងគ្រោះដែរឬទេ វាមានសារៈសំខាន់ដែលយើងពិនិត្យទស្សនៈរបស់ជនរងគ្រោះនៅក្នុងបរិការណ៍នេះ។

### ៥.៦.២- ការយល់ឃើញរបស់ជនរងគ្រោះ

ផលវិបាកតាមផ្លូវច្បាប់ និងជាក់ស្តែងនៃរបបសំណងទាក់ទិនដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានពិនិត្យពីខាងលើ។ ផ្នែកនេះនឹងផ្តោតលើការយល់ឃើញ ទស្សនៈ ព្រមទាំងការយល់ដឹងរបស់ជនរងគ្រោះអំពីសំណងដោយសារតែផលវិបាកដូចបានលើកឡើងខាងលើ។ ដូចបានឃើញស្រាប់ ជនរងគ្រោះទំនងជាមានការរំពឹងទុកខ្ពស់ពាក់ព័ន្ធសំណង ប៉ុន្តែជាក់ស្តែងប្រហែលជាមិនសមតាមការរំពឹងទុកទាំងនោះទេ។ យើងនឹងត្រូវត្រឡប់មកចំណុចខាងក្រោមនេះវិញ បន្ទាប់ពីពិនិត្យមើលសក្ខីកម្មរបស់ជនរងគ្រោះទាក់ទងបទពិសោធន៍របស់ពួកគេជាមួយរបបសំណងរបស់ អ.វ.ត.ក។

ជាចំណុចចាប់ផ្តើម វាមានសារៈសំខាន់ក្នុងការញែកភាពខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។ សារៈសំខាន់នៃសំណងត្រូវបានឆ្លុះបញ្ចាំងយ៉ាងខ្លាំងក្លាមិនត្រឹមតែក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទទួលបានការសម្ភាសចំនួន ៣៥ នាក់ដែលចាប់អារម្មណ៍លើចំណាត់ការនីតិវិធី និងយ៉ាងហោចណាស់ត្រូវបានជូនដំណឹងបានល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងចំណោមដើមបណ្តឹងជាជនរងគ្រោះចំនួន ១៥ នាក់ផងដែរ។ ដើមបណ្តឹងជាជនរងគ្រោះគ្មានសិទ្ធិទទួលបានសំណងទេ។ ទោះជាយ៉ាងណា ពួកគេពិតជាមានការរំពឹងទុកក្នុងនាមជាជនរងគ្រោះក្នុងរបបដូចគ្នា ថានឹងទទួលបានសំណងស្រដៀងនឹងអតីតដើមបណ្តឹងរដ្ឋប្បវេណីដែរ។ ទស្សនៈដែលត្រូវបានបញ្ចេញប្រហែលជាការយល់ថា ការទទួលបានសេវាថែទាំសុខភាពឥតគិតថ្លៃមានសារៈសំខាន់។ ចំណុចទាំងនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់ក្នុងចម្លើយខាងក្រោមផ្តល់ដោយដើមបណ្តឹងជាជនរងគ្រោះម្នាក់ដែលត្រូវបានសម្ភាសនៅសៀមរាប៖

ខ្ញុំចង់បានប័ណ្ណដែលអនុញ្ញាតឱ្យខ្ញុំទទួលបានការថែទាំសុខភាពឥតគិតថ្លៃ និងការអប់រំថ្នាក់ឧត្តមសិក្សាឥតគិតថ្លៃសម្រាប់កូនៗរបស់ខ្ញុំ។ ខ្ញុំចង់ឱ្យផ្តល់សំណងប្រភេទនេះ

---

[96] កិច្ចសន្ទនាជាមួយមេធាវីការពារក្តី របស់អៀង សារី សំណុំរឿង ០០២ អ.វ.ត.ក កំណត់សម្គាល់ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ។
[97] ព្រះរាជអាជ្ញា និង *នួន ជា និងខៀវ សំផន* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/TC ការសម្រេច (ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤) កថាខណ្ឌទី ១១៥១ដល់ ១១៦៤។ អាចរកបាននៅ៖http://www.eccc.gov.kh/sites/default/files/documents/courtdoc/2014-08-07%2017:04/E313_Trial%20Chamber%20Judgement%20Case%20002_01_ENG.pdf (accessed on 18 November 2015).

> ដល់ *ជនរងគ្រោះទាំងអស់*។ [98]

តម្រូវការជាមូលដ្ឋាននូវការថែទាំសុខភាពឥតគិតថ្លៃ ក៏បង្ហាញជាក់ស្តែងដែរនៅក្នុងសម្រង់ពីបទសម្ភាសន៍មួយធ្វើឡើងជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ក្នុងសំណុំរឿង ០០១៖

> ខ្លួនខ្ញុំផ្ទាល់ចង់ឱ្យតុលាការសហការជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់ប្រព័ន្ធមួយដល់ជនរងគ្រោះតាមរយៈការចែកប័ណ្ណសុខភាពដល់ជនរងគ្រោះ ដែលនៅមានជីវិតរស់រានពីរបបខ្មែរក្រហម ដើម្បីពួកគេមានលទ្ធភាពទទួលបានសេវាសុខាភិបាលដោយមិនចាំបាច់បង់ប្រាក់ ពីព្រោះពួកគេក្រីកក្រ។ [99]

មូលហេតុដែលត្រូវការទទួលបានការថែទាំសុខភាពឥតគិតថ្លៃ ត្រូវបានបន្សល់បកស្រាយដោយបទសម្ភាសន៍មួយទៀតដែលបាននិយាយថា

> ប្រសិនបើមានមន្ទីរពេទ្យ និងអង្គការសម្រាប់ជនរងគ្រោះ វាជាការល្អដើម្បីឱ្យយើងមិនចាំបាច់ចំណាយច្រើនលើសេវាទាំងនេះ។ សព្វថ្ងៃយើងមានមណ្ឌលសុខភាពឃុំប៉ុន្តែប្រសិនបើយើងឈឺ ហើយគ្មានលុយ វាមិនងាយស្រួលទេសម្រាប់យើង។ អំឡុងពេលប្រជុំ ខ្ញុំធ្លាប់បានលើកឡើងរួចហើយអំពីការព្រួយបារម្ភរបស់ខ្ញុំថា គួរតែមានមន្ទីរពេទ្យសម្រាប់ជនរងគ្រោះដើម្បីឱ្យយើងមិនចាំបាច់ចំណាយប្រាក់ច្រើន។ យើងក្នុងនាមជាជនរងគ្រោះ ធ្លាប់បានទទួលការឈឺចាប់រួចមកហើយពីរបបនោះ ហើយពេលនេះនៅពេលយើងឈឺត្រូវចូលមន្ទីរពេទ្យ យើងត្រូវបង់ថ្លៃពេញ។ នេះជារឿងតែមួយគត់ដែលខ្ញុំចង់បាន។ [100]

ខណៈការថែទាំសុខភាពជាការព្រួយធំបំផុតរបស់ជនរងគ្រោះ ដែលត្រូវបានសម្ភាសប្រធានបទទូទៅមួយទៀតក្នុងបទសម្ភាសន៍ដែលធ្វើឡើង ពាក់ព័ន្ធយុត្តាធិការមានកម្រិតរបស់ អ.វ.ត.ក ក្នុងការផ្តល់សំណងសមូហភាពដែលផ្ទុយនឹងសំណងបុគ្គល។ ជាទូទៅ ការបញ្ចេញមតិលើចំណុចនេះមានការខ្វែងគ្នា ដោយអ្នកផ្តល់បទសម្ភាសន៍ម្នាក់អះអាងថា

> ទាក់ទិនសំណង ជនរងគ្រោះមួយចំនួនចង់បានសំណងបុគ្គល ហើយខ្លះទៀតចង់បានសំណងសមូហភាព។ ប៉ុន្តែចុងក្រោយ សំណងបុគ្គលមិនអាចទៅរួច។ ហើយនេះជាផលប៉ះពាល់ដែលទាក់ទិនការទាមទាររបស់ពួកគេ៖ ឧទាហរណ៍ ប្រសិនបើតុលាការផ្តល់ឱ្យជនរងគ្រោះម្នាក់ ១០.០០០ ដុល្លារ តុលាការត្រូវចំណាយរាប់លានដុល្លារ ពីព្រោះមានជនរងគ្រោះរាប់លាននាក់។ ដូច្នេះយើងមិនអាចធ្វើបានទេ។ ចំនួនសរុបនៃដើមបណ្តឹងរដ្ឋប្បវេណីមានជាង ៤.០០០ នាក់ ហើយចំនួននេះនឹងកើន

---

[98] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០១ និង០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសៀមរាប ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤) ការសង្កត់បញ្ជាក់ត្រូវបានបន្ថែម។

[99] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០១ នៅភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤)។

[100] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។

ឡើងប្រសិនបើតុលាការមិនបានបិទការដាក់ពាក្យជាដើមបណ្តឹងរដ្ឋប្បវេណី។ [101]

ស្រដៀងគ្នានេះដែរ ការបញ្ចេញមតិខាងក្រោមធ្វើឡើងអំឡុងបទសម្ភាសន៍ផ្សេងមួយទៀតៈ

> និយាយពីសំណង គ្មានអ្វីដែលធ្វើឱ្យខ្ញុំព្រួយបារម្ភឡើយ ពីព្រោះសំណងមិនអាចផ្តល់ដល់បុគ្គលម្នាក់ៗបានទេ។ ដូច្នេះវាត្រូវតែជាសំណងសមូហភាព ពីព្រោះមិនមែនមានតែសមាជិកគ្រួសាររបស់ខ្ញុំទេដែលស្លាប់ គឺប្រជាពលរដ្ឋជាច្រើនទៀតដ៏ស្លាប់ដែរ។ ដូច្នេះសំណងបុគ្គលមិនអាចទៅរួចទេ។ ដូច្នេះវាត្រូវតែជាសំណងសមូហភាពដែលជានិមិត្តរូប ហើយខ្ញុំអាចទទួលយកបាន។ ហើយខ្ញុំក៏យល់ដែរថារដ្ឋាភិបាលគ្មានថវិកាគ្រប់គ្រាន់សម្រាប់ផ្តល់សំណងបុគ្គលទេ។ ដូច្នេះយើងអាចទទួលយកបានទាក់ទិនសំណងសមូហភាព។ ដូច្នេះវាសមហេតុផលសម្រាប់ខ្ញុំ។ [102]

ចំណុចសំខាន់ពីរចេញពីមតិយោបល់ទាំងនេះគឺៈ ទី១ ដើមបណ្តឹងរដ្ឋប្បវេណីទទួលស្គាល់ថាធនធានមានកំណត់ ដូច្នេះសំណងផ្តល់ជូនអ្នកដែលរងគ្រោះដោយសារការរងគ្រោះយ៉ាងរង្គាលក៏នឹងមានកំណត់តាមនោះដែរ។ ទី២ ក៏មានការទទួលស្គាល់ដែរថា ការរងគ្រោះកើតឡើងទូទៅ មិនមែនកើតឡើងតែទៅលើគ្រួសារណាមួយនោះទេ។

ទោះជាយ៉ាងណា មិនមែនមនុស្សគ្រប់រូបសុទ្ធតែមានទស្សនៈបែបនេះឡើយ ដោយមួយចំនួនផ្តោតសំខាន់លើការរងគ្រោះរបស់បុគ្គល។ ដូច្នេះការគ្មានយុត្តាធិការក្នុងការផ្តល់សំណងបុគ្គលត្រូវបានអ្នកផ្តល់បទសម្ភាសន៍ម្នាក់ចាត់ទុកជា "ចន្លោះប្រហោង"។ [103] អ្នកផ្តល់បទសម្ភាសន៍ម្នាក់ទៀតបានលើកឡើងថា

> សំណងមានពីរប្រភេទគឺៈ សំណងផ្លូវចិត្ត និងសំណងសមូហភាព។ សំណងទាំងពីរប្រភេទនេះល្អរួចទៅហើយ ប៉ុន្តែវានៅខ្វះសំណងបុគ្គល។ តុលាការគួរតែមានសំណងបុគ្គលសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ពីព្រោះពួកគេសុទ្ធតែមាន ជីវភាពយ៉ាប់យ៉ឺនខ្លាំង។ ដូច្នេះ តុលាការគួរតែផ្តល់យ៉ាងហោចណាស់ទឹកប្រាក់បន្តិចបន្តួចជាសំណងបុគ្គលដែរ។ ការពិតទៅ អាយុជីវិតរបស់សាច់ញាតិដែលបានបាត់បង់អំឡុងរបបខ្មែរក្រហម មិនអាចកាត់ថ្លៃបានទេ។ [104]

ទោះជាយ៉ាងណា អ្នកផ្តល់បទសម្ភាសន៍ម្នាក់ទៀតបានទាញទន្ទឹករណ៍ភ្លាមៗអំពីធនធានមានកម្រិត ដោយញែកភាពខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងជាជនរងគ្រោះដូចបានពណ៌នាខាងលើ ហើយសង្កត់ធ្ងន់ថា

> ជនរងគ្រោះបានស្នើសុំសំណងបុគ្គល ពីព្រោះពួកគេមានវ័យចាស់ទៅហើយ និងត្រូវ

101 ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០១ និង០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤)។

102 ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅសៀមរាប ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤)។

103 ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០១ និង០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤)។

104 ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០២ របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤)។

> ការប្រាក់សម្រាប់ទ្រទ្រង់ជីវភាពរស់នៅ និងសម្រាប់ចេញថ្លៃព្យាបាលសុខភាពរបស់ខ្លួន។ នេះជាសំណើដែលជនរងគ្រោះបានលើកឡើង។ ខ្ញុំក៏ជាតំណាងដើម
> បណ្ដឹងរដ្ឋប្បវេណីដែរនៅក្នុងរាជធានីភ្នំពេញ ហើយខ្ញុំក៏បានស្នើសុំដូចគ្នានេះដែរ។ យើងចេះតែព្យាយាមស្នើសុំទៅ ទោះបីជាយើងដឹងថាគេមិនឱ្យក៏ដោយ។ អ្នកខ្លះនិយាយថា ជនរងគ្រោះមានច្រើន ដូច្នេះជនរងគ្រោះមិនគួរស្នើសុំសំណងបុគ្គលទេ។ ចំណែកឯអ្នកខ្លះទៀតបានទាញទន្លឹករណ៍ថា ទេ មានជនរងគ្រោះតែ ៤.០០០ នាក់ប៉ុណ្ណោះដែលបានដាក់ពាក្យស្នើសុំ។ ដូច្នេះសំណងបុគ្គលគឺសម្រាប់អ្នកដែលបានដាក់ពាក្យស្នើសុំ មិនមែនសម្រាប់អ្នកដែលមិនបានដាក់ពាក្យស្នើសុំនោះទេ។ ជាការពិតមានជនរងគ្រោះរាប់លាននាក់ ប៉ុន្តែយោងតាមដំណើរការនីតិវិធីក្នុងតុលាការ មានតែអ្នកដែលបានដាក់ពាក្យស្នើសុំប៉ុណ្ណោះដែលនឹងទទួលបានសំណង។[105]

ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ និងជាអ្នកមានជីវិតរស់រានពីមន្ទីរស-២១ បានបញ្ចេញមតិខ្លាំងៗបំផុតក្នុងបទសម្ភាសន៍ពាក់ព័ន្ធ អ.វ.ត.ក

> ប៉ុន្តែក្នុងនាមជាជនរងគ្រោះ ខ្ញុំមិនទទួលបានសំណងបុគ្គលទេ។ វាធ្វើឱ្យខ្ញុំខកចិត្ត។ ដូច្នេះ អ.វ.ត.ក គ្រាន់តែជាតុលាការប្រឌិតប៉ុណ្ណោះ។ វាគ្រាន់តែបង្ហាញពិភពលោកថាមានសវនាការជំនុំជម្រះ ប៉ុន្តែគ្មានសំណង។ ដូច្នេះតុលាការនេះមិនលើកកម្ពស់មនុស្សជាតិទេ។ រយៈពេលជាង ១៥ ឆ្នាំទៅ ២០ ឆ្នាំ គ្មានសំណងបុគ្គលសម្រាប់ជនរងគ្រោះទេ ហើយនេះមិនមែនជាគំរូសម្រាប់ពិភពលោកអនុវត្តតាមឡើយ។[106]

គេក៏អាចសង្កេតឃើញការខ្វែងគំនិតស្រដៀងៗគ្នាដែរនៅក្នុងការប្រជុំក្រុមគោលដៅចំនួន ៥ លើកដែលធ្វើឡើងនៅប្រទេសកម្ពុជា ដោយអ្នកខ្លះយល់ស្របថាមានសំណងសមូហភាពតែមួយគត់ ហើយអ្នកផ្សេងទៀតដែលសម្ដែងការខកចិត្តចំពោះការគ្មានយុត្តាធិការក្នុងការផ្ដល់សំណងបុគ្គល ជាពិសេសជាមួយនឹងទស្សនៈទទួលសេវាថែទាំសុខភាពឥតគិតថ្លៃ។[107]

បន្ទាប់ពីការវិភាគលើការប្រជុំក្រុមគោលដៅ និងបទសម្ភាសន៍ដែលត្រូវបានធ្វើឡើងបង្ហាញយ៉ាងច្បាស់ថា បូជនីយដ្ឋានក៏សំខាន់ដែរ។ ក្នុងវប្បធម៌ និងសាសនារបស់កម្ពុជា បូជនីយដ្ឋានត្រូវបានចាត់ទុកជាចំណុចស្នូលនៃពិធីសាសនា និងជីវិតរស់នៅក្នុងសង្គម។ ដូចអ្នកផ្ដល់សម្ភាសន៍ម្នាក់បានបញ្ចេញមតិថា "ខ្ញុំចង់ឱ្យមានស្តូបរំឭកវិញ្ញាណក្ខន្ធនៅកន្លែងណាមួយទុកសម្រាប់ជាបូជនីយដ្ឋាន។ ប្រសិនបើមានស្តូបរំឭកវិញ្ញាណក្ខន្ធ យើងអាចធ្វើពិធីសាសនាបានងាយស្រួល និងមិនពិបាកធ្វើដំណើរឆ្ងាយ។ ក្នុងស្មារតីនេះ ជនរងគ្រោះភាគច្រើនដែលត្រូវបានសម្ភាស បានសម្ដែងការពេញចិត្តចំពោះវិធានការសំណង

---

105 ប្រតិចារឹកនៃបទសម្ភាសន៍ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅភ្នំពេញ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤)។

106 ប្រតិចារឹកនៃបទសម្ភាសន៍ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០១ និង០០២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤)។

107 ចូរមើលសំណុំរឿង០០២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាក្រុមគោលដៅនៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។ សំណុំរឿង០០១ និង០០២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅខេត្តព្រៃវែង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤។ ប្រតិចារឹកនៃការប្រជុំស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ។

ផ្ដល់ដោយតុលាការក្នុងសំណុំរឿង ០០២/០១ ទាក់ទងការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធ។ ទោះជាយ៉ាងណា មានការត្រៀមទុកខ្លះពាក់ព័ន្ធចំនួនស្តូបរំឭកវិញ្ញាណក្ខន្ធព្រមទាំងទីតាំងភូមិសាស្ត្ររបស់វាដូចដែលបានផ្ដល់ជាឧទាហរណ៍តាមរយៈមតិយោបល់ខាងក្រោមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ក្នុងសំណុំរឿង ០០២/០១ អំឡុងពេលសម្ភាសន៍៖

> សព្វថ្ងៃ យើងបានរក្សាទុកទួលពោធិ៍ជ្រៃមិនប៉ះពាល់ទេ ហើយយើងបានរង់ចាំក្រែងលោតុលាការបញ្ជាឱ្យសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធនៅទីនោះ។ ប្រសិនបើសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធតែនៅក្នុងរាជធានីភ្នំពេញ យើងត្រូវធ្វើដំណើរទៅទីនោះដើម្បីបួងសួងដល់វិញ្ញាណក្ខន្ធសាច់ញាតិដែលបានចែលឋាន ពីព្រោះវាឆ្ងាយពីទីនេះ ហើយយើងបានស្នើសុំឱ្យតុលាការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធនៅក្នុងខេត្តនីមួយៗ។ [108]

សម្រាប់អ្នកផ្ដល់បទសម្ភាសន៍ខ្លះ ការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធត្រូវបានផ្ដល់តម្លៃស្មើគ្នានឹងការផ្ដល់ការថែទាំសុខភាពឥតគិតថ្លៃពាក់ព័ន្ធសំណង។ ដូចដែលអ្នកផ្ដល់បទសម្ភាសន៍ម្នាក់ទៀតបានស្នើឡើងថា

> ... អ្វីដែលយើងចង់បានបំផុតគឺសេវាថែទាំសុខភាព និងការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធបន្ថែមទៀតនៅក្នុងខេត្ត និងស្រុកនីមួយ។ ទោះជាយ៉ាងណា យើងមិនដឹងថា តើយើងនឹងទទួលអ្វីដែលយើងបានស្នើសុំ ឬក៏អត់ទេ។ យោងតាមព័ត៌មានដែលខ្ញុំទទួលបាន ការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធត្រូវការដីសម្រាប់សាងសង់ និងការអនុម័តពីអាជ្ញាធរមូលដ្ឋាន។ [109]

ផ្ទុយទៅវិញ អំឡុងបទសម្ភាសន៍ជាមួយដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ផ្សេងទៀត ភាពខុសគ្នាត្រូវបានញែកចេញរវាងសំណួរពាក់ព័ន្ធស្តូបរំឭកវិញ្ញាណក្ខន្ធ និងបញ្ហាសំណងសមូហភាពធៀបនឹងសំណងបុគ្គល៖

> ការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធក្នុងខេត្តនីមួយៗមិនអាចទៅរួចទេ។
> ខ្ញុំចង់បានសំណងបុគ្គល។ [110]

ដូច្នេះមានបញ្ហាជាក់ស្តែងដែលដើមបណ្ដឹងជាជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងទាក់ទិនសំណង។ ក្នុងចំណោមក្ដីកង្វល់ភាគច្រើន គឺការគ្មានសំណងបុគ្គល ការទទួលបានការថែទាំសុខភាពឥតគិតថ្លៃនៅមានកម្រិត និងការសាងសង់ស្តូបរំឭកវិញ្ញាណក្ខន្ធតាមបណ្ដាខេត្តទូទាំងប្រទេសកម្ពុជា។

ពិតណាស់ថា ការខកចិត្តរបស់ពួកគេចំពោះការមិនបានដូចការរំពឹងទុក បានធ្វើឱ្យប៉ះពាល់

[108] ប្រតិចារិកនៃបទសម្ភាសន៍ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។
[109] ចូរមើលសំណុំរឿង០០២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាក្រុមគោលដៅនៅស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។
[110] ប្រតិចារិកនៃបទសម្ភាសន៍ស្ដីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០១ និង០០២ របស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅសៀមរាប ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៤)។

ដល់ទស្សនៈរបស់ជនរងគ្រោះលើការចូលរួមរបស់ពួកគេក្នុងដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក ដោយសំណងបានក្លាយជាបញ្ហាដែលមានការជំទាស់បំផុត និងជជែកច្រើនបំផុត។ គេកំពុងរង់ចាំមើលនៅឡើយថា តើការផ្តល់សំណងក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២/០១ នឹងមានផលប៉ះពាល់យ៉ាងណាលើការចូលរួមរបស់ជនរងគ្រោះ និងថា តើវានឹងបន្ទុចបង្អាក់ជនរងគ្រោះមិនឱ្យដាក់ពាក្យដើម្បីចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការជំនុំជម្រះដែលអាចកើតមាននាពេលខាងមុខ (សំណុំរឿង ០០៣ និងសំណុំរឿង ០០៤) ដែរ ឬទេ។ ទោះជាយ៉ាងណា អ្វីដែលមិនគួរបំភ្លេចដូចបានបង្ហាញក្នុងសម្រង់សម្តីដែលត្រូវបានប្រើប្រាស់ក្នុងផ្នែកនេះ ដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកសំណងសមូហភាពដែលផ្តល់ដោយ អ.វ.ត.ក ថាមានន័យ និងមានសារៈសំខាន់។ បាច់ត្រូវធ្វើការវាយតម្លៃលើការមិនពេញចិត្តរបស់ពួកគេចំពោះរបបសំណងបច្ចុប្បន្នដែលមិនមែនតែធ្វើឡើងទៅលើការគ្មានសំណងបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវធ្វើការវាយតម្លៃទៅលើការទទួលស្គាល់របស់ជនរងគ្រោះថាសំណងសមូហភាពមានសារៈសំខាន់ផងដែរ។ ទន្ទឹមនឹងនេះ គួរតែចាំទុកក្នុងចិត្តថា ប្រជាជនកម្ពុជា ភាគច្រើនចាត់ទុកខ្លួនឯងជាជនក្រីក្រ ហេតុដូច្នេះការផ្តល់សំណងជាលុយកាក់ ផ្តល់អត្ថប្រយោជន៍ច្បាស់លាស់ និងចាំបាច់ដល់ពួកគេ។

ដូចបានបញ្ជាក់ពីខាងលើ ត្រូវប្រុងប្រយ័ត្នថា ព័ត៌មានមានសារៈសំខាន់ចំពោះការសម្រេចបំណងតាមការរំពឹងទុក។ ក្នុងស្មារតីនេះ ធនធានមានកម្រិតសម្រាប់ការអប់រំផ្សព្វផ្សាយ និងការចែកចាយព័ត៌ដើរតួនាទីយ៉ាងសំខាន់។ ការជជែកជាសាធារណៈលើសំណងទាក់ទិនដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានជំរុញដោយសង្គមស៊ីវិល មេធាវីការពារសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាល ហើយក្នុងករណីខ្លះប្រហែលជាអាចមានការលាបពណ៌ផ្ទុយពីការពិតដែលបានបង្កឱ្យមានការរំពឹងចង់បានមិនសមហេតុផល។ នេះសបង្ហាញឱ្យឃើញថា ដើមរដ្ឋប្បវេណីជាបុគ្គលមិនចាំបាច់យល់ដឹងច្បាស់អំពីយុត្តាធិការមានដែនកំណត់របស់ អ.វ.ត.ក ទេ។ ជាពិសេស បញ្ហាពិបាកដោះស្រាយគឺការយល់ដឹងនៅមានកម្រិតទាក់ទិនកង្វះសំណងបុគ្គល ទោះបីវាជាការទទួលខុសត្រូវរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធានាថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានជូនដំណឹងគ្រប់គ្រាន់អំពីសិទ្ធិរបស់ពួកគេនៅក្នុងដំណើរការនីតិវិធី និងសំណងច្បាស់លាស់ក្តី។ អំឡុងពេលសវនាការជំនុំជម្រះទាំងមូលនៅ អ.វ.ត.ក រំហូរព័ត៌មានទាក់ទិនការមានសំណង ទំនងជាមិនគ្រប់គ្រាន់ទេ ហើយពេលខ្លះអាចធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានការរំពឹងទុកមិនពិត។ ទោះជាយ៉ាងណា មានភាពប្រសើរឡើងច្រើនអំឡុងដំណើរការសំណុំរឿង ០០២ លើផ្នែកនៃអង្គភាពគាំពារជនរងគ្រោះ (VSS) សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងផ្នែកច្បាប់របស់បុគ្គលដែលកាន់តែចេះបង្ការជាមុន និងបានផ្តល់ព័ត៌មានច្រើនអំពីសំណងសម្រាប់ជនរងគ្រោះ។

### ៥៧.- ការផ្សះផ្សា

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ក្តីបារម្ភណ៍របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា នៅក្នុងការស្វែងរកយុត្តិធម៌ និងការផ្សះផ្សាជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ”។ [111] ដូច្នេះការផ្សះផ្សាគឺជាគោលបំណងស្នូលដែល អ.វ.ត.ក មានបំណងសម្រេចឱ្យបាននៅទីបំផុត។ ចំណុចដូចគ្នានេះត្រូវបានលើកឡើងដោយ Thoms et al. (២០១០) ដែលការស្រាវជ្រាវរបស់ខ្លួនបានសន្និដ្ឋានថា ប្រធានបទទូទៅមួយនៅក្នុងឯកសារស្តីពីយុត្តិធម៌អន្តរកាល គឺប្រសិទ្ធភាពព្យាបាលនៃសវនាការជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិលើអ្នករស់រានមានជីវិតពីអំពើឧក្រិដ្ឋកម្មឃោរឃៅទ្រង់ទ្រាយធំ ដែលរួមមានការជំរុញឱ្យមានការលើកលែងទោស និងការផ្សះផ្សាក្នុងចំណោមប្រជាពលរដ្ឋ ក្រោយកើតមានអំពើហិង្សាយ៉ាងវិករាលដាល។ ពិតមែនហើយ Gee-kin Ip (២០១៣៖៨៦៧) ថែមទាំងចាត់ទុកការផ្សះផ្សាជាតិជា “វត្ថុបំណងដ៏សំខាន់” របស់ អ.វ.ត.ក ទៀតផង។

វាគួរឱ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា ការផ្សះផ្សាត្រូវបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងជាជនរងគ្រោះនៅក្នុងបទសម្ភាសន៍ទាំងអស់ដែលបានធ្វើឡើង។ ទោះជាយ៉ាងណា វានឹងច្បាស់នៅក្នុងការវិភាគខាងក្រោមថា ពិតជាគ្មាននិយមន័យច្បាស់លាស់ដែលគេទទួលស្គាល់ជាសកលថា “ការផ្សះផ្សា” មានន័យឱ្យប្រាកដយ៉ាងណាឡើយ ទោះបីជាគេឃើញថាមានស្នូលរួមដោយអ្នកផ្តល់បសម្ភាសន៍ភាគច្រើនក្តី។

សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលមានជីវិតរស់រានពីមន្ទីរឃុំឃាំងស-២១ ការផ្សះផ្សាគឺជាការផ្តុយគ្នាស្រឡះពីការបំបែកចេញ និងការព្រាត់ប្រាស់គ្នា។ ដូច្នេះគាត់ទាញទន្និករណ៍ថា

> ប្រជាពលរដ្ឋប្រារព្ធពិធីសាសនានៅទីនេះ [នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង] ដូច្នេះទាំងជនរងគ្រោះ និងឧក្រិដ្ឋជនអាចមកជួបជុំគ្នាបាន។ ជាលទ្ធផល ពួកគាត់លែងមានកំហឹង និងចង់សងសឹកគ្នាទៀតហើយ។ ប្រសិនបើយើងបំបែកជនរងគ្រោះ និងឧក្រិដ្ឋជនចេញពីគ្នា ពួកគេនឹងនៅតែបន្តការសងសឹកគ្នា ដូច្នេះកម្ពុជា នឹងមិនអាចផ្សះផ្សាបានទេ។ ប៉ុន្តែប្រសិនបើយើងធ្វើនៅទូទាំងប្រទេសដូចដែលយើងធ្វើនៅគុកទួលស្លែងនេះ ពេលនោះប្រទេសជាតិយើងទាំងមូលអាចផ្សះផ្សាបានហើយ។

ការដកស្រង់នេះទាក់ទាញការចាប់អារម្មណ៍ទៅលើសារៈសំខាន់នៃជំនឿព្រះពុទ្ធសាសនាក្នុងសង្គមកម្ពុជា ដែលបានលើកឡើងរួចមកហើយក្នុងបរិបទកត្តាវប្បធម៌សង្គមដែលប៉ះពាល់ដល់ការចូលរួមរបស់ជនរងគ្រោះនៅ អ.វ.ត.ក។ មិនគួរមើលស្រាលការផ្សះផ្សាដែលប្រកាន់យកមាគ៌ាកណ្តាលតាមផ្លូវព្រះពុទ្ធសាសនាដែលប្រឆាំងការសងសឹកឡយ។ ដូចដែល Gee-kin IP បានទាញទន្និករណ៍ហើយថា នៅក្នុងទិដ្ឋភាពដែល អ.វ.ត.ក ផ្តោតលើគណនេយ្យភាពក្នុងបំណងបញ្ចប់
និទណ្ឌភាព "វាគួរឱ្យមានមន្ទិលសង្ស័យថា តើប្រជាជនកម្ពុជា អាចយល់ពីបញ្ហានេះដែរទេដោយសារទស្សនៈលើកឡើងផ្សេងៗដូចជា ការទទួលយក ការអត់ឱន និងចិត្តមេត្តាករុណាដែលជាញឹកញាប់ត្រូវបានទទួលយកកាន់តែច្រើនក្នុងសហគមន៍កម្ពុជា” (Gee-kin IP, 2013: 868)។

តម្លៃទាំងនេះក៏បង្ហាញយ៉ាងច្បាស់ដែរនៅក្នុងការឆ្លើយតបខាងក្រោម។ ឧទាហរណ៍ ដើមបណ្តឹងជាជនរងគ្រោះម្នាក់បានលើកឡើងអំពីការផ្សះផ្សាគួរឱ្យកត់សម្គាល់ថា៖

---

111 ចូរមើល៖ http://www.eccc.gov.kh/sites/default/files/legal-documents/Agreement_between_UN_and_RGC.pdf (បានចូលទៅកាន់នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥)។

ពួកគាត់ប្រជាជនកម្ពុជា] ] អាចរស់នៅជាមួយគ្នាក្នុងសហគមន៍ដោយសុខសាន ពីព្រោះពេលនេះប្រជាជនសូម្បីតែនៅតំបន់ជនបទ ក៏មានការយល់ដឹងកាន់តែច្រើន និងមានទំនាក់ទំនងមិត្តភាពល្អ ហើយពួកគាត់គួរតែដឹងអំពីទង្វើខុសឆ្គងរបស់ខ្លួន ហើយដឹងថាមិនគួរប្រព្រឹត្តទង្វើទាំងអស់នោះ។ [112]

សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នេះ ការអភ័យទោសជាជាងការសងសឹងក៏ជាលទ្ធផលផ្ទាល់ដែលកើតចេញពីសាលក្រមរបស់ អ.វ.ត.ក ដែរ៖

អ្វីដែលតុលាការធ្វើ គឺដើម្បីលើកទឹកចិត្តខ្ញុំឱ្យផ្សះផ្សាជាមួយឧក្រិដ្ឋជន។ បន្ទាប់ពីអ្វីដែលតុលាការបានធ្វើ ពេលនេះខ្ញុំអាចទទួលយកបាន។ តុលាការបានស្វែងរកយុត្តិធម៌ឱ្យខ្ញុំ ហើយបង្ហាញថា ឧក្រិដ្ឋជនពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មមែន។ ដូច្នេះ ខ្ញុំអាចទទួលយកបាន ពីព្រោះជនជាប់ចោទពិតជាសារភាពថាបានប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយខ្ញុំអាចលើកលែងទោសឧក្រិដ្ឋជនបាន និងមិនចង់សងសឹកលើពួកគេវិញទេ។

ប្រធានបទដូចគ្នានេះ ត្រូវបានកើនឡើងដោយអ្នកផ្តល់បទសម្ភាន៍ប្រកបដោយសុទិដ្ឋិនិយមម្នាក់ទៀតដែលបានភ្ជាប់ការអភ័យទោស និងសន្តិភាពទៅនឹងការរីកចម្រើនរបស់សង្គមកម្ពុជា៖

គេបានប្រាប់យើង និងណែនាំយើងឱ្យចេះស្រឡាញ់គ្នា និងរស់នៅជាមួយគ្នាដោយសុខសាន។ យើងគួរតែរួបរួមគ្នាឡើងវិញ ហើយជំរុញប្រទេសរបស់យើងឱ្យដើរទៅមុខ ព្រោះយើងទាំងអស់គ្នាសុទ្ធតែជាខ្មែរ។ ជនរងគ្រោះ និងឧក្រិដ្ឋជនរស់នៅជាមួយគ្នាក្នុងភូមិតែមួយ។ ពេលខ្លះយើងឃើញអ្នកដែលបណ្តាប់ព្យាយាមសម្លាប់យើង ហើយយើងមានអារម្មណ៍ភ័យខ្លាច។ ប៉ុន្តែខ្ញុំគិតថា អ្វីគ្រប់យ៉ាងនឹងលែងមានបញ្ហានៅពេលអនាគត។

ទោះជាយ៉ាងណា វាមិនត្រឹមត្រូវឡើយក្នុងការសន្មត់ថា គេយល់ស្របទូទៅតាមយោបល់ដែលបានលើកឡើងពីខាងលើ។

ដូចបានលើកឡើងពីខាងដើមហើយថា ការផ្សះផ្សាអាចមានន័យខុសៗគ្នាសម្រាប់មនុស្សផ្សេងគ្នា។ ដូច្នេះអ្នកផ្តល់បទសម្ភាសន៍មួយក្រុមទៀតដែលអាចបង្កើតជាក្រុមបានសម្រាប់គោលបំណងបច្ចុប្បន្នជឿថា ការសងសឹកពាក់ព័ន្ធការផ្តន្ទាទោស។ ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នៅក្នុងក្រុមនេះយល់ថា ការផ្សះផ្សា និងការសងសឹកគឺផ្ទុយគ្នាស្រឡះ។ ទោះយ៉ាងណា គាត់ "អាចផ្សះផ្សាបានតែជាមួយអ្នកនៅថ្នាក់ក្រោមជាតិប៉ុណ្ណោះ។ និយាយពីមេដឹកនាំ និងមន្រ្តីទទួលខុសត្រូវជាន់ខ្ពស់វិញ [គាត់] អាចផ្សះផ្សាបានលុះត្រាតែពួកគេត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត"។[113] ស្រដៀងគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតបានលើកឡើងអំឡុងបទសម្ភាសន៍មួយថា

មុនពេលចូលរួមសវនាការនៅសាលាក្តីខ្មែរក្រហម ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនពេញចិត្តទេ ដោយសារតែរបៀបយើងផ្សះផ្សាគ្នា នៅពេលយើងបានបាត់បង់អ្វីៗគ្រប់យ៉ាងទៅហើយ

[112] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងជាជនរងគ្រោះ នៅភ្នំពេញ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤)។

[113] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ និង០០២ នៅភ្នំពេញ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤)។

> នោះ! ក្រោយមក យើងមានអារម្មណ៍ធូរស្រាលបន្ទាប់ពីបានស្តាប់ព័ត៌មានថា សាលាក្តីខ្មែរក្រហមកំពុងធ្វើការដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះតាមរយៈការចាប់ឧក្រិដ្ឋជនឱ្យទទួលខុសត្រូវ។ ខ្ញុំពេញចិត្តបែបនេះដោយសារតែសាលាក្តីខ្មែរក្រហម ជាតុលាការកូនកាត់ដែលសហការជាមួយអង្គការសហប្រជាជាតិ ស្វែងរកឧក្រិដ្ឋជន និងផ្តន្ទាទោសពួកគេដើម្បីកុំឱ្យមេដឹកនាំអនាគតធ្វើតាមអ្វីដូចដែលឧក្រិដ្ឋជនបានប្រព្រឹត្ត។ នៅទីបំផុត សាលាក្តីខ្មែរក្រហមពិតជាបានផ្តន្ទាទោសដាក់ពន្ធនាគារពួកគេអស់មួយជីវិតមែន ហើយខ្ញុំពេញចិត្តនឹងរឿងនេះ។ [114]

សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតដែលជឿថា ការពង្រឹង “សមភាពសង្គម” និងការស្តារសេចក្តីថ្លៃថ្នូររបស់មនុស្សឡើងវិញមានសារៈសំខាន់ជាងគេនោះ ត្រូវពេញចិត្តនឹងលក្ខខណ្ឌពីរជាមុនសិន មុនពេលប្រជាជនកម្ពុជា អាចបោះជំហានចេញពីអតីតកាលបាន៖

> យើងត្រូវការការផ្សះផ្សាជាតិ។ ប៉ុន្តែយើងក៏ត្រូវគិតអំពីសារៈសំខាន់នៃច្បាប់ និងការផ្តន្ទាទោសដែរ។ យើងត្រូវការការផ្សះផ្សាជាតិដោយសារតែយើងមិនអាចបណ្តោយឱ្យប្រទេសរបស់យើងធ្លាក់ខ្លួនក្នុងឧក្រិដ្ឋកម្មសង្គ្រាមម្តងទៀតបានឡើយ។ ចំណុចទី២គឺថា យើងត្រូវការផ្តន្ទាទោសឧក្រិដ្ឋជន។ ការផ្សះផ្សាអាចទទួលយកបានសម្រាប់យើង ប៉ុន្តែយើងត្រូវការផ្តន្ទាទោសមេដឹកនាំខ្មែរក្រហម និងឧក្រិដ្ឋជន... អ្វីដែលខ្ញុំចង់បំផុតគឺពង្រឹងសមភាពសង្គម។ យើងមិនត្រឹមតែចង់ឱ្យមេដឹកនាំរបស់ប្រទេសកម្ពុជា ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមេដឹកនាំជុំវិញពិភពលោកផងដែរ ផ្តល់អាទិភាពទៅលើការថែទាំសម្រាប់មនុស្សជាតិ និងសិទ្ធិក្នុងការរស់នៅ។ មនុស្សត្រូវការសេចក្តីថ្លៃថ្នូរ។ [115]

យោងតាមទស្សនៈនេះ ការផ្សះផ្សា និងស្តាឡើងវិញនូវសមធម៌សង្គម និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ មិនអាចកើតឡើងបានដោយគ្មានការផ្តន្ទាទោសលើក្រុមមេដឹកនាំរបបខ្មែរក្រហមដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាមនោះឡើយ។ នេះអាចជាភារកិច្ចមួយដ៏លំបាកក្នុង ការសម្រេចទៅបានដោយពាក់ព័ន្ធទៅនឹងការដាក់កម្រិតរបស់ អ.វ.ត.ក ដែលត្រូវបានពិចារណាក្នុងផ្នែកដំបូងនៃរបាយការណ៍នេះ។ ការដាក់កម្រិតដ៏ចាំបាច់នៃការផ្តន្ទាទោសលើឧក្រិដ្ឋជន និងនៃ ‘ការស្វែងរកយុត្តិធម៌’ ត្រូវបានទទួលស្គាល់ក្នុងសម្រង់ខាងក្រោម ដែលស្របពេលជាមួយគ្នានេះដែរ បានលើកឡើងសាជាថ្មីនៃអន្តរទំនាក់ទំនងយ៉ាងជិតស្និទ្ធនៃការផ្សះផ្សា និងការផ្តន្ទាទោស៖

> វាជាសំណួរដ៏ពិបាកក្នុងការឆ្លើយ ទាក់ទងនឹងការផ្សះផ្សាផ្លូវចិត្តរវាងជនរងគ្រោះ និងឧក្រិដ្ឋជនដែលមិនទាន់បានចាប់ខ្លួននៅឡើយ។ ដូចដែលខ្ញុំបានដឹងពីអារម្មណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងខ្លួនខ្ញុំផ្ទាល់

[114] Transcript of interview on file with the author (Civil Party Case 002, Phnom Penh, 4 November 2014).
[115] Transcript of interview on file with the author (Civil Party Case 001, Siem Reap Province, 24 October 2014).

> អ្វីដែលសំខាន់នោះគឺថា ប្រសិនបើយើងចង់សម្រេចការផ្សះផ្សាផ្លូវចិត្តនោះ ដំបូងយើងត្រូវតែស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះជាមុនសិន ទោះបីមិនបាន ១០០ ភាគរយនៃយុត្តិធម៌ក៏ដោយ ក៏ប៉ុន្តែការសម្រេចបានពី ៦០ ទៅ ៧០ ភាគរយ ក៏យើងអាចទទួលយកបានដែរ។ ឥឡូវនេះ យើងមិនទាន់សម្រេចគោលដៅនោះនៅឡើយទេ។[116]

ជាធម្មតា វាបានលើកឡើងនូវសំណួរពិបាកៗលើការកំណត់បរិមាណ ពោលតើអ្នកវាស់ស្ទង់ 'យុត្តិធម៌' ដោយរបៀបណា? ដូចបានលើកឡើងពីខាងលើ នេះមិនបានពិចារណាទៅលើភាពខុសប្លែកគ្នារវាងយុត្តិធម៌ និងការផ្តន្ទាទោសនោះទេ បើទោះបីជាជនរងគ្រោះបានគិតថា ទស្សនទាន ទាំងពីរនេះ មានលក្ខណៈគ្រាន់តែស្រដៀងគ្នាក៏ដោយ។ ដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងជាជនរងគ្រោះទាំងពីរក្រុមធំៗនេះ មានឥរិយាបថខុសប្លែកពីគ្នាចំពោះការសងសឹក ឬការផ្តន្ទាទោស ហើយនិងទំនាក់ទំនងរបស់វាជាមួយការផ្សះផ្សាថ្នាក់ជាតិ។ លើសពីនេះទៀត គេមានក្រុមអន្តរការីដែលបដិសេធពីសញ្ញាណនៃការសងសឹក ឬការចង់គំនុំ ដែលក្នុងពេលជាមួយគ្នានេះ ត្រូវទទួលស្គាល់ថា យុត្តិធម៌ក្នុងការដាក់ទោស គឺជា និងគួរតែជាផ្នែកមួយនៃសង្គមក្រោយពីសង្គ្រាមរបស់ប្រទេសកម្ពុជា។ ក៏ប៉ុន្តែ ការសងសឹក និងការផ្សះផ្សា មិនត្រូវចាត់ទុកជាការពង្រឹងគ្នាទៅវិញទៅមកឡើយ។

ហេតុដូច្នេះ សម្រាប់អ្នកចូលរួមក្នុងការប្រជុំក្រុមគោលដៅដែលបានធ្វើឡើងនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤ ការទទួលយកយុត្តិធម៌ក្នុងការដាក់ទោសនៅ អ.វ.ត.ក បានបោះជំហានទៅមុខលើការផ្សះផ្សានេះ៖

> ខ្ញុំបានឈប់គិតពីការសងសឹកទៅហើយ នៅពេលដែលខ្ញុំបានឮអំពីការបង្កើតអ.វ.ត.ក នេះ។ វាបានធ្វើឱ្យខ្ញុំធូរស្បើយក្នុងចិត្តពីការឈឺចុកចាប់ និងទង្វើដ៏អាក្រក់ដែលខ្ញុំបានទទួលក្នុងអំឡុងពេលនោះ។ កំហឹងរបស់យើងចង់ឱ្យពួកគេសងជីវិតមកជនរងគ្រោះដែលបានស្លាប់ទៅ ប៉ុន្តែយើងមានអារម្មណ៍ប្រសើរឡើង បន្ទាប់ពីការបង្កើតតុលាការនេះ នៅពេលដែលតុលាការនេះកំពុងតែខិតខំព្យាយាមយ៉ាងសកម្មក្នុងការនាំយុត្តិធម៌មកឱ្យយើង។ ដូច្នេះ យើងគួរតែចេះគ្រប់គ្រងអារម្មណ៍របស់ខ្លួន។[117]

ចំណុចស្រដៀងគ្នានេះ ត្រូវបានបង្កើតឡើងក្នុងកិច្ចពិភាក្សាក្រុមគោលដៅនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤ អំឡុងពេលអ្នកចូលរួមម្នាក់ដែលបានសង្កត់ធ្ងន់លើសារៈសំខាន់នៃយុទ្ធនាការអប់រំ និងការផ្សព្វផ្សាយព័ត៌មាន បានលើកឡើងថា៖

> វា [អ.វ.ត.ក] ពិតជាបានជួយក្នុងការផ្សះផ្សាមែន ហើយយើងក៏បានផ្សះផ្សាផង ដែរ។ បើមិនដូច្នេះទេ យើងនៅតែស្វែងការសងសឹកដដែល។ បន្ទាប់ពីការដួលរលំរបបខ្មែរក្រហមភ្លាមៗនោះ

[116] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (សំណុំរឿង០០១ និង ០០២ នៅភ្នំពេញ ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៤)។

[117] សូមមើលដើមបណ្តឹងរដ្ឋប្បវេណីក្រុមគោលដៅសំណុំរឿង ០០១ និង ០០២ នៅវត្តសេរីសាគរ ខេត្តព្រៃវែង ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៤។ ប្រតិចារឹកនៃការប្រជុំស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ។

> យើងមានអារម្មណ៍ខឹងសម្បានឹងពួកគេ ហើយចង់តែសងសឹកប៉ុណ្ណោះ។ ប៉ុន្តែក្រោយមក បន្ទាប់ពីការបង្កើតអ.វ.ត.ក ហើយ យើងបានទទួលការអប់រំនិងពន្យល់ជាច្រើន។ ដូច្នេះ យើងមិនមានចិត្តខឹងសម្បា ឬបំណងសងសឹកអ្វីទៀតទេ បើទោះបីជាពួកគេកំពុងតែរស់នៅជាមួយយើងក៏ដោយ។[118]

ជាទូទៅ ក្រុមអ្នកផ្តល់បទពិសោធន៍ដែលគាំទ្រការញែកឱ្យដាច់ពីការដាក់ទោសនិងការផ្សះផ្សាដែលត្រូវបានចាត់ទុកការផ្សះផ្សាជាការសម្រេចបានរួចមកហើយ។ ក្រុមផ្សេងទៀតបានសម្តែងឱ្យឃើញនូវឧបសគ្គដែលនៅមានលើផ្លូវទៅកាន់ការផ្សះផ្សាជាតិ។ ជាការពិតណាស់ ចំនួនអ្នកផ្តល់បទសម្ភាសន៍មានច្រើនគួរឱ្យកត់សម្គាល់រួមមានទាំងដើមបណ្តឹងរដ្ឋប្បវេណី និងដើមបណ្តឹងជាជនរងគ្រោះដែលជឿថាការផ្សះផ្សារអាចត្រូវបានសម្រេច ឬយ៉ាងហោចណាស់កំពុងស្ថិតនៅក្នុងដំណើរការ ។ សម្រាប់អ្នកខ្លះ ការផ្សះផ្សាត្រូវបានកម្រិតទៅកាន់អ្នកដែលធ្លាប់ជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនឆ្នាំណាស់មកហើយ ហើយអ្នកចូលរួមដែលអាចផ្សះផ្សាជាមួយជនល្មើសបាន បាននិយាយនៅពេលនោះថា

> សម្រាប់អ្នកដែលចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីរបស់តុលាការអស់រយៈពេលពី៦ទៅ៧ឆ្នាំ ខ្ញុំអាចនិយាយបានថាវាជាការផ្សះផ្សាដែលអាចទទួលយកបាន។ *ពួកយើងបានផ្សះផ្សារួចមកហើយ។* នេះសំដៅទៅលើអ្នកដែលចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ។ សម្រាប់អ្នកដែលមិនបានចូលរួម ពួកគេគ្រាន់តែប្រកបអាជីវកម្មរបស់ពួកវា ពួកគេមិនដែលខ្វល់ឡើយ។[119]

ពួកគួរការពារខ្លួនយើងទល់នឹងការសន្និដ្ឋានកន្លងមកដែលថា ដើមបណ្តឹងជាជនរងគ្រោះដោយគ្មានឋានៈស្របច្បាប់នៃដើមបណ្តឹងរដ្ឋប្បវេណី ‘មិនខ្វល់’។ ដូចបានឃើញនៅខាងលើ វាមានហេតុផលខុសៗគ្នានូវមូលហេតុអ្វីបានជាជនរងគ្រោះមិនអាច ឬមិនចូលរួមនៅក្នុងការជំនុំជម្រះក្តី។ នៅក្នុងករណីណាក៏ដោយ ការផ្សះផ្សាជាតិត្រូវពាក់ព័ន្ធជាមួយមនុស្សទាំងអស់ មិនមែនត្រឹមចំនួនដើមបណ្តឹងរដ្ឋប្បវេណីដែលមានផលប៉ះពាល់តិចតែប៉ុណ្ណោះទេ។ នេះទាមទារឱ្យមានប្រព័ន្ធដើម្បីជំរុញការផ្សះផ្សាលើសពីកម្រិតរបស់តុលាការដោយអនុវត្តយន្តកាលនៃយុត្តិធម៌អន្តរកាលផ្សេងទៀតដូចជាការពិតដ៏សំខាន់និងគណៈកម្មការផ្សះផ្សាកម្មវិធីចុះតាមមូលដ្ឋាន។ល។ ដែលវាជាអត្ថប្រយោជន៍ផ្ទាល់ដែលមិនមែនចំពោះតែដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះទេ

[118] សូមមើលដើមបណ្តឹងរដ្ឋប្បវេណីក្រុមគោលដៅសំណុំរឿង ០០២ នៅវត្តសេរីសាគរ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។ ប្រតិចារឹកនៃការប្រជុំស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ។

[119] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០២ ភ្នំពេញ ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១៤) ការបញ្ជាក់ត្រូវបានបន្ថែម។

ប៉ុន្តែសម្រាប់សហគមន៍ទាំងមូល។ នៅក្នុងបរិបទនេះ ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតយល់ថាពេលវេលាតិចតួចគឺគ្រប់គ្រាន់ដើម្បីព្យាបាលរបួស។ គាត់បាននិយាយថា

> វាគឺជារយៈពេល។ វាមានរយៈពេល៣៥ឆ្នាំមកហើយ ដូចនេះ គំនិតព្យាបាទនិងការឈឺចាប់របស់យើងបានកាត់បន្ថយជាបណ្តើរៗនាពេលកន្លងមករហូតអ.វ.ត.កត្រូវបានបង្កើតឡើងដើម្បីកាត់ទោសចុងចោទ។ ហើយតុលាការនេះកំពុងស្វែងរកភស្តុតាងដើម្បីចោទប្រកាន់នូវឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្ត ហើយយើងជាដើមបណ្តឹងរដ្ឋប្បវេណីក៏ដូចជាជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងដំណើរការរបស់តុលាការ។ យើងអាចមើលឃើញថាចិត្តរបស់យើងបានស្ងប់ស្ងាត់ ហើយបច្ចុប្បន្ននេះ ពួកយើងកាន់តែស្ងប់ស្ងាត់ទៅ ស្ងប់ស្ងាត់ទៅ។ ពីមុន នៅពេលខ្ញុំឃើញឧក្រិដ្ឋជនទាំងនោះ ខ្ញុំចង់សម្លាប់ពួកគេភ្លាមៗនៅពេលយើងឃើញពួកគេ។ ... ប៉ុន្តែឥលូវនេះ យើងដឹងថាប្រទេសរបស់យើងអនុវត្តតាមនីតិរដ្ឋ យើងគោរពច្បាប់និងសិទ្ធិមនុស្ស។[120]

ការពិចារណាជាច្រើនគួរតែលើកឡើងនៅពេលពិភាក្សាបញ្ហានៃការផ្សះផ្សា។ ដូច Bockers et al. បានលើកឡើងថា ‘តើរយៈពេលឆាប់រហ័សប៉ុណ្ណាដែលប្រទេសក្រោយជម្លោះអាចផ្សះផ្សាបានគឺពឹងផ្អែលលើកត្តាខុសៗគ្នាជាច្រើន ដូចជាលក្ខណនៃជម្លោះ ស្ថានភាពសង្គមបច្ចុប្បន្ន និងលក្ខណដែលសង្គមដោះស្រាយជាមួយអតីតកាលរបស់ខ្លួន។’ (Bockers Stammel & Knaevelsrud ២០១១:៧១)។

[120] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង០០២ ភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិការ ឆ្នាំ២០១៤)។

## ៦- សន្និដ្ឋានអំពីអត្ថប្រយោជន៍ និងការប្រឆាំងទៅលើផលប៉ះពាល់នៃការចូលរួមរបស់ជនរងគ្រោះ៖ ការពិនិត្យនៅក្នុងតថភាព

ការវិភាគទុកជាមុនបានផ្តល់ការយល់ឃើញដ៏សំខាន់នៅក្នុង ‘គុណធម៌’និងសន្និដ្ឋានអំពីអត្ថប្រយោជន៍នៃការចូលរួមរបស់ជនរងគ្រោះ ដូចជាការធានាថាផលប្រយោជន៍របស់ជនរងគ្រោះនឹងត្រូវបានយកទៅពិចារណា គោរពជនរងគ្រោះ ផ្តល់វេទិការសម្រាប់ឱ្យសំលេងរបស់ពួកគេមានការដឹងឮ គាំទ្រពួកគេនៅក្នុងដំណើរការនៃការស្វែងរកយុត្តិធម៌ ការពិត សំណង និងជំរុញឱ្យមានសម្រុះសម្រួល។ ដូចដែលបានឃើញនៅក្នុងការវិភាគនៃទិដ្ឋភាពខុសៗគ្នានៃការចូលរួមរបស់ជនរងគ្រោះសិទ្ធិអំណាចរបស់ជនរងគ្រោះនៅក្នុងទម្រង់នៃការចូលរួមយ៉ាងសកម្មបាននាំឱ្យមានអត្ថប្រយោជន៍ដ៏ល្អប្រសើរសម្រាប់ជនរងគ្រោះផ្ទាល់ក៏ដូចជាស្ថាប័ននៃយុត្តិធម៌អន្តរកាល ។ វាអាចត្រូវបានលើកឡើងថាភស្តុតាងជាក់ស្តែងគាំទ្រនូវគំនិតដែល ‘ការចូលរួមស្មើនឹងការផ្តល់សិទ្ធិអំណាច’និងដែលការចូលរួមបានឱ្យជនរងគ្រោះទទួលបាននូវ ‘ស្មារតីគ្រប់គ្រង លទ្ធភាពក្នុងការកាត់បន្ថយភាពឯការរបស់ខ្លួន និងត្រូវបានរាប់បញ្ចូលនៅក្នុងសហគមន៍របស់ពួកគេសារជាថ្មី ’ ក៏ដូចជា ‘ ភាពដែលអាចទៅរួចនៃការស្វែងរកអត្ថន័យតាមរយៈការចូលរួម’ ។ (Roht-Arriaza ១៩៩៥៖១៩)។

នៅក្នុងបរិបទនោះ អត្ថប្រយោជន៍នៃការចូលរួមខុសៗគ្នាហាក់បីដូចជាលើសពីជនរងគ្រោះទាំងនោះដែលបានចូលរួមយ៉ាងសកម្មជាមួយតុលាការ។ ការចូលរួមរបស់ជនរងគ្រោះត្រូវបានគេឃើញថាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើដំណើរការយុត្តិធម៌អន្តរកាល ជាពិសេសចាត់តាំងពីអ.វ.ត.កមានមូលដ្ឋាននៅក្នុងប្រទេសនៃអន្តរកាល ហើយដូចនេះ អត្ថប្រយោជន៍ដែលមានការសន្និដ្ឋានគឺមានការជាក់ស្តែងជាង។ យ៉ាងណាក៏ដោយ វាបន្សល់នូវការវាស់ស្ទង់ថាតើអត្ថប្រយោជន៍ទាំងនោះត្រូវបានប្រគល់ទៅឱ្យការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងស្រុង ឬជាពិសេស ឬថាតើសហគមន៍ និងភាពនៅកៀកគ្នានៅក្នុងភូមិសាស្ត្រមានផលប៉ះពាល់ទៅលើការចូលរួមទាំងអស់ជាមួយស្ថាប័ននៅក្នុងប្រទេសដែរឬទេ។ យ៉ាងណាក៏ដោយ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅអ.វ.ត.ក ជាសមាសភាគយុត្តធម៌កើតឡើងវិញដែលបានរួមបញ្ចូលនៅក្នុងយន្តកាលតុលាការ បានបង្ហាញពីលក្ខណទិដ្ឋភាព និងស្មុគស្មាញនៃការកសាងប្រលោមលោក។ ការវិភាគទុកមុនបានបាត់បង់ការបំភ្លឺនៅក្នុងបញ្ហាជាច្រើន ភាពតានតឹងក៏ដូចជាតម្រូវការសំខាន់ៗក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ដែលមានផលប៉ះពាល់ដល់សហគមន៍ អ្នកជំនាញ និងអ្នកបង្កើតគោលនយោបាយ។

### ៦.១- ការប្រមើលមើលនូវផលប៉ះពាល់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី

នៅពេលវិភាគគោលបំណងនិងតួនាទីរបស់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ការពិចារណាយ៉ាងហ្មត់ចត់ត្រូវផ្តល់ទៅលើការអនុវត្តជាក់ស្តែងដែលថា ការចូលរួមនោះមានផលប្រយោជន៍សម្រាប់ភាគីទាំងអស់ក៏ដូចជាដំណើរការរបស់តុលាការ។ ថ្វីបើមានការអភិវឌ្ឍយ៉ាងនេះក៏ដោយ ដំណើរការរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានភាពស្មុគស្មាញមិនត្រូវបានធ្វើឡើងដោយគ្មានបញ្ហាប្រឈមនោះទេ។

បញ្ហាមួយនៃបញ្ហាដំណើរការភស្តុតាងជាក់ស្តែងជាងគេបំផុតដែលបានកើតមានឡើង ក្រៅពីការចូលរួមត្រូវបានរិះគន់ជាញឹកញាប់ថា ការចូលរួម 'ប៉ះពាល់ដល់ការរាំងស្ទះលំនឹងរវាងអយ្យការ និងមេធាវីការពារក្តី ' (Baumgartner ២០០៨:៤៣២) និងដែលវាជាការរំលោភសិទ្ធិរបស់ចុងចោទចំពោះតុលាការដែលយុត្តិធម៌និងសវនាការយ៉ាងឆាប់រហ័ស។ ការជម្រះក្តីនៅក្នុងករណី០០១ និង០០២/០១បានបង្ហាញថាការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាពលើសមភាពនៃអាវុធនិងមុខងាររបស់ដំណើរការតុលាការ។ ដូចដែលបានវិភាគដូចខាងក្រោម បញ្ហាដែលព្រួយបារម្ភដល់ការពន្យាពេលរបស់ដំណើរការរបស់តុលាការ ការប្រាប់នូវបញ្ហាក៏ដូចជាផលប៉ះពាល់នៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងការកាត់ទោស តំណាងឱ្យទិដ្ឋភាពចម្រូងចម្រាស់ភាគច្រើននៃរបបការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ បន្ថែមពីនេះទៅទៀត លទ្ធផលនៃការស្រាវជ្រាវបានចោទសួរពីការសន្និដ្ឋានថាការចូលរួមដ៏ច្រើននៅក្នុងនីតិវិធីព្រហ្មទណ្ឌបន្ថែមលើផលប្រយោជន៍របស់ជនរងគ្រោះ។ ទិដ្ឋភាពពីដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនិងដើមបណ្តឹងជាជនរងគ្រោះត្រូវបានផ្តល់ឱ្យមានការយល់ដឹងប្រសើរឡើងនូវផលប៉ះពាល់របស់ដើមបណ្តឹងរដ្ឋប្បវេណីទៅលើជនរងគ្រោះពួកគេផ្ទាល់។

### ៦.១.១- ការពន្យាពេលនៃការជំនុំជម្រះក្តីរបស់តុលាការ

បញ្ហាប្រឈមដ៏ធំមួយត្រូវបានបង្ហាញដោយការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងផលប៉ះពាល់ដែលការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានមកលើការពន្យាពេលនៃនីតិវិធីរបស់តុលាការ ដូចនេះការកើនឡើងនូវការចំណាយនៃការជំនុំជម្រះក្តី (McGonigle Leyh ២០១១:២០៤)។ ទោះបីនៅក្នុងសំណុំរឿង០០១ ដែលជាសំណុំរឿងបង្ខាំងទុកជាមួយនឹងវិសាលភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលចុងចោទមួយរូបបានសារភាពជាមួយដើមបណ្តឹងរដ្ឋប្បវេណី៩៦នាក់ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានបន្ថែមរយៈពេលបួនខែនៃការជម្រះក្តីដោយយោងទៅតាមការវាយតម្លៃទាប។ត្រូវចងចាំថាកង្វះខាតនៃការចូលរួមរបស់ជនរងគ្រោះដូចដែលមាននៅក្នុងការជំនុំជម្រះក្តីរបស់ឌុច និងត្រូវដឹងជាមុនពីភាពស្មុគស្មាញនៃសំណុំរឿង០០២ វាបានក្លាយជាភស្តុតាងទៅកាន់តុលាការ ដូចដែលមន្ត្រីច្បាប់ជាន់ខ្ពស់នៅក្នុងសភាបានអះអាងថាយន្តកាលនៃ'ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចដែលបានអនុវត្តនៅក្នុងការជំណុំជម្រះរឿងក្តីរបស់ឌុចដែលនាំឱ្យមានភាពស្មុគស្មាញដល់ការជំនុំជម្រះក្តី(ទីពីរ)។ ជាលទ្ធផល យន្តកាលថ្មីនៃការចូលរួមជាសមូហភាពនៅក្នុងដំណើរការកាត់ទោសខិតខំរុះរើការកំណត់ដ៏អាក្រក់បំផុតពីប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឱ្យរីករាលដល់ការជំនុំជម្រះលើកទី១។'[121] ជាលទ្ធផល យន្តកាលថ្មីនៃការចូលរួមជាសមូហភាពនៅក្នុងដំណើរការកាត់ទោសខិតខំរុះរើការកំណត់ដ៏អាក្រក់បំផុតពីប្រព័ន្ធដើមបណ្តឹងរដ្ឋប្បវេណីដែលធ្វើឱ្យរីករាលដល់ការជំនុំជម្រះលើកទី១។

### ៦.១.២- ការបង្ហាញនូវបញ្ហា

បញ្ហាដ៏សំខាន់ផ្សេងទៀតដែលកើតមានឡើងដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការបង្ហាញនូវបញ្ហា។ យោងទៅតាមគំរូដែលបានអនុវត្តដោយអ.វ.ត.ក ទាំងមន្ត្រីនៃសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីត្រូវបានទាមទារក្នុងការបង្ហាញនូវភស្តុតាងដែលមានទោស។ ទោះបីជាយ៉ាងណាក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីមិនស្ថិតនៅក្រោមកាតព្វកិច្ចនេះទេ។ បច្ចុប្បន្ននេះ នេះបានបង្កើតនូវបញ្ហាព្រួយបារម្ភ ហើយអយ្យការជាន់ខ្ពស់បានលើកឡើងថា

[121] កិច្ចសន្ទនាជាមួយមន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះរបស់អ.វ.ត.ក សម្គាល់លើសំណុំរឿងជាមួយអ្នកនិពន្ធ។

> នៅពេលបញ្ចប់ការសុំដាក់ពាក្យជាសាក្សីនិងសក្ខីកាមដាក់ស្តែង ដើមបណ្តឹងរដ្ឋប្បវេណីកំពុងតែប្រមូលភស្តុតាង ទោះបីជាវាមិនត្រូវបានគេកោះហៅនៅក្នុងរបៀបនេះក៏ដោយ។ ប្រសិននៅក្នុងដំណើរការនោះ ពួកគេកំពុងប្រមូលសម្ភារដែលមានទោស ជាក់ស្តែង ពួកគេមិនត្រូវបានទាមទារក្នុងការបង្ហាញវានោះទេ។[122]

ជាលទ្ធផល ការរារាំងនេះថែមទាំងបន្ថែមនូវសមភាពរវាងទាហាន និងភាគី ជាពិសេសនៅក្នុងចំណាយលើមេធាវីការពារក្តី។ នៅក្នុងការយល់ដឹងពីគោលការណ៍តួនាទីក្នុងការបង្ហាញនូវការដាក់បន្ទុក និងភស្តុតាងដែលមានទោសបានជ្រាបចូលទៅក្នុងការយល់ដឹងដ៏ជ្រៅនៃតុលាការយុត្តិធម៌ និងដំណើរការប្រកបដោយភាពត្រឹមត្រូវ។

### ៦.១.៣- ផលប៉ះពាល់លើអយ្យការ និងមេធាវីការពារក្តី

ការអនុវត្តនៃការចំណាយដែលបង្កើតឡើងដោយការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់អយ្យការ និងមេធាវីការពារក្តីបាននាំយកនូវការផ្តោតទៅលើតម្រូវការសម្រាប់អ.វ.ត.ក និងតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដើម្បីរៀបចំការចូលរួមរបស់ជនរងគ្រោះនៅក្នុងរបៀបដើម្បីធ្វើឱ្យស្របទៅតាមអត្ថប្រយោជន៍ប្រកួតប្រជែងដ៏ល្អបំផុត។ ឥទ្ធិពលនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅលើសិទ្ធិរបស់អ្នកការពារខ្លួនមានមុនពេលការជំនុំជម្រះរឿងក្តីរបស់ឌុច ហើយទោះបីជាការធ្វើវិសោធនកម្មដើម្បីកាត់បន្ថយការពន្យាពេលដែលមិនចាំបាច់ ភាពតានតឹងនៅតែមានតាមរយៈការជំនុំជម្រះលើកទីពីរ។ គោលការណ៍មូលដ្ឋានមួយដោយផ្អែកលើមុខងារ អ.វ.ត.កដែលការជំនុំជម្រះក្តីត្រូវ មានភាពយុត្តិធម៌ និងមានការសួរដេញដោល និងរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគី។’[123] ទោះបីជាវិធានផ្ទៃក្នុងការផ្តល់សម្រាប់ ‘គោលការណ៍គ្រោង’ ស្តីពីរបៀបធ្វើឱ្យមានតុល្យភាពនូវសិទ្ធិក្នុងការគោរពរបស់ភាគី (ព្រះរាជអយ្យការចុងចោទ និងដើមបណ្តឹងរដ្ឋប្បវេណី) អយ្យការចាំបាច់ធ្វើការជ្រើសរើសដើម្បីកំណត់ប៉ារ៉ាម៉ែត្រនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលអាចនាំទៅកាន់ ‘ភាពមិនច្បាស់លាស់នៃច្បាប់សម្រាប់ភាគីទាំងអស់ដែលពាក់ព័ន្ធ’ (Khan and Rudy ២០១០)។

នៅក្នុងការជំនុំជម្រះក្តីនៅអ.វ.ត.ក ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានក្លាយជាបញ្ហាគ្រប់គ្រងការជំនុំជម្រះក្តី ដែលបណ្តាលឱ្យសភាអនុវត្តនូវប្រព័ន្ធកំណត់ពេលវេលាសម្រាប់រាល់ភាគីទាំងអស់ជា ‘ការឆ្លើយតបក្នុងការព្រួយបារម្ភលើការជំនុំជម្រះក្តីដ៏យឺត’(McGonigle Leyh ២០១១៖ ២០៩)។ មេធាវីការពារក្តីតែងតែជំទាស់ទៅនឹងពេលវេលាដែលបានផ្តល់ទៅឱ្យពួកគេ ដែលបានលើកឡើងថាការប្រឈមមុខជាមួយ ‘អយ្យការរពីរនាក់ ’និងការរពឹងទុក ‘ក្នុងការឆ្លើយតបទៅកាន់ការរារាំងពាក្យបណ្តឹងដោយដើមបណ្តឹងរដ្ឋប្បវេណី[124]។

---

122 កិច្ចសន្ទនាជាមួយជំនួយការអយ្យការជាន់ខ្ពស់ មន្រ្តីរបស់អ.វ.ត.កនៃសហព្រះរាជអាជ្ញា សម្គាល់លើសំណុំរឿងជាមួយអ្នកនិពន្ធ។
123 វិធានផ្ទៃក្នុងរបស់អ.វ.ត.ក r ២១ (១) (ក)។
124 សំណុំរឿងរបស់កាំងហ្គេកអ៊ីវ (សំណុំរឿង០០១) T ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ទំ១១។

ភាពមិនស្មើគ្នាទៅលើការរំលោភសិទ្ធិនៃចុងចោទ[125]
ដូចដែលទីប្រឹក្សាមេធាវីការពារក្តីបានលើកឡើងថា៖

តាមគំនិតរបស់មេធាវីការពារ វាជាការខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃរបស់តុលាការ។ មិនមានន័យថា វាស្ថិតក្នុងបន្ទះបង្អាប់ ប៉ុន្តែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រោកឈរហើយសួរសំណួរដល់សាក្សីទាំងអស់ ដោយមិនបន្ថែមច្រើនចំពោះអ្វីដែលការចោទប្រកាន់បានគ្របដណ្តប់រួចហើយឡើយ។[126]

មេធាវីការពារផ្សេងទៀតបានចាត់ទុកការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាយន្តការច្បាប់ស្មុគស្មាញដែលជួនកាលក្លាយជាបញ្ហាគាំទ្រកាន់តែច្រើនសម្រាប់មេធាវីជាជាងការចាំបាច់សម្រាប់ជនរងគ្រោះ។[127] យោងតាមមេធាវីការពាររូបនេះបានឱ្យដឹងថា បញ្ហានេះពិតជាលុបលើក្នុងសំណុំរឿង០០១ ទីដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានតំណាងដោយក្រុមផ្នែកច្បាប់និងមេធាវីផ្សេងៗ ដែលពួកគាត់មួយចំនួនមិនមានបទពិសោធន៍ពីមុនៗដែលអនុវត្តនៅចំពោះមុខសាលាក្តី ឧក្រិដ្ឋកម្មអន្តរជាតិ និងមិនពាក់ព័ន្ធនឹងទំហំ និងការទាមទាររបស់សវនាការជំនុំជម្រះអន្តរជាតិឡើយ។[128] វាក៏គួរកត់សម្គាល់ផងដែរថា បើទោះជាបញ្ហានេះកំពុងប្រឈមជាមួយមេធាវីការពារក៏ដោយ ក៏មេធាវីការពារច្រើនបំផុតដូចជាយល់ពីការលំបាកដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឹងប្រែងនៅក្នុងសវនាការជំនុំជម្រះលើកទី២ដែរ។ ដូចការលើកឡើងដោយមេធាវីការពារផ្សេងទៀតថា៖

> ប្រសិនបើខ្ញុំធ្វើការបន្តពីសហមេធាវីឈានមុខ ខ្ញុំនឹងឈឺចាប់ច្រើននឹងវិធីដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានដកចេញនៅក្នុងសវនាការជំនុំជម្រះនោះ។ មិនថាពួកគេប្រើវិធីសាស្ត្ររបស់តុលាការ ដោយការឈានដល់ចំណុចដែលការិយាល័យព្រះរាជអាជ្ញាទំនាក់ទំនងពួកគេចាត់ទុកជា ‘ប្រជាពលរដ្ឋថ្នាក់ទី២’ នៅក្នុងសាលសវនាការឡើយ។[129]

ក្រៅពីការពន្យារពេលមិនចាំបាច់ និងការគ្រប់គ្រងពេលវេលារបស់តុលាការ ការជំទាស់ផ្សេងៗដែលបានលើកឡើងដោយមេធាវីការពារបារម្ភពីវិសាលភាពពិតប្រាកដនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ឧទាហរណ៍ អំឡុងសវនាការជំនុំជម្រះរឿងក្តីរបស់ ឌុច មេធាវីការពារលើកឡើងថា ‘ដើមបណ្តឹងរដ្ឋប្បវេណី នឹងមិនត្រូវបានអនុញ្ញាតឱ្យសាកសួរ ឌុច ឬសាក្សីផ្សេងទៀតស្តីពីប្រធានបទដែលមិនទាក់ទងដោយផ្ទាល់ទៅនឹងការរងគ្រោះ របស់កូនក្តីខ្លួន )McGonigle, 2011:209)ឡើយ។ ភាពតានតឹងនេះបានបន្តមានវត្តមាននៅក្នុងសវនាការជំនុំជម្រះក្នុងសំណុំរឿង០០២ជាទំនង និង ០១/ផងដែរ។០២/០០២ងសំណុំរឿងក្នុបន្តផ្នែកដ៏គួរឱ្យកត់សម្គាល់មួយទៀតដែលទំនងជាមិនជាក់ស្តែង នោះគឺថា ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីអាចកើតមាន មិនត្រឹមតែមេធាវី ការពារប៉ុណ្ណោះទេ ថែមទាំងស្តីពីការងាររបស់អយ្យការផងដែរ ជារឿយៗបណ្តាលមកពីភាពតានតឹងបន្តពីភាពមិនស្របគ្នាចាប់ពីទ្រឹស្តីនៃការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះភ័ស្តុតាងដ៏ចម្រូងចម្រាស និងបញ្ហាផ្សេងៗទៀត។ ដូចសាលាក្តីបានលើកឡើង ការអះអាងពីការចូលរួមរបស់ជនរងគ្រោះអាចជួយដល់អយ្យការគឺគួរឱ្យសង្ស័យ ហើយក្នុងករណីជាច្រើន មិនពិត )Trumbull, 2008:807)។ ឧទាហរណ៍ជាក់ស្តែងនៃភាពមិនស្របគ្នាទាំងនេះគឺច្បាស់ណាស់ក្នុងសវនាការជំនុំជម្រះរឿងក្តី ឌុច។ សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានទស្សនៈផ្ទុយគ្នាស្តីពីសហគ្រាសឧក្រិដ្ឋកម្មរួមជាផ្នែកនៃការទទួលខុសត្រូវ ដែលគេអាច

[125] ដូចខាងលើ។
[126] ការសន្ទនាជាមួយមេធាវីការងារ សំណុំរឿង០០២អ្នកនិពន្ធយជាមួឯកសារហេតុភ្នំពេញ កំណត់ ០០១/
[127] ការសន្ទនាជាមួយមេធាវីការងារ សំណុំរឿង០០២អ្នកនិពន្ធយជាមួរឯកសាហេតុភ្នំពេញ កំណត់ ០០១/
[128] ដូចខាងលើ
[129] ដូចខាងលើ

បកស្រាយថាមានការមើលស្រាលពីយុទ្ធសាស្ត្ររបស់អយ្យការនៅសវនាការ និងថា បណ្ដាលឱ្យមានការពន្យារពេលបន្ថែមទៀត។ ដូចមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់បានបរិយាយលម្អិតថា៖

> គេអាចលើកឡើងថា បញ្ហានេះអាចត្រូវបានដោះស្រាយដោយការក្រុមមេធាវី ឬ មេធាវីដែលមានប្រសិទ្ធភាពបន្ថែមទៀត ទោះយ៉ាងណា សក្ដានុពលតែងមាននៅទីនោះ។[130]

ឧទាហរណ៍មួយចំនួននៅក្នុងសវនាការលើកទី១ និងទី២ បានបង្ហាញថា ហានិភ័យនៃភាពតានតឹងស្ដីពីការខិតខំប្រឹងប្រែងរបស់អយ្យការនឹងនៅតែមានវត្តមានដដែល ជាសំខាន់ដោយសារហេតុពិតថា មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសិទ្ធិទទួលបានភ័ស្តុតាងក្នុងសំណុំរឿងខាងលើ។ ការចោទប្រកាន់នេះមិនស្ថិតក្រោមកាតព្វកិច្ចផ្លូវច្បាប់ក្នុងការលាតត្រដាងនូវព័ត៌មានដល់ពួកគេជាមុនទេ។ បញ្ហានេះអាចឈានដល់សេណារីយ៉ូមួយយ៉ាងងាយស្រួលទីដែលមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីនឹងផ្ដោតលើការសួរដេញដោលហួសពីនេះឬក្នុងទិសដៅផ្សេងពីការដែលអយ្យការផ្ដល់ឱកាសដល់សាក្សីការពារក្នុងការទទួលស្គាល់កំហុសដែលបានប្រព្រឹត្តអំឡុងការសួរដេញដោលរបស់ព្រះរាជអាជ្ញា )Trumbull, 2008:809)។ នៅក្នុងឧទាហរណ៍បុរាណ ក្នុងសវនាជំនុំជម្រះរឿងក្ដី ឌុច មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសាកសួរសាក្សីជាជនរងគ្រោះបានលើកឡើងថា ការផ្ដល់សក្ខីកម្មរបស់គាត់ផ្ទុយទៅនឹងចម្លើយលើកមុនស្ដីពីរបាយការណ៍ជាមួយតុលាការ )McGonigle Leyh, 2011: 212) ដែលធ្វើឱ្យប៉ះពាល់ដល់ការខិតខំប្រឹងប្រែងរបស់ព្រះរាជអាជ្ញាដោយការចង្អុលបង្ហាញទៅនឹងភាពមិនស្របគ្នានៃចម្លើយរបស់សាក្សី និងភាពជឿទុកចិត្តរបស់គាត់។ តុលាការបានចាត់វិធានការមួយចំនួនក្នុងសវនាការលើកទី២ ដោយរៀបចំដំណើរការនេះ និងដោយកាត់បន្ថយផលប៉ះពាល់នៃការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីអយ្យការ និងមេធាវីការពារ។

### ៦.២- ការខិតខំប្រឹងប្រែងដោយមិនបានគ្រោងទុកលើជនរងគ្រោះ

បើទោះជាដឹងថា
ការខិតខំប្រឹងប្រែងលើកកម្ពស់សិទ្ធិរបស់ជនរងគ្រោះអាចឈានដល់ការដឹងច្បាស់ពីបំណងនៃយុត្តិធម៌ដែលបានស្ដារសម្រាប់ជនរងគ្រោះក៏ដោយ
ក៏ការវិវត្តជាក់ស្ដែងទាមទារឱ្យមានការពិចារណារដោយប្រុងប្រយ័ត្នពីការសន្និដ្ឋានដែលអាចទទួលយកបានដែលការចូលរួមស្ថិតក្នុងផលប្រយោជន៍ប្រសើរបំផុតរបស់ជនរងគ្រោះ។
មានពីរផ្នែកចំពោះការខិតខំប្រឹងប្រែងនៃការចូលរួមរបស់ជនរងគ្រោះ
ទី១ទាក់ទងនឹងជនរងគ្រោះដែលត្រូវបានទទួលស្គាល់ថា ជាដើមបណ្ដឹងរដ្ឋប្បវេណី និងទី២ទាក់ទងជនរងគ្រោះដែលមិនត្រូវបានទទួលស្គាល់។

ទាក់ទងនឹងជនរងគ្រោះដែលត្រូវបានទទួលស្គាល់
ដោយសារកង្វះព័ត៌មាននៃនីតិវិធីនៅក្នុងវិធានផ្ទៃក្នុង
ជនរងគ្រោះត្រូវបានតម្រូវដូចដែលបានបង្ហាញខាងលើ ឱ្យជ្រើសរើសនៅក្នុងសវនាការជំនុំជម្រះថាតើគាត់ចង់ចូលរួមជាសាក្សី ឬជាដើមបណ្ដឹងរដ្ឋប្បវេណី។ ហេតុដូចនេះហើយ ជនរងគ្រោះដែលចូលរួមអាចត្រូវបានបដិសេធឱកាសក្នុងការផ្ដល់សក្ខីកម្មដោយការស្បថស្បែជាសាក្សី ឬយ៉ាងណា។
បញ្ហានេះក៏អាចប៉ះពាល់ដល់ឱកាសរបស់អយ្យការក្នុងការបង្ហាញព័ត៌មានដែលអាចជួយបន្ថែមទៀតក្នុងការដាក់បន្ទុកលើចុងចោទ (Trumbull, 2008: 212)។ ឧទាហរណ៍នៅក្នុងសវនាជំនុំជម្រះរឿងក្ដីឌុចជនរងគ្រោះផ្ទាល់ជាច្រើនដែលអាចផ្ដល់សក្ខីកម្មដោយការស្បថស្បែ

[130] ការសន្ទនាជាមួយមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ អង្គជំនុំជម្រះអង្គកនិពន្ធជាមួយឯកសារហេតុស្ដីពីក កំណត់.ត.វ.

អំពីទោសកំហុសរបស់ចុងចោទ ផ្ទុយទៅវិញបែរជាជ្រើសរើសចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី (McGonigle Leyh, 2009: 212) ។ ផ្ទុយទៅវិញការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនធ្វើឡើងដោយការស្បថស្បែទេ ហេតុនេះហើយមិនសូវមានទម្ងន់ដូចភ័ស្តុតាងដែលផ្តល់ដោយការស្បថស្បែឡើយ។ លើសពីនេះទៅទៀត ដើមបណ្តឹងរដ្ឋប្បវេណី មិនដូចជាសាក្សីឡើយ បានចូលរួមសវនាការបិទទ្វារ និងសាធារណៈទាំងអស់មុនពេលផ្តល់សក្ខីកម្មដែលអាចមានផលប៉ះពាល់ដល់ព័ត៌មានដែលពួកគេផ្តល់ឱ្យ។ នៅពេលសួរថា តើមូលហេតុអ្វីបានជាជ្រើសរើសជាដើមបណ្តឹងរដ្ឋប្បវេណីជាជាងជាសាក្សីនៅក្នុងសវនាការជំនុំជម្រះ ភាគច្រើននៃជនរងគ្រោះដែលត្រូវបានសម្ភាសបង្ហាញថា បញ្ហានៃការផ្តល់សំណងគឺជាមូលហេតុសំខាន់ចំពោះការសម្រេចរបស់ពួកគាត់។ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនដែលត្រូវបានសម្ភាសនៅក្នុងខេត្តព្រៃវែងបានលើកឡើងថា

> សម្រាប់ខ្ញុំវាសំខាន់ណាស់ក្នុងការចូលរួមនៅក្នុងសវនាការរបស់តុលាការ។ ការសម្រេចចិត្តរបស់ខ្ញុំក្នុងការក្លាយជាដើមបណ្តឹងរដ្ឋប្បវេណីផ្អែកលើព័ត៌មានដែលខ្ញុំទទួលបានពីសមាគមអាដហុក និងផ្នែកគាំពារជនរងគ្រោះ។ ខ្ញុំរីករាយនឹងចូលរួមជាសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ ជាអកុសល តុលាការមិនអនុញ្ញាតចំពោះរឿងនោះទេ ហើយយើងត្រូវជ្រើសរើសជាមុននៅក្នុងសវនាការថា តើយើងចង់ធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងនាមជាសាក្សីឬយ៉ាងណា។ ហើយខ្ញុំដឹងថា ខ្ញុំអាចទទួលបានសំណងលុះណាតែខ្ញុំដើរតួជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែមិនមែនជាសាក្សីទេ។ [131]

យោបល់នេះត្រូវបានចែករំលែកជាមួយជនរងគ្រោះផ្សេងទៀតអំឡុងការសម្ភាសរបស់ក្រុមគោលដៅនៅក្នុងខេត្តព្រៃវែង។ អ្វីដែលកើតឡើងពីបទសម្ភាសន៍គឺថា សេចក្តីសម្រេចរបស់ជនរងគ្រោះត្រូវបានជះឥទ្ធិពលយ៉ាងខ្លាំងដោយព័ត៌មានដែលបានផ្តល់ឱ្យពួកគាត់ដោយផ្នែកគាំពារជនរងគ្រោះ និងសមាគមអាដហុក ហើយថា ពួកគាត់ភាគច្រើនមិនដឹងទេនៅពេលចាប់ផ្តើមពីអ្វីដែលជាភាពខុសគ្នាសំខាន់ៗរវាងឋានៈទាំងពីរ។ នៅក្នុងបរិបទនេះ ភាគីដើមបណ្តឹងផ្សេងទៀតបានលើកឡើងថា៖

> ខ្ញុំមិនដឹងថាអ្វីជាភាពខុសគ្នាសំខាន់ៗរវាងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ ខ្ញុំគិតថា ពួកគាត់ទាំងពីរត្រូវបានផ្តល់ឱកាសឱ្យប្រឈមមុខជាមួយចុងចោទ និងនិយាយអំពីការឈឺចាប់នេះ។ ក្រោយមកខ្ញុំដឹងថា ភាពខ្វែងគំនិតគ្នាមួយក្នុងចំណោមភាពខ្វែងគំនិតគ្នាសំខាន់ៗគឺថាដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំសំណង ហើយចំណែកសាក្សីមិនអាចទេ[132]។

ភាគីដើមបណ្តឹងមួយចំនួនដែលបានសម្ភាសបានសម្តែងការខកចិត្តនៅពេលពួកគាត់ដឹងថា ការផ្តល់សក្ខីកម្មរបស់ខ្លួនមិនត្រូវបានផ្តល់ក្រោមការស្បថស្បែ ហេតុនេះហើយមិនសូវមានទម្ងន់ជាងការធ្វើជាសាក្សីឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានលើកឡើងថា ‘ខ្ញុំដឹងថា សំណងគឺសំខាន់ ប៉ុន្តែសម្រាប់ខ្ញុំ

[131] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (តុលា ១០ថ្ងៃទី ព្រៃវែង ០០២សំណុំរឿង រដ្ឋប្បវេណីដើមបណ្តឹង)

[132] ប្រតិចារឹកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ ថ្ងៃទី ស្តីកំពង់បសេដ្ឋ ខេត្តរដ្ឋប្បវេណី ស្រុកដើមបណ្តឹងរបស់០០២សំណុំរឿង) (២០១៤តុលា ១០

ការស្វែងរកទោសកំហុសរបស់ចុងចោទគឺសំខាន់ស្មើគ្នា។ ខ្ញុំគិតថា ការចូលរួមរបស់ខ្ញុំបានជួយដល់តុលាការ' [133]។

ហេតុនេះហើយ វាសំខាន់ណាស់ចំពោះការចូលរួមដ៏សំខាន់របស់ជនជនរងគ្រោះដែលជនរងគ្រោះត្រូវបានផ្តល់ព័ត៌មានគ្រប់គ្រាន់និងពេញលេញស្តីពីគុណសម្បត្តិនិងគុណវិបត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងស្ថានភាពសាក្សី ដោយអនុញ្ញាតឱ្យពួកគាត់ធ្វើការសម្រេចចិត្តកាន់តែត្រឹមត្រូវឆាប់រហ័សនៅក្នុងនីតិវិធីជំនុំជម្រះ។

ទាក់ទងនឹងជនរងគ្រោះដែលមិនត្រូវបានទទួលស្គាល់ (ដើម្បីបណ្តឹងជាជនរងគ្រោះ) ធៀបទៅនឹងប្រជាជនប្រហែល១,៧លាននាក់ដែលស្លាប់ក្រោមរបបខ្មែរក្រហម ជនរងគ្រោះដែលត្រូវបានទទួលស្គាល់ជាដើម្បីបណ្តឹងរដ្ឋប្បវេណីដោយអ.វ.ត.ក តំណាងមួយផ្នែកក្នុងចំណោមចំនួនសរុបនៃជនរងគ្រោះដោយផ្ទាល់និងមិនផ្ទាល់ ។ ក្នុងការកំណត់ពីតួនាទី និងផលប៉ះពាល់នៃការចូលរួមរបស់ជនរងគ្រោះនៅអ.វ.ត.ក គេគួរប្រយ័ត្នប្រយែងអំពីផលប៉ះពាល់ដែលការចូលរួមបែបនេះអាចមានលើជនរងគ្រោះ ដែលមិនត្រូវបានផ្តល់ការអនុញ្ញាតដោយតុលាការក្នុងការចូលរួមក្នុងការជំនុំជម្រះក្តី។ ការផ្តល់ការអនុញ្ញាតដល់ជនរងគ្រោះមួយចំនួនដោយមិនរាប់បញ្ចូលអ្នកផ្សេងអាចនាំមកនូវផលវិបាកដែលគ្មានបំណងនិងមិនចង់បាន ជាពិសេសក្នុងន័យផ្សះផ្សារជាតិ និងបំណងប្រាថ្នារបស់ជនរងគ្រោះដើម្បីស្វែងរកការពិត ទាំងវត្ថុបំណងសំខាន់នៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិ។ ក្នុងបរិបទនេះ ការសម្ភាសជាមួយដើមបណ្តឹងជាជនរងគ្រោះបានបង្ហាញពីទស្សនៈខុសគ្នាស្តីពីប្រសិទ្ធភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី លើជនរងគ្រោះ និងសង្គមខ្មែរទាំងមូល។ ជនរងគ្រោះម្នាក់បានលើកឡើងថាៈ

> ខ្ញុំបានដាក់ពាក្យបណ្តឹងដើម្បីជម្រាបជូនតុលាការពីការឈឺចាប់របស់ខ្ញុំ។ ប៉ុន្តែ ខ្ញុំមិនដែលត្រូវបានអញ្ជើញឱ្យនិយាយនៅចំពោះមុខតុលាការឡើយ។ ខ្ញុំគិតថា តុលាការមិនផ្តល់ឱកាសច្រើនដល់ជនរងគ្រោះកម្ពុជាប្រាប់ពីរឿងរ៉ាវឈឺចាប់របស់ខ្លួនឡើយ។ មានតែជនរងគ្រោះតិចតួចប៉ុណ្ណោះ។ ទោះយ៉ាងណា ខ្ញុំបានដឹងច្រើនពីខ្មែរក្រហមដោយការតាមដានសវនាការជំនុំជម្រះនេះ[134]។

វាបង្ហាញថា កម្រិតនៃការខកចិត្តក្នុងចំណោមជនរងគ្រោះដែលមិនត្រូវបានទទួលស្គាល់ថាជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងកង្វះព័ត៌មានច្បាស់លាស់និងគ្រប់គ្រាន់ដែលផ្តល់ដល់ពួកគាត់។ ជនរងគ្រោះភាគច្រើនដែលត្រូវបានសម្ភាសហាក់ដូចជាមិនបានយល់ដឹងពេញលេញអំពីទំហំ និងប៉ារ៉ាម៉ែត្រនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងលក្ខណៈទៅទៅរបស់ អ.វ.ត.ក។

ប៉ុន្តែ រូបភាពនេះខុសគ្នាបន្តិចបន្តួចក្នុងចំណោមជនរងគ្រោះភាគច្រើនដែលមានការអប់រំច្រើន

[133] ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ វិច្ឆិកា ៤ថ្ងៃទី ភ្នំពេញ ០០២រដ្ឋប្បវេណីដើមបណ្តឹងរបស់០០២សំណុំរឿង) (២០១៤

[134]ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងជាជនរងគ្រោះ ភូមិស្រះកែវ ឃុំវាំងចាស់ ស្រុកឧត្តុង្គ ថ្ងៃទី៤ ខែវិច្ឆិកា ២០១៤)

ដែលហាក់ដូចជាទទួលស្គាល់ការកំណត់របស់អ.វ.ត.កថាជាតុលាការឧក្រិដ្ឋកម្ម។ ជនរងគ្រោះម្នាក់ដែលជាសាស្ត្រាចារ្យបានលើកឡើងថាៈ

> អ.វ.ត.កគឺជាតុលាការ ហើយមិនមែនជាគណៈកម្មការស្វែងរកការពិតទេ។ វាមិនអាចទៅរួចទេសម្រាប់តុលាការក្នុងការស្តាប់ជនរងគ្រោះទាំងអស់នោះ។ វត្ថុបំណងសំខាន់របស់តុលាការគឺត្រូវបង្កើតគណនេយ្យភាព។ វាជាការប្រសើរដែលតុលាការអនុញ្ញាតឱ្យជនរងគ្រោះមួយចំនួនចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី[135]។

បើទោះជាវិធីសាស្ត្រផ្តោតលើជនរងគ្រោះត្រូវបានអនុម័តយល់ព្រមដោយអ.វ.ត.កទំនងជារួមចំណែកវិជ្ជមានចំពោះបទពិសោធន៍របស់ជនរងគ្រោះ។ គេនៅតែឃើញថា តើសិទ្ធិចូលរួមដែលត្រូវបានពង្រីកនឹងផ្តល់ជាផលប្រយោជន៍បន្ថែមដល់ជនរងគ្រោះឬយ៉ាងណា។

ទីបញ្ចប់ ដូចលោក Trumbull លើកឡើងថា ក្នុងការកំណត់ពីទំហំអតិបរមានៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី អ.វ.ត.ក ត្រូវវាយតម្លៃដោយប្រុងប្រយ័ត្នអំពីផលប្រយោជន៍បន្ទាប់បន្សំចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលរួមប្រឆាំងការរំលោភសិទ្ធិចុងចោទ ប្រសិទ្ធភាពនៃការចូលរួមស្តីពីការជំនុំជម្រះក្តីរបស់តុលាការ (Trumbull 2008: 822) ហើយវាសំខាន់ដូចគ្នានឹងឥទ្ធិពលអវិជ្ជមានណាមួយដែលត្រូវណែនាំដល់សហគមន៍។

## ៧- សេចក្តីសន្និដ្ឋាន

ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាយន្តការ TJ គឺជាការបង្កើតថ្មីនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយជាគោលការណ៍បានពង្រីកវិសាលភាពសិទ្ធិនៃការជំនុំជម្រះក្តីនិងសិទ្ធិសំខាន់ៗសម្រាប់ជនរងគ្រោះដោយអំពើសាហាវយង់ឃ្នង។ ប៉ុន្តែ ដូចរបាយការណ៍បានបង្ហាញ ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងជាច្រើនចំពោះបញ្ហាប្រឈម និង លើកឡើងនូវសំណួរអំពីការសម្របសម្រួលដ៏លំបាក រវាងសិទ្ធិរបស់ជនរងគ្រោះ និងការការពារសិទ្ធិរបស់ចុងចោទចំពោះដំណើរការអនុវត្តឱ្យបានត្រឹមត្រូវ ហើយម្យ៉ាងវិញទៀតសញ្ញាណនៃការទទួលខុសត្រូវបែបព្រហ្មទណ្ឌ និងយុត្តិធម៌អន្តរកាលមិនត្រូតស៊ីគ្នាទេ។ ភាពតានតឹងដ៏ស្មុគស្មាញនេះ និងវិធីដែលក្នុងនោះ អ.វ.ត.កបានស្វះស្វែងពុះពារបញ្ហាដែលបានលើកឡើង បានជូនដំណឹងពីការវិភាគរបាយការណ៍នេះ ហើយឈានដល់ការបង្កើនការស្វែងយល់ពីតួនាទី ផលប៉ះពាល់ និងសារៈសំខាន់នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងន័យនេះ មិនមែនត្រឹមតែផ្តោតទៅលើប្រព័ន្ធយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តោតលើជនរងគ្រោះផងដែរ ដោយឆ្លុះបញ្ចាំងពីវិធីសាស្ត្រផ្តោតលើជនរងគ្រោះតាមរយៈយន្តការ TJ។ ការសន្និដ្ឋានពីគំនិតនេះអាចត្រូវធ្វើឡើងតាម៦ចំណុចគឺៈ

ទី១ តាំងពីការចាប់ផ្តើមមក អ.វ.ត.កទំនងជាធ្វើឱ្យមានការភ្ញាក់ផ្អើលដោយការបង្កើតការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលទំនងជានៅក្នុងភាពស្ទាក់ស្ទើររបស់តុលាការ ហើយពេលខ្លះស្ទាក់ស្ទើរក្នុងការអនុវត្តយន្តការថ្មីឱ្យបានពេញលេញ។

[135]ប្រតិចារិកនៃបទសម្ភាសន៍ស្តីពីសំណុំរឿងជាមួយអ្នកនិពន្ធ (ដើមបណ្តឹងជាជនរងគ្រោះ ខេត្តសៀមរាប ថ្ងៃទី២៤ ខែតុលា ២០១៤)

កង្វះការរៀបចំនេះគឺមានជាក់ស្តែងទាក់ទងចៅក្រមនៅអ.វ.ត.ក ព្រមទាំងមន្ត្រីផ្នែកច្បាប់ សមាជិកក្រុមអយ្យការ មេធាវីការពារ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ទោះយ៉ាងណា វាចាំបាច់ស្តីពីមន្ត្រីតុលាការទាំងនេះក្នុងការបង្ហាញពីព្រំដែននៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់វិសាលភាពពេញលេញចំពោះការអនុវត្តជាក់
ស្តែង។

**ទី២** មានការកាត់ផ្តាត់ទំនាក់ទំនងរវាងការរំពឹងទុកខ្ពស់និងការប្រាថ្នារបស់ជនរងគ្រោះម៉្យាង និងម៉្យាងទៀតតាមការពិតជាក់ស្តែង។ជាពិសេស តួនាទីរបស់ជនរងគ្រោះ និង នៅអ.វ.ត.ក និងតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតែជានិមិត្តរូបដ៏សំខាន់បើទោះជាជនបរងគ្រោះមានសិទ្ធិចូលរួមសវនាការជំនុំជម្រះរបស់ខ្លួនក៏ដោយ។
បញ្ហានេះបណ្តាលឱ្យមានការដឹងច្បាស់ពេញលេញពីសិទ្ធិសំខាន់ៗចំពោះជនរងគ្រោះជាពិសេសទាក់ទងនឹងសិទ្ធិក្នុងការទទួលបានសំណង។ ជាការពិត អ .វ.ត.ក ត្រូវកំណត់ដោយភាពមិនគ្រប់គ្រាន់និងការកំណត់នៅពេលនិយាយពីសិទ្ធិសំខាន់របស់ជនរងគ្រោះ ដូចដែលបានបង្ហាញយ៉ាងច្បាស់នៅក្នុងបទសម្ភាសន៍។
និយាយពីការប៉ះទង្គិចផ្លូវចិត្តបន្ទាប់បន្សំដែលបណ្តាលមកពីការបង្កើតក្តីសង្ឃឹមក្លែងក្លាយនៅក្នុង ដើមបណ្តឹងរដ្ឋប្បវេណី ជាបញ្ហាដែលមាននៅក្នុងបទសម្ភាសន៍
អ.វ.ត.កគួរចាត់វិធានការដើម្បីការដាក់កម្រិតរបស់តុលាការ
និងការដាក់កម្រិតបែបរចនាសម្ព័ន្ធដែលមាននៅក្នុងលក្ខខណ្ឌស្តីពីការផ្តល់សំណងដធ្វើក្លាយជាវោហារសាស្ត្រដ៏គួរឱ្យចាប់អារម្មណ៍អំពីសិទ្ធិរបស់ជនរងគ្រោះឱ្យក្លាយជាការពិត។ លើសពីនេះទៅទៀត វាសំខាន់ណាស់ដែលជនរងគ្រោះបានផ្តល់ព័ត៌មានពិត ទូលំទូលាយ និងដែលអាចទទួលយកបានអំពីអ្វីដែលអ.វ.ត.កអាចសម្រេចបានសម្រាប់ពួកគេដើម្បីទប់ស្កាត់ការខកចិត្ត និងជាពិសេសផលប៉ះពាល់ខ្ទេចខ្ទាំនៃការក្លាយជាជនរងគ្រោះបន្ទាប់បន្សំ។

**ទី៣** អ.វ.ត.កមានផ្នែកមួយចំនួនដែលបានពុះពារនូវឧបសគ្គផ្លូវច្បាប់ និងនីតិវិធីមួយចំនួនទាក់ទងនឹងការចូលរួមរបស់ដើម្បីបណ្តឹងរដ្ឋប្បវេណី
ដោយគូសបញ្ជាក់ពីភាពលំបាកក្នុងការកំណត់អំពីភាពច្បាស់លាស់នៃទំហំនិងគោលបំណងរបស់យន្តការ TJ នេះ។ មូលដ្ឋានច្បាប់សមហេតុផលដែលមានវិធានច្បាស់លាស់ លម្អិត និងទូលំទូលាយដើម្បីណែនាំដល់អ.វ.ត.កក្នុងការផ្តល់បទដ្ឋាននីតិវិធី
និងការការពារជាមួយដើមបណ្តឹងរដ្ឋប្បវេណី
និងជនរងគ្រោះគឺចាំបាច់តាមមធ្យោបាយច្បាប់ដែលបញ្ជាក់យ៉ាងច្បាស់លាស់អំពីសិទ្ធិដើម្បីបណ្តឹងរដ្ឋប្បវេណីព្រមទាំងការទទួលខុសត្រូវរបស់តុលាការ និងមន្ត្រីរបស់ខ្លួនជាមួយដើមបណ្តឹងរដ្ឋប្បវេណី។ ការជំនុំជម្រះបន្ថែមទៀតនៅអ.វ.ត.កនឹងលែងដក់ជាប់នៅក្នុងអារម្មណ៍ជា‘មន្ទីរពិសោធន៍សាកល្បង’ ពីព្រោះករណីនេះមានការជំនុំជម្រះពីរលើកមកហើយ ហើយផ្ទុយទៅវិញផ្តោតលើការសម្រេចបានយុត្តិធម៌ពិតប្រាកដសម្រាប់ជនរងគ្រោះដោយផ្អែកលើវិធាននីតិវិធីដែលមានការយល់យ៉ាងច្បាស់។

**ទី៤** ការយល់ដឹងជាក់ស្តែង និងការវាយតម្លៃគុណវិបត្តិនៃការចូលរួមរបស់ជនរងគ្រោះគឺមានតម្លៃណាស់ដើម្បីឱ្យអ.វ.ត.កធ្វើឱ្យមានតុល្យភាពទាក់ទងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធផ្សេងៗ នៅក្នុងសវនាជំនុំជម្រះដោយយុត្តិធម៌។ ជាពិសេសបញ្ហានេះទាក់ទងនឹងសិទ្ធិរបស់ចុងចោទក្នុងការទទួលបានសវនាការត្រឹមត្រូវនិងយុត្តិធម៌ សិទ្ធិនិងតម្រូវការរបស់ជនរងគ្រោះ
និងផលប្រយោជន៍ដែលមានស្រាប់របស់តុលាការក្នុងការទទួលបានដំណើរការដោយយុត្តិធម៌

និងមានប្រសិទ្ធភាព។ ហេតុដូចនេះហើយ វាមិនទាន់គ្រប់គ្រាន់ទេក្នុងការសន្និដ្ឋានថា ការពង្រីកសិទ្ធិចូលរួមរបស់ជនរងគ្រោះមានសារៈប្រយោជន៍ដល់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ផ្ទុយទៅវិញ ការព្យាយាមវាយតម្លៃចំពោះសិទ្ធិចូលរួមដែលត្រូវបានពង្រីកទាមទារឱ្យមានការពិចារណាប្រុងប្រយ័ត្ន ថាតើ វាពិតជាផ្តល់ផលប្រយោជន៍ពិតល្អបំផុតដល់ជនរងគ្រោះ និងការទទួលបានយុត្តិធម៌កាន់តែទូលំទូលាយឬយ៉ាងណា។ ហេតុដូចនេះហើយ តុលាការប្រឈមលំហាត់លំបាកៗក្នុងការសម្របសម្រួលអំពីគុណតម្លៃដែលមិនអាចប្រៀបធៀបបាន ដែលមានការប្រកួតប្រជែង។ ម្យ៉ាងវិញទៀត វាជាការមិនត្រឹមត្រូវក្នុងការប្រើប្រាស់ភាសា 'តុល្យភាព' នៅក្នុងបរិបទនេះ ពីព្រោះនេះយល់ព្រមដោយផ្ទាល់ពីគំនិតដែលផលប្រយោជន៍របស់អ្នកពាក់ព័ន្ធទាំងបីត្រូវបានជំទាស់ទាំងស្រុង ដែលក្នុងនោះចំពោះវិសាលភាពដ៏ធំធេងដែលមិនស្របជាមួយទស្សនទានរបស់ជនរងគ្រោះរបស់ TJ និងទំនាក់ទំនងរបស់ពួកគេជាមួយមេធាវីការពារ និងតុលាការ។ អ.វ.ត.កដឹងពីតម្រូវការក្នុងការការពារសិទ្ធិនិងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធទាំងអស់ ហើយមិនពាក់ព័ន្ធនឹងភាពរឹងត្អឹង ហើយផ្ទុយទៅវិញអនុម័តនូវវិធីសាស្ត្រដែលកំណត់ស្វែងរកយុត្តិធម៌គ្រប់កាលៈទេសៈទាំងអស់។

**ទី៥** ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងទម្រង់ផ្សេងៗទៀតនៃការចូលរួមរបស់ជនរងគ្រោះនៅក្នុងសវនាការជំនុំជម្រះរបស់តុលាការគឺមានតម្លៃណាស់ ទាំងការចំណាយប្រាក់ដោយផ្ទាល់ និងពេលវេលាបន្ថែមដែលតម្រូវសម្រាប់ការចូលរួមធ្វើការងារនេះ។ ផ្នែកផ្សេងទៀតនៃចំណុចដែលបានលើកឡើងខាងលើគឺថាមូលនិធិ ឬបុគ្គលិកគ្រប់គ្រាន់ តុលាការ ឬសាលាក្តីនឹងត្រូវណែនាំឱ្យបានល្អដើម្បីចៀសវាងកុំអនុម័តសិទ្ធិចូលរួមដែលត្រូវបានពង្រីកសម្រាប់ជនរងគ្រោះ ។ ភាពជោគជ័យនៃយន្តការ TJគឺពឹងផ្អែកលើក្របខ័ណ្ឌច្បាប់ដែលដំណើរការបានល្អ និងមានប្រសិទ្ធភាពដែលមានការទទួលយកជាទូទៅដោយជនរងគ្រោះ ដោយតម្រូវឱ្យមានការលះបង់ធនធានចំពោះសេវាកម្មរបស់ជនរងគ្រោះ រួមមានការផ្តល់ជំនួយផ្នែកច្បាប់ជាដើម។ ទាក់ទងអ.វ.ត.ក ការស្រាវជ្រាវក្នុងការចងក្រងសម្រាប់ឯកសារនេះបានបង្ហាញថា តុលាការបំពាក់បំប៉នមិនបានពេញលេញ ហើយត្រូវការធនធានច្រើនដើម្បីផ្តល់ការចូលរួមបន្ថែមទៀតដល់ជនរងគ្រោះ

ទីបញ្ចប់ លក្ខណៈ និងរចនាសម្ព័ន្ធនៃដំណើរការផ្លូវច្បាប់មិនតែងតែសមស្របចំពោះដំណើរការដោះស្រាយជម្លោះទាំងអស់ឡើយ ជាពិសេស ទីដែលមានការចាំបាច់ស្តីពីផ្នែករបស់ជនរងគ្រោះក្នុងការផ្តល់នូវរឿងរ៉ាវផ្ទាល់ខ្លួននិងការអនុវត្តរួមនៅក្នុងសង្គមតាមការចងចាំ។ ដូចដែលបានគាំទ្រដោយបទសម្ភាសន៍ជាមួយជនរងគ្រោះនៅអ.វ.ត.ក របាយការណ៍នេះបង្ហាញថា ការទទួលស្គាល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបានយុត្តិធម៌ និងសំណងដោយស្មើភាពនិងមានប្រសិទ្ធភាពចំពោះការទទួលរងគ្រោះនោះ ទាមទារឱ្យមានវិធីសាស្ត្ររួមនិងទូលំទូលាយ ដែលតុលាការមិនត្រូវបានកំណត់ក្នុងការសម្រេចបានដោយខ្លួនឯង។ មានស្ថាប័នស្រាវជ្រាវកើនឡើងនិងច្រើនស្តីពីជម្រើសយន្តការ TJដូចជាគណៈកម្មការស្វែងរកការពិត

និងការផ្សះផ្សារ និងគំនិតផ្តួចផ្តើមបែបអប់រំដែលត្រូវប្រើអមមកជាមួយនិងទីដែលគុណវិបត្តិត្រូវបានកំណត់ ការបំពេញបន្ថែមលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅអ.វ.ត.ក។

## ៨. អនុសាសន៍

### ៨.១- សម្រាប់ការចូលរួមរបស់អ.វ.ត.ក

- ធានាយុត្តិធម៌ដោយការលើកកម្ពស់ការចូលរួមដ៏សំខាន់សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះកាន់តែទូលំទូលាយ ដោយផ្តល់ឥទ្ធិពលពេញលេញដល់សិទ្ធិក្នុងការទទួលបានសវនាការជំនុំជម្រះ និងសិទ្ធិសវនាការសំខាន់របស់ជនរងគ្រោះ។
- ធានាការការពារនិងគាំទ្រសម្រាប់ជនរងគ្រោះ ព្រមទាំងដំណោះស្រាយគ្រប់គ្រាន់និងភ្លាមៗដោយការបង្កើតគម្រោងផ្តល់សំណងឱ្យបានគ្រប់ជ្រុងជ្រោយ និងមានន័យក្នុងការដោះស្រាយទំហំសម្ភារពេញលេញ ផលប៉ះពាល់ចិត្តសង្គម និងផលប៉ះពាល់ធ្ងន់ធ្ងរផ្សេងទៀតដែលជនរងគ្រោះទទួលរង។
- រៀបចំ និងអនុវត្តក្របខ័ណ្ឌច្បាប់និងនីតិវិធីត្រឹមត្រូវដោយការកំណត់អំពីទំហំនៃយុត្តាធិការរបស់តុលាការ ដោយផ្អែកលើច្បាប់គ្រប់គ្រងរបស់ខ្លួន និងដោយការមានវិធានច្បាស់លាស់ លម្អិត និងទូលំទូលាយដើម្បីផ្តល់ជាការណែនាំស្តីពីសិទ្ធិ និងភារកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងតុលាការ។
- ស្រមើស្រមៃ និងបង្កើតវិធីសាស្ត្រតាមបទដ្ឋាននិងតម្លាភាពដែលអនុញ្ញាតឱ្យតុលាការថ្លឹងថ្លែងពីវត្ថុបំណងបណ្តឹងប្រជែងដល់ភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងសវនាជំនុំជម្រះ ពោលគឺសិទ្ធិរបស់ចុងចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័ស ការអនុវត្តនីតិវិធីតុលាការ និងសិទ្ធិរបស់ជនរងគ្រោះដោយខ្លួនឯង។
- អនុម័តវិធីសាស្ត្រសមាមាត្រចំពោះនីតិវិធីដ៏ឆាប់រហ័ស និងការកាត់បន្ថយផលប៉ះពាល់
- បណ្តោះអាសន្នលើរយៈពេលសវនាការដែលបណ្តាលមកពីគុណតម្លៃនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយការធ្វើឱ្យមានតុល្យភាពរវាងការទាមទាររបស់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការនេះ។
- ចាត់វិធានការដើម្បីជម្នះការដាក់កំរិតលើរចនាសម្ព័ន្ធនិងយុត្តាធិការដែលមាននៅក្នុងការផ្តល់សំណង ដើម្បីធ្វើឱ្យហួសពីវោហារសាស្ត្រដោយការផ្តល់យុត្តិធម៌ជាក់ស្តែងបន្ថែមទៀតដល់ជនរងគ្រោះនៃបទឧក្រិដ្ឋអន្តរជាតិ។
- ផ្តល់ព័ត៌មានត្រឹមត្រូវ ទូលំទូលាយ និងដែលអាចទទួលយកបានដល់ជនរងគ្រោះអំពីអ្វីដែលតុលាការអាចសម្រេចបានដោយប្រាកដនិយមសម្រាប់ពួកគេដើម្បីចៀសវាងការដែលអាចក្លាយជាជនរងគ្រោះបន្ទាប់។
- ផ្តល់អំណាចដល់ផ្នែកគាំពារជនរងគ្រោះ និងមេធាវីដើមបណ្តឹងរដប្បវេណីដោយការផ្តល់ធនធាននិងមូលនិធិបន្ថែមដើម្បីឱ្យពួកគាត់អាចបំពេញការងាររបស់ខ្លួនបានកាន់តែប្រសើររួមទាំងការចែកចាយព័ត៌មានអំពីការងាររបស់តុលាការ ការផ្តល់សេវាព័ត៌មានឱ្យបានស៊ីជម្រៅ

ព្រមទាំងធ្វើការពិគ្រោះយោបល់ឱ្យបានជិតដល់ជាមួយជនរងគ្រោះក្នុងការរៀបចំគម្រោងផ្តល់សំណង។

- ធានារក្សាការចងចាំរបស់ជនរងគ្រោះមិនត្រឹមតែជាការផ្តល់សំណងជានិមិត្តរូបប៉ុណ្ណោះទេ ថែមទាំងជាយន្តការ TJផងដែរ ដោយផ្តល់វេទិកាចាំបាច់សម្រាប់ការផ្តល់យោបល់របស់ជនរងគ្រោះ និងដោយការកត់ត្រាកំណត់ហេតុអចិន្ត្រៃយ៍ពីរឿងរ៉ាវ និងបទពិសោធន៍របស់ជនរងគ្រោះ។
- ជំរុញការផ្សះផ្សារដែលជាវត្ថុបំណងស្នូលនៃអ្វីដែលតុលាការមានបំណងសម្រេចឱ្យបានជាយន្តការ TJ។
- ចៀសវាងមិនពង្រីកសិទ្ធិចូលរួមរបស់ជនរងគ្រោះឱ្យហួសពីអ្វីដែលតុលាការមានសមត្ថភាព ធនធាន និងបុគ្គលិកដែលអាចផ្តល់ឱ្យឡើយ។

## ៨២.- សម្រាប់ការចូលរួមរបស់រាជរដ្ឋាភិបាលកម្ពុជា

- ការពារឯករាជភាពតុលាការរបស់អ.វ.ត.ក និងចៀសវាងការជ្រៀតជ្រែកណាមួយនូវដំណើរការរបស់តុលាការដោយការប្រកាន់ខ្ជាប់នូវគោលការណ៍នីតិរដ្ឋ។
- ផ្តល់ឧបាស្រ័យនិងសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះទូទៅរួមទាំងសំណងជាប្រាក់ និងសេវាគាំទ្រដល់ជនរងគ្រោះស្របតាមគោលការណ៍មូលដ្ឋានរបស់អង្គការសហប្រជាជាតិ និងការណែនាំស្តីពីសិទ្ធិនិងដំណោះស្រាយ និងសំណងសម្រាប់ជនរងគ្រោះដោយការរំលោភបំពានដ៏ធ្ងន់ធ្ងរនូវច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរនូវច្បាប់មនុស្សធម៌អន្តរជាតិ។
- ផ្តល់សេវាផ្នែកច្បាប់និងសេវាគាំទ្រផ្សេងទៀតដល់ជនរងគ្រោះតាមដែលអាចធ្វើទៅបានតាមរយៈកម្មវិធីផ្សេងៗដូចជាជំនួយផ្នែកច្បាប់ដែលមិនរឹតបន្តឹងដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីជាដើម។
- ធ្វើការយ៉ាងជិតស្និទ្ធជាមួយអ.វ.ត.កដើម្បីអភិវឌ្ឍវិធីសាស្រ្តប្រកបដោយចីរភាព និងដែលអាចសម្រេចបានចំពោះ បញ្ហាផ្តល់សំណងដែលឆ្លើយតបនឹងការព្រួយបារម្ភនិងការរំពឹងទុករបស់ជនរងគ្រោះ។

៨.៣- សម្រាប់ការចូលរួមរបស់សហគមន៍អន្តរជាតិ

- ជំរុញការចូលរួមរបស់ជនរងគ្រោះឱ្យបានសកម្មតាមរយៈការផ្តល់ធនធាននិងមូលនិធិចាំបាច់ដល់អ.វ.ត.កដើម្បីឱ្យតុលាការធានាការចូលរួមដ៏សំខាន់តែអាចគ្រប់គ្រងបាន និងការកាត់បន្ថយឥទ្ធិពលអវិជ្ជមានដល់ការចូលរួមរបស់ជនរងគ្រោះ។
- គាំទ្រនិងផ្តល់អំណាចដល់អ.វ.ត.កក្នុងតួនាទីរបស់ខ្លួនជាយន្តការ TJដោយការផ្តល់មធ្យោបាយចាំបាច់ក្នុការបំពេញការងាររបស់ខ្លួន ជាពិសេសទាក់ទងនឹងដំណោះស្រាយសំខាន់ៗ និងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី។
- ពង្រឹងអ.វ.ត.កដោយការតតាំងនឹងសម្ពាធ ការជ្រៀតជ្រែក និងដោយការផ្តល់អំណាចដល់តុលាការ ព្រមទាំងអង្គការសង្គមស៊ីវិលនៅក្នុងតួនាទីរបស់ខ្លួនជាអ្នកឃ្លាំមើលសវនាការ។
- បង្ហាញសាមគ្គីភាពឱ្យបានប្រសើរឡើងជាមួយការឈឺចាប់របស់ជនរងគ្រោះដោយការផ្តល់ហិរញ្ញវត្ថុនិងទម្រង់ផ្សេងៗទៀតនៃការគាំទ្រដែលជាការរួមចំណែកដល់ការស្តារ ការធ្វើសមាហរណកម្មឡើងវិញ និងការស្តារសេចក្តីថ្លៃថ្នូររបស់ពួកគាត់។

- ស្វែងយល់ពីគម្រោងរួមនិងទូលំទូលាយនៃយន្តការ TJ ដែលបំពេញឱ្យគ្នាទៅវិញទៅមកដើម្បីផ្តល់វិសាលភាពធំធេងសម្រាប់ការដឹងច្បាស់ពីសិទ្ធិសំខាន់របស់ជនរងគ្រោះ  ជាអ្វីៗដែលអ.វ.ត.កវិតក្បិតមិនឱ្យសម្រេចបាន។។

## ៨- គន្ថនិទ្ទេស


Andrews, M. (1995) Against Good Advice: Reflections on Conducting Research in a Country Where You Don't Speak the Language, *Oral History Review*, 22(2): 75-86.

Arnstein, S.R. (1969) A Ladder of Citizen Participation, *Journal of the American Planning Association* 35(4): 216-224.

Bair, James. P (2009) From the Numbers Who Died to Those Who Survived: Victim Participation in the Extraordinary Chambers in the Courts of Cambodia, *31 Hawaii L. Rev. 507.*

Bacik, I., Maunsell, C. and Grogan, S., (1998) *The Legal Process and Victims of Rape,* Dublin Rape Crisis Centre: Trinity College Dublin.

Bassiouni, M.C. (2006) International Recognition of Victim's Rights, *6 Human Rights Law Review* 6 (203): 260.

Bates, A. (2007) "Cambodia's Extraordinary Chamber: Is It the Most Effective and Appropriate Means of Addressing the Crimes of the Khmer Rouge" in Henham, R. and Behrens, P. (eds), *The Criminal Law of Genocide: International Comparative and Contextual Aspects:* Ashgate: Farnham.

Baumgartner, E. (2008) Aspects of Victim Participation in the Proceedings of the International Criminal Court, *International Review of the Red Cross* 90: 870.

Bockers, E., Stammel, N., Knaevelsrud, C. (2011) Reconciliation in Cambodia: Thirty Years After the Terror of the Khmer Rouge Regime, *Torture* 21(2):71-83.

Boyle, D. (2006) The Rights of Victims: Participation, Representation, Protection, Reparation, *Journal of International Criminal Justice* 4:310.

Cartwright, S (Dame) ECCC Trial Chamber Judge, 'International Criminal Trial. A promise fulfilled?' (The 2011 Annual Hawke Lecture, Adelaide 9 June 2011). Available at: http://w3.unisa.edu.au/hawkecentre/ahl/2011AHL_Cartwright.pdf.

Chandler, D. (1999) *Brother Number One: A Political Bibliography of Pol Pot,* Boulder: Westview Press.

Chandler, D, (2008) *A History of Cambodia,* Boulder: Westview Press.

Ciorcari, J. D. (2008) Who Should Stand Trial in Cambodia?, *Oxford Transitional Justice Research (OTJR) Working Paper Series*, 1. Available at: http://www.csls.ox.ac.uk/documents/Ciorciari_Final.pdf.

de Hemptinne, J. (2010) Challenges Raised by Victims' Participation in the Proceedings of the Special Tribunal for Lebanon, *Journal of International Criminal Justice,* 8: 165-179.

Doak, J., (2005) Victim's Rights in Criminal Trials: Prospects for Participation, *32 Journal of Law and Society 294.*

Elander, M. (2013) The Victim's Address: Expressivism and the Victim at the Extraordinary Chambers in the Courts of Cambodia, *International Journal of Transitional Justice* 7(1): 95-115.

Harris, I. (2005) "Onslaught on Beings: A Theravada Buddhist Perspective on Accountability for Crimes Committed in the Democratic Kampuchea Period" in Ramji, J. and Van Schaack, B. (eds), *Bringing the Khmer Rouge to Justice: Prosecuting Mass Violence Before the Cambodian Court,* Lewiston: Edwin Mellen Press.

Hoven, E. (2013) Civil Party Participation in Trials of Mass Crimes: A Qualitative Study at the Extraordinary Chambers in the Courts of Cambodia, *Journal of International Criminal Justice* 1-27.

Jain, N. (2009) Between the Scylla and Charybdis of Prosecution and Reconciliation: The Khmer Rouge Trials and the Promise of International Criminal Justice: *Duke Journal of Comparative and International Law* 20(2): 249.

Jasini, R. & Phan, V. (2011) Victim Participation at the Extraordinary Chambers in the Courts of Cambodia: Are Retributive and Restorative Principles Enhancing the Prospect for Justice?, *Cambridge Review of International Affairs*, 24:3, 379-401.

Jasini, R (2015) *Contextualising Victim Participation in International Criminal Proceedings*, Unpublished dissertation, Oxford: University of Oxford.

Ken G. I. (2013) Fulfilling the Mandate of National Reconciliation in the Extraordinary Chambers in the Courts of Cambodia (ECCC): An Evaluation through the Prism of Victim's Rights, *International Criminal Law Review* 13: 865-894.

Kerr, R. and Mobekk, E. (2007) *Peace and Justice: Seeking Accountability after War*', Cambridge: Polity Press.

Khan, K. and Rudy, D (2010) The Right of the Civil Parties to Participate v. the Right of the Accused to a Fair and Expeditious Trial: Challenges at the ECCC?, *Oxford Transitional Justice Research (OTJR)* Working Paper Series, 2. Available at: http://www.csls.ox.ac.uk/documents/KhanandRudy_TheRightofCivilPartiesvTheRightoftheAccused.pdf.

Kiernan, B. (2002) *The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge,* 2nd edn New Haven: Yale University Press.

Kiernan, B. (2008) *The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge* , 3rd edn, New Haven: Yale University Press.

Laub, D. (1992) "An Event Without a Witness: truth, testimony and Survival" in Felman, S. and Laub, D. Testimony*: Crisis of Witnessing in Literature, Psychoanalysis, and History*, London: Routledge.

McGonigle Leyh, B. (2009) Current Legal Developments. Two for the Price of One: Attempts by the Extraordinary Chambers in the Courts of Cambodia to Combine Retributive and Restorative Justice Principles, *Leiden Journal of International Law* 22: 136.

McGonigle Leyh, B. (2011) *Procedural Justice? Victim Participation in International Criminal Proceedings:* Mortsel: Intersentia.

McGonigle Leyh, B. (2012) Victim-Oriented Measures at International Criminal Institutions: Participation and its Pitfalls, *International Criminal Law Review* 12: 375–408.

Roht-Arriaza, N. (1995) *Impunity and Human Rights in International Law and International Law Practice*, Oxford: Oxford University Press.

Rose, R. (2009 A Predictable Disagreement with an Uncertain Outcome, *Oxford Transitional Justice Research (OTJR) Working Paper Series*, 1. Available at: http://www.csls.ox.ac.uk/documents/RoseFinal.pdf.

Sperfeldt, C. (2012) Cambodian Civil Society and the Khmer Rouge Tribunal, International Court of Justice, 6: 149-160.

Steinberg, D. J. (1959) *Cambodia: Its People, Its Society, Its Culture* New Haven: HRAF Press.

Stover, E., Balthazard, M. and Koening, K.A. (2011) Confronting *Duch*: Civil Party Participation in Case 001 at the Extraordinary Chambers in the Courts of Cambodia, International Review of the Red Cross, 93 (882): 503- 546.

Taylor, D (2014) *Victim Participation in Transitional Justice Mechanisms: Real Power or Empty Ritual?*, Discussion Paper, Impunity Watch. Available at: http://www.impunitywatch.org/docs/IW_Discussion_Paper_Victim_Participation1.pdf.

Thoms, O.N.T, Ron, J. and Paris, R. (2010) State-Level Effects of Transitional Justice: What Do We Know?, *The International Journal of Transitional Justice*, 4: 329–354.

Trumbull, C. P. (2008) The Victims of Victim Participation in International Criminal Proceedings, *Michigan Journal of International Law*, 29: 777-826.

Tsang, E. W. (1998) Inside Story: Mind Your Identity When Conducting Cross National Research, *Organization Studies* 19(3), pp. 511-515.

Van Dijk, P. (1983) *The Right of the Accused to a Fair Trial under International Law*, SIM Special Publication.

Weitekamp, E., Parmentier, S., Vanspauwen, K., Valinas, M., & Gerits, R. (2006) "How to Deal with Mass Victimization and Gross Human Rights Violations: A Restorative Justice Approach", in U. Ewald and K. Turkovic (eds), *Large-Scale Victimisation as a Potential Source of Terrorist Activities*. NATO Security through Science Series, E: Human and Societal Dynamics, 13: 217-241.

Wilshire, B. (2005) *Get 'Em All! Kill 'Em: Genocide, Terrorism, Righteous Communities,* Lanham: Lexington Books.

អង្គការឃ្លាំមើលនិទណ្ឌភាព (IW) មានមូលដ្ឋានក្នុងប្រទេសហូឡង់ ជាអង្គការអន្តរជាតិមិនរកប្រាក់ចំណេញដែលស្វែករកក្នុងការលើកកម្ពស់គណនេយ្យភាពសម្រាប់ភាពឃោរឃៅនៅក្នុងប្រទេសដែលលេចចេញឡើងនូវអំពើហិង្សាតាំងពីអតីតកាល។ IW បានធ្វើការស្រាវជ្រាវតាមរយៈពេលវេលានិងនិរន្តរភាពស្តីពីដើមចមនៃនិទណ្ឌភាពដែលរាប់បញ្ចូលសំលេងនៃផលប៉ះពាល់ដល់សហគមន៍ក្នុងការបង្កើតការណែនាំគោលនយោបាយផ្អែកលើការស្រាវជ្រាវលើដំណើរការដែលមានគោលបំណងក្នុងការអនុវត្តសិទ្ធិរបស់ពួកគេដើម្បីស្វែងរកការពិត យុត្តិធម៌ សំណង និង មិនកើតឡើងវិញ។ IW បានធ្វើការយ៉ាងជិតស្និទ្ធិជាមួយអង្គការសង្គមស៊ីវិលដើម្បីបង្កើនឥទ្ធិពលរបស់ពួកគេអំពីការបង្កើតនិងអនុវត្តគោលនយោបាយពាក់ព័ន្ធ។

របាយការណ៍ស្រាវជ្រាវនាពេលបច្ចុប្បន្នត្រូវបានបង្កើតឡើងជាផ្នែកមួយនៃគម្រោងប្រៀបធៀបច្រើនឆ្នាំដែលមានគោលបំណងគាំទ្រនិងពង្រឹងការចូលរួមរបស់ជនរងគ្រោះនិងសហគមន៍ដែលរងការប៉ះពាល់នៅក្នុងដំណើរការយុត្តិធម៌អន្តរកាល។ យើងខ្ញុំសូមថ្លែងអំណរគុណដល់ Oak Foundation និង Hivos សម្រាប់ជំនយផ្នែកហិរញ្ញវត្ថុ និងបន្តរការគាំទ្រការងាររបស់យើង។

សូមទំនាក់ទំនង៖

**អង្គការឃ្លាំមើលនិទណ្ឌភាព**

't Goylaan ១៥
៣៥២៥ AA Utrecht
ប្រទេសហូឡង់
ទូរស័ព្ទលេខ៖ +៣១.៣០២.៧២០.៣១៣
អ៊ីម៉ែល៖: info@impunitywatch.org
ធ្វីតធឺ: @ImpunityWatch
www.impunitywatch.org

© អង្គការឃ្លាំមើលនិទណ្ឌភាពប្រចាំឆ្នាំ២០១៦